សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ ២០១៦

# លីអាហូណា



**ហារ៉ូល ដប្លុយ ហ៊ុនធើរ ៖ ឪពុក មេធាវី តន្ត្រីករ ព្យាការី ទំព័រ ១៨**

អំណាចព្រះគម្ពីរក្នុងការផ្លាស់ប្ដូរជីវិតរបស់អ្នក ទំព័រ ២៤, ៤០, ៥៦, ៦៨, ៧២

ការទទួលបានចំណេះដឹងមួយអំពីក្រុមព្រះ ទំព័រ ៣២

កំពុងតែពុះពារដើម្បីកសាងជីវិតរបស់អ្នកឬ ? សាកល្បងប្លង់មេរបស់ព្រះ ទំព័រ ៦២



*« ហើយយើងនឹងរៀបចំផ្លូវសម្រាប់អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ហេតុដូច្នោះហើយ ដរាបណាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹងត្រូវបាននាំទៅដែនដីសន្យា ហើយអ្នករាល់គ្នានឹងដឹងថា គឺយើងនេះហើយដែលបាននាំអ្នករាល់គ្នាទៅ »* ។

នីហ្វៃទី ១ ១៧:១៣

ឆ្នេរសមុទ្រនៅក្បែរទីក្រុងឌូបៃ ប្រទេសអេមីរ៉ាតអារ៉ាប់រួម នៅភាគខាងកើតនៃឧបទ្វីបអារ៉ាប់ ។ លីហៃ និង គ្រួសាររបស់លោកបានធ្វើដំណើរទៅទិសខាងត្បូង ចេញពីក្រុងយេរូសាឡិម នៅភាគខាងលិចនៃឧបទ្វីបនេះ។

# លីអាហូណា ខែ មករា ឆ្នាំ ២០១៦




## សារលិខិត


៤ **សារលិខិតគណៈប្រធានទីមួយ សុភមង្គលសម្រាប់មនុស្សដែលយើងស្រឡាញ់**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង

៧ **សារលិខិតបង្រៀនសួរសុខទុក្ខ**
**ក្រុមគ្រួសារ — ការប្រកាសដល់ពិភពលោក**


## អត្ថបទពិសេសៗ


១៨ **ហារើដ ដបុលយូ ហ៊ីនធើរ ៖ ឪពុកខ្ញុំ ជាព្យាការី**
ដោយ រីឆាត អេ ហ៊ីនធើរ
*ទស្សនៈវិស័យរបស់កូនប្រុសម្នាក់អំពីព្យាការីថ្ងៃចុងក្រោយមួយរូប*

២៤ **អំណាចការផ្លាស់ប្រែចិត្តជឿនៃព្រះគម្ពីរមរមន**
ដោយអែលឌើរ ខេវីន អេស ហាមីលថុន
*មានគន្លឹះសំខាន់មួយចំពោះការទទួលបានទីបន្ទាល់មួយអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។*

២៨ ***ចូរមកតាមខ្ញុំ* ៖ ការបង្រៀនគោលការណ៍មូលដ្ឋាននៅក្នុងគេហដ្ឋាន**
ដោយ អាលីសា ស្តានថុន និង ណាថាលី ខេមបែល
*គំនិតយោបល់សម្រាប់ការរៀនសូត្រ ជាក្រុមគ្រួសារ អំពីប្រធានបទយុវវ័យប្រចាំខែ ។*

៣២ **ការស្គាល់ក្រុមព្រះ**
ដោយ អែលឌើរ ជែហ្វ្រីអ័រ ហូឡិន
*យើងគប្បីព្យាយាមប្រែក្លាយទៅជាតែមួយនឹងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ដូចដែលព្រះយេស៊ូវបានអធិស្ឋានសុំឲ្យយើងប្រែក្លាយជាយ៉ាងនោះ ។*


## ផ្នែកនានា


៨ **សៀវភៅកំណត់ចំណាំសន្និសីទ ខែ តុលា ឆ្នាំ ២០១៥**

១០ **អ្វីដែលយើងជឿ: យើងជឿលើការមានភាពវិជ្ជមាន**

១២ **គេហដ្ឋាន គឺជាក្រុមគ្រួសាររបស់យើង: ការការការពារដ៏ល្អបំផុតនៅទីបំផុតរបស់យើងទាស់នឹងរបស់យើងទាស់នឹងរូបអាសគ្រាម**
ដោយ ឃែរី ហានសុន ជែនសិន

១៤ **កាគិតពិចារណា: ពុំមែនជាអព្ភូតហេតុដែលយើងចង់បានទេ**
ដោយ ប្រ៊ិថានី យីង

១៥ **ការបម្រើនៅក្នុងសាសនាចក្រ: សូមអធិស្ឋានអំពីវា**
ដោយ ថារីន ថេលើរ

១៦ **ព័ត៌មាននៃសាសនាចក្រ**

៤០ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

៨០ **លុះត្រាយើងជួបគ្នាម្តងទៀត: រឿងប្រៀបធៀបអំពីរថភ្លើងល្បឿនលឿនឈ្មោះ ទីទុយ**
ដោយ អែលឌើរ ជេម អ៊ី ថាល់មេហ្គ


**នៅលើក្របមុខ**
ខាងមុខ ៖ រូបថតរបស់ ប្រធាន ហារើដ ដបុលយូ ហ៊ីនធើរ ជាមួយនឹងចៅស្រី ខាតថ្លីន និង អានី ។ ខាងក្នុងគម្របមុខ ៖ រូបថតដោយ អាប់បា ម៉ូស៊ីន ។ ខាងក្នុងគម្របក្រោយ ៖ រូបថតដោយ រ៉ូប៊ើត ខាស៊ី ។

## យុវមជ្ឈិមវ័យ





**៤៤ ភាពពិតអំពីជីវិតរមែងស្លាប់ ដែលបានបើកបង្ហាញ**
ដោយ អែលឌើរ ប៉ូល ប៊ី ផៃបកើរ
*យើងត្រូវតែបដិសេធការកុហករបស់ សាតាំង ដើម្បីទទួល បទពិសោធន៍ភាពពេញលេញ នៃជីវិតរមែងស្លាប់ ដែលនាំទៅរកសុភមង្គល ដ៏អស់កល្បជានិច្ច ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណា ដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើការធ្វើដំណើរប្រភេទណា ដែលអ្នកធ្លាប់បានមាន ?***

## យុវវ័យ


**៥០ បាវចនាម្ជុំធលឆ្នាំ ២០១៦ ៖ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ**
ដោយគណៈប្រធានយុវជន និងយុវនារីទូទៅ

**៥២ មួយបន្ទាត់ម្តងៗ ៖ នីហ្វៃទី ២ ៣១:២០**

**៥៣ ប័ណ្ណប្រកាស: ឈានទៅមុខ**

**៥៤ ការរៀនអំពីព្រះវរបិតាសួគ៌ ៖ ការសិក្សាអំពីប្រធានបទសំខាន់ដ៏សមៀម**
*តើអ្នកស្គាល់ព្រះវរបិតាសួគ៌របស់អ្នកច្បាស់ប៉ុណ្ណាដែរ ?*

**៥៦ ម៉ូរ៉ូណៃ ម្តាយខ្ញុំ និង មេរៀនមួយសម្រាប់ជីវិតខ្ញុំ**
ដោយ លូវីសា ហូ
*ការរៀនដំណឹងល្អនៅគេហដ្ឋាន គឺជាពរជ័យដ៏មហិមាមួយចំពោះខ្ញុំ ។*

**៥៨ ទីកន្លែងរបស់យើង**

**៦០ ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ: របៀបឈានទៅមុខ**
ដោយ អែលឌើរ នែល អិល អាន់ឌើរសិន

**៦១ ចំទៅនឹងចំណុច**

**៦២ សូមទុកឲ្យព្រះធ្វើជារបស់អ្នក**
ដោយ ដេវីឌ ឌីកសុន
*ព្រះមានគម្រោងល្អប្រសើរមួយសម្រាប់ ជីវិតអ្នក ជាងអ្នកអាចសុបិនឃើញទៅទៀត ។*





## កុមារ





**៦៦ កុមារដែលឈររឹងមាំ: ការឈររឹងមាំនៅក្នុងប្រទេសអេត្យូពី**
ដោយ អេមី ជេន ឡីវិត

**៦៨ ការអានឲ្យល្អប្រសើរជារៀងរាល់ថ្ងៃ**
ដោយ ម៉ារីសា វីឌីសុន និងសូញ៉ា ឃ្វីនណាឡាតា
*ព្រះគម្ពីរមរមន បានជួយយ៉ូសែប រៀនអានបានកាន់តែល្អប្រសើរ !*

**៧០ ចម្លើយមកពីសាវកម្នាក់: តើខ្ញុំអាចទទួលទីបន្ទាល់ផ្ទាល់ខ្លួនមួយបានដោយរបៀបណា ?**
ដោយ អែលឌើរ រ៉ូប៊ឺត ឌី ហែល

**៧១ ការតមអាហាររបស់ វិលហ្វ្រឺឌ**
ដោយអែលឌើរ ឈី ហុង (សាំ) វ៉ុង
*វិលហ្វ្រឺឌ ពុំរកបានប្រាក់ទេ ប៉ុន្តែគាត់នៅតែចង់ចែកចាយនូវអ្វីដែលគាត់ពិតជាមាន ។*

**៧២ ព្រះគម្ពីរមរមនបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ**
*គ្រប់ព្យាការីនៅក្នុងព្រះគម្ពីរមរមន បានបង្រៀនអំពីព្រះយេស៊ូវ ។*

**៧៤ វីរបុរសក្នុងព្រះគម្ពីរមរមន: នីហ្វៃបានគោរពប្រតិបត្តិ**

**៧៥ ខ្ញុំអាចអានព្រះគម្ពីរមរមន**

**៧៦ សម្រាប់កុមារតូចៗ: ការធ្វើដំណើរនៅក្នុងព្រៃរហោស្ថាន**

**៧៩ ទំព័រផាត់ពណ៌: ខ្ញុំអាចជ្រើសរើសផ្លូវត្រូវ**

**លេខ ១ វ៉ុលទី ៤០ ចុះ ខែ មករា ឆ្នាំ ២០១៦**
លីអាហូណា ១៣២៨១ ២៥៨
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌែល ជី. រ៉ង់ឡាន់

**អ្នកកែសម្រួល ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការអ្នកកែសម្រួល ៖** ជេមស៍ ប៊ី ម៉ាទីណូ, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** បេន ខេ អាសស្តុន, បនដុល ខេ ប៊ើនេត, គ្រេក អេ ខាដុន, ម៉ារី អ័រ ដូហាំ, គ្រីស្តូហ្វើរ ហ្គោឌិន, ដូហ្គ្លាស ឌី ហូម៉េស, ឡារី អ័រ ឡរ៉េន, ខារ៉ូល អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយប៊ិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ៃអិន ខារ
ជំនួយការផ្នែកបោះពុម្ព ៖ លីស្សា ស៊ី ឡូប៉េស្ស
**និពន្ធ និងកែសម្រួល ៖** ប្រ៊ិតថានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាថាយ ឌី ហ្វឺតតុន, ឡារី ហូលើរ, ហ្គាប៉េត អេច ហ្គាហ្វ, ឡាប៉ែន ផតទើរ ហ្វាន, ជីល ហាកឃីង, ឆាលទ្បិត ឡាកាបាល់, មីនឌី អាន លីវីត, ម៉ៃឃល អរ ម៉ូរីស, សាលី ចនសុន អូដេឃឺក, យ៉ូស្វេ ជេ ភឺគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, ប៉ុល វ៉ានឌិនប៊ើហ្គ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ចាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, ម៉ែនឌី បិនថ៍លី, ស៊ី ឃីមប៊ល បុត, ថូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កត អិម ម៉ូយ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉កឃិនហូស
**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នេបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខន្នី បិវទ្ទប ប្រ៊ិច, ជូលី ប៊ឺដេត, ខេទី ដានខាន, ប្រៃអិន ដ័បុលយូ ជីជី, ជិន្នីស ខឹប៊ី, ជីន្នី ជេ នីលសុន, ហ្គែល ធេត រ៉ាហ្វីធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ទេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉េលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), គ្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2016 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉េល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
January 2016 Vol. 15 No. 1. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address *must* be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store .lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារបាន ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



« ***ចូរមកតាមខ្ញុំ* ៖ ការបង្រៀនគោលការណ៍មូលដ្ឋាននៅក្នុងគេហដ្ឋាន** » ទំព័រ ២៨ ៖ អត្ថបទនេះ មានគំនិតយោបល់អំពីការបង្រៀន និងការរៀនសូត្រចំពោះប្រធានបទចំនួនប្រាំមួយ ។ អ្នកអាចប្រើគំនិតយោបល់សម្រាប់ប្រធានបទយុវវ័យនៃខែមករា អំពីក្រុមព្រះ នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។ អ្នកក៏អាចរំឭកជាគ្រួសារផងដែរអំពីវិធីសាស្ត្រនៃការរៀនសូត្រ ដែលបានពិពណ៌នានៅក្នុងអត្ថបទ ហើយពិភាក្សាថាតើវិធីសាស្ត្រជាក់លាក់ណាមួយដែលមានប្រយោជន៍ចំពោះគ្រួសាររបស់អ្នក ។ អ្នកអាចអញ្ជើញសមាជិកគ្រួសារអ្នកឲ្យប្រើវិធីសាស្ត្រទាំងនេះ ដើម្បីរៀបចំមេរៀនរាត្រីជួបជុំក្រុមគ្រួសារនាពេលអនាគត ដោយផ្អែកទៅលើប្រធានបទដំណឹងល្អនៅក្នុងអត្ថបទនេះ ។

« **ការធ្វើដំណើរនៅក្នុងព្រៃរហោស្ថាន** »ទំព័រ ៧៦ ៖ ចូរពិចារណាធ្វើការរៀបចំជាវគ្គសិក្សាមួយដោយដាក់ជាឧបសគ្គតូចមួយនៅក្នុងគេហដ្ឋានរបស់អ្នក អ្នកអាចត្រូវផ្លាស់ប្ដូរទីតាំងគ្រឿងសង្ហារឹមសារជាថ្មីឡើងវិញ ហើយចងខ្សែកាត់តាមផ្លូវដើរ ។ បិទភ្នែកសមាជិកគ្រួសារគ្រប់រូប ទុកតែមនុស្សម្នាក់ដែលនឹងណែនាំដល់សមាជិកគ្រួសារទាំងមូលអំពីរបៀបដើម្បីដើរឆ្លងកាត់ឧបសគ្គនោះ ។ បន្ទាប់មកអ្នកអាចពិភាក្សាអំពីរបៀបដែលព្រះវរបិតាសួគ៌ បានដឹកនាំនីហ្វៃ និងគ្រួសាររបស់គាត់ឲ្យទៅកាន់ដែនដីសន្យា ។ រួចហើយអ្នកអាចពិភាក្សាអំពីវិធីសាស្ត្រនានាដែលព្រះវរបិតាសួគ៌ បានប្រទានឲ្យអ្នក និងគ្រួសារអ្នកដើម្បីជួយអ្នកឲ្យធ្វើដំណើរទៅកាន់គេហដ្ឋាននៅឯស្ថានសួគ៌វិញដោយសុវត្ថិភាព ។

## ជាភាសារបស់អ្នក

*លីអាហូណា* និងធនធានផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។ សូមមើលគេហទំព័រ **facebook.com/liahona.magazine** ( ដែលមានជាភាសាអង់គ្លេស ភាសាព័រទុយហ្គាល់ និង ភាសាអេស្ប៉ាញ ) ដើម្បីទទួលបានគំនិតនានាអំពីរាត្រីជួបជុំក្រុមគ្រួសារ ជំនួយសម្រាប់មេរៀនថ្ងៃអាទិត្យ និង មាតិកាដែលអ្នកអាចចែកចាយជាមួយមិត្តភក្តិ និង គ្រួសារ ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយ គឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

***ការគោរពប្រតិបត្តិ,*** *៤, ៣២, ៦០, ៦២, ៧០, ៧៤*
***ការបង្រៀន,*** *២៨*
***ការប្រែចិត្តជឿ,*** *៤០*
***ការសិក្សាព្រះគម្ពីរ,*** *១២, ៥៤, ៥៦, ៥៨, ៧០, ៧២, ៧៥*
***ការហៅ,*** *១៥*
***ការអធិស្ឋាន,*** *១៤, ១៥*
***កិច្ចការផ្សព្វផ្សាយសាសនា,*** *១២, ៥៨, ៦៦*
***កុមារ,*** *១៤, ១៥, ៤៤*
***ក្រុមគ្រួសារ,*** *៧, ១២, ១៤*
***ក្រុមព្រះ,*** *២៨, ៣២*
***ជីវិតដ៏នៅអស់កល្បជានិច្ច,*** *៥០, ៥២*
***ដង្វាយតមអាហារ,*** *៧១*
***ទីបន្ទាល់,*** *៣២, ៤២, ៥៨, ៦៦, ៧០*
***ធ្វើការ,*** *៤៤*
***បព្វជិតភាព,*** *២៨, ៥០*
***ផែនការនៃសេចក្ដីសង្គ្រោះ,*** *២៨, ៤៤*
***ពលិកម្ម,*** *១៨, ៧១*
***ព្យាការីទាំងឡាយ,*** *១៨, ២៨*
***ព្រះគម្ពីរមរមន,*** *១២, ២៤, ៤០, ៤១, ៤២, ៤៣, ៦៦, ៦៨, ៧២, ៧៤, ៧៥, ៧៦*
***ព្រះយេស៊ូវគ្រីស្ទ,*** *២៨, ៣២, ៥០, ៥២, ៧០, ៧២*
***ព្រះវរបិតាសួគ៌,*** *៣២, ៥៤, ៧០*
***ព្រះវិញ្ញាណបរិសុទ្ធ,*** *៤, ២៨, ៣២, ៥០, ៥២, ៧០, ៧២*
***យុវវ័យ,*** *៥០, ៥៨*
***រាត្រីជួបជុំក្រុមគ្រួសារ,*** *១២, ២៨, ៥៤*
***សណ្ដានចិត្តល្អ,*** *១៨, ៧១*
***សិទ្ធិជ្រើសរើស,*** *៤, ៤៤*
***សេចក្ដីជំនឿ,*** *៥០, ៥៨, ៦០, ៦២, ៨០*
***សេចក្ដីស្រឡាញ់,*** *៤, ៣២, ៥០, ៥២, ៦០*
***សេចក្ដីសង្ឃឹម,*** *៥០, ៥២, ៦០, ៦២*
***សេចក្ដីអំណរ,*** *៤, ១០*
***ហឺនតើរ ហាវើដ ដបុលយូ,*** *១៨*
***អាពាហ៍ពិពាហ៍,*** *១៨, ៤៤*
***ឥរិយាបថ,*** *១០, ៥០*

សារលិខិតគណៈប្រធានទីមួយ



**ដោយ ប្រធាន**
**ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# សុភមង្គល
## សម្រាប់មនុស្សដែលយើងស្រឡាញ់

យើងទាំងអស់គ្នាចង់បានសុភមង្គលសម្រាប់អស់អ្នកដែលយើងស្រឡាញ់ ហើយយើងចង់ឲ្យពួកគេមានការឈឺចាប់តិចបំផុត បើអាចធ្វើទៅបាន ។ នៅពេលយើងអានអំពីដំណើររឿងទាំងឡាយនៃសុភមង្គល — និងអំពីការឈឺចាប់ — នៅក្នុងព្រះគម្ពីរមរមន នោះដួងចិត្តរបស់យើងត្រូវបានពុះកញ្ជ្រោល នៅពេលយើងគិតអំពីមនុស្សជាទីស្រឡាញ់របស់យើង ។ នេះគឺជាដំណើររឿងពិតមួយអំពីគ្រានៃសុភមង្គល ៖

« ហើយហេតុការណ៍បានកើតឡើងថា គ្មានការទាស់ទែងគ្នានៅក្នុងដែនដីឡើយ ដោយព្រោះមកពីសេចក្ដីស្រឡាញ់នៃព្រះ ដែលបានស្ថិតនៅក្នុងចិត្តរបស់មនុស្ស ។

« ហើយពុំមានការឈ្នានីស ការទាស់ទែងគ្នា ការច្របូកច្របល់ ការសហាយស្មន់ ការភូតកុហក ការកាប់សម្លាប់ ឬក៏អំពើអាសអាភាសណាមួយឡើយ ហើយពិតជាគ្មានប្រជាជនណា ដែលរីករាយសប្បាយជាងប្រជាជនដែលបានត្រូវបង្កើតដោយព្រះហស្តនៃព្រះឡើយ » ។

រួចហើយយើងអាន ៖

« ហើយពួកគេបានទទួលពរដ៏ម្ល៉េះហ្ន៎ ! ព្រោះព្រះអម្ចាស់ទ្រង់បានប្រទានពរដល់ពួកគេ ចំពោះគ្រប់កិច្ចការរបស់គេ មែនហើយពួកគេបានទទួលពរ ហើយចម្រើនឡើង រហូតដល់ឆ្នាំទីមួយរយដប់បានកន្លងផុតទៅ ហើយតំណរទីមួយ ចាប់ពីព្រះគ្រីស្ទទ្រង់យាងមក ក៏បានស្លាប់ទៅ ហើយនៅលើដែនដីទាំងមូល ពុំមានការទាស់ទែងអ្វីឡើយ » ( នីហ្វៃទី ៤ ១:១៥–១៦, ១៨ ) ។

ពួកសិស្សជាទីស្រឡាញ់របស់ព្រះគ្រីស្ទ បានអធិស្ឋាន ហើយខិតខំធ្វើការដើម្បីឲ្យពរជ័យបែបនោះកើតមានចំពោះមនុស្សដទៃ និងខ្លួនពួកគេផ្ទាល់ ។ ចេញមកពីដំណើររឿងនៅក្នុងគម្ពីរមរមន ចេញមកពីបទពិសោធន៍ផ្ទាល់ខ្លួន ចំពោះមនុស្សយើងភាគច្រើន យើងបានដឹងថា យើងអាចទទួលបានអំណោយទាននៃសុភមង្គល ។ យើងដឹងថា មាគ៌ាទៅកាន់សុភមង្គលគឺត្រូវបានគូសចំណាំយ៉ាងច្បាស់ ។ យើងក៏ដឹងផងដែរថា ការរក្សាឲ្យមានសុភមង្គល គឺពុំងាយស្រួលទេ លុះត្រាតែដូចជាពួកសាសន៍នីហ្វៃ បន្ទាប់ពីការយាងទៅជួបរបស់ព្រះអង្គសង្គ្រោះដែលមាន « សេចក្ដីស្រឡាញ់របស់ព្រះ » ស្ថិតនៅក្នុងដួងចិត្តរបស់ពួកគេប៉ុណ្ណោះ ។

សេចក្ដីស្រឡាញ់នោះ គឺស្ថិតនៅក្នុងដួងចិត្តរបស់ពួកសាសន៍នីហ្វៃ ដោយសារតែពួកគេរក្សាក្រឹត្យវិន័យដែលធ្វើឲ្យពរជ័យអាចកើតមានឡើងបាន ។ សេចក្ដីសង្ខេបអំពីក្រឹត្យវិន័យនោះ គឺត្រូវអាចរកឃើញនៅក្នុងការអធិស្ឋានពិធីសាក្រាម៉ង់ ដែលចាប់ផ្ដើមដោយការទូលអង្វរចេញពីដួងចិត្តទៅកាន់ព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើង ។ យើងអធិស្ឋានជាមួយដួងចិត្តដែលពោរពេញដោយសេចក្ដីជំនឿ និងដោយសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ ទៅកាន់ព្រះអង្គសង្គ្រោះរបស់យើងផ្ទាល់ ។ យើងតាំងចិត្តដោយបំណងពិត ដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមរបស់ទ្រង់ ដើម្បីចងចាំទ្រង់ ហើយរក្សាបទបញ្ញត្តិទាំងអស់របស់ទ្រង់ ។ ទីបំផុត យើងអនុវត្តសេចក្ដីជំនឿដែលជឿថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាសមាជិកទីបីនៃក្រុមព្រះ តែងតែគង់នៅជាមួយយើង ថ្លែងទីបន្ទាល់ដល់ដួងចិត្តរបស់យើងអំពីព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាសំណព្វរបស់ទ្រង់ ។ ( សូមមើល  គ. និង ស. ២០:៧៧, ៧៩ ) ។

ដោយមានភាពជាដៃគូពីព្រះវិញ្ញាណបរិសុទ្ធ នោះដួងចិត្តរបស់យើងអាចផ្លាស់ប្ដូរដើម្បីឲ្យយើងចង់បាន និងស្វាគមន៍ចំពោះសេចក្ដីស្រឡាញ់នៃព្រះវរបិតាសួគ៌របស់យើង និងនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ របៀបទទួលបានសេចក្ដីស្រឡាញ់នៃព្រះដាក់នៅក្នុងដួងចិត្តរបស់យើង គឺសាមញ្ញទេ ក៏ដូចគ្នានឹងរបៀបដើម្បីបាត់បង់អារម្មណ៍នៃសេចក្ដីស្រឡាញ់នោះនៅក្នុងដួងចិត្តយើងដូច្នោះដែរ ។ ឧទាហរណ៍ មនុស្សម្នាក់អាចនឹងជ្រើសរើសធ្វើការអធិស្ឋានមិនសូវញឹកញាប់ទៅកាន់ព្រះវរបិតាសួគ៌ ឬមិនថ្វាយដង្វាយមួយភាគក្នុងដប់ ឬឈប់ទទួលទានព្រះបន្ទូលនៃព្រះ ឬបដិសេធជនក្រីក្រ និងជនទុគត៌ជាដើម ។

រាល់ជម្រើសដែលពុំរក្សានូវព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ អាចបណ្ដាលឲ្យព្រះវិញ្ញាណឃ្លាតឆ្ងាយពីដួងចិត្តរបស់យើង ។ ជាមួយនឹងការបាត់បង់នោះ សុភមង្គលក៏នឹងរលាយបាត់ទៅដែរ ។

សុភមង្គលដែលយើងចង់បានសម្រាប់មនុស្សជាទីស្រឡាញ់របស់យើង គឺអាស្រ័យទៅលើជម្រើសរបស់ពួកគេ ។ ទោះជាយើងស្រឡាញ់កូនយើង អ្នករៀនថ្មី ឬមិត្តរបស់យើងច្រើនយ៉ាងណាក្ដី ក៏យើងពុំអាចបង្ខំពួកគេឲ្យកាន់តាមបទបញ្ញត្តិទាំងឡាយ ដើម្បីឲ្យពួកគេបានសក្ដិសមនឹងមានព្រះវិញ្ញាណបរិសុទ្ធ



មករំជួលចិត្តពួកគេ ឬផ្លាស់ប្ដូរដួងចិត្តរបស់ពួកគេបានឡើយ ។

ដូច្នេះជំនួយល្អបំផុតដែលយើងអាចផ្ដល់ឲ្យ គឺជាអ្វីៗក៏ដោយដែលដឹកនាំមនុស្សដែលយើងស្រឡាញ់ ឲ្យចេះពិចារណាអំពីជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ ។ អាលម៉ា បានធ្វើវាដោយការអញ្ជើញមួយ ដែលអ្នកអាចផ្ដល់ឲ្យ ៖

« សូមឲ្យអ្នករាល់គ្នាបន្ទាបខ្លួនចំពោះព្រះអម្ចាស់ ហើយអំពាវនាវដល់ព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ហើយចាំយាម និង អធិស្ឋានជានិច្ច ដើម្បីកុំឲ្យអ្នកត្រូវល្បួងលើសជាងអ្វីដែលអ្នករាល់គ្នាអាចអត់ទ្រាំបានឡើយ ម្ល៉េះហើយ សូមឲ្យបាននាំដោយព្រះវិញ្ញាណបរិសុទ្ធ សូមឲ្យបានក្លាយទៅជារាបទាប ស្លូតបូត ចុះចូល ទ្រាំទ្រ ពោរពេញទៅដោយសេចក្ដីស្រឡាញ់ និងគ្រប់ទាំងសេចក្ដីអត់ធ្មត់

« សូមឲ្យមានសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់ សូមឲ្យមានសេចក្ដីសង្ឃឹមមួយថា អ្នករាល់គ្នានឹងទទួលជីវិតដ៏នៅអស់កល្បជានិច្ច សូមឲ្យមានសេចក្ដីស្រឡាញ់នៃព្រះនៅក្នុងចិត្តអ្នកជានិច្ច ដើម្បីឲ្យអ្នករាល់គ្នាបានលើកឡើងនៅថ្ងៃចុងក្រោយបង្អស់ ហើយចូលទៅក្នុងសេចក្ដីសម្រាករបស់ទ្រង់ » ( អាលម៉ា ១៣:២៨–២៩ ) ។

ខ្ញុំអធិស្ឋានសុំឲ្យអ្នកទាំងឡាយដែលអ្នកស្រឡាញ់ អាចទទួលយកការអញ្ជើញដ៏បំផុសគំនិតមួយ ដើម្បីជ្រើសរើសយកផ្លូវទៅកាន់សុភមង្គលដ៏គង់វង្សជានិច្ច ។ ■

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រធាន អាវរិង បានបង្រៀនថា សុភមង្គល ដែលយើងទទួលដឹងនៅក្នុងជីវិត អាស្រ័យលើការសម្រេចចិត្តដែលយើងធ្វើ ។ នៅពេលអ្នកពិភាក្សាអំពីសារលិខិតនេះ ចូរពិចារណាអំពីការផ្ដោតទៅលើរឿងទាំងឡាយដែលប្រធាន អាវរិង បានប្រាប់ ដែលយើងអាចជ្រើសរើសធ្វើតាម ( ដូចជាការអធិស្ឋាន ការប្រឹងប្រែងធ្វើការ ការអនុវត្តសេចក្ដីជំនឿ និងការតាំងចិត្តខ្លួនយើងដោយបំណងពិត ) ដើម្បីដឹកនាំយើងទៅកាន់ផ្លូវនៃសុភមង្គលនោះ ។ អ្នកអាចអញ្ជើញអ្នកទាំងឡាយដែលអ្នកបង្រៀនឲ្យសរសេរនូវសកម្មភាពពីរ ឬបី ដែលពួកគេចង់ធ្វើ ដើម្បីអាចដឹកនាំពួកគេដ៏ល្អប្រសើរទៅកាន់ « ផ្លូវទៅរកសុភមង្គលដ៏គង់វង់ជានិច្ច » ។



## សកម្មភាពដែលដឹកនាំទៅរកសុភមង្គល

ប្រធាន អារវិង បង្រៀនថា « សុភមង្គលដែលយើងចង់បានសម្រាប់មនុស្សជាទីស្រឡាញ់របស់យើង គឺអាស្រ័យទៅលើជម្រើសរបស់ពួកគេ » ។

អ្នកអាចអានអំពីលទ្ធផលដែលការជ្រើសរើសទាំងឡាយ អាចកើតមានចេញមកពីគំរូរបស់ នីហ្វៃ លេមិន និង លេមយួល ។ លេមិន និង លេមយួល បានរអ៊ូរទាំ ហើយពុំចង់កាន់តាមបទបញ្ញត្តិទាំងឡាយទេ ( សូមមើល នីហ្វៃទី ១ ២:១២ ) ។ ជាលទ្ធផល ពួកគេ និងកូនចៅរបស់ពួកគេ ត្រូវទទួលបណ្ដាសារ ហើយកាត់ចេញពីវត្តមានរបស់ព្រះអម្ចាស់ ( សូមមើលនីហ្វៃទី ២ ៥:២០–២៤ ) ។ នីហ្វៃ បានជ្រើសរើសគោរពតាមបទបញ្ញត្តិទាំងឡាយ ( សូមមើល នីហ្វៃទី ១ ៣:៧ ) ហើយដោយសារជម្រើសនោះ គាត់ និងប្រជាជនរបស់គាត់ « បានរស់នៅតាមរបៀបនៃសុភមង្គល » ( នីហ្វៃទី ២ ៥:២៧ ) ។

អ្នកអាចជ្រើសរើសដើម្បីមានសុចរិតភាព និងសប្បាយរីករាយ ។ ប៉ុន្តែមនុស្សនៅជុំវិញអ្នក នឹងប្រហែលជានៅតែធ្វើការជ្រើសរើសមិនត្រឹមត្រូវ ដែលនាំទៅរកសេចក្ដីវេទនា ឬគ្មានភាពសុខសាន្ត ។ ខណៈដែលការសម្រេចចិត្តទាំងនោះ គឺជារបស់ផងពួកគេ នោះគំរូរបស់អ្នក អាចមានឥទ្ធិពលលើការជ្រើសរើសរបស់ពួកគេសម្រាប់សេចក្ដីល្អ ។ តើការជ្រើសរើសរបស់អ្នកអាចនាំមកនូវសុភមង្គលដល់អ្នកដទៃដោយរបៀបណា ? ចូរពិភាក្សាជាមួយនឹងគ្រួសាររបស់អ្នកអំពីរបៀបផ្សេងៗ ដែលអ្នកអាចជះឥទ្ធិពលវិជ្ជមានដល់មនុស្សដែលនៅជុំវិញអ្នក ហើយជួយពួកគេឲ្យមានអារម្មណ៍នៃសុភមង្គល ។



## ការធ្វើសំណូមពរឲ្យមានសណ្ដានចិត្តល្អ

នៅពេលព្រះយេស៊ូវបានយាងមកជួបនឹងប្រជាជននៅទ្វីបអាមេរិក ទ្រង់បានបង្រៀនពួកគេឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយមានសណ្ដានចិត្តល្អ ។ តើអ្នកអាចធ្វើដូចម្ដេចខ្លះ ដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ ហើយស្រឡាញ់អ្នកដទៃ ? ទាំងនេះ គឺជាគំនិតយោបល់មួយចំនួន ។ ចូរគូសចោលនូវការធ្វើសំណូមពរនីមួយៗ ពេលអ្នកបានធ្វើបញ្ចប់ ។




រូបថតត្រីវិស័យ © ISTOCK/THINKSTOCK; រចនារូបភាពដោយ ខេតធី ម៉ាកធី

*សូមសិក្សាឯកសារនេះប្រកបដោយការអធិស្ឋាន ហើយព្យាយាមយល់ដឹងនូវអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងគោលលទ្ធិអំពីគ្រួសារ នឹងប្រទានពរដល់អស់អ្នក ដែលអ្នកត្រូវមើលថែក្នុងការបង្រៀនសួរសុខទុក្ខតាមផ្ទះយ៉ាងដូចម្ដេច ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក



ក្នុងការប្រជុំសមាគមសង្គ្រោះទូទៅនាឆ្នាំ ១៩៩៥ នៅពេលប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានអានជាលើកដំបូង « គ្រួសារ ៖ ការប្រកាសដល់ពិភពលោក » បូនី អិល អូស្ការសុន ដែលជាប្រធានយុវនារីទូទៅបានមានប្រសាសន៍ ៖ « យើងមានអំណរគុណណាស់ ហើយឲ្យតម្លៃទៅលើភាពច្បាស់លាស់ ភាពសាមញ្ញ និងសេចក្ដីពិតនៃឯកសារដ៏ប្រកបដោយវិវរណៈនេះ ។ . . . ការប្រកាសអំពីគ្រួសារ បានក្លាយជាបទដ្ឋានគោលរបស់យើង ដើម្បីវិនិច្ឆ័យអំពីទស្សនៈវិជ្ជារបស់ពិភពលោក ហើយខ្ញុំថ្លែងទីបន្ទាល់ថា គោលការណ៍ទាំងឡាយដែលបានស្ថាបនាឡើង . . . គឺជាការពិតនាសព្វថ្ងៃនេះ ដូចកាលពីមុន ពេលវាត្រូវបានផ្ដល់ឲ្យយើងដោយព្យាការីនៃព្រះស្ទើរតែ ២០ ឆ្នាំកន្លងទៅហើយនោះ ។[១]

« ចេញមកពីការប្រកាសអំពីគ្រួសារ » ខារ៉ូល អិម ស្ទីហ្វិន បានដែលជាទីប្រឹក្សានៅក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ បានបន្ថែមថា « យើងរៀនថា ‹ នៅជីវិតមុនផែនដី បុត្រា និង បុត្រីខាងវិញ្ញាណទាំងឡាយ បានស្គាល់ ហើយបានថ្វាយបង្គំព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ ›[២]. . .

« . . . យើងម្នាក់ៗមានចំណែកយ៉ាងសំខាន់ក្នុងក្រុមគ្រួសាររបស់ព្រះ » ។[៣]

យើងរស់នៅក្នុងគ្រាមួយដែលឪពុកម្ដាយត្រូវតែការពារដល់គេហដ្ឋាន និងក្រុមគ្រួសាររបស់ពួកគេ ។ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » អាចដឹកនាំយើង ។

### *សូមពិចារណាអំពីសំណួរនេះ*

តើ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ជាឯកសារមួយសម្រាប់ជំនាន់យើងយ៉ាងដូចម្ដេច ?

### *បទគម្ពីរបន្ថែម*

ម៉ូសាយ ៨:១៦–១៧;
គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៨

កំណត់ចំណាំ


១. បូនី អិល អូស្ការសុន « អ្នកការពារសេចក្ដីប្រកាសក្រុមគ្រួសារ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៤-១៥ ។
២. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ។
៣. ខារ៉ូល អិម ស្ទីហ្វិន « គ្រួសារគឺមកពីព្រះ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១១ ។
៤. នីកូល ស៊ីម្ប « ‹ គ្រួសារ ៖ A Proclamation to the World › reaches 10-Year Milestone » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ១២៧ ។
៥. បាបារ៉ា ថមសុន នៅក្នុង *Daughters in My Kingdom:* The History and Work of Relief Society *{៦៦}* ( ឆ្នាំ ២០១១ ) ទំព័រ ១៤៨ ។


សេចក្ដីជំនឿ ក្រុមគ្រួសារ
ការសង្គ្រោះ

### *ដំណើររឿងរបស់មនុស្សដែលរស់នៅសព្វថ្ងៃនេះ*

« លី ម៉ី ធិន ហូ មកពីវួដ តៅយួន ទីបីស្តេក តៅ យ៉ាន ប្រទេសតៃវ៉ាន់ បានមានប្រសាសន៍ថា ការប្រកាសបានបង្រៀនគាត់ថា ទំនាក់ទំនងគ្រួសារជួយអភិវឌ្ឍចរិតលក្ខណៈដ៏ទេវភាពដូចជា សេចក្ដីជំនឿ ការអត់ធ្មត់ និងសេចក្ដីស្រឡាញ់ ។ គាត់បានមានប្រសាសន៍ថា ‹ នៅពេលខ្ញុំព្យាយាមដើម្បីកែលម្អខ្លួនខ្ញុំ ស្របតាមការប្រកាសនេះ ខ្ញុំអាចទទួលបានបទពិសោធន៍នៃសុភមង្គលពិត › » ។[៤]

បាបារ៉ា ថមសុន ដែលមានវត្តមាននៅពេលដែលការប្រកាសនេះត្រូវបានអានជាលើកដំបូង ហើយក្រោយមក បានបម្រើជាទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានសមាគមសង្គ្រោះបានមានប្រសាសន៍ ៖ « ខ្ញុំបានគិតមួយស្របក់ថា [ការប្រកាសអំពីគ្រួសារ] ពុំសូវទាក់ទងជាមួយខ្ញុំទេ ពីព្រោះខ្ញុំពុំទាន់រៀបការ និងគ្មានកូនចៅផង ។ ប៉ុន្តែមួយរំពេចនោះខ្ញុំបានគិតឃើញថា ‹ វាពិតជាទាក់ទងនឹងខ្ញុំ ។ ព្រោះខ្ញុំជាសមាជិកម្នាក់ក្នុងក្រុមគ្រួសារមួយ ។ ខ្ញុំជាកូនស្រី ជាបង ឬ ជាប្អូនស្រីជាមីង ជាបងប្អូនជីដូនមួយ ជាក្មួយ និងជាចៅស្រីមួយរូបដែរ ។ . . . ទោះជាខ្ញុំគឺជាសមាជិកសាសនាចក្រដែលនៅរស់តែម្នាក់គត់ក្នុងគ្រួសារខ្ញុំក្ដី ក៏ខ្ញុំនៅតែជាសមាជិកនៃគ្រួសាររបស់ព្រះដែរ › » ។[៥]

# សៀវភៅកំណត់ចំណាំសន្និសីទ ខែ តុលា ឆ្នាំ ២០១៥

*« អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ . . . ទោះជាដោយសំឡេងរបស់យើងផ្ទាល់ ឬ ក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្ដីគឺដូចតែគ្នា » ( គ. និង ស. ១:៣៨ ) ។*

*នៅពេលអ្នកមើលសន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៥ ឡើងវិញ នោះអ្នកអាចប្រើប្រាស់ទំព័រទាំងនេះ ( និង សៀវភៅកំណត់ចំណាំសន្និសីទនៅច្បាប់ចេញផ្សាយនាពេលខាងមុខទៀត ) ដើម្បីជួយអ្នកសិក្សា ហើយអនុវត្តការបង្រៀនថ្មីៗរបស់ព្យាការី និង សាវកដែលរស់នៅ ព្រមទាំងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ។*

**ការដកស្រង់គោលលទ្ធិសំខាន់ៗ**



រូបថតសមាជិកកំពុងទស្សនាសន្និសីទនៅទីក្រុង ខៀវ ប្រទេស អ៊ុយក្រែន ដោយ ម៉ារីណា លូកខាច

## សេចក្ដីជំនឿគឺជាជម្រើសមួយ

« សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ គឺពុំមែនជាអ្វីដែលអណ្ដែតរសាយប៉ាយតាមខ្យល់នោះឡើយ ។ សេចក្ដីជំនឿនឹងពុំកើតមានដល់យើងដោយចៃដន្យឡើយ ហើយសេចក្ដីជំនឿក៏មិននៅជាប់ជាមួយយើងដោយសារតែមរតករបស់បងប្អូនដែរ ។ វាគឺដូចជាព្រះគម្ពីរចែងថា ‹ ចិត្តដែលដឹងជាក់ . . . ជាសម្គាល់ពីការដែលមើលមិនឃើញ › [ ហេព្រើរ ១១:១ ] ។ សេចក្ដីជំនឿបញ្ចេញពន្លឺខាងវិញ្ញាណ ហើយពន្លឺនោះគឺអាចញែកចេញបាន ។ សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាអំណោយមួយពីឋានសួគ៌ដែលប្រទានមក នៅពេលយើងជ្រើសរើសដើម្បីជឿ និង នៅពេលយើងស្វះស្វែងរកវា ហើយតោងជាប់នឹងវា ។ សេចក្ដីជំនឿអាចប្រែកាន់តែខ្លាំងឡើងៗ ឬ ក៏អាចចុះខ្សោយទៅៗ ។ សេចក្ដីជំនឿគឺជាគោលការណ៍នៃអំណាច ពុំមែនសំខាន់គ្រាន់តែសម្រាប់ជីវិតនេះនោះទេ ប៉ុន្តែវាសំខាន់នៅក្នុងការរីកចម្រើនរបស់យើងបន្ទាប់ពីសេចក្ដីស្លាប់ ។ តាមរយៈព្រះគុណនៃព្រះគ្រីស្ទ នោះថ្ងៃណាមួយ យើងនឹងត្រូវបានសង្គ្រោះតាមរយៈសេចក្ដីជំនឿលើព្រះនាមទ្រង់ ។ អនាគតនៃសេចក្ដីជំនឿរបស់អ្នក គឺពុំមែនកើតមកពីភាពចៃដន្យនោះទេ ប៉ុន្តែមកពីជម្រើសវិញ » ។

អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « សេចក្ដីជំនឿពុំមែនកើតមកពីភាពចៃដន្យនោះទេ ប៉ុន្តែមកពីជម្រើសវិញ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៦៥ ។

**ការសន្យាទាយទុកជាមុន**



## ចូរធ្វើឲ្យពន្លឺរបស់អ្នកបានភ្លឺឡើង

« នៅពេលយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នោះយើងនឹងមានឱកាសដើម្បីធ្វើជាពន្លឺនៅក្នុងជីវិតអ្នកដទៃ ទោះជាពួកគេជាគ្រួសារយើង មិត្តភក្តិ សហការី អ្នកស្គាល់គ្នា ឬមនុស្សមិនស្គាល់មុខក្ដី ។

« ខ្ញុំសូមនិយាយចំពោះបងប្អូនម្នាក់ៗថា បងប្អូនជាបុត្រា ឬបុត្រីរបស់ព្រះវរបិតាសួគ៌យើង ។ អ្នកបានមកពីវត្តមានរបស់ទ្រង់ ដើម្បីរស់នៅក្នុងផែនដីនេះមួយរយៈកាល ដើម្បីធ្វើជាគំរូនៃសេចក្ដីស្រឡាញ់ និងការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ហើយឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺចំពោះមនុស្សទាំងអស់ដោយក្លាហាន ។ នៅពេលជីវិតមែងស្លាប់របស់អ្នកបានបញ្ចប់ ប្រសិនបើអ្នកបានធ្វើនូវចំណែករបស់អ្នក នោះអ្នកនឹងមានពរជ័យដ៏រុងរឿងនៃការត្រឡប់ទៅរស់នៅជាមួយទ្រង់ជារៀងរហូត » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « ចូរធ្វើជាគំរូ និង ពន្លឺ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៨៨ ។

## សាក្សីពិសេសថ្មី



« ខ្ញុំមានអំណរគុណចំពោះដង្វាយធួនរបស់ព្រះអង្គសង្គ្រោះរបស់យើង ហើយចង់ស្រែកដូចអាលម៉ាជាមួយនឹងត្រែនៃព្រះ » ។ —អែលឌើរ រ៉ូណល អេ រ៉ាសបាន « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » ទំព័រ ៩០ ។



ខ្ញុំបានទទួលនូវអារម្មណ៍ជាក់លាក់ . . . ដែលពុំផ្ដោតតែលើអ្វីដែលខ្ញុំពុំអាចធ្វើនោះទេ ប៉ុន្តែទៅលើអ្វីដែលខ្ញុំអាចធ្វើវិញ ។ ខ្ញុំអាចថ្លែងទីបន្ទាល់អំពីសេចក្ដីពិតច្បាស់លាស់ និងមានតម្លៃនៃដំណឹងល្អ ។ —អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន « សេចក្ដីពិតច្បាស់លាស់ និងមានតម្លៃ » ទំព័រ ៩២ ។



« ខ្ញុំចង់ក្លាយជាអ្នកដើរតាមដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទដោយអស់ពីដួងចិត្តរបស់ខ្ញុំ ។ ខ្ញុំស្រឡាញ់ទ្រង់ ។ ខ្ញុំកោតសរសើរទ្រង់ ។ ខ្ញុំឃើញពីជាតុពិតនៃព្រះជន្មដ៏រស់រវើករបស់ទ្រង់ » ។ —អែលឌើរ ឌែល ជី រ៉េង្ឡាន់ « តាមរយៈព្រះនេត្ររបស់ព្រះ » ទំព័រ ៩៤ ។

## ចម្លើយសម្រាប់អ្នក

សន្និសីទនីមួយៗ ពួកព្យាការី និងពួកសាវក ផ្ដល់ចម្លើយដ៏បំផុសគំនិតចំពោះសំណួរ ដែលសមាជិកសាសនាចក្រអាចមាន ។ សូមប្រើប្រាស់ច្បាប់ចេញផ្សាយខែ វិច្ឆិកា ឆ្នាំ ២០១៥ ឬ ចូលទៅកាន់គេហទំព័រ conference.lds.org ដើម្បីស្វែងរកចម្លើយចំពោះសំណួរទាំងនេះ ៖

- ហេតុអ្វីបានជាសាសនាចក្រហាក់ដូចជាផ្ដល់ផលប្រយោជន៍ ដល់មនុស្សមួយចំនួនជាជាងមនុស្សឯទៀត ? សូមមើល ឌៀថើរ អេស្វ អុជដូហ្វ « វាផ្ដល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ ! » ទំព័រ ២០ ។
- តើមានសេចក្ដីពិត និង គោលលទ្ធិអ្វីខ្លះ ដែលអាចរក្សាយើងឲ្យតោងជាប់នឹងសាសនាចក្រដោយសុវត្ថិភាព ? សូមមើល អិម រ័សុល បាឡឺដ « ព្រះគង់នៅឯចង្កូត » ទំព័រ ២៤ ។
- ហេតុអ្វីបានជាតំណែងអ្នកដឹកនាំរៀមច្បងនៃសាសនាចក្រ ត្រូវបានបំពេញដោយបុរសចាស់ទុំទៅវិញ ? សូមមើល ដេវីឌ អេ បែដណា « ត្រូវបានជ្រើសរើសឲ្យថ្លែងទីបន្ទាល់អំពីនាមរបស់យើង » ទំព័រ ១២៨ ។
- ហេតុអ្វីបានជាខ្ញុំត្រូវចូលសាសនាចក្រ ប្រសិនបើខ្ញុំគិតថាខ្លួនខ្ញុំមានជីវភាពខាងវិញ្ញាណរួចទៅហើយដោយមិនចាំបាច់ចូលនោះក្តី ? សូមមើល ឌី ថត គ្រីស្តូហ្វឺសិន « ហេតុអ្វីជាសាសនាចក្រនេះ » ទំព័រ ១០៨ ។

ការបង្រៀនដែលស្របគ្នា

# ពិធីសាក្រាម៉ង់

ពេលខ្លះ មានអ្នកឡើងនិយាយជាច្រើន បានលើកឡើងអំពីប្រធានបទនៃដំណឹងល្អដូចៗគ្នា ។ នេះជាអ្វីដែលអ្នកឡើងនិយាយបីរូប បានថ្លែងពីពិធីសាក្រាម៉ង់ ៖

- « ប្រសិនបើយើងទទួលទានសាក្រាម៉ង់ដោយសេចក្ដីជំនឿ នោះព្រះវិញ្ញាណបរិសុទ្ធនឹងការពារយើង ព្រមទាំងមនុស្សដែលយើងស្រឡាញ់ពីការល្បួងដែលមានកម្លាំងខ្លាំងក្លា » ។ —ប្រធាន ហិនរី ប៊ី អាវរិង « ព្រះវិញ្ញាណបរិសុទ្ធជាដៃគូរបស់អ្នក » ទំព័រ ១០៤ ។
- « ថ្ងៃឈប់សម្រាក និង ពិធីសាក្រាម៉ង់ប្រែកាន់តែរីករាយខ្លាំងឡើងនៅពេលយើងសិក្សារឿងអំពីព្រះគ្រីស្ទ ។ នៅពេលធ្វើដូច្នោះ នោះយើងបង្កើតទំនៀមទម្លាប់នានាដែលស្ថាបនាសេចក្ដីជំនឿ និងទីបន្ទាល់របស់យើង ព្រមទាំងការពារក្រុមគ្រួសារយើងផងដែរ » ។ —អែលឌើរ ក្លូឌីអូ អរ អែម កូស្តា « ថាពួកគេនឹងចងចាំទ្រង់ជានិច្ច » ទំព័រ ១០១ ។
- « ពេលប្រសើរបំផុតដើម្បីទូលសួរថា ‹ តើខ្ញុំនៅខ្វះអ្វីទៀត ? › គឺជាពេលយើងទទួលទានសាក្រាម៉ង់ ។ . . . ក្នុងបរិយាកាសដ៏គារវភាពនេះ កាលគំនិតយើងបែរទៅរកស្ថានសួគ៌ នោះព្រះអម្ចាស់អាចមានបន្ទូលប្រាប់យើងដោយស្រទន់ អំពីអ្វីយើងត្រូវធ្វើបន្ទាប់ទៀត » ។ —អែលឌើរ ឡែរី អរ ឡរិន « តើខ្ញុំនៅខ្វះអ្វីទៀត ? » ទំព័រ ៣៤ ។

ដើម្បីអាន ទស្សនា ឬ ស្ដាប់សុន្ទរកថាសន្និសីទទូទៅ សូមចូលទៅកាន់គេហទំព័រ conference.lds.org ។

# យើងជឿលើការមានភាពវិជ្ជមាន

ជាញឹកញាប់យើងបានរកឃើញដំបូន្មាននៅក្នុងបទគម្ពីរឲ្យ « រីករាយ » និង « ឲ្យសង្ឃឹមឡើង » ។ ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់យើងនៅក្នុង នីហ្វៃទី ២ ២:២៥ ថា « មានមនុស្សលោកដើម្បីឲ្យពួកគេមានសេចក្ដីអំណរ » ។ គោលបំណងនៃជីវិតនេះ គឺត្រូវនាំយើងឲ្យទៅរកសេចក្ដីអំណរ ដែលព្រះអម្ចាស់បានសន្យានៅទីបំផុតនោះ ។

ការមានសង្ឃឹម ពុំមែនមានន័យថា ធ្វើជាមនុស្សល្ងង់ខ្លៅ ឬងងឹតងងល់ចំពោះឧបសគ្គនៃជីវិតនោះទេ ។ អែលឌើរ នែល អេ ម៉ាក់ស្វែល ( ឆ្នាំ ១៩២៦–២០០៤ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពិពណ៌នាដោយសេចក្ដីសោមនស្សថាជា « ការទុកចិត្តដ៏ជ្រាលជ្រៅទៅលើគោលបំណងដែលបើកបង្ហាញដោយព្រះ — ពុំគ្រាន់តែសម្រាប់មនុស្សលោកទាំងអស់ទេ ប៉ុន្តែសម្រាប់យើងដែលជាបុគ្គលម្នាក់ៗផងដែរ » ។[1] ឧបសគ្គនឹងកើតមានយ៉ាងជាក់ច្បាស់ ដ្បិតវាជាចំណែកមួយតាមធម្មជាតិនៃជីវិតរមែងស្លាប់ ប៉ុន្តែយើងពុំត្រូវធ្វេសប្រហែស... 

ព្រះយេស៊ូវគ្រីស្ទបានសន្យានឹងយើងថា យើងនឹងជួបសេចក្ដីវេទនា ប៉ុន្តែទ្រង់ក៏បានប្រាប់យើង « ឲ្យត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ » ( យ៉ូហាន ១៦:៣៣ ) ។ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន ( ឆ្នាំ ១៩៨៨–១៩៩៤ ) បានបង្រៀនថា ដោយសារតែយើងមានដំណឹងល្អនោះ « ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងគប្បីមានសុទិដ្ឋិនិយមឲ្យបានច្រើនបំផុត ហើយមានទុទិដ្ឋិនិយមឲ្យបានតិចបំផុត » ។[2]

យើងទាំងអស់គ្នាមានអារម្មណ៍សោកសៅ និងបាក់ទឹកចិត្តពីមួយគ្រាទៅមួយគ្រា ប៉ុន្តែយើងនៅតែអាចសង្ឃឹមជានិច្ច ។ អែលឌើរ រីឆាដ ជី ស្កត ( ១៩៨២-២០១៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ខ្ញុំសូមធ្វើជាសាក្សីថា តាមរយៈការមានសេចក្ដីជំនឿទៅលើព្រះអង្គសង្គ្រោះ និង ការគោរពប្រតិបត្តិតាមការបង្រៀនរបស់ទ្រង់ នោះអ្នកនឹងមានសុភមង្គលជានិច្ច រីឯសេចក្ដីសោកសៅនោះក៏នឹងរសាយបាត់ទៅវិញ »[3] យើងអាចរស់នៅដោយក្ដីអំណរដោយដឹងថា « សេចក្ដីទុក្ខលំបាករបស់យើងនោះ គ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ » ( គ. និង ស. ១២១:៧ ) ។

នៅពេលយើងដាក់នូវការទុកចិត្តរបស់យើងទៅលើផែនការរបស់ព្រះមានចំពោះយើង ហើយជ្រើសរើសរស់នៅដោយមានអាកប្បកិរិយាវិជ្ជមាន នោះសមត្ថភាពរបស់យើងក្នុងការទប់ទល់នឹងឧបសគ្គនៃជីវិតនឹងត្រូវបានពង្រឹងឡើង ។ ការបារម្ភ និងភាពភ័យខ្លាចរបស់យើង នឹងពុំសូវមានឥទ្ធិពលមកលើយើងឡើយ ហើយយើងនឹងមានបទពិសោធន៍នៃក្ដីអំណរដែលទ្រង់សព្វព្រះទ័យប្រទានដល់យើងជាមិនខាន ។ ■

### ជ្រើសរើសមានភាពសប្បាយរីករាយ



« មានអ្វីៗជាច្រើននៅក្នុងជីវិតនេះ ដែលពឹងផ្អែកទៅលើឥរិយាបថរបស់យើង ។ របៀបដែលយើងជ្រើសរើសអាកាត់ និងតបចំពោះអ្នកដទៃពិតជាសំខាន់ក្រៃលែង ។ ការធ្វើដោយអស់ពីសមត្ថភាពរបស់យើង ហើយបន្ទាប់មកជ្រើសរើសមានភាពសប្បាយរីករាយ នៅក្នុងកាលៈទេសៈទាំងឡាយរបស់យើង ថ្វីបើជាអ្វីក៏ដោយ នោះវានឹងអាចនាំមកនូវសន្តិភាព និង ការសប្បាយចិត្ត ។ យើងមិនអាចបញ្ជាខ្យល់បានទេ ប៉ុន្តែយើងអាចបង្វែរក្ដោងបាន ។ ដើម្បីបានសុភមង្គល ភាពសុខសាន្ត និង ភាពសុខដុមរមនាជាអតិបរិមា សូមឲ្យយើងជ្រើសរើសឥរិយាបទដ៏វិជ្ជមានមួយ ។

ប្រធាន ថូម៉ាស អេស ម៉នសុន « **Living the Abundant Life** » ***Liahona,*** ខែ មករា ឆ្នាំ ២០១២ ទំព័រ ៤ ។

កំណត់ចំណាំ

១. នែល អេ ម៉ាក់ស្វែល « But a Few Days » ( សុន្ទរកថាទៅកាន់គ្រូបង្រៀនសាសនា ស៊ី អ៊ី អេស ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៨២ ) ទំព័រ ៤ ។
២. អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន « Do not Despair » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៧៤ ទំព័រ ៦៥ ។
៣. រីឆាដ ជី ស្កត « Finding Joy in Life » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ២៦ ។
៤. ហ្គរដុន ប៊ី ហ៊ិងគ្លី « The Continuing Pursuit of Truth » *Ensign,* ខែ មេសា ឆ្នាំ ១៩៨៦ ទំព័រ ៤ ។

**បទគម្ពីរ និងពួកព្យាការីទាំងឡាយ បង្រៀនយើងអំពីរបៀបដែលយើងអាចមានអកប្បកិរិយាវិជ្ជមាន ៖**





*ភាពពេញលេញពិតនៃសេចក្តីអំណរ កើតមានមកតែតាមរយៈព្រះប៉ុណ្ណោះ ( សូមមើល គ. និង ស. ១០១:៣៦ ) ។ នៅពេលយើងងាកទៅរកទ្រង់ នោះដួងចិត្តរបស់យើងនឹងផ្លាស់ប្តូរ ។*

*ព្រះប្រទានពរដល់ជីវិតរបស់យើងម្នាក់ៗ ( សូមមើលទំនុកតម្កើង ១៤៥:៩ ) ។ យើងអាចព្យាយាមស្គាល់អំពីព្រះគុណដ៏ទន់ភ្លន់របស់ទ្រង់នៅក្នុងជីវិតរបស់យើង ។*



*ការផ្តោតការយកចិត្តទុកដាក់របស់យើងទៅលើព្រះជាប់ជានិច្ច គឺពុំមែនកើតឡើងតែម្តងនោះទេ ។ យើងត្រូវតែធ្វើ និងរក្សាសេចក្តីសញ្ញាដោយខ្ជាប់ខ្ជួន ដូចជាការទទួលទានសាក្រាម៉ង់ដោយសក្តិសមរាល់សប្តាហ៍ជាដើម ។*



*យើង ក៏ដូចជានីហ្វៃ អាចរីករាយនៅក្នុងបទគម្ពីរ ( នីហ្វៃទី ២ ៤:១៥–១៦ ) ។ ការអានព្រះបន្ទូលនៃព្រះ និងប្រសាសន៍ទាំងឡាយរបស់ពួកព្យាការីទ្រង់ទាំងឡាយ នឹងធ្វើឲ្យដួងចិត្តយើងរីករាយ ។*



*ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានលើកទឹកចិត្តយើងឲ្យ « និយាយអំពីគុណធម៌របស់គ្នាទៅវិញទៅមក ឲ្យច្រើនជាងយើងនិយាយអំពីកំហុសរបស់គ្នាទៅវិញទៅមក » ហើយ « សរសើរអំពីគុណធម៌ និងការខិតខំប្រឹងប្រែងឲ្យបានកាន់តែសប្បុរស » ។[៤]*

រចនារូបភាពដោយ ជេ បើត ប៊ិបសុន

# ការការពារដ៏ល្អបំផុតនៅទីបំផុតរបស់យើងទាស់នឹងរូបអាសគ្រាម

ដោយ ឃែរី ហានសុន ដែនសិន

*នៅក្នុងខគម្ពីរមួយ ខ្ញុំបានឃើញគន្លឹះរបស់គ្រួសារខ្ញុំដើម្បីចៀសវាងពីរូបភាពជាក់ស្ដែង ដែលហាក់ដូចជាមាននៅគ្រប់ទីកន្លែង ។*

ខ្ញុំបានដើរផ្សារកទិញសម្លៀកបំពាក់ទៅរៀនជាមួយនឹងកូនប្រុសអាយុប្រាំបួនឆ្នាំរបស់ខ្ញុំ នៅពេលដែលការសន្ទនារបស់យើង បានផ្លាស់ប្ដូរពីការនិយាយដោយរីករាយទៅជាចម្ងល់កាន់តែហ្មត់ចត់មួយវិញ ។ « ម៉ាក់ ហេតុអ្វីក៏ពួកគេដាក់អ្វីៗទាំងនោះនៅគ្រប់បង្អួចហាងដូច្នេះ ? 

« អ្វីៗទាំងនោះ » គឺគាត់ចង់សំដៅទៅលើរូបភាពអសីលធម៌ ដែលដាក់តាំងនៅស្ទើរតែគ្រប់ហាងដែលយើងបានដើរឆ្លងកាត់ ។ ទោះជារូបភាពនានាហាក់ដូចជាមាននៅទីនោះជានិច្ចក្ដី តែខ្ញុំពុំបានយកចិត្តទុកដាក់នឹងវាទេពីមុនមកនោះ ។ ប៉ុន្តែធាតុពិតដែលកូនប្រុសច្បងរបស់ខ្ញុំបានចាប់ផ្ដើមកត់សម្គាល់ បានបណ្ដាលឲ្យខ្ញុំបានចាប់អារម្មណ៍ជាថ្មី ។ នៅប៉ុន្មានសប្ដាហ៍ក្រោយមក ខ្ញុំបានចាប់ផ្ដើមឃើញរូបភាពទាំងនេះនៅគ្រប់ទីកន្លែង ៖ នៅតាមទូរទស្សន៍ នៅតាមហាងលក់ម្ហូបអាហារ នៅតាមភោជនីយដ្ឋាន នៅក្នុងការផ្សាយពាណិជ្ជកម្ម ដែលផ្ញើមកតាមអ៊ីម៉ែល ។ ខ្ញុំពុំអាចគេចចេញពីវាឡើយ ។ រូបភាពមួយចំនួន បានបង្ហាញស្ដែងខ្លាំងពេក ដែលខ្ញុំចាប់ផ្ដើមមានអារម្មណ៍ច្របូកច្របល់ ហើយចាប់ផ្ដើមមានអារម្មណ៍ភ័យខ្លាច នៅក្នុងដួងចិត្តខ្ញុំ ។ តើខ្ញុំត្រូវការពារគ្រួសារខ្ញុំពីអន្ទាក់នៃរូបអាសគ្រាមយ៉ាងដូចម្ដេច ?

នៅគ្រប់សន្និសីទទូទៅ យើងបានស្ដាប់ឮការព្រមានអំពីឥទ្ធិពលដ៏បំផ្លិចបំផ្លាញរបស់វា ហើយយើងបានស្គាល់ជនរងគ្រោះរបស់វា ។ យើងបានប្រុងប្រយ័ត្នយ៉ាងខ្លាំងចំពោះកុំព្យូទ័រ និងប្រព័ន្ធផ្សព្វផ្សាយ ដែលមាននៅក្នុងផ្ទះរបស់យើងប៉ុន្តែច្បាស់ណាស់ លុះត្រាតែកូនៗរបស់យើងត្រូវបានដាក់ឃុំឃាំងនៅឲ្យឆ្ងាយដាច់តែឯង បើមិនដូច្នោះទេ វាហាក់ដូចជាគ្មានផ្លូវណាដែលអាចចៀសផុតពីការមើលឃើញនូវរូបភាពដែលយើងពុំចង់មើលឃើញ ដែលនឹងនាំឲ្យចង់ដឹងចង់ឃើញបន្ថែមនោះទេ ។ តើការមើលឃើញដោយគ្មានកំហុសរបស់កូនប្រុសខ្ញុំនៅឯហាងលក់ម្ហូបអាហារ អាចក្លាយទៅជាបញ្ហាខាងរូបអាសគ្រាមពេញមួយជីវិតរបស់គាត់ដែរឬទេ ? ការបារម្ភរបស់ខ្ញុំចំពោះរឿងនេះបានមានកាន់តែខ្លាំងឡើងៗ ហើយខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ថាគ្មានប្រយោជន៍ និងធ្វើមិនបានល្អនៅក្នុងការការពារកូនរបស់ខ្ញុំ ។

បន្ទាប់មកនៅថ្ងៃមួយ ពេលខ្ញុំកំពុងអានព្រះគម្ពីរមរមន ខ្ញុំបានរកឃើញនូវការអះអាងមួយដោយពុំរំពឹងទុកជាមុននៅក្នុង នីហ្វៃទី ១ ១៥ ។ នីហ្វៃកំពុងពន្យល់អំពីការនិមិត្តរបស់លីហៃអំពីដើមឈើនៃជីវិតទៅដល់លេមិន និងលេមយួល នៅពេលពួកគេសួរអំពីអត្ថន័យនៃទឹកទន្លេ ។ នីហ្វៃបានឆ្លើយនៅក្នុងខទី ២៧ ៖ « ហើយខ្ញុំបាននិយាយទៅពួកគេថា ទឹកដែលឪពុកខ្ញុំឃើញនោះ គឺជាភាពស្មោកគ្រោក *ហើយដោយចិត្តលោករវល់តែគិតដល់រឿងផ្សេងៗទៀត បានជាលោកមិនបានឃើញភាពស្មោកគ្រោកនៃទឹកនោះ* » ( សេចក្ដីបញ្ជាក់ត្រូវបានបន្ថែម ) ។ គំនិតរបស់លីហៃបានផ្ដោតទៅលើដើមឈើនៃជីវិត ហើយបាននាំគ្រួសារលោកឲ្យផ្ដោតលើវា ដើម្បីទទួលទានផ្លែឈើនោះ ! លោកពុំបានមើលឃើញនូវភាពស្មោគគ្រោករបស់វាទេ ដោយសារតែការផ្ដោតចិត្តនេះ ។

នោះគឺជាចម្លើយ ! ការរារាំងកុំឲ្យមានប្រព័ន្ធផ្សព្វផ្សាយមិនល្អនៅក្នុងផ្ទះរបស់យើង គឺជាការចាប់ផ្ដើម ប៉ុន្តែកិច្ចខិតខំដែលកាន់តែដោយផ្ទាល់ និងដោយយកចិត្តទុកដាក់ក្នុងការបង្រៀនកូនៗរបស់យើងអំពីដំណឹងល្អ គឺជាអ្វីដែលនឹងជាការការពារដ៏ល្អបំផុតនៅទីបំផុត ទាស់នឹងរឿងគ្រប់យ៉ាងដែលអាចនាំពួកគេឲ្យឃ្លាតឆ្ងាយពីនោះ ។

ដោយសារតែបទពិសោធន៍ជាមួយនឹងព្រះគម្ពីរនេះ ស្វាមីខ្ញុំ និងខ្ញុំបានសម្រេចចិត្តខិតខំបន្ថែមទៀតក្នុងការបង្រៀនដល់កូនៗរបស់យើង ហើយរក្សាកែភ្នែករបស់យើងផ្ដោតទៅលើសេចក្ដីស្រឡាញ់នៃព្រះ ជំនួសឲ្យភាពស្មោកគ្រោកខាងលោកិយ ។ យើងមានអារម្មណ៍ដ៏អស្ចារ្យដើម្បីផ្ដោតទៅលើចំណុចបីផ្សេងៗគ្នា* ៖

សម្រាប់អ្នកទាំងឡាយដែលមានបញ្ហាជាមួយនឹងរូបអាសគ្រាម នោះមាននូវធនធាននានាដែលអាចរកបាននៅលើគេហទំព័ររបស់សាសនាចក្រ **overcomingpornography.org** និងនៅក្នុងអត្ថបទថ្មីៗមួយដោយអែលឌើរ ដាល្លិន អេក អូក « ការជាសះស្បើយពីអន្ទាក់នៃរូបអាសគ្រាម » នៅក្នុងខែតុលា ឆ្នាំ ២០១៥ *លីអាហូណា* ។



*គំនិតរបស់លីហៃបានផ្ដោតទៅលើដើមឈើនៃជីវិត ហើយបាននាំគ្រួសារលោកឲ្យផ្ដោតលើវា ដើម្បីទទួលទានផ្លែឈើ ! លោកពុំបានមើលឃើញនូវភាពស្មោគគ្រោករបស់វាទេ ដោយសារតែការផ្ដោតរបស់លោក ។*

ប្រភាពរូបថតពី ដើមឈើនៃ ជីវិត, ដោយ កាសូកូ ស៊ីតា

**១. បង្កើនការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់យើង ហើយបន្ថយ « សំឡេង » ដែលនៅជុំវិញយើង ។** ដូចជា លីហៃ ដែរ គំនិតរបស់យើង ត្រូវតែពោរពេញទៅដោយរឿងវិជ្ជមានដើម្បីស្ដាប់ឮការបំផុសគំនិតពីព្រះវិញ្ញាណ ហើយរក្សាយើងឲ្យផ្ដោតការយកចិត្តទុកដាក់ទៅលើការបោះយុថ្កាគ្រួសាររបស់យើងនៅក្នុងដំណឹងល្អ ។ ស្វាមីរបស់ខ្ញុំ និងខ្ញុំ ព្យាយាមចំណាយពេលពិភាក្សាអំពីតម្រូវការខាងវិញ្ញាណរបស់សមាជិកម្នាក់ៗក្នុងគ្រួសារ និងរបៀបដែលយើងអាចបំពេញតម្រូវការទាំងនោះ ហើយធ្វើឲ្យគេហដ្ឋានក្លាយជាកន្លែងដែលព្រះវិញ្ញាណអាចរីកចម្រើនឡើងជាទៀងទាត់ ។

**២. ការធ្វើឲ្យការសិក្សាព្រះគម្ពីរជាគ្រួសារកាន់តែមានអត្ថន័យ ។** ថ្វីបើវាតម្រូវឲ្យមានការខិតខំយ៉ាងច្រើនដើម្បីប្រមូលសមាជិកគ្រួសារជុំគ្នាជារៀងរាល់ថ្ងៃដើម្បីអានព្រះគម្ពីរក្ដី ក៏យើងកំពុងព្យាយាមដើម្បីមានការពិភាក្សាកាន់តែច្រើន នៅពេលយើងអានព្រះគម្ពីរដែរ ។ យើងមានកូនៗដែលមានអាយុឃ្លាតៗគ្នាខ្លាំង ដូច្នេះយើងអានព្រះគម្ពីរជាមួយនឹងកូនតូចៗពេលថ្ងៃ ហើយអានជាមួយនឹងកូនធំៗនៅពេលព្រឹកព្រលឹម ជាពេលដែលកូនតូចៗកំពុងតែនៅគេងនៅឡើយ ដូច្នេះមានការរំខានតិច ហើយមានឱកាសកាន់តែច្រើនសម្រាប់ការពិភាក្សាគ្នា ។ យើងបានឃើញថា យើងបានពិភាក្សាស្ទើរតែរាល់ថ្ងៃអំពីព្រឹត្តិការណ៍បច្ចុប្បន្នដែលទាក់ទងទៅនឹងបទគម្ពីរដែលយើងអាន ។

ពេលព្រឹកភាគច្រើនគឺពុំសូវល្អទេ ប៉ុន្តែដោយសារការស៊ូទ្រាំ នោះយើងអាចឃើញថា កូនៗគឺពិតជាស្ដាប់ ហើយចូលរួម ទោះជាពេលខ្លះវាត្រូវចំណាយការខិតខំច្រើនដើម្បីឲ្យគ្រប់គ្នាមកចូលរួមក្ដី ។

**៣. ការធ្វើកិច្ចការផ្សព្វផ្សាយសាសនា ។** នៅពេលយើងថ្លែងទីបន្ទាល់នោះព្រះវិញ្ញាណបានថ្លែងទីបន្ទាល់ថា អ្វីៗដែលយើងនិយាយគឺពិត ហើយទីបន្ទាល់របស់យើងរីកចម្រើន ។ យើងព្យាយាមធ្វើឲ្យកិច្ចការផ្សព្វផ្សាយសាសនាជាកិច្ចការរបស់គ្រួសារ ។ យើងនិយាយអំពីការចែកចាយដំណឹងល្អ ហើយយើងក៏បានអញ្ជើញមិត្តភក្ដិមកផ្ទះរបស់យើងយ៉ាងទៀងទាត់ ។ យើងក៏អាចឆ្លៀតគ្រប់ឱកាសដើម្បីអញ្ជើញអ្នកផ្សព្វផ្សាយសាសនា និងអ្នករៀនថ្មីមកចូលរួម នៅពេលមានការពិភាក្សាអំពីដំណឹងល្អផងដែរ ។ យើងមានបទពិសោធន៍ដ៏អស្ចារ្យជាច្រើនក្នុងការអញ្ជើញសមាជិកថ្មីនៃសាសនាចក្រ និងអ្នករៀនថ្មីមករៀនក្នុងផ្ទះរបស់យើង ហើយវាបានធ្វើឲ្យកូនៗរបស់យើងចាប់អារម្មណ៍ នៅពេលពួកគេនឹកគិតអំពីទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេ និងបានស្ដាប់ឮមកពីអ្នកផ្សព្វផ្សាយសាសនាទាំងនោះ ។

ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះព្រះគម្ពីរមរមន ហើយរបៀបដ៏ប្រកបដោយអព្ភូតហេតុនោះ គឺខគម្ពីរមួយ បានផ្ដល់នូវការអះអាងដល់ខ្ញុំ និងការដឹកនាំដ៏ច្បាស់មួយសម្រាប់គ្រួសាររបស់យើង ។ បទគម្ពីរពិតជាអាចយកមកដាក់ជំនួសភាពភ័យខ្លាច និងភាពគ្មានជំនួយដោយព្រះចេស្ដា និងភាពសុខសាន្តយ៉ាងពិតប្រាកដមែន ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ វ៉ាស៊ីងតោន ស.រ.អា. ។*

* ក្រុមគ្រួសារផ្សេងអាចនឹងចាំបាច់ត្រូវផ្ដោតទៅលើផ្នែកផ្សេងទៀត ដូចជាមេរៀនដើម្បីបង្រៀនកូនៗអំពីប្រព័ន្ធផ្សព្វផ្សាយ អំពីរូបកាយរបស់យើង និងភាពសមរម្យខាងផ្លូវភេទ ។

# ពុំមែនជាអព្ភូតហេតុដែលយើងចង់បានទេ

ដោយ ប្រិថានី យីង

*ពេលខ្លះយើងអធិស្ឋានហើយអធិស្ឋានទៀត រហូតដល់ជង្គង់របស់យើងឈឺ ដើម្បីសុំឲ្យមានអព្ភូតហេតុដែលយើងចង់បាន ប៉ុន្តែក្រោយមកព្រះបានប្រទានដល់យើងនូវអព្ភូតហេតុដែលយើងត្រូវការ ។*

ក្នុងប៉ុន្មានខែទៀត ខ្ញុំនឹងបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ហើយខ្ញុំសង្ឃឹមថានឹងមានកូនដំបូង ។ ស្វាមីខ្ញុំ មានចិត្តអន្ទះសារឲ្យខ្ញុំចាប់ផ្តើមមានកូនៗ ។

មួយឆ្នាំ បួនខែ មានការធ្វើតេស្តអំពីការមានផ្ទៃពោះ លទ្ធផលអវិជ្ជមានជាងដប់ពីរដង ការធ្វើតេស្តអំពីការបង្កកំណើតលទ្ធផលអវិជ្ជមានប្រាំដង ហើយបានលេបថ្នាំចំនួនពីរខែយ៉ាងធុញទ្រាន់ ហើយរងទឹកភ្នែករាប់ពាន់ដំណក់ យើងគ្មានកូនទេ ហើយមានក្តីសង្ឃឹមតិចតួចណាស់ចំពោះការមានកូនតាមធម្មជាតិនោះ ។ នៅពេលការិយាល័យវេជ្ជបណ្ឌិតបានទូរសព្ទមក ហើយសុំណែនាំយើងឲ្យទៅពេទ្យជំនាញខាងជំងឺអារ យើងបានបដិសេធ ។ យើងមានភាពអស់សង្ឃឹមច្រើនល្មមគ្រប់គ្រាន់ហើយ យើងត្រូវការការសម្រាក ។ ពីមុនខ្ញុំបិទទូរសព្ទ គិលានុប្បដ្ឋាយិកាបាននិយាយថា « សូមទូរសព្ទមកកាន់យើង បើអ្នកមានអព្ភូតហេតុមួយ » ។

មែនហើយ អព្ភូតហេតុ គឺជាភាពអស្ចារ្យ ។ វាកើតមានឡើងទាំងធំ និងតូច ។ អព្ភូតហេតុកើតមានឡើងនៅពេលយើងពុំសូវរំពឹងអំពីវា ហើយនៅពេលយើងត្រូវការវាជាចាំបាច់ ។ ហើយពេលខ្លះយើងអធិស្ឋានហើយអធិស្ឋានទៀត រហូតដល់ជង្គង់របស់យើងឈឺ ដើម្បីសុំឲ្យមានអព្ភូតហេតុដែលយើងចង់បាន ប៉ុន្តែក្រោយមកព្រះបានប្រទានដល់យើងនូវអព្ភូតហេតុដែលយើងត្រូវការ ។

អស់រយៈពេលជាយូរ យើងបានអធិស្ឋានយ៉ាងខ្លាំងសុំឲ្យមានកូន ប៉ុន្តែស្ថានសួគ៌ហាក់ដូចជាពុំឆ្លើយតបសោះ ។ នៅទីបញ្ចប់ វាបានកើតឡើងចំពោះយើងថា យើងកំពុងអធិស្ឋានសុំខុសរឿង ។ ព្រះជ្រាបថាពរជ័យអ្វីខ្លះដែលយើងត្រូវការ ហើយនៅពេលណាយើងត្រូវការវា ។ ទ្រង់ទតឃើញរូបភាពទាំងមូល ។ យើងមើលឃើញតែ*ពេលឥឡូវនេះ*ទេ ។ ដូច្នេះយើងបានផ្លាស់ប្តូរគំនិត ។ យើងឈប់អធិស្ឋានសុំអ្វីដែលយើងចង់បាន ប៉ុន្តែបានចាប់ផ្តើមថ្លែងពាក្យ « អរគុណ » ។

*ព្រះវរបិតាសួគ៌អើយ សូមអរគុណទ្រង់ដែលប្រទានពរឲ្យយើងបានរួមជីវិតនឹងគ្នា ។*

*អរព្រះគុណទ្រង់ចំពោះគ្រួសារ និងមិត្តភក្តិដែលគេយកចិត្តទុកដាក់នឹងយើង ។*

*អរព្រះគុណទ្រង់ចំពោះកុមារតូចៗដែលនៅជុំវិញយើង ដែលយើងអាចរីករាយរហូតដល់ពេលយើងនឹងមានកូនតូចៗខ្លួនយើង ។*

*អរព្រះគុណទ្រង់ចំពោះវេជ្ជបណ្ឌិត និងវិទ្យាសាស្ត្រដែលជួយរកឃើញនូវអ្វីដែលរូបកាយយើងដំណើរការ និងមិនដំណើរការ ។*



*ហើយ* ( ឥឡូវរឿងដែលលំបាកបំផុតដែលយើងត្រូវថ្លែងគឺ ) *អរគុណទ្រង់ចំពោះការសាកល្បងនេះ ។*

ការមានអំណរគុណចំពោះអ្វីដែលធ្វើឲ្យយើងបាក់ទឹកចិត្ត គឺជារឿងលំបាក ប៉ុន្តែយើងដឹងថាព្រះវរបិតាសួគ៌ ស្រឡាញ់យើង ។ ដូច្នេះនៅក្នុងការសាកល្បងនេះ មាននូវពរជ័យនៅកន្លែងណាមួយហើយ ។ យើងនឹងពុំរកឃើញពរជ័យទេ បើយើងពុំទុកឲ្យការសាកល្បងមានមកលើយើងនោះ ។ ផ្ទុយទៅវិញ យើងបានជ្រើសរើសដើម្បីមានអំណរគុណ — ហើយនៅពេលយើងបានធ្វើដូច្នោះ នោះពរជ័យបានបង្ហាញច្បាស់ ៖

យើងពឹងផ្អែកទៅលើគ្នាទៅវិញទៅមកច្រើនជាងមុន បានចែកចាយអារម្មណ៍ច្រើនជាងមុន ហើយស្រឡាញ់គ្នាច្រើនជាងមុន ។

យើងពឹងផ្អែកទៅលើព្រះច្រើនជាងមុន ហើយអធិស្ឋានច្រើនជាងមុន ។

យើងបានខិតមកកាន់តែជិតព្រះអង្គសង្គ្រោះច្រើនជាងមុន ហើយដឹងពីវត្តមានទ្រង់ច្រើនជាងមុន ហើយស្រឡាញ់ទ្រង់ច្រើនជាងមុន ។

យើងដឹងពីក្តីស្រឡាញ់របស់គ្រួសារ និងមិត្តភក្តិដែលកំពុងអធិស្ឋានសម្រាប់យើង ។

ហើយនៅពេលយើងទទួលស្គាល់នូវពរជ័យទាំងអស់នេះ នោះយើងយកឈ្នះដោយដួងចិត្តបរិសុទ្ធបំផុត ភាពសុខសាន្តដ៏ផ្អែមល្ហែមបំផុត តាមដែលអាចនឹកស្រមៃដល់ ។

កាលដែលយើងពុំមានគ្រួសារមួយនៅគ្រានោះ ពុំមែនមានន័យថាព្រះពុំយកព្រះទ័យទុកដាក់នឹងយើងនោះទេ ។ យើងចាំបាច់គ្រាន់តែទុកចិត្តទៅលើពេលវេលារបស់ទ្រង់ ហើយយើងត្រូវការនូវភាពសុខសាន្តរបស់ទ្រង់ ដើម្បីរក្សាឲ្យមានទំនុកចិត្តនោះឲ្យរស់រវើក ។ យើងត្រូវការភាពសុខសាន្តរបស់ទ្រង់ ដើម្បីចងរុំដួងចិត្តប្រេះស្រាំរបស់យើង ហើយប្រទានដល់យើងនូវសេចក្តីជំនឿដើម្បីបន្តឆ្ពោះទៅមុខទៀត ។

ភាពសុខសាន្តគឺជាអព្ភូតហេតុដែលយើងត្រូវការ — ពុំមែនជាអព្ភូតហេតុដែលយើងទទូចសូមនោះទេ ប៉ុន្តែជាអ្វីដែលយើងត្រូវការបំផុត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*



# សូមអធិស្ឋានអំពីវា

ដោយ ថារីន ថេលើរ

*ខ្ញុំបានសុំព្រះអម្ចាស់ឲ្យបង្ហាញខ្ញុំអំពីរបៀបដើម្បីក្លាយជាម្ដាយកាន់តែល្អប្រសើរ ហើយទ្រង់បានប្រទានដល់ខ្ញុំនូវការហៅបម្រើដែលនឹងបង្រៀនខ្ញុំអំពីវិធីសាស្ត្រដើម្បីធ្វើបែបនោះ ។*

ខ្ញុំបានប្រាប់ប៊ីស្សពថា លោកបានរើសមនុស្សខុសហើយ ។

ខ្ញុំបាននិយាយថា « ខ្ញុំពុំចូលចិត្តកូនរបស់អ្នកផ្សេងទេ ខ្ញុំពុំដែលបង្រៀនកុមារតូចៗទេ ហើយខ្ញុំពុំចេះច្រៀងទេ » ។

លោកបានតបថា « បងស្រី ថេលើរ ព្រះអម្ចាស់នឹងធ្វើឲ្យមនុស្សទាំងអស់ដែលទ្រង់ហៅបានសក្តិសម ។ បងស្រីនឹងធ្វើបានល្អ » ។

លោកបានសុំឲ្យខ្ញុំគិតអំពីការហៅបម្រើនោះ ហើយចូរប្រាប់ឲ្យលោកបានដឹងវិញនៅថ្ងៃអាទិត្យក្រោយ ថាខ្ញុំនឹងទទួលយកឬអត់ ។

ខ្ញុំបាននិយាយថា « ខ្ញុំព្យាយាមចិញ្ចឹមកូនអាយុប្រាំមួយឆ្នាំ បីឆ្នាំ និងកូនតូចមួយទៀត » ។ « ខ្ញុំស្ទើរតែមិនអាចមើលថែទាំកូនរបស់ខ្ញុំបានផង ហើយឥឡូវលោកចង់ឲ្យខ្ញុំមើលកុមារ ៤០ នាក់ជាងទៀត ហើយខ្ញុំត្រូវបង្រៀនតន្ត្រីដល់ពួកគេទៀត ? »

លោកបានតបថា « ចូរអធិស្ឋានអំពីវា » ។

នៅល្ងាចនោះ ខ្ញុំបានព្យាយាមពន្យល់ដល់ស្វាមីរបស់ខ្ញុំ ម៉ាក អំពីមូលហេតុដែលខ្ញុំគិតថាការហៅនេះជាគំនិតមិនល្អ ។ តើខ្ញុំអាចធ្វើការនៅក្នុងថ្នាក់អង្គការបឋមសិក្សាបានយ៉ាងដូចម្ដេច បើខ្ញុំពុំអាចធ្វើជាម្ដាយម្នាក់ចំពោះកូនៗរបស់ខ្ញុំ តាមសេចក្ដីប្រាថ្នាចង់ធ្វើផងនោះ ? ភាពភ័យខ្លាចបានរំខានខ្ញុំរាប់ខែ ដែលខ្ញុំពុំបានធ្វើជាម្ដាយល្អម្នាក់នោះទេ ។

មួយសប្ដាហ៍បានកន្លងហួសទៅយ៉ាងលឿន ប៉ុន្តែគំនិតរបស់ខ្ញុំបានគិតពីពាក្យរបស់ប៊ីស្សព ។ ទីបំផុត នៅព្រឹកថ្ងៃអាទិត្យក្នុងបន្ទប់គេងរបស់ខ្ញុំ ខ្ញុំបានលុតជង្គង់ចុះអធិស្ឋាន ។ ទឹកភ្នែកបានស្រក់ចុះ ប៉ុន្តែភាពសុខសាន្តដ៏ផ្អែមល្ហែមបានមានពេញក្នុងដួងចិត្តរបស់ខ្ញុំ ។ រំពេចនោះ ខ្ញុំបានដឹងថាវាគឺជារឿងត្រឹមត្រូវដើម្បីទទួលយកការហៅបម្រើនោះ ។ ដោយបានចុះចូលតាមព្រះទ័យនៃព្រះអម្ចាស់ នោះរាល់ភាពភ័យខ្លាចទាំងអស់បានរលត់បាត់ពីដួងចិត្តរបស់ខ្ញុំ ។

នៅពេលខ្ញុំចូលទៅក្នុងបន្ទប់ថ្នាក់បឋមសិក្សាបន្ទាប់ពីការប្រជុំសាក្រាម៉ង់ ប្រធានអង្គការបឋមសិក្សាបានណែនាំអំពីខ្ញុំ ហើយកុមារតូចៗបានច្រៀងចម្រៀងស្វាគមន៍មួយបទ ។ ពេលមើលទៅកែវភ្នែកប្រកបដោយក្ដីសង្ឃឹមរបស់ពួកគេ និងពេលមើលឃើញរស្មីនៅក្នុងកូនប្រុសអាយុប្រាំមួយឆ្នាំរបស់ខ្ញុំ នោះខ្ញុំបានក្លាយទៅជាអ្នកដឹកនាំភ្លេងថ្នាក់បឋមសិក្សាដ៏ល្អបំផុតដែលខ្ញុំអាចធ្វើបាន ។

ចាប់ពីពេលនោះមក ខ្ញុំបានចំណាយពេលច្រើនរៀនបទចម្រៀង ហើយរៀបចំមេរៀន ។ ខ្ញុំបានចាក់បទចម្រៀងកុមារនៅផ្ទះ ក្នុងឡាន និងពេលដើរ ។ ខ្ញុំបានស្រាវជ្រាវរកវិធីបង្រៀនផ្សេងៗ ហើយបានលះបង់ពេលវេលាជាច្រើនម៉ោងរាល់សប្ដាហ៍ដើម្បីធ្វើបណ្ណប្រកាស ហើយបង្កើតល្បែងកំសាន្ត ។

នៅពេលខ្ញុំបានរៀបចំមេរៀនសម្រាប់ម៉ោងច្រៀងនាល្ងាចមួយនៅតុបាយ ខ្ញុំបានច្រៀងរហឹមៗនូវបទ « អំណាចព្រះគម្ពីរ » ។ កូនប្រុសអាយុប្រាំមួយឆ្នាំរបស់ខ្ញុំអង្គុយនៅតុញ៉ាំសាំងវិច ហើយកូនអាយុបីឆ្នាំរបស់ខ្ញុំ អង្គុយកាត់ក្រដាសក្បែរខ្ញុំ ។ នៅពេលខ្ញុំច្រៀងរហឹមៗនៅកន្លែងបន្ទរ រំពេចនោះកូនខ្ញុំទាំងពីរនេះបានច្រៀងថា ៖

*អំណាចគម្ពីររក្សាខ្ញុំពីបាប ។*
*អំណាចគម្ពីរជាអំណាចដើម្បីឈ្នះ ។*
*អំណាចនៃព្រះគម្ពីរ ! ខ្ញុំត្រូវការរាល់ថ្ងៃ*
*អំណាចដែលខ្ញុំទទួលរាល់ពេលខ្ញុំអាន ។*[១]

ពេលនោះហើយដែលខ្ញុំដឹងថា ការហៅបម្រើគឺជាចម្លើយចំពោះការអធិស្ឋានរបស់ខ្ញុំ ។ ខ្ញុំបានទូលសូមព្រះអម្ចាស់ដើម្បីបង្ហាញខ្ញុំពីរបៀបដើម្បីធ្វើជាម្ដាយកាន់តែល្អប្រសើរ នោះទ្រង់បានប្រទានការហៅបម្រើមួយដល់ខ្ញុំ ដែលនឹងបង្រៀនខ្ញុំពីរបៀបនោះ ពេលខ្ញុំបង្រៀនតន្ត្រីដល់កូនៗរបស់ខ្ញុំ ។

ខ្ញុំមានអំណរគុណចំពោះការបំផុសគំនិតរបស់ប៊ីស្សពខ្ញុំ និងពាក្យសម្ដីជាទីស្រឡាញ់របស់លោក ៖ « សូមអធិស្ឋានអំពីវា » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*

កំណត់ចំណាំ

១. ក្លីវ រ៉មនី « Scripture Power » lds.org/callings/primary/sharing-time-music ។

រចនារូបភាពដោយ ខាធី ផេន

# ព័ត៌មាននៃសាសនាចក្រ

*សូមចូលទៅកាន់គេហទំព័រ news.lds.org សម្រាប់ព័ត៌មាន និង ព្រឹត្តិការណ៍នានាបន្ថែមទៀត ។*









*ខាងលើ ៖ ព្រះវិហារបរិសុទ្ធ ទីក្រុងឥណ្ឌាណាប៉ូលី អិនឌីអាណា ខាងស្តាំ ពីលើ ៖ ព្រះវិហារបរិសុទ្ធ ទីក្រុងហ្វីជី ប្រទេសស៊ូវ៉ា ព្រះវិហារបរិសុទ្ធ ទីក្រុងម៉ិកស៊ិកូ ប្រទេសម៉ិកស៊ិក ព្រះវិហារបរិសុទ្ធ ទីក្រុងកំដូបា ប្រទេសអាហ្សង់ទីន*

## ភាពរីកចម្រើននៃព្រះវិហារបរិសុទ្ធ

ក្នុងឆ្នាំ ២០១៥ ព្រះវិហារបរិសុទ្ធចំនួនប្រាំត្រូវបានឧទ្ទិសឆ្លង ចំនួនពីរត្រូវបានឧទ្ទិសឆ្លងឡើងវិញ និង ចំនួនបួនទៀតបានបើកការដ្ឋានសាងសង់ ។

**ព្រះវិហារបរិសុទ្ធដែលបានឧទ្ទិសឆ្លងក្នុងឆ្នាំ ២០១៥ ៖** ទីក្រុងកំដូបា ប្រទេសអាហ្សង់ទីន ទីក្រុងភេសិន រដ្ឋយូថាហ៍ ស.រ.អា ទីក្រុងទ្រូជីឡូ ប្រទេសប៉េរូ ទីក្រុងឥណ្ឌាណាប៉ូលី អិនឌីអាណា ស.រ.អា និង ទីក្រុងទីយូណា ប្រទេសម៉ិកស៊ិក ។

**ព្រះវិហារបរិសុទ្ធដែលបានឧទ្ទិសឆ្លងឡើងវិញក្នុងឆ្នាំ ២០១៥ ៖** ទីក្រុងម៉ិកស៊ិកូ ប្រទេសម៉ិកស៊ិក និង ទីក្រុងម៉ុងរ៉េអាល ទីក្រុងហ្គូបិក ប្រទេសកាណាដា ។ ព្រះវិហារបរិសុទ្ធ ទីក្រុងហ្វីជី ប្រទេសស៊ូវ៉ា ត្រូវបានដាក់កាលវិភាគដើម្បីឧទ្ទិសឆ្លងឡើងវិញក្នុងខែ កុម្ភៈ ឆ្នាំ ២០១៦ ។

**ពិធីបើកការដ្ឋានសាងសង់ក្នុងឆ្នាំ ២០១៥ ៖** ទីក្រុងស្ទារ វាលី ទីក្រុងវ៉ាយអូមីង ស.រ.អា ទីក្រុងសេដា រដ្ឋយូថាហ៍ ស.រ.អា ទីក្រុងខុងសេព្សុង ប្រទេសឈីលី និង ទីក្រុងទុកសុន រដ្ឋអារីហ្សូណា ស.រ.អា ។

ព្រះវិហារបរិសុទ្ធទីក្រុងហ្វ្រេងហ្វើត និង ហ្វ្រីប៊ើក ប្រទេសអាល្លឺម៉ង់ត្រូវបានបិទ ដើម្បីជួសជុលកែលម្អបន្ថែមកាលពីឆ្នាំមុន ហើយ ព្រះវិហារបរិសុទ្ធ ទីក្រុងយ័រដាន់ រីវើ រដ្ឋយូថាហ៍ នឹងត្រូវបានបិទដើម្បីកែលម្អបន្ថែមនៅដើមខែ កុម្ភៈ ឆ្នាំ ២០១៦ ។ ព្រះវិហារបរិសុទ្ធ ទីក្រុងប្រូវ៉ូ កណ្តាល នៅទីក្រុងប្រូវ៉ូ រដ្ឋយូថាហ៍ ស.រ.អា នឹងត្រូវបានឧទ្ទិសឆ្លងក្នុងខែ មិនា ឆ្នាំ ២០១៦ ។

សាសនាចក្រមានព្រះវិហារបរិសុទ្ធកំពុងដំណើរការចំនួន ១៤៨ ជុំវិញពិភពលោក ដោយមានចំនួន ១១ កំពុងសាងសង់ និង ១៤ ត្រូវបានប្រកាស ប៉ុន្តែពុំទាន់ចាប់ផ្តើមនៅឡើយ ។ ■

## ការការពារសេរីភាពខាងសាសនា

អ្នកទាំងឡាយណាដែលជឿថា ព្រះប្រទានឲ្យយើងនូវសមត្ថភាពដើម្បីជ្រើសរើសរវាងត្រូវ និង ខុសនោះ ត្រូវតែធ្វើការរួមគ្នាដើម្បីពង្រឹងសេរីភាពក្នុងការការពារ និង ការប្រតិបត្តិសាសនា ដែលអែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍នៅក្នុងសុន្ទរកថាទៅកាន់ក្រុមប្រឹក្សាទំនាក់ទំនងអន្តរជាតិអាហ្សង់ទីន ។

លោកបានមានប្រសាសន៍ថា « ការការពារសេរីភាពខាងសាសនា អាស្រ័យទៅលើការយល់ដឹង និង ការគាំទ្រពីសំណាក់សាធារណជនដល់សេរីភាពដ៏ចាំបាច់នេះ » ។ « វាអាស្រ័យទៅលើតម្លៃដែលសាធារណជនផ្តល់ឲ្យដល់ការបង្រៀនអំពីត្រូវ និង ខុស នៅក្នុងគ្រីស្តសាសនា សាសនាយូដា និង សាសនាអ៊ីស្លាម ។ ទោះជាយ៉ាងណាក៏ដោយ ពួកអ្នកមានជំនឿ និង មិនមានជំនឿទាំងឡាយ ត្រូវតែមានគេជួយឲ្យយល់ថា នេះគឺជាសេចក្តីជំនឿទៅលើព្រះ — ដែលបកស្រាយការបង្រៀនខាងសាសនាទៅជាតវិយោបថខាងក្រមសីលធម៌ ដែលផ្តល់ជាប្រយោជន៍ដល់ប្រទេសជាតិ » ។ ■

*អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទៅកាន់ ក្រុមប្រឹក្សាទំនាក់ទំនងអន្តរជាតិអាហ្សង់ទីន ( CARI ) នៅប្រទេសអាហ្សង់ទីន ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ ។*




រូបថត © ២០១៥ ដោយ INTELLECTUAL RESERVE, INC ។ រក្សាសិទ្ធិគ្រប់យ៉ាង

# ឧស្សាហ៍ចូលរួម

ពួកបរិសុទ្ធថ្ងៃចុងក្រោយ « ឧស្សាហ៍ចូលរួម » ( សូមមើល គ. និង ស. ៥៨:២៧ ) ក្នុងការធ្វើល្អទូទាំងពិភពលោក ។ នេះគឺជាការលើកឡើងខ្លះៗពីឆ្នាំមុន ៖

- នៅប្រទេស ហុងឌូរ៉ាស យុវវ័យពួកបរិសុទ្ធថ្ងៃចុងក្រោយចំនួន ៦០០ នាក់បានធ្វើការជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ និង អ្នកតំណាងគ្រូពេទ្យ និង ទាហាន ដើម្បីសម្អាតតំបន់មានមូសខ្លា ។
- នៅប្រទេសឥណ្ឌា យុវវ័យពួកបរិសុទ្ធថ្ងៃចុងក្រោយបានលាបថ្នាំជញ្ជាំង និង សម្អាតថ្នាក់រៀន នៅវិទ្យាល័យក្មេងស្រីរបស់រដ្ឋាភិបាល នៅទីក្រុងហៃឌើរបាដ ។
- នៅប្រទេសឡាវៀ សមាជិក — បានពាក់អាវកាក់ និង អាវយឺតដៃជំនួយមរមន — សម្អាតតំបន់ក្នុងសហគមន៍មួយ ដោយប្រមូលបានសំរាមចំនួន ៧០ ស្បោង ។
- នៅប្រទេសតុងហ្គា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានជួបជុំគ្នា ហើយបញ្ជូនមើមដំឡូងមី និង ផ្លែចម្ប៉ាដាក់ ទៅទីក្រុង វ៉ាណូអេទូ ដើម្បីជួយដល់ជនរងគ្រោះពីព្យុះស៊ីក្លូន ។
- នៅប្រទេសម៉ាឡេស៊ី សាសនាចក្របានធ្វើការជាមួយភ្នាក់ងាររដ្ឋាភិបាល ដើម្បីផ្ដល់បរិក្ខារចម្អិនម្ហូប និង ទូទឹកកក ទៅដល់ជនរងគ្រោះពីទឹកជំនន់ ហើយបានបង្រៀនស្ត្រីៗអំពីរបៀបចម្អិនដោយប្រើម៉ាស៊ីនវាយ និង ឡអគ្គិសនី ។
- នៅលើកោះសាឡូម៉ូន សមាជិកបានជួយសាងសង់អាងស្តុកទឹក ដើម្បីផ្ដល់ទឹកស្អាតដល់ប្រជាពលរដ្ឋប្រមាណ ២០០០ នាក់ ។
- នៅប្រទេសរុស្ស៊ី ពួកបរិសុទ្ធថ្ងៃចុងក្រោយបានចូលរួមសម្អាតសហគមន៍នាចុងសប្ដាហ៍នៃបុណ្យអ៊ីស្ទើរ ។
- នៅប្រទេសតួគី សមាជិកសាសនាចក្របានចូលរួមក្នុងក្រុមចម្រៀងអន្តរជំនឿ ដែលរួមបញ្ចូលទាំងនិកាយកាតូលិក ប្រូតេស្តង់ និង អ៊ីស្លាម ។ ■





*ពីខាងលើ ៖ ពួកអ្នកស្ម័គ្រចិត្តបម្រើនៅប្រទេសឡាវៀ កោះសាឡូម៉ូន និង ហុងឌូរ៉ាស ។*





*អែលឌើរ នែល អិល អាន់ឌើរសិន ជាមួយនឹងលោកអភិបាលក្រុង នៀរ បារខាត*

# អែលឌើរ អាន់ឌើរសិន នៅទីក្រុង យេរូសាឡិម

អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ កាលកំពុងចូលរួមសន្និសីទពង្សាវតាអន្តរជាតិមួយនៅទីក្រុងយេរូសាឡិម បានជួបជាមួយ នៀរ បារខាត ដែលជាអភិបាលក្រុង ។ ពួកលោកបានពិភាក្សាអំពីពង្សប្រវត្តិ និង កម្មវិធីទាំងឡាយនៃមជ្ឈមណ្ឌលក្រុងយេរូសាឡិមនៃសាកលវិទ្យាល័យព្រិកហាំ យ៉ង់ សម្រាប់ការសិក្សាភូមិភាគខាងកើត ដែលបានដំណើរការនៅទីក្រុងយេរូសាឡិមអស់រយៈពេល ២៧ ឆ្នាំមកហើយ ថែមទាំងពិភាក្សាអំពីកិច្ចការនៃសាសនាចក្រក្នុងការរក្សាពង្សប្រវត្តិផងដែរ ។

សន្និសីទពង្សាវតានោះបានទាក់ទាញភ្ញៀវចូលរួមរាប់រយនាក់ រួមបញ្ចូលទាំងអ្នកជំនាញ និង អ្នកស្រាវជ្រាវខាងពង្សប្រវត្តិមកពីអ៊ីស្រាអែល អាមេរិកខាងជើង អឺរ៉ុប និង តំបន់ដទៃៗទៀតនៅលើពិភពលោក ។ ■



# ហារើដ ដបុលយូ ហ៊ីនធើរ ៖ ឪពុកខ្ញុំជាព្យាការី



**ដោយ រីចាត អេ ហ៊ីនធើរ**
( ត្រូវបានបង្ហាញនៅឆ្វេងដៃ )

ខ្ញុំបានជឿថា បុរស និងស្ត្រី គឺត្រូវបានវាស់វែងតាមអ្វីដែលពួកគេឲ្យតម្លៃ និងតាមអ្វីដែលពួកគេមានឆន្ទៈដើម្បីធ្វើតាមគុណតម្លៃទាំងនោះ ។ មនុស្សអស្ចារ្យ ហាក់ដូចជាធ្វើអ្វីដែលត្រូវបានសុំឲ្យធ្វើដោយខ្ជាប់ខ្ជួនក្នុងជីវិតដោយសារតម្លៃរបស់ពួកគេ ទោះជាត្រូវលះបង់ច្រើនក្ដី ។ ឪពុកខ្ញុំគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សអស្ចារ្យទាំងនេះ ។ ខ្ញុំមានឯកសិទ្ធិរៀននូវរឿងអស្ចារ្យមកពីគាត់អំពីអត្ថន័យពិតនៃភាពអស្ចារ្យ ។ មេរៀនពុំកើតចេញមកពីអ្វីដែលគាត់បានប្រាប់ខ្ញុំទេ ប៉ុន្តែចេញមកពីអ្វីដែលគាត់ធ្វើ និងមកពីខ្លួនគាត់ ។

រឿងដូចខាងក្រោមបង្ហាញនូវអ្វីដែលខ្ញុំធំឡើងជាមួយនឹងឪពុករបស់ខ្ញុំ ៖ ជាមេធាវី ជាតន្ត្រីករ ជាអ្នកមើលថែ ជាព្យាការី — លើសពីនោះ ជាបុរសម្នាក់ដែលមានចិត្តល្អ ហើយមានឆន្ទៈផ្ដល់នូវអ្វីៗដល់ព្រះ និង គ្រួសារគាត់ ។

*ជាញឹកញាប់ មិត្តភក្តិបានសួរសំណួរចំនួនពីរមកកាន់ខ្ញុំ ៖ « តើការធ្វើជាកូនប្រុសរបស់ព្យាការី ហើយធំឡើងជាមួយនឹងបុរសដ៏អស្ចារ្យរូបនេះយ៉ាងម៉េចដែរ ? » ហើយ « តើអ្នកពិតជាគិតថាឪពុករបស់អ្នកជាព្យាការីនៃព្រះមែនទេ ? »*

## ពលិកម្មដើម្បីសេចក្ដីល្អនៃគ្រួសាររបស់គាត់

ពេលខ្ញុំនៅជាយុវវ័យ ខ្ញុំបានស្វែងរកនៅលើឡៅតឿរបស់ខ្ញុំថ្ងៃមួយ ហើយបានជួបនឹងប្រអប់ប្រឡាក់ដីមួយគំនរ ។ ខ្ញុំបានរកឃើញខ្លុយមួយ ស្រឡៃមួយ វីយូឡុងមួយ និង ស្គរមួយ ។ បន្ទាប់ពីសួរប៉ារបស់ខ្ញុំអំពីរបស់របរទាំងនោះ ខ្ញុំបានដឹងថា នេះគឺជាឧបករណ៍មួយចំនួនដែលគាត់ចេះលេង ។ គាត់មានក្រុមភ្លេងមួយពេលគាត់នៅរៀនវិទ្យាល័យនៅ ប៉័យសឺ រដ្ឋ អៃដាហូ ស.រ.អា ។ គាត់គឺជាតន្ត្រីករដ៏ជំនាញមួយរូប ដែលស្រឡាញ់តន្ត្រី និងការនិពន្ធភ្លេងយ៉ាងខ្លាំង ។ ក្រុមភ្លេងរបស់គាត់ បានលេងឲ្យព្រឹត្តិការណ៍សង្គមសំខាន់ៗនៅទីក្រុង ប៉័យសឺ ហើយបានចេញទៅលេងនៅតាមកប៉ាល់កំសាន្តទៅប៉ែកអាស៊ីផងដែរ ។ បន្ទាប់ពីគាត់បានផ្លាស់មកប៉ែកខាងត្បូងរដ្ឋ កាលីហ្វូញ៉ា ស.រ.អា នៅឆ្នាំ ១៩២៨ ក្រុមភ្លេងត្រូវបានគេទទួលស្គាល់ ហើយបានមានភាពល្បីល្បាញយ៉ាងខ្លាំង ។

នៅក្នុងឆ្នាំ ១៩៣១ គាត់បានរៀបការនឹងម្ដាយខ្ញុំ ក្លារ៉ា ជេហ្វស៍ ។ ពួកគាត់ចង់បានកូន ។ គាត់បានមានអារម្មណ៍ថា ចំពោះគាត់តម្រូវការនៃការកំសាន្តនៅក្នុងពិភពលោក គឺពុំសឹសង្វាក់គ្នានឹងគ្រួសារដ៏មានអត្ថន័យដែលគាត់ចង់បាននោះទេ ។ ដូច្នេះនៅថ្ងៃមួយ គាត់បានដាក់ឧបករណ៍ទាំងអស់នេះនៅក្នុងកេសរបស់វា ហើយយកទៅដាក់ទុកនៅឡៅតឿ ។ ក្រៅពីកម្មវិធីគ្រួសារដ៏កម្រកើតឡើង នោះគាត់ពុំដែលលេងឧបករណ៍ទាំងនោះម្ដងទៀតទេ ។






ខ្ញុំពុំបានដឹងថាគាត់បានធ្វើការលះបង់ដូច្នោះទេ រហូតដល់ពេលក្រោយមក ។ នៅឆ្នាំ ១៩៩៣ គាត់បានផ្លាស់ចេញពីផ្ទះនៅទីក្រុងសលត៍ លេករដ្ឋយូថាហ៍ ស.រ.អា របស់គាត់ ទៅនៅផ្ទះតូចមួយក្នុងកណ្ដាលទីក្រុង សលត៍លេក នៅជិតនឹងការិយាល័យរបស់គាត់ ។ អំឡុងពេលនៃការផ្លាស់ផ្ទះនេះ គាត់បានឃើញឧបករណ៍ម្ដងទៀត ។ ខ្ញុំសួរគាត់បើសិនជាគាត់ចង់ឲ្យឧបករណ៍ទាំងនោះទៅដល់សាសនាចក្រ ដោយសារវាមានចំណែកយ៉ាងសំខាន់នៅក្នុងជីវិតវ័យក្មេងរបស់គាត់ ។ គាត់បានឆ្លើយដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ៖ « នៅទេ ។ ប៉ាពុំអាចឃ្លាតពីវាបានទេឥឡូវនេះ » ។

ទោះបីជាប៉ាបានដឹងថា គាត់នឹងពុំលេងឧបករណ៍ទាំងនោះម្ដងទៀតក្ដី ក៏គាត់នៅតែពុំគិតថានឹងលះបង់វាដែរ ។ នៅពេលនោះ ដែលខ្ញុំបានដឹងថា វាគឺជាការលះបង់ដ៏ធំដែលគាត់បានធ្វើ ។

**ការបង្កើនការតាំងចិត្តចំពោះពង្សប្រវត្តិ**

បន្ទាប់ពីឪពុកម្ដាយខ្ញុំរៀបការ ការហៅបម្រើដំបូងរបស់ប៉ាខ្ញុំមួយគឺបង្រៀនថ្នាក់ពង្សប្រវត្តិ ។ អំឡុងពេលនេះ គាត់បានតាំងចិត្តយ៉ាងខ្លាំងចំពោះការធ្វើកិច្ចការពង្សប្រវត្តិផ្ទាល់ខ្លួន ។ កាលវិភាគនៅការិយាល័យច្បាប់របស់គាត់ មាននូវការណាត់ជួបពេលល្ងាចជាច្រើនដើម្បីទៅបណ្ណាល័យសាធារណៈនៅ ឡូសអាន់ជើរឡេស ដើម្បីធ្វើការស្រាវជ្រាវពង្សប្រវត្តិ ។ គាត់បានចាប់ផ្ដើមរៀបចំក្រដាសក្រុមគ្រួសារប្រវែង ប្រាំមួយហ្វីត ( ១.៨ ម. ) ដែលគាត់បានចងក្រងនៅក្នុងបញ្ជីដ៏មាំជាច្រើន ។

ប៉ាក៏បានប្រមូលទិន្នន័យ ហើយទាក់ទងទៅកាន់សាច់ញាតិរបស់យើងផងដែរ ។ គាត់បានផ្ញើសំបុត្ររាប់រយទៅកាន់សាច់ញាតិ នៅពេលគាត់បានរកឃើញថាពួកគេជានរណានោះ ។ អំឡុងពេលវិស្សមកាលគ្រួសាររបស់យើងជាញឹកញាប់យើងទៅសួរសុខទុក្ខបងប្អូនជីដូនមួយ ម្ដាយមីង និងឪពុកមាជាច្រើន ។ ចេញមកពីការណ៍នេះ ខ្ញុំបានរៀនអំពីសេចក្ដីល្អ ដែលអាចត្រូវបានធ្វើ នៅពេលអ្នកលះបង់ថ្ងៃវិស្សមកាលកំសាន្ត ។

**ការបង្ហាញនូវការតាំងចិត្តខ្ពស់នៅក្នុងសាលាច្បាប់**

នៅពេលខ្ញុំកើតមក ឪពុករបស់ខ្ញុំបានអានសៀវភៅអំពីឆន្ទៈ និងភស្ដុតាងនានានៅក្នុងបន្ទប់រង់ចាំនៅមន្ទីរពេទ្យ ។ គាត់បានសម្រេចចិត្តចង់ក្លាយជាសិស្សសាលាច្បាប់ នៅពេលគាត់បានធ្វើការជាមួយនឹងមេធាវីនៅមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់នៅឡូស




រូបថតប្រវត្តិសាស្ត្រ ទទួលបានសិទ្ធិអនុញ្ញាតមកពីគ្រួសារហិនធើរ បណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ និង សារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ រូបថតដោយ © ISTOCK/THINKSTOCK



*« គ្រួសារគឺជាអង្គភាពសំខាន់បំផុតមួយនៅក្នុងជីវិតនេះ និងជីវិតអស់កល្បជានិច្ច ហើយលើសហួសពីចំណាប់អារម្មណ៍ផ្សេងទៀតក្នុងជីវិត » ។*[1]

អាន់ដើរឡេស នៅប៉ែកខាងត្បូងរដ្ឋ កាលីហ្វញ៉ា ។ គាត់តែងតែជាបុរសគិតពីគ្រួសារជាខ្លាំង ដូច្នេះ ប៉ារបស់ខ្ញុំបានមានអារម្មណ៍ថា គាត់អាចផ្គត់ផ្គង់គ្រួសារបានល្អប្រសើរជាង បើគាត់ធ្វើជាមេធាវីខ្លួនឯង ។ ទោះបីជាមានប្រពន្ធ មានកូនពីរនាក់ ហើយនិងមានការងារពេញម៉ោងក្តី ក៏គាត់បានដឹងថា សាលារៀន និងការសិក្សាត្រូវធ្វើឡើងនៅពេលយប់ ។

ក្រោយមក នៅពេលខ្ញុំទៅរៀននៅសាលាច្បាប់ខ្លួនឯង ខ្ញុំបានងឿងឆ្ងល់ថា តើប៉ារបស់ខ្ញុំអាចបែងចែកយ៉ាងដូចម្តេច ។ ខ្ញុំបានសួរគាត់ថា « តើពេលណាប៉ាចូលសំរាន្ត ? » គាត់បានមានប្រសាសន៍ថា គាត់សិក្សាឲ្យច្រើនតាមដែលគាត់អាចធ្វើទៅបាន ហើយនៅពេលគាត់ហត់ខ្លាំងពេក គាត់ពុំអាចសិក្សាតទៅទៀត នោះគាត់នឹងសំរាន្តរយៈពេលបីទៅបួនម៉ោង ។ ការធ្វើដូច្នោះបានបន្តអស់រយៈពេលប្រាំឆ្នាំ ។ ខ្ញុំស្ញើចសរសើរចំពោះការតាំងចិត្តដ៏ខ្ពស់របស់គាត់ ។

**ការចំណាយពេលជាមួយកូនប្រុសៗរបស់គាត់**

ប៉ាមានជីវិតដ៏រវល់មួយ ប៉ុន្តែគាត់នៅតែមានពេលសម្រាប់គ្រួសាររបស់គាត់ ។ នៅពេលខ្ញុំជាកាយឫទ្ធិម្នាក់ ក្រុមរបស់យើងបានរៀបចំចុះទៅទន្លេ រ៉ូហ្គ នៅទីក្រុងអ័រហ្គិន ស.រ.អា ដោយជិះទូកដែលយើងធ្វើដោយខ្លួនឯង ។ ប៉ាបានស្ម័គ្រចិត្តទៅជាមួយពួកយើង ទោះជាគាត់ពុំមែនជាអ្នកចូលចិត្តបោះជំរុំ ដេកនៅលើដីក្តី ។ យើងបានចំណាយពេលជាច្រើនម៉ោងនៅក្នុងបន្ទប់ដាក់រថយន្តធ្វើការជាមួយគ្នាបង្កើតទូកកៃយ៉ាក់របស់យើង ។

មុនពេលយើងបានដាក់ទូកចុះលើទឹក ។ ខ្ញុំបានអង្គុយនៅខាងមុខកាន់កន្សៃទូក ហើយប៉ាជិះនៅខាងក្រោយ ។ នៅពេលយើងជិះតាមទន្លេនោះ មិនយូរប៉ុន្មាន យើងបានឆ្ពោះទៅកន្លែងទឹកធ្លាក់ដ៏គ្រោះថ្នាក់ ។

នៅពេលក្បាលទូករបស់យើង ជ្រមុជចុះក្នុងទឹកនៅត្រង់ទឹកធ្លាក់ នោះទូកក៏ក្រឡាប់ ហើយបោកយើងទាំងពីរនាក់ទៅក្នុងទឹកទន្លេ ។ ខ្ញុំបានងើបឡើងវិញ ហើយរកមើលប៉ា តែពុំឃើញគាត់ទេ ។ ទីបំផុត គាត់បានផុសឡើង ហើយយើងបានបង្វែរទូកឲ្យទៅគោលដៅត្រឹមត្រូវវិញ ហើយឡើងជិះម្តងទៀត ។ មុនពេលយើងអាចជិះទៅដល់ច្រាំងដើម្បីគិតពីអ្វីដែលបានកើតឡើង នោះទឹកទន្លេក៏បានបោកយើងចូលទៅក្នុងទឹកធ្លាក់បន្ទាប់ទៀត ។ យើងពុំមានពេលដើម្បីបង្វែទូកឲ្យត្រូវទិសម្តងទៀតទេ នៅពេលទឹកគួចវាគួចយើងវិលជុំវិញ ហើយយើងបានធ្លាក់ទៅតាមចរន្តទឹកថយក្រោយដ៏ឆ្ងាយមួយ ហើយពុំអាចគ្រប់គ្រងស្ថានការណ៍បានទេ ។

ទីបំផុតយើងបានត្រឡប់ទៅកាន់ជំរឹញនាល្ងាចនោះ ជាមួយនឹងពួកកាយឫទ្ធិដទៃទៀត ។ ប៉ាបានប្រាប់ខ្ញុំពីរឿងរបស់យ៉ូបនូវរឿងលម្អិតខ្លះៗ ។

ចាប់តាំងពីព្រឹត្តិការណ៍ថ្ងៃនោះ និងដំណើររឿងរបស់យ៉ូប យើងបានរៀនថា ជីវិតគឺពុំងាយស្រួលជានិច្ចនោះទេ ។ នៅព្រឹកស្អែកឡើង ជាជាងត្រឡប់ទៅផ្ទះវិញ ប៉ាបានដើរឡើងត្រឡប់ទៅកន្លែងទុកតូចរបស់យើង ហើយបានបន្តការធ្វើដំណើរតាមទន្លេរបស់យើងទៀត ។ បទពិសោធន៍ដែលបានបង្រៀនខ្ញុំពីបុរសដ៏អស្ចារ្យមួយរូបនេះបានធ្វើ នៅពេលគាត់ឲ្យតម្លៃគ្រួសាររបស់គាត់ ។

**ការយកចិត្តទុកដាក់ចំពោះភរិយារបស់គាត់**

នៅឆ្នាំ ១៩៧០ ម្តាយរបស់ខ្ញុំត្រូវធ្វើរោគវិនិច្ឆ័យឃើញថា មានជំងឺរ៉ាំរ៉ៃមួយ ដែលសរសៃឈាមក្រហមឈប់ហូរទៅចិញ្ចឹមខួរក្បាលរបស់គាត់ ។ គាត់គឺជាស្ត្រីដែលវាងវៃ ស្រស់ស្រាយ និងមានកំប្លែងកក្តីថ្លាគួរឲ្យស្រឡាញ់ ។ ប៉ុន្តែអស់រយៈពេល ១៣ ឆ្នាំក្រោយមកនេះ ស្ថានភាពសុខភាពរបស់គាត់ធ្លាក់ចុះ ។ វាហាក់ដូចជាបាត់បង់មិត្តល្អម្នាក់បន្តិចម្តងៗ ។

ប៉ាបានធ្វើជាអ្នកមើលថែគាត់ជាចម្បង ។ នៅទីដំបូងឡើយ ប៉ាបានធ្វើការលះបង់តិចតួចដើម្បីធ្វើឲ្យគាត់បានសុខស្រួល និងរីករាយ ។ ប៉ាបានរៀបចំអាហារ ច្រៀងចម្រៀង និងកាន់ដៃម្តាយខ្ញុំ ។ ទោះជាយ៉ាងណាក៏ដោយ យូរៗទៅការមើលថែម្តាយរបស់ខ្ញុំមានការលំបាកកាន់តែខ្លាំង និងត្រូវថែទាំរាងកាយគាត់កាន់តែខ្លាំងឡើង ។ វាជាការលំបាកសម្រាប់ប៉ាខ្ញុំ ។

នៅពេលស្ថានភាពម្តាយខ្ញុំកាន់តែធ្ងន់ធ្ងរទៅៗ នោះសុខភាពផ្ទាល់ខ្លួនរបស់ឪពុកខ្ញុំក៏ចាប់ផ្តើមមានការបារម្ភផងដែរ ។ ខ្ញុំបាននៅទីនោះ ពេលវេជ្ជបណ្ឌិតរបស់គាត់ប្រាប់គាត់ថា ម្តាយខ្ញុំត្រូវការនូវការមើលថែពេញម៉ោងនៅក្នុងកន្លែងមើលថែដែលមានជំនាញមួយ ។ ប៉ានឹងអាចស្លាប់ជាមិនខាន បើគាត់បន្តមើលថែដល់ម្តាយខ្ញុំដោយខ្លួនឯង តាមកម្រិតជំងឺម្តាយខ្ញុំដែលត្រូវការការថែទាំនោះ រួចហើយម្តាយខ្ញុំនឹងគ្មាននរណាមើលថែគាត់ទៀតទេ ។

ក្នុងរយៈពេល ១៣ ខែចុងក្រោយនៃជីវិតម្តាយរបស់ខ្ញុំ ប៉ាបានទៅជួបនឹងគាត់នៅកន្លែងមើលថែនោះជារៀងរាល់ថ្ងៃ ដើម្បីកុំឲ្យគាត់ឃ្លាតពីកិច្ចការសាសនាចក្រ ។ ម្តាយខ្ញុំពុំស្គាល់ប៉ាទេ ប៉ុន្តែនោះពុំខុសប្លែកអីចំពោះគាត់ទេ ។ គាត់បាននិយាយជាមួយម្តាយខ្ញុំ ហាក់ដូចជាអ្វីៗគ្រប់យ៉ាងល្អអញ្ចឹង ។ ខ្ញុំឃើញគាត់ត្រឡប់មកពីទៅសន្និសីទស្តេកមួយ នៅតំបន់ឆ្ងាយខ្លះៗ ។ គាត់នឿយហត់ ។ ប៉ុន្តែរឿងដំបូងដែលគាត់នឹងធ្វើ នៅពេលគាត់មកដល់ គឺទៅមើលម្តាយរបស់ខ្ញុំ ដើម្បីនាំមកនូវក្តីរីករាយតាមដែលគាត់អាចធ្វើបាន ។

ប៉ារបស់ខ្ញុំ ពុំអាចមើលថែម្តាយរបស់ខ្ញុំប្រសើរជាងនេះទៀតទេ ។ ខ្ញុំរៀនច្រើនពីការលះបង់របស់គាត់ មកពីការមើលគាត់ មើលថែដល់ម្តាយខ្ញុំ ។

*« ខ្ញុំទទួលយកនូវការហៅ . . . ចំពោះខ្ញុំ ដោយគ្មានការបម្រុងទុក ហើយខ្ញុំស្ម័គ្រចិត្តលះបង់ជីវិតរបស់ខ្ញុំ និងអ្វីៗទាំងអស់ដែលខ្ញុំមានចំពោះការបម្រើនេះ » ។២*



### ការលះបង់សម្រាប់ការហៅបម្រើរបស់គាត់

ប៉ាមានអារម្មណ៍ថា ការហៅបម្រើរបស់គាត់ក្នុងនាមជាសាវកម្នាក់ គឺជាអាទិភាពទាំងស្រុងមួយ — ហើយសម្រាប់មូលហេតុល្អ ។ មានតែបុរសមួយក្រុមតូចប៉ុណ្ណោះដែលត្រូវបានហៅឲ្យធ្វើជាសាក្សីពិសេសដើម្បីដឹកនាំកិច្ចការរបស់ព្រះនៅលើផែនដី ហើយពួកគាត់ពុំអាចសុំឈប់សម្រាកមួយថ្ងៃណាមួយក្នុងមួយឆ្នាំៗទេ ។

ការបំពេញនូវកិច្ចចាត់តាំងរបស់គាត់ គឺសំខាន់ចំពោះប៉ារបស់ខ្ញុំ ជាងចំពោះសុខភាពរបស់គាត់ ។ ប៉ាបានទុកឲ្យព្រះអម្ចាស់ដើម្បីធ្វើឲ្យរូបកាយរបស់គាត់បានថ្មី ( សូមមើលគ. និង ស. ៨៤:៣៣ ) ។ មានម្ដងនោះ គាត់បានសុំខ្ញុំឲ្យទៅជាមួយគាត់ទៅកាន់សន្និសីទក្នុងតំបន់មួយ នៅទីក្រុង ប៉ារីស ប្រទេសបារាំង ។ វេជ្ជបណ្ឌិតរបស់គាត់បានគិតថា គាត់គប្បីធ្វើដំណើរទៅជាដំណាក់ៗដោយត្រូវចំណាយពេលបួនប្រាំថ្ងៃទៅ ដោយសាររូបកាយរបស់ប៉ាខ្ញុំនឹងអស់ថាមពលច្រើន ប៉ុន្តែយើងបានធ្វើដំណើរតម្រង់ឆ្ពោះទៅទីក្រុងប៉ារីសផ្ទាល់តែម្ដង ។ ខ្ញុំស្ទើរតែពុំអាចបើកភ្នែករួច តែប៉ារបស់ខ្ញុំបានទៅដឹកនាំការប្រជុំ ធ្វើការសម្ភាស និងលើកស្ទួយដល់អ្នកដទៃទៀតប្រកបដោយថាមពល ។

ឈានចូលទៅដល់ចុងបំផុតនៃជីវិតគាត់ ជាញឹកញាប់គាត់មានការឈឺចាប់ដ៏ខ្លាំង ។ ខ្ញុំមិនដឹងថារូបកាយរបស់មនុស្សអាចស៊ូទ្រាំនឹងការឈឺចាប់ដូច្នេះបានដោយរបៀបណាទេ ។ ខ្ញុំបានសួរថា « ប៉ា តើប៉ាគិតថាយើងពិតជាស្រែកដោយអំណរដើម្បីរបាងកាយដូច្នេះឬ ? » គាត់បានឆ្លើយដោយការជឿជាក់ថា « ពិតហើយ » ។ បន្ទាប់មកគាត់បានបន្ថែមនូវការនិយាយលេងសើចថា « ប៉ាដឹងមិនច្បាស់ថាយើងបានដឹងរឿងទាំងមូលទេ » ។

### ការបង្ហាញនូវសណ្ដានចិត្តល្អ

ប៉ាឲ្យតម្លៃលើការមានសណ្ដានចិត្តល្អ គាត់បានថ្លែងដោយសិទ្ធិអំណាចដ៏មានសីលធម៌នៃមនុស្សល្អ ។ គាត់ត្រូវបានអ្នកជិតខាង គ្រួសារ មិត្តភក្តិ អតិថិជន សហការី និងសមាជិកសាសនាចក្រស្គាល់ និង គោរពរាប់អានថាជាបុរសមានសណ្ដានចិត្តល្អ ។



ពេលខ្ញុំធំឡើង ខ្ញុំពុំចាំពីគ្រាដែលគាត់បានប្រព្រឹត្តនឹងខ្ញុំដោយធ្ងន់ធ្ងរ ឬមិនដោយចិត្តល្អឡើយ ។ ទោះជាពេលដែលខ្ញុំសមនឹងទទួលនូវការឆ្លើយតបខ្លាំងៗក្ដី ក៏គាត់គ្រប់គ្រងស្ថានភាពនិមួយៗដោយការបង្រៀនជាជាងការដាក់ទណ្ឌកម្មដែរ ។ យើងនឹងពិភាក្សាគ្នាអំពីមូលហេតុដែលខ្ញុំបានធ្វើ គឺជាការខុសឆ្គង និងអ្វីដែលខ្ញុំគប្បីធ្វើវិញ ។ ចំពោះខ្ញុំ ការណ៍នោះដំណើរការបានល្អ — ឬយ៉ាងហោចណាស់បានល្អ តាមដែលអាចរំពឹងទុក ។

ឪពុករបស់ខ្ញុំបានបម្រើជាប៊ីស្សពនៅវួដ អែល សឺរីណូ នៅពេលដែលសាសនាចក្រទើបតែចាប់ផ្ដើមមាននៅ ឡូស អាន់ជេឡែស រដ្ឋកាលីហ្វូញ៉ា ។ សមាជិកវួដនៅតែនិយាយអំពីសណ្ដានចិត្តល្អរបស់គាត់ចំពោះពួកគេ និងក្រុមគ្រួសាររបស់ពួកគេ ។ នៅថ្ងៃអាទិត្យមួយ ប៉ាពុំនៅក្នុងការប្រជុំបព្វជិតភាពទេ ។ មនុស្សគ្រប់គ្នាងឿងឆ្ងល់ថាតើមានរឿងអ្វីកើតឡើងចំពោះគាត់ ។ ក្រោយមកពួកគេបានដឹងថា សង្ឃម្នាក់មានបញ្ហា

ខាងលើខាងឆ្វេង ៖ ថតរូបដោយ ជូឌី ស្ទូត រូបថតផ្ដល់ឲ្យដោយ *DESERET NEWS*

ក្នុងការក្រោកពីគេងទាន់ម៉ោងដើម្បីទៅកាន់ការប្រជុំ ។ ដូច្នេះដោយសណ្ដានចិត្តល្អ គាត់បានធ្វើការប្រជុំកូរ៉ុមនៅក្នុងបន្ទប់គេងរបស់សង្ឃនោះ ។

មិត្តនៅវិទ្យាល័យរបស់ខ្ញុំម្នាក់ គឺជាមនុស្សអស្ចារ្យដែលមានសក្ដានុពលដ៏មហិមា ប៉ុន្តែនាងបារម្ភអំពីការត្រឡប់ទៅមហាវិទ្យាល័យ បន្ទាប់ពីឆ្នាំសិក្សាដំបូងរបស់នាង ដោយសារតែចំណាយលើថ្លៃសាលា ។ ប៉ាបានដឹងអំពីកង្វល់របស់នាង ហើយបានអញ្ជើញនាងឲ្យមកការិយាល័យរបស់គាត់ ។ នៅចុងបញ្ចប់នៃការជួបនេះ គាត់បានឲ្យមូលប្បទានបត្រមួយដល់នាងដែលគាត់បានត្រៀមជាស្រេច ដើម្បីជួយនាងត្រឡប់ទៅសាលារៀនវិញ ។

ខ្ញុំមានមិត្តនៅវិទ្យាល័យម្នាក់ទៀត ក្នុងស្តេក ប៉ាសាដេណា ខណៈដែលប៉ាខ្ញុំជាប្រធានស្តេក ។ នាងបានទៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ។ ក្នុងពេលការធ្វើដំណើរមួយដែលតំណាងឲ្យសាលា នាងបានជួបនឹងគ្រោះថ្នាក់ចរាចរណ៍រថយន្តដ៏អាក្រក់មួយ ហើយត្រូវស្នាក់នៅមន្ទីរពេទ្យមួយ នៅទីក្រុងឡាស វ៉េហ្គាស រដ្ឋ ណេវ៉ាដា ស.រ.អា ។ ពេលប៉ាបានដឹងអំពីស្ថានភាពរបស់នាង នោះគាត់បានបើកឡានចម្ងាយ ២៧០ ម៉ែល ( ៤៣៥ គ.ម ) ពីទីក្រុងឡូស អាន់ជើរឡេស ទៅទីក្រុងឡាស វ៉េហ្គាស ដើម្បីមើលនាង ហើយនាំក្តីស្រឡាញ់ និងការលើកទឹកចិត្តទៅដល់នាង ។

ខ្ញុំមិនដឹងថា ទង្វើសណ្ដានចិត្តល្អច្រើនប៉ុណ្ណាទៀត ដែលប៉ាខ្ញុំបានធ្វើដូចនេះទេ ។ គាត់ពុំដែលនិយាយអំពីរឿងនោះមកប្រាប់យើង ឬប្រាប់នរណាម្នាក់ទេ ។ មនុស្សចិត្តល្អ ជាធម្មតាពុំប្រាប់គេទេ ។

ខ្ញុំបានដឹងអំពីទង្វើសណ្ដានចិត្តល្អមួយចំនួនទាំងនេះតាមរយៈសំបុត្រដែលគាត់បានរក្សាទុកដែលគាត់ទទួលមកពីមនុស្សដែលបានសរសេរមកអរគុណដល់គាត់ ។ សំបុត្រនេះ គឺជាប្រភេទសំបុត្រដែលគាត់បានទទួល ៖ « ដោយក្តីអស់សង្ឃឹម ខ្ញុំបានសរសេរសំបុត្រអំពីកូនស្រីច្បងរបស់យើង ។ . . . លោកបានចំណាយពេល និងយកចិត្តទុកដាក់ទូរសព្ទទៅនាងដើម្បីសួរសុខទុក្ខដោយទន់ភ្លន់ ហើយឲ្យលេខទូរសព្ទផ្ទាល់ខ្លួនរបស់លោកទៅដល់នាង ។ នាងមានការភ្ញាក់ផ្អើល និងអស្ចារ្យក្នុងចិត្តដែលលោកបានឃើញថានាងមានតម្លៃ ។ ការទូរសព្ទ និងការទៅជួបដោយផ្ទាល់នោះ គឺជាការប្រព្រឹត្តដ៏សប្បុរសនៅក្នុងជីវិតរបស់នាង ។ សំបុត្រនោះក្រោយមកបានប្រាប់អំពីការត្រឡប់មកសាសនាចក្រវិញរបស់នាង និងការផ្សាភ្ជាប់របស់នាងនៅក្នុងព្រះវិហារបរិសុទ្ធ និងជីវិតរីករាយ និងផលដ៏បរិបូរណ៍ ។ « បន្ទាប់ពីអានសេចក្តីថ្លែងការណ៍របស់លោក [ អំពីសណ្ដានចិត្តល្អនៅក្នុងសន្និសីទទូទៅខែតុលា ឆ្នាំ ១៩៩៤ ] វាបានធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក ដែលដឹងថា លោកបានអនុវត្តវាអស់ជាច្រើនឆ្នាំនូវអ្វីដែលអ្នកកំពុងលើកទឹកចិត្តដល់យើងទាំងអស់គ្នាឲ្យធ្វើឥឡូវនេះ » ។

## ឪពុករបស់ខ្ញុំ គឺជាព្យាការីមួយរូបនៃព្រះ

ប៉ាជឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ គាត់បានធ្វើឲ្យវាមានភាពងាយស្រួលសម្រាប់ខ្ញុំក្នុងការជឿទៅលើព្រះគ្រីស្ទផងដែរ ។ ខ្ញុំបានឃើញនូវអ្វីដែលមនុស្សម្នាក់បានធ្វើ ដែលជឿលើព្រះគ្រីស្ទ ហើយឲ្យដូចជាទ្រង់នោះ ។ ខ្ញុំមានអារម្មណ៍សុខសាន្ត ក្តីសង្ឃឹម និង អំណរដែលលេចចេញមកពីការរស់នៅប្រភេទនោះ ។

ឥឡូវ សម្រាប់សំណួរចុងក្រោយ ៖ « តើអ្នកគិតថា ឪពុករបស់អ្នកគឺពិតជាព្យាការីរបស់ព្រះឬទេ ? » សំណួរនេះ តែងតែងាយស្រួលសម្រាប់ខ្ញុំដើម្បីឆ្លើយ ។ ខ្ញុំពុំធ្លាប់ចាំថាមានគ្រាមួយក្នុងរឿងផ្ទាល់ខ្លួន គ្រួសារ អាជីព ឬជីវិតសាសនាចក្ររបស់ឪពុកខ្ញុំ ដែលនាំឲ្យខ្ញុំគិតថា គាត់ពុំសក្តិសមនោះទេ ។ ប៉ុន្តែរឿងនោះគឺខុសប្លែកពីការជឿថា គាត់គឺពិតជាត្រូវបានហៅឲ្យធ្វើជាអ្នកតំណាងរបស់ព្រះចំពោះកូនចៅទាំងអស់របស់ទ្រង់នៅលើផែនដី ។ ខ្ញុំបានដឹងថា គាត់គឺជាព្យាការីមួយរូបនៃព្រះ ប៉ុន្តែចំណេះដឹងនោះពុំកើតមានមកពីការស្គាល់គាត់ការមើលគំរូគាត់ ឬការត្រូវបានប៉ះដល់ដួងចិត្តចំពោះអ្វីដែលខ្ញុំបានឃើញគាត់ធ្វើ ឬនិយាយនោះទេ ។ រឿងទាំងនោះអាចជាជំនួយ ។ ប៉ុន្តែចំណេះដឹងនោះ ត្រូវបានផ្តល់មកឲ្យខ្ញុំ ជាអំណោយទានដ៏ប្រកបដោយព្រះគុណ មកពីព្រះដូចគ្នាដែលបានហៅគាត់ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*



*« ខ្ញុំនឹងអញ្ជើញសមាជិកទាំងអស់នៃសាសនាចក្រឲ្យរស់នៅកាន់តែយកចិត្តទុកដាក់ចំពោះជីវិត និងគំរូរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ជាពិសេសក្តីស្រឡាញ់ និងក្តីសង្ឃឹម និងក្តីមេត្តាករុណាដែលទ្រង់បានបង្ហាញ ។ ខ្ញុំអធិស្ឋានសុំឲ្យយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយសណ្ដានចិត្តល្អកាន់តែច្រើនឡើង » ។*[៣]

កំណត់ចំណាំ
1. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ហាវើដ ដបុលយូ ហឹនធើរ* ( ឆ្នាំ ២០១៥ ) ទំព័រ ២២១ ។
2. *ការបង្រៀន ៖ ហាវើដ ដបុលយូ ហឹនធើរ* ទំព័រ ២៤៣ ។
3. *ការបង្រៀន ៖ ហាវើដ ដបុលយូ ហឹនធើរ* ទំព័រ ១ ។



**ដោយអែលឌើរ**
**ខេវីន អេស ហាមីលថុន**
នៃពួកចិតសិបនាក់

# អំណាចការផ្លាស់ប្រែចិត្តជឿ
## នៃព្រះគម្ពីរមរមន

*សេចក្ដីពិតទាំងអស់នៃដំណឹងល្អនឹងជាការណ៍ត្រឹមត្រូវ នៅពេលយើងបានដឹងថា មូលដ្ឋាននៃទីបន្ទាល់របស់យើង — ដែលជាព្រះគម្ពីរមរមននោះ — គឺពិត ។*

កាលនៅក្មេង ខ្ញុំចូលចិត្តដាក់តម្រៀបដូមីណូជាជួរវែងដោយរៀបចំយ៉ាងប៉ិនប្រសប់ រួចហើយរុញបន្ទះដូមីណូដំបូងគេឲ្យរលំ ។ ប្រតិកម្មមកពីការបន្ទាក់គ្នានោះ នឹងបណ្ដាលឲ្យដូមីណូដែលតៗគ្នានិមួយៗរលំលើគ្នាតពីមួយទៅមួយរហូតដល់ចុងគេ ។ ខ្ញុំនឹងចំណាយពេលរៀបចំដូមីណូដោយយកចិត្តទុកដាក់តាមកន្លែងដើម្បីរីករាយមើលឃើញវារលំចុះ ។

ទីបន្ទាល់អំពីព្រះគម្ពីរមរមន គឺជាជំហានមួយដំបូងគេ ក្នុងការទទួលទីបន្ទាល់នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដរាបណាដូមីណូទីមួយធ្វើឲ្យដូមីណូដទៃទៀតរលំតៗគ្នាពីដំបូងមក បើយើងបានស្គាល់ថា ព្រះគម្ពីរមរមនពិត នោះយើងក៏អាចដឹងថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះរបស់យើងដែរ ក៏ដឹងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ទ្រង់ ដែលបាននាំឲ្យមានការស្ដារឡើងវិញ ហើយក៏ដឹងថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានស្ដារឡើងវិញដោយព្រះចេស្ដា និងសិទ្ធិអំណាចនៅលើផែនដីសព្វថ្ងៃនេះ ។

### ព្រះគម្ពីរមរមនគឺជាចំនុចសំខាន់នៃសារលិខិតរបស់យើង

ស្ដីអំពីព្រះគម្ពីរមរមន ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា « ខ្ញុំបានប្រាប់បងប្អូនទាំងឡាយថា ព្រះគម្ពីរមរមន គឺជាគម្ពីរដ៏ត្រឹមត្រូវបំផុតជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនាចក្ររបស់យើង ហើយបុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារការធ្វើតាមសិក្ខាបទទាំងឡាយនៃគម្ពីរដទៃទាំងអស់ » ។[១]



យ៉ូសែប បានបង្រៀនបន្ថែមទៀតថា វាសំខាន់ចំពោះសេចក្ដីជំនឿ ជំនឿ និងទីបន្ទាល់របស់យើង ។ លោកបានមានប្រសាសន៍សួរថា « បើដកព្រះគម្ពីរមរមន និងវិវរណៈចេញ តើសាសនារបស់យើងនៅកន្លែងណា ? » « យើងគឺគ្មានអ្វីទាល់តែសោះ » ។[២]

ភាពស្រស់ស្អាតនៃសារលិខិតដំណឹងល្អ គឺថាយើងម្នាក់ៗ អាចដឹងដោយខ្លួនយើងថា ព្រះគម្ពីរមរមន គឺពិត ។

ក្នុងនាមជាប្រធានបេសកកម្មនៅប្រទេសបារាំង បែលហ្ស៊ិក និង ហូឡង់ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំមានឯកសិទ្ធិ និងពរជ័យដើម្បីសម្ភាសបុគ្គលម្នាក់ៗអំពីភាពសក្តិសមដើម្បីទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំនឹងពុំភ្លេចនូវការសម្ភាសមួយដែលខ្ញុំមានជាមួយនឹងបងស្រីម្នាក់បានឡើយ ។

អំឡុងការសម្ភាសរបស់យើង ខ្ញុំបានសួរគាត់ថាតើគាត់បានដឹងថាសាសនាចក្រពិតដោយរបៀបណា ។ គាត់បានលូកដៃចូលកាបូបដៃរបស់គាត់ ហើយបានដកយកព្រះគម្ពីរមរមនចាស់មួយក្បាលចេញមក ។ គាត់បានបើកគម្ពីរទៅនីហ្វៃទី ៣ ២៧ហើយបានពន្យល់ថា នេះគឺជាជំពូកទីមួយដែលអ្នកផ្សព្វផ្សាយសាសនាបានអញ្ជើញឲ្យគាត់អាន ។ គាត់បានប្រាប់ថា នៅពេលគាត់បានចាប់ផ្ដើមអាន គាត់បានទទួលនូវអារម្មណ៍បំផុសដ៏អស្ចារ្យមកពីអ្វីដែលគាត់បានអាន ហើយគាត់បានដឹងនូវព្រះវិញ្ញាណក្នុងអារម្មណ៍ ។ គាត់បានពោរពេញដោយព្រះវិញ្ញាណអំពីព្រះគម្ពីរមរមន ដែលគាត់បានដកយកខ្មៅដៃក្រហមចេញ មក ហើយបានចាប់ផ្ដើមគូសបន្ទាត់ពីក្រោមពាក្យដែលធ្វើឲ្យគាត់ចាប់អារម្មណ៍បំផុត ។

បន្ទាប់មក គាត់បានបង្ហាញព្រះគម្ពីរមរមនមកដល់ខ្ញុំ បើកទៅនីហ្វៃទី ៣ ២៧។ ស្ទើរតែគ្រប់ពាក្យក្នុងជំពូកនោះ ត្រូវបានគូសបន្ទាត់ពណ៌ក្រហមពីក្រោម ។

គាត់បាននិយាយថា « នោះជាហេតុផល ដែលខ្ញុំជឿ » ។ « គម្ពីរនេះនិយាយមកកាន់ខ្ញុំតាមរបៀបមួយដែលពុំអាចបដិសេធបានឡើយ ។ ខ្ញុំដឹងថាវាជាការពិត ហើយខ្ញុំដឹងថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយពិត » ។

គាត់បានទទួលបុណ្យជ្រមុជទឹក ហើយបានក្លាយជាសមាជិកស្មោះត្រង់ក្នុងសាសនាចក្រ ។

## បុព្វកថានៃព្រះគម្ពីរមរមន

បុព្វកថានៃព្រះគម្ពីរមរមន ផ្ដល់ដល់យើងនូវគំរូមួយ ដែលយើងអាចដឹងដោយខ្លួនយើងថា សារលិខិតដំណឹងល្អគឺពិត ។ បុព្វកថា « គឺត្រូវបានបោះពុម្ពដំបូងនៅក្នុងការកែសម្រួលនៃព្រះគម្ពីរមរមន ឆ្នាំ ១៩៨១ ។ វាណែនាំព្រះគម្ពីរមរមនទៅកាន់អ្នកអានសម័យទំនើបដោយការផ្ដល់នូវជីវប្រវត្តិព័ត៌មាន និងការពិពណ៌នាអំពីគម្ពីរ » ។[៣]

បុព្វកថា ចាប់ផ្ដើមដោយប្រាប់យើងយ៉ាងលម្អិតថា ព្រះគម្ពីរមរមន គឺជា ៖ « ភាគនៃគម្ពីរពិសិដ្ឋមួយប្រៀបបានទៅនឹងព្រះគម្ពីរប៊ីប ។ ព្រះគម្ពីរនេះ គឺជាបញ្ជី

*នៅពេលយើងទទួលបានសាក្សីដ៏ទេវភាពមកពីព្រះវិញ្ញាណបរិសុទ្ធថា ព្រះគម្ពីរមរមនពិត នោះយើងអាចដឹងដោយខ្លួនយើងច្បាស់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក ។*

ប្រវត្តិអំពីការទំនាក់ទំនងនៃព្រះចំពោះប្រជាជនជំនាន់ដើមនៃទ្វីបអាមេរិក ហើយវាមាននូវភាពពោរពេញនៃដំណឹងល្អដ៏អស់កល្បជានិច្ច » ។ យើងដឹងថា វា « ត្រូវបានសរសេរដោយពួកព្យាការីបុរាណជាច្រើន ដោយវិញ្ញាណនៃការព្យាករ និងវិវរណៈ » នៅលើផ្ទាំងមាសទាំងឡាយ ហើយសង្ខេបដោយ « ព្យាការី-ប្រវត្តិសាស្ត្រម្នាក់មាននាមថា មរមន » ។

យើងក៏បានដឹងផងដែរថា « ព្រឹត្តិការណ៍ដ៏សំខាន់បំផុត ដែលមានកត់ត្រាទុកក្នុងព្រះគម្ពីរមរមន គឺជាការងារបម្រើនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទផ្ទាល់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ។ ព្រះគម្ពីរនេះនាំមកនូវគោលលទ្ធិទាំងឡាយនៃដំណឹងល្អ ផ្ដល់នូវចំណុចសំខាន់អំពីផែនការនៃសេចក្ដីសង្គ្រោះ ហើយប្រាប់ដល់មនុស្សទាំងឡាយអំពីអ្វីដែលគេត្រូវធ្វើដើម្បីឲ្យបានទទួលសេចក្ដីសុខសាន្តនៅក្នុងជីវិតនេះ និងសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ចនៅក្នុងជីវិតខាងមុខ » ។

រឿងដ៏សំខាន់បំផុតមួយដែលយើងអាចរៀនមកពីព្រះគម្ពីរមរមន គឺថា សាសនាចក្រដែលត្រូវបានស្ដារឡើងវិញដោយព្រះយេស៊ូវគ្រីស្ទ តាមរយៈ យ៉ូសែប ស្ម៊ីធ គឺជាសាសនាចក្រដ៏ពិត ។

បុព្វកថា អញ្ជើញយើង «ឲ្យអានព្រះគម្ពីរមរមនដើម្បីពិចារណានៅក្នុងដួងចិត្ត [ របស់យើង ] អំពីសារលិខិតដែលមាននៅក្នុងនោះ រួចហើយទូលសួរដល់ព្រះ ជាព្រះវរបិតាសួគ៌ នៅក្នុងព្រះនាមនៃព្រះគ្រីស្ទ បើគម្ពីរនេះពិត » ។ យើងត្រូវបានសន្យាថា « អស់អ្នកណាដែលធ្វើតាមបែបនេះ ហើយសូមសួរដោយសេចក្ដីជំនឿ នោះនឹងបានទទួលសេចក្ដីបន្ទាល់អំពីសេចក្ដីពិត និងទេវភាពរបស់គម្ពីរនេះ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ ( សូមមើល ម៉ូរ៉ូណៃ ១០:៣–៥ ) » ។



*រឿងដ៏សំខាន់បំផុតមួយដែលយើងអាចរៀនមកពីព្រះគម្ពីរមរមន គឺថា សាសនាចក្រដែលត្រូវបានស្ដារឡើងវិញដោយព្រះយេស៊ូវគ្រីស្ទ តាមរយៈ យ៉ូសែប ស្ម៊ីធ គឺពិត ។*

ការសន្យាបន្ថែមទៀតនេះមានដូចខាងក្រោម ៖ « អស់អ្នកណាដែលបានទទួលទីបន្ទាល់ដ៏ប្រសើរពីព្រះវិញ្ញាណបរិសុទ្ធ ក៏នឹងបានដឹងដោយសារព្រះចេស្ដាដដែលថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោកថា យ៉ូសែប ស្ម៊ីធ គឺជាអ្នកទទួលវិវរណៈ និងជាព្យាការីរបស់ទ្រង់ នៅជាន់ចុងក្រោយបង្អស់ ហើយថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជានគរនៃព្រះអម្ចាស់ ដែលបានសាងឡើងវិញម្ដងទៀតនៅលើផែនដី ដើម្បីរៀបចំសម្រាប់ការយាងមកជាលើកទីពីរនៃព្រះមែស៊ី » ។

សូមគិតពីការណ៍នេះ ! យើងអាចដឹងដោយខ្លួនយើងដោយពិត ៖

- ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ព្រះអង្គសង្គ្រោះនៃពិភពលោក និងជាព្រះប្រោសលោះនៃមនុស្សលោកទាំងអស់ ។
- យ៉ូសែប ស្ម៊ីធ គឺជាព្យាការីពិត ។ លោកប្រាប់អំពីសេចក្ដីពិត ។ លោកបានឃើញនូវអ្វីៗដែលលោកបានប្រាប់ថា លោកបានឃើញ និងស្ដាប់ឮនូវពាក្យទាំងឡាយ ដែលលោកបាននិយាយថាលោកបានស្ដាប់ឮ ។
- « ព្រះអម្ចាស់បានប្រកាសថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជា ‹ សាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីទាំងមូល › ( គ. និង ស. ១:៣០ ) ។ វាគឺជាសាសនាចក្រនៃព្រះគ្រីស្ទ ។ វាមានសេចក្ដីពិត អំណាច សិទ្ធិអំណាច និងពិធីបរិសុទ្ធទាំងឡាយ ។ វាត្រូវបានដឹកនាំដោយព្រះអម្ចាស់ទ្រង់ផ្ទាល់ និងព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ តាមរយៈពួកព្យាការីនៅរស់ទាំងឡាយ ។

អ្វីៗទាំងអស់នេះ យើងអាចដឹង នៅពេលយើងដឹងថា ព្រះគម្ពីរមរមនគឺពិត ។ វាមាននូវអំណាចនៃការផ្លាស់ប្រែចិត្តជឿ និងការបញ្ចុះបញ្ចូល ។

**ទីបន្ទាល់របស់ខ្ញុំអំពីព្រះគម្ពីរមរមន**

ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងបម្រើនៅក្នុងប្រទេសបារាំង ខ្ញុំចង់ដឹងដោយខ្លួនឯងថា ព្រះគម្ពីរមរមនពិតឬអត់ ។ ខ្ញុំបានជឿថា វាពិត ។ ខ្ញុំបានសង្ឃឹមថា វាពិត ។ ខ្ញុំបានចេញទៅបេសកកម្មដោយសេចក្ដីជំនឿថា វាពិត ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលខ្ញុំធ្វើការពីមួយថ្ងៃទៅមួយថ្ងៃក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ហើយបានប្រាប់គេឯងអស់ពីសមត្ថភាពរបស់ខ្ញុំ ដោយភាសាបារាំងទាំងលំបាកថា ខ្ញុំមានទីបន្ទាល់អំពីព្រះគម្ពីរ ក៏ខ្ញុំនៅតែមិន*ដឹង* ច្បាស់ដោយខ្លួនខ្ញុំដែរ ។

ផ្ទះតូចរបស់យើងស្ថិតនៅភាគខាងត្បូងប្រទេសបារាំង ត្រជាក់ ហើយសើមនៅក្នុងរដូវត្រជាក់ដំបូងនោះ ។ នៅរាល់ព្រឹកនិងរាល់ល្ងាច ពីមុន និងក្រោយពីកិច្ចការនៅថ្ងៃនោះ ខ្ញុំតែងតែគ្រលំក្នុងភួយ ហើយឃ្លុំអាវរងារដើម្បីអាន និងសិក្សាព្រះគម្ពីរមរមនរបស់ខ្ញុំ ។ ខ្ញុំដឹងអំពីការសន្យារបស់ម៉ូរ៉ូណៃ ថាបើខ្ញុំអាន ពិចារណា និងអធិស្ឋាន ខ្ញុំក៏អាចដឹងផងដែរ ។ ដ្បិតនៅថ្ងៃ និងសប្ដាហ៍ដែលខ្ញុំអាន គ្មានអ្វីកើតឡើងទេ ។ គ្មានឃើញពន្លឺ គ្មានទេវតា

គំនូរ យ៉ូសែប ស្ម៊ីធ ដោយអែរ៉ាត បើដ ទទួលបានសិទ្ធិអនុញ្ញាតមកពីសារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ ខាងស្ដាំ ៖ រចនាលម្អដោយ ប៊ិន ស៊ូវីតស៍



គ្មានសំឡេងអ្វីទាំងអស់ — ក្រៅពីអារម្មណ៍នៃភាពសុខសាន្ត ពេលខ្ញុំអានឡើយ ។

ខ្ញុំបានបន្តអាន និងគូសបន្ទាត់ពីក្រោមវគ្គគម្ពីរ ដែលមានអត្ថន័យ ហើយអធិស្ឋានដើម្បីដឹងថា ព្រះគម្ពីរមរមនគឺពិត ។ អព្ភូតហេតុបានកើតមានឡើងនៅទីបំផុត ។ ដូចជាអែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពិពណ៌នាថា វាគឺដូចជាព្រះអាទិត្យរះឡើងសន្សឹមៗ ជាជាងដូចជាការបើកភ្លើងឆេះឆ្លោឡើង ។[៤] ពន្លឺបានចាប់ផ្ដើមបំភ្លឺគំនិត និងដល់ដួងចិត្តរបស់ខ្ញុំ ។ ខ្ញុំបានចាប់ផ្ដើមមើលឃើញព្រះគម្ពីរមរមនតាមរបៀបផ្សេងមួយ ។ វគ្គគម្ពីរដែលខ្ញុំបានអានពីមុន បានចាប់ផ្ដើមមានន័យអ្វីមួយថ្មី ។ វិធីល្អបំផុតដែលខ្ញុំអាចពិពណ៌នាអំពីបទពិសោធន៍ គឺថា គំនិតរបស់ខ្ញុំត្រូវបានចាប់ផ្ដើមបំភ្លឺ ។

អស់រយៈពេលជាច្រើនសប្ដាហ៍ និងច្រើនខែក្រោយមក ខ្ញុំអាចនិយាយថា ខ្ញុំបានដឹងច្រើនជាងអ្វីៗដែលខ្ញុំធ្លាប់ដឹងពីមុនថា ព្រះគម្ពីរមរមនគឺជាព្រះបន្ទូលរបស់ព្រះ ។ ខ្ញុំបានដឹងថា វាត្រូវបានសរសេរឡើង និងរក្សាទុកសម្រាប់ជំនាន់របស់យើង ហើយត្រូវបាននាំចេញមកជាសាក្សីដ៏មានអានុភាពនៃព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់ ។ ចំណាប់អារម្មណ៍ដែលបានផុសចេញមកដល់ខ្ញុំម្ដងហើយម្ដងទៀត តាមរយៈសំឡេងនៃព្រះវិញ្ញាណគឺថា « វាពិត វាពិត វាពិតគ្រប់យ៉ាង » ។

អស់រយៈពេលសែសិបឆ្នាំក្រោយមក សាក្សីដដែលនោះបានបន្តមាននឹងខ្ញុំ ។ ឥឡូវខ្ញុំបានអានព្រះគម្ពីរមរមនជាច្រើនដង ហើយរាល់ពេល — រាល់លើក — ខ្ញុំបានស្ដាប់ឮពាក្យថា « វាពិត » ម្ដងទៀត ។ ការណ៍នេះត្រូវបានផ្ដល់ឲ្យខ្ញុំនូវការបញ្ជាក់អះអាងថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ ហើយថានេះគឺជាកិច្ចការនៃសេចក្ដីសង្គ្រោះដ៏អស្ចារ្យរបស់ទ្រង់ ។

ក៏ដូចជាដូមីណូ ដែលខ្ញុំចូលចិត្តលេងកាលពីនៅក្មេងដែលវារលំចុះទាំងអស់ នៅពេលខ្ញុំរុញដូមីណូទីមួយឲ្យរលំដែរ នោះវាក៏ដូចគ្នានឹងសេចក្ដីពិតទាំងអស់នៃដំណឹងល្អ ដែលវាត្រឹមត្រូវនៅពេលយើងបានដឹងថា មូលដ្ឋាននៃទីបន្ទាល់របស់យើង — ដែលជាព្រះគម្ពីរមរមននោះ — គឺជាការពិត ។ ■

កំណត់ចំណាំ

១. យ៉ូសែប ស្ម៊ីធ នៅក្នុងបុព្វកថាព្រះគម្ពីរមរមន សូមមើលផងដែរ *History of the Church* ៤:៤៦១ ។
២. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប អេហ្វ ស្ម៊ីធ* ( ឆ្នាំ ២០០៧ ) ទំព័រ ១៩៦ ។
៣. *Book of Mormon Teacher Resource Manual* ( ឆ្នាំ ២០០៤ ) ទំព័រ ១៩ ។
៤. សូមមើល ដេវីឌ អេ បែដណា « The Spirit of Revelation » *Liahona,* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៨៧–៩០ ។



**ផ្នែកសំខាន់នៃការស្ដារឡើងវិញ**

« ព្រះគម្ពីរមរមនគឺជាផ្នែកសំខាន់នៃការស្ដារឡើងវិញ ។ វាត្រូវបានសរសេរ រក្សាទុក ហើយបានប្រគល់ឲ្យនៅក្រោមការដឹកនាំរបស់ព្រះអម្ចាស់ ។ វាត្រូវបានបកប្រែដោយ ‹ អំណោយទាន និងព្រះចេស្ដារបស់ព្រះ › » ។

**ប្រធាន រ័សុល អិម ណិលសុន ប្រធាន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Catch the Wave »** ***Liahona,*** **ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៤៧ ។**

# ចូរមកតាមខ្ញុំ ៖ ការបង្រៀនគោលការណ៍មូលដ្ឋានចាំបាច់នៅក្នុងគេហដ្ឋាន

កម្មវិធីយុវវ័យថ្ងៃអាទិត្យ — *ចូរមកតាមខ្ញុំ* — បង្រៀនគោលលទ្ធិនៃដំណឹងល្អជាមូលដ្ឋានមួយជារៀងរាល់ខែ ។ នេះគឺជារបៀបមួយចំនួនដើម្បីរៀននូវគោលការណ៍ខាងគោលលទ្ធិទាំងនោះជាមួយគ្រួសារអ្នក ។

**ដោយ អាលីសា ស្តានថុន និង ណាថាលី ខេមបែល**

ពេលអង្គុយក្នុងរាត្រីជួបជុំក្រុមគ្រួសារ ម្តាយម្នាក់បានចាប់ផ្តើមដោយការសួរដល់កូនៗគាត់ថា « តើពេលណាខ្លះ ដែលកូនៗបានទទួលអារម្មណ៍ដឹកនាំដោយព្រះវិញ្ញាណ ? »

កូនស្រីអាយុ ១៧ ឆ្នាំរបស់គាត់បានរអ៊ូរទាំថា « ខ្ញុំបានរៀនមេរៀនដែលស្តីអំពីព្រះវិញ្ញាណចំនួនបីទៅហើយនៅខែនេះ » ។

ឪពុកបានតបនឹងនាងថា « ល្អ នោះកូននឹងអាចរួមចំណែកបានច្រើន » ។ នោះក៏មានភាពស្ងាត់ស្ងៀម នៅពេលម្តាយ និងឪពុករង់ចាំដោយអត់ធ្មត់ ខណៈដែលកូនៗរបស់ពួកគាត់កំពុងគិតអំពីសំណួរ ។

ទីបំផុត កូនប្រុសអាយុ ១៤ ឆ្នាំ របស់ពួកគាត់ បានចែកចាយបទពិសោធន៍មួយនៅសាលានាថ្ងៃនោះ ។



ម្តាយបានតបថា « មែនហើយ រឿងនោះបានរំឭកម៉ាក់អំពីនីហ្វៃ ដែលធ្វើតាមព្រះវិញ្ញាណនៅពេលគាត់ពុំដឹងថាត្រូវទៅយកផ្ទាំងពីឡាបាន់ដោយរបៀបណានោះ » ។

កូនស្រីរបស់គាត់ក៏បាននិយាយដោយចែកចាយពីរបៀបដែលនាងបានធ្វើតាមការបំផុសគំនិតឲ្យនិយាយទៅកាន់យុវនារីឯកោម្នាក់នៅលើឡានក្រុង ។ ឪពុករបស់នាងបានសរសើរដល់ការសម្រេចចិត្តរបស់នាង ហើយរ៉ាយរ៉ាប់អំពីបទពិសោធន៍មួយដែលគាត់មាននៅកន្លែងធ្វើការ ។

ពួកគេទាំងអស់គ្នាបានបញ្ចប់ការពិភាក្សាដោយការច្រៀងបទ « ទុកឲ្យព្រះវិញ្ញាណដឹកនាំ » ( *សៀវភៅទំនុកតម្កើង* លេខ ៨១ ) ។

វិធីសាស្រ្តបង្រៀនដ៏សាមញ្ញមួយ — ការចែកចាយបទពិសោធន៍អំពីគោលលទ្ធិនេះ — ធ្វើឲ្យរាត្រីជួបជុំក្រុមគ្រួសារនេះបានប្រព្រឹត្តទៅដោយជោគជ័យ ។

អត្ថបទនេះ ផ្តល់នូវគំរូជីវិតពិតអំពីរបៀបដែលមនុស្សបានរៀនដំណឹងល្អតាមកម្មវិធីសិក្សារបស់យុវវ័យនៅថ្ងៃអាទិត្យ ដែលបានរៀបចំតាមខែ ។ ប្រាកដណាស់ គំរូទាំងនេះពុំគ្រាន់តែជារបៀបដើម្បីរៀនអំពីគោលលទ្ធិទាំងឡាយប៉ុណ្ណោះទេ ។ អ្នកអាចស្វែងរកការបំផុសគំនិតសម្រាប់សេចក្តីត្រូវការនៃគ្រួសារអ្នក ។





# ខែ មករា

## ក្រុមព្រះ

សមាជិកនៃក្រុមព្រះ — ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ — គឺជាតួអង្គដាច់ដោយឡែកពីគ្នាបីអង្គ ប៉ុន្តែរួមគ្នានៅក្នុងគោលបំណង និងសិរីល្អ ។

យុវនារីម្នាក់ប្រាប់ពីការរៀនអំពីក្រុមព្រះ ៖ « វាសំខាន់ចំពោះខ្ញុំដែលព្រះវរបិតាសួគ៌របស់ខ្ញុំ ព្រះអង្គសង្គ្រោះរបស់ខ្ញុំ និង ព្រះវិញ្ញាណបរិសុទ្ធ ជាតួអង្គផ្សេងពីគ្នា ដើម្បីខ្ញុំអាចរៀនស្គាល់អង្គនិមួយៗ ប៉ុន្តែធ្វើតាមនៅក្នុងសាមគ្គីភាព ។ ខ្ញុំបានទទួលស្គាល់ដោយការដឹងគុណថា ខ្ញុំអាចប្រែក្លាយដូចជាព្រះ ដោយសារតែក្រុមព្រះ ពុំមែនជាអង្គធាតុដែលពុំមានទ្រង់ទ្រាយ ឬពុំអាចយល់បាននោះទេ ប៉ុន្តែជាតួអង្គដ៏ទេវភាព ដែលស្រឡាញ់ ប្រទានពរ ដឹកនាំ ហើយស្គាល់រូបខ្ញុំ » ។

ដើម្បីបង្រៀនគោលលទ្ធិនេះ អ្នកអាចព្យាយាមពិភាក្សាសំណួរដូចតទៅថា « តើយើងអាចរៀនមកពីក្រុមព្រះ អំពីការធ្វើការរួមគ្នាក្នុងសាមគ្គីភាពដោយរបៀបណា ? » ឬ « តើយើងអាចពង្រឹងទំនាក់ទំនងរបស់យើងជាមួយនឹងសមាជិកនៃក្រុមព្រះយ៉ាងដូចម្ដេច ? »

ការប្រៀបធៀប យ៉ូហាន ១០:៣០ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤៣ អាចបំផុសឲ្យមានការពិភាក្សាគ្នាល្អ ហើយផ្ដល់គំនិតអំពីសាមគ្គីភាព ។

# ខែ កុម្ភៈ

## ផែនការនៃសេចក្ដីសង្គ្រោះ

ផែនការនៃសុភមង្គល ឆ្លើយសំណួរសំខាន់បំផុតរបស់មនុស្សដូចជា « តើខ្ញុំជានរណា ? » និង « តើគោលបំណងនៃជីវិតនេះគឺជាអ្វី ? » ការសួរសំណួរផ្ទាល់ខ្លួនអ្នក និងការស្រាវជ្រាវរកចម្លើយ អាចជាវិធីដ៏មានអានុភាពដើម្បីរៀនអំពីផែនការនៃសុភមង្គលរបស់ព្រះបិតា ។

ឧទាហរណ៍ យុវជនម្នាក់បានចាប់ផ្ដើមការសិក្សាព្រះគម្ពីររបស់គាត់ដោយសួរថា « តើចរិតលក្ខណៈរបស់ព្រះជាយ៉ាងណា បើប្រៀបធៀបទៅនឹងចរិតលក្ខណៈដែលខ្ញុំមាននៅក្នុងជីវិតមុនជីវិតរមែងស្លាប់នោះ ? នឹងចរិតលក្ខណៈដែលខ្ញុំមានឥឡូវនេះ ? ដែលខ្ញុំសង្ឃឹមថានឹងមាននៅក្នុងជីវិតក្រោយនោះ ? » គាត់បានសរសេរចម្លើយចំពោះសំណួរទាំងនេះនៅពេលគាត់រកឃើញនៅក្នុងបទគម្ពីរ ហើយប្រើវាដើម្បីបង្រៀនអ្នកដទៃអំពីផែនការនៃសេចក្ដីសង្គ្រោះ ។

តើសំណួរដែលកូនៗរបស់អ្នកមានអំពីផែនការនៃសេចក្ដីសង្គ្រោះមានអ្វីខ្លះ ?



### ធនធាននានាសម្រាប់ការបង្រៀន

សាសនាចក្រផ្ដល់នូវធនធានជាច្រើនដើម្បីជួយអ្នករៀន និងបង្រៀនគោលការណ៍ខាងគោលលទ្ធិទាំងនេះ ។ បន្ថែមពីលើបទគម្ពីរ និងសុន្ទរកថាសន្និសីទទូទៅ ចូរពិចារណាអំពីជម្រើសទាំងនេះ ៖

***ការបង្រៀនរបស់ប្រធានសាសនាចក្រ*** ។ សូមចូលទៅកាន់គេហទំព័រ lds.org/manual/teachings-of-presidents ។

***ពិតចំពោះសេចក្ដីជំនឿ*** ។ សូមចូលទៅកាន់គេហទំព័រ lds.org/manual/home-and-family ។

***ប្រកាសដំណឹងល្អរបស់យើង*** និងកូនសៀវភៅអមមកជាមួយ ។ សូមចូលទៅកាន់គេហទំព័រ lds.org/manual/missionary ។

**តន្ត្រី** ។ តន្ត្រីនៅក្នុងទំនុកតម្កើង និង*សៀវភៅចម្រៀងកុមារ* ជួយគាំទ្រដល់គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ សូមចូលទៅកាន់គេហទំព័រ lds.org/music ។

**វីដេអូ** ។ វីដេអូសាសនាចក្រ ក៏ចូលរួម និងអាចជួយចាប់ផ្ដើមការសន្ទនាអំពីដំណឹងល្អនៅផ្ទះផងដែរ ។ សូមចូលទៅកាន់គេហទំព័រ lds.org/media-library ។

**សិល្បៈកម្ម** ។ ការប្រើប្រាស់សិល្បៈដូចនេះ ដែលរកបាននៅក្នុង*សៀវភៅសិល្បៈដំណឹងល្អ* អាចជួយបំផុសគំនិតយោបល់អំពីបទគម្ពីរ ។ សូមចូលទៅកាន់គេហទំព័រ lds.org/media-library ។



# ខែ មិនា

**ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ**

តើយើងរៀន មិនគ្រាន់តែអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែក៏រៀនអំពីសេចក្ដីសង្ឃឹមដ៏មុតមាំរបស់ព្រះអង្គសង្គ្រោះរបស់យើង ដែលសង្ឃឹមថាយើងនឹងប្រើដង្វាយធួនរបស់ទ្រង់នៅក្នុងជីវិតរបស់យើងយ៉ាងដូចម្ដេច ?

ដោយសារយើងទាំងអស់គ្នាធ្លាប់ឯកោ ធ្វើកំហុស ហើយត្រូវការភាពរឹងមាំ នោះយើងទាំងអស់គ្នាមានតម្រូវការដើម្បីយល់ដឹងឲ្យបានល្អប្រសើរ ហើយប្រើដង្វាយធួន ។ អ្នកឲ្យដំបូន្មានក្រុមយុវនារីម្នាក់ បានប្រើវីដេអូមួយ ដើម្បីជួយសិស្សក្នុងថ្នាក់របស់គាត់ យល់អំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះកាន់តែប្រសើរ ។

នេះគឺជាបទពិសោធន៍របស់យុវនារីម្នាក់ ៖

« យើងកំពុងមើលរឿង ‹ គ្មាននរណាម្នាក់នៅជាមួយទ្រង់ › ( វីដេអូ LDS.org ) ។ នៅពេលសំឡេងខ្លុយលេងបទទួញសោក នោះសំឡេងរបស់អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា ‹ ការលួងលោមចិត្តដ៏មហិមាមួយនៃរដូវកាលបុណ្យអ៊ីស្ទើរនេះ គឺថា ដោយសារព្រះយេស៊ូវបានយាងនៅលើផ្លូវដ៏វែង និងឯកោដោយព្រះអង្គឯង នោះ*យើង* ពុំចាំបាច់ត្រូវធ្វើដូច្នោះទេ › ។

« ខ្ញុំមានអារម្មណ៍ខ្មាស់អៀន ដែលតម្រូវនូវដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ប៉ុន្តែខ្ញុំទម្លាក់ខ្លួនទាំងស្រុងទៅក្នុងព្រះវិញ្ញាណ ដែលខ្ញុំមានអារម្មណ៍ពីក្ដីសង្ឃឹមថាដង្វាយធួនរបស់ទ្រង់បោសសម្អាតនូវអារម្មណ៍ទោសកំហុសរបស់ខ្ញុំទាំងឡាយ ។ ព្រះអម្ចាស់បានប្រទានជីវិតរបស់ទ្រង់ដើម្បីខ្ញុំ ទ្រង់ពុំសោកស្ដាយទេ ហើយខ្ញុំក៏ពុំគួរសោកស្ដាយដែរ » ។

ដោយសារដង្វាយធួនគឺជាព្រឹត្តការណ៍ដ៏មហិមានៃសេចក្ដីសង្គ្រោះរបស់យើង នោះយើងត្រូវតែបង្រៀន និងរៀនអំពីវាដោយមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ ប្រហែលជាអ្នកនឹងត្រូវដឹកនាំឲ្យពិភាក្សាខគម្ពីរ ឬទីបន្ទាល់របស់សាវក ដូចជា « ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក » ( *លីអាហូណា*, ខែមេសា ឆ្នាំ ២០០០ ទំព័រ ២ ) ។ ចូរពិចារណាធ្វើការពិភាក្សាសំណួរមួយដូចជា « តើអ្នកធ្លាប់មានអារម្មណ៍ថាត្រូវបានព្យាបាល ពង្រឹង ឬប្រោសលោះដោយព្រះចេស្ដានៃដង្វាយធួននៅពេលណា ? »



# ខែ មេសា

**គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និង ការស្ដារឡើងវិញ**

ការយល់ដឹងអំពីការក្បត់សាសនា — ការធ្លាក់ចេញពីដំណឹងល្អពិត — ជួយយើងឲ្យយល់ពីតម្រូវការដើម្បីមានការស្ដារឡើងវិញនៃដំណឹងល្អបព្វជិតភាព និងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។

គោលបំណងមេរៀននៅខាងក្រោមនេះ បានជួយអ្នកផ្សព្វផ្សាយសាសនាមួយចំនួនបង្រៀនអ្នករៀនថ្មីម្នាក់អំពីការក្បត់សាសនា និងការស្ដារឡើងវិញ ។

« ដៃគូខ្ញុំ និងខ្ញុំ បានប្រើពែងជ័រជាច្រើន ដែលមានបិទស្លាកដោយពាក្យចំណែកនៃសេចក្ដីពិតក្នុងសាសនាចក្រដោយសង់ជារូបពីរ៉ាមីតដោយពែងទាំងនោះ ហើយពន្យល់អំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានស្ថាបនាសាសនាចក្រទ្រង់ឡើង ។

« បន្ទាប់មក យើងបានពន្យល់អំពីការក្បត់សាសនា នៅពេលយើងដកពែងមួយដែលតំណាងពួកសាវកចេញ ហើយមើលឃើញសំណង់ទាំងមូលរលំចុះ ។ នៅពេលយើងបានពន្យល់អំពីការស្ដារឡើងវិញនៃដំណឹងល្អតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ នោះយើងសង់ប៉មនោះឡើងវិញ ដោយបង្ហាញថា សាសនាចក្រសព្វថ្ងៃនេះ ត្រូវបានរៀបចំឡើងតាមរបៀបដូចគ្នាដែលព្រះគ្រីស្ទបានរៀបចំវាឡើងកាលពីដើម ។

« នេះជាលើកដំបូងដែលបុរសនេះបានយល់អំពីវា ។ ទីបំផុត គាត់បានយល់នូវអត្ថន័យនៃការស្ដារឡើងវិញ ពេលគាត់យល់ថាហេតុអ្វីបានជាវាចាំបាច់ » ។

មានរបៀបជាច្រើនផ្សេងទៀត ដែលតំណាងឲ្យវដ្ដនៃគ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និងការស្ដារឡើងវិញ ។ អ្នកអាចអានវគ្គគម្ពីរអំពីប្រធានបទទាំងនេះ ហើយធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ដើម្បីបង្កើតនូវការតំណាងផ្ទាល់ខ្លួនរបស់អ្នកអំពីអ្វីដែលអ្នករៀន ( សូមមើល ឧទាហរណ៍ អាម៉ុស ៨:១១–១២, នីហ្វៃទី ១ ១៣, គ. និង ស. ១៣៦:៣៦–៣៨, ម៉ូសេ ៥:៥៥–៥៩ ) ។



រូបភាពពែង © MOODBOARD/THINKSTOCK

# ខែ ឧសភា

**ព្យាការី និង វិវរណៈ**



ព្រះអម្ចាស់ខ្វល់ព្រះទ័យយ៉ាងខ្លាំងអំពីការទំនាក់ទំនងជាមួយនឹងយើង ។ យើងទទួលបានការដឹកនាំរបស់ទ្រង់នៅក្នុងជីវិតរបស់យើង តាមរយៈវិវរណៈដែលទ្រង់ប្រទានដល់ពួកព្យាការីរបស់ទ្រង់ និងចំពោះយើងដោយផ្ទាល់ ។ ជាញឹកញាប់ យើងអាចយល់ពីគោលការណ៍ដំណឹងល្អកាន់តែល្អប្រសើរ បើយើងប្រៀបធៀបវាទៅនឹងវត្ថុ ឬបទពិសោធន៍នៅក្នុងជីវិតសព្វថ្ងៃរបស់យើង ។ យុវនារីម្នាក់រៀបរាប់អំពីរបៀបដែលការប្រៀបធៀបមួយ បានជួយនាងឲ្យស្គាល់វិវរណៈ ៖

« ខ្ញុំបានរៀនអំពីវិវរណៈ តាមរយៈព្យាការីសព្វថ្ងៃ ។ អែលឌើរ ដាវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍អំពីវិញ្ញាណនៃវិវរណៈ ហើយបានពន្យល់វា ដោយប្រៀបទៅនឹងពន្លឺ ។ ជួនកាល វិវរណៈកើតមានភ្លាមៗ និងច្បាស់ៗ ដូចជាការបើកភ្លើងក្នុងបន្ទប់ងងឹត ។ ជាធម្មតានោះ វាកើតមានមកបន្តិចម្ដងៗ ដូចជាព្រះអាទិត្យរះឡើងចាំងពន្លឺភ្លឺឡើងបន្តិចម្ដងៗយ៉ាងខ្ជាប់ខ្ជួន ។ ជាញឹកញាប់បំផុត អែលឌើរ បែដណា បានថ្លែងថា វិវរណៈ គឺដូចជាពន្លឺនៅថ្ងៃដែលមានចុះអ័ព្ទ ។ ‹ មានពន្លឺគ្រប់គ្រាន់ដែលអ្នក . . . អាចមើលឃើញល្មមដើម្បីបោះជំហានទៅមុខនៅក្នុងភាពចុះអ័ព្ទនោះ › ( នៅក្នុង « Patterns of Light: Spirit of Revelation » [ វីដេអូ ], LDS.org ) ។ ការប្រៀបធៀបនេះ វាសាមញ្ញ តែមានអត្ថន័យយ៉ាងខ្លះចំពោះខ្ញុំ ដោយសារខ្ញុំបានដឹងថា វិវរណៈ គឺមានសម្រាប់ខ្ញុំ បើខ្ញុំចំណាយពេលដើម្បីចាំមើល » ។

នៅពេលយើងចំណាយពេលសិក្សាការប្រៀបធៀបរឿងប្រៀបធៀប និងនិមិត្តរូបនានា នោះការយល់ដឹងរបស់យើងអំពីគោលលទ្ធិ អាចបន្តរីកចម្រើន ។ វិធីសាស្ត្របង្រៀនទាំងនេះជួយយើងឲ្យរៀនកាន់តែច្រើន នៅពេលយើងអនុញ្ញាតឲ្យព្រះវិញ្ញាណបើកសម្ដែងនូវទស្សនៈវិស័យថ្មីមកកាន់យើង ។

# ខែ មិថុនា

**បព្វជិតភាព និងកូនសោបព្វជិតភាព**

បព្វជិតភាព គឺជាប្រធានបទសំខាន់មួយចំពោះមនុស្សគ្រប់គ្នា ។ វាគឺជាព្រះចេស្ដានៃព្រះ ហើយអាចប្រទានពរដល់យើងទាំងអស់គ្នា ។ យើងម្នាក់ៗមានតួនាទីសំខាន់មួយដើម្បីដើរតួនៅក្នុងកិច្ចការបព្វជិតភាព ។

មនុស្សខ្លះពុំស្គាល់កាតព្វកិច្ច តំណែង និងប្រវត្តិនៃបព្វជិតភាពទេ ។ ការប្រឡងអាចនឹងជាវិធីដ៏សប្បាយមួយ ដើម្បីរៀនអំពីគំនិតទាំងនេះ ។

ដោយសំអាងទៅលើអ្វីដែលអ្នកចង់រៀន អ្នកអាចប្រើសំណួរមួយចំនួនដូចខាងក្រោម ហើយអញ្ជើញកូនៗរបស់អ្នកឲ្យស្វែងរកចម្លើយនៅក្នុងបទគម្ពីរ និងការបង្រៀនអំពីពួកព្យាការីសម័យទំនើបទាំងឡាយ ។

- តើអ្វីខ្លះជាតំណែង និងកាតព្វកិច្ចនៃបព្វជិតភាពអើរ៉ុន ? នៃបព្វជិតភាពមិលគីស្សាដែក ?
- តើកូនសោបព្វជិតភាពគឺជាអ្វី ? តើនរណាកាន់កូនសោទាំងនោះ ? ហេតុអ្វីកូនសោទាំងនោះចាំបាច់ ?
- តើអ្វីជាភាពខុសគ្នារវាងតំណែងបព្វជិតភាព សិទ្ធិអំណាច និងអំណាចបព្វជិតភាព ?
- តើបព្វជិតភាពប្រទានពរដល់មនុស្សទាំងប្រុស និងស្រីយ៉ាងដូចម្ដេច ?

ចម្លើយអាចរកបាននៅក្នុងសៀវភៅយោង ដូចជាសៀវភៅ *គោលការណ៍ដំណឹងល្អ* ( ឆ្នាំ ២០០៩ ) និងសៀវភៅ *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* ( ឆ្នាំ ២០០៤ ) និងនៅក្នុងគម្ពីរដូចជាគោលលទ្ធិ និងសេចក្ដីសញ្ញា ១៣, ២០ និង ១០៧ ។

ចម្លើយចំពោះសំណួរចុងក្រោយ « តើបព្វជិតភាពប្រទានពរដល់មនុស្សទាំងប្រុស និងស្រីយ៉ាងដូចម្ដេច ? » អាចរកបាននៅក្នុងបទគម្ពីរ ប៉ុន្តែសំខាន់បំផុតគឺត្រូវឆ្លុះបញ្ចាំងអំពីរបៀបដែលគោលលទ្ធិនេះ ជះឥទ្ធិពលដល់យើងផ្ទាល់ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*



*ផ្នែកទីពីរនៃអត្ថបទនេះ ការចែកចាយគំនិតសម្រាប់ខែកក្កដា-ខែធ្នូ នឹងត្រូវបានបោះពុម្ពនៅពេលក្រោយក្នុងឆ្នាំនេះ ។*





**ដោយ អែលឌើរ**
**ជែហ្វ្រី អ័រ ហូឡិន**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# ការស្គាល់អំពី ក្រុមព្រះ

*យើងត្រូវស្គាល់តួអង្គព្រះទាំងនេះតាមគ្រប់វិធីដែលយើងអាចធ្វើបាន ។ យើងត្រូវស្រឡាញ់ពួកទ្រង់ ខិតទៅជិតទ្រង់ គោរពប្រតិបត្តិទ្រង់ ហើយព្យាយាមប្រែក្លាយដូចជាពួកទ្រង់ ។*

*ដកស្រង់ចេញពីសុន្ទរកថា « ក្រុមព្រះ » ដែលបានធ្វើឡើងនៅក្នុងសិក្ខាសាលាសម្រាប់ប្រធានបេសកកម្មថ្មី នៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាទីក្រុង ប្រូវ៉ូ នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៣ ។*

ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា « វាគឺជាគោលការណ៍ទីមួយនៃដំណឹងល្អ ដែលត្រូវស្គាល់ឲ្យច្បាស់នូវចរិតលក្ខណៈរបស់ព្រះ » ។[១] លោកបានបន្ថែមតទៅទៀតថា « ខ្ញុំចង់ឲ្យអ្នកទាំងអស់គ្នាស្គាល់ទ្រង់ ហើយមានភាពជិតស្និទ្ធនឹងទ្រង់ » ។[២] យើងត្រូវតែមាន «គំនិត *ត្រឹមត្រូវ* មួយអំពីភាពល្អឥតខ្ចោះរបស់ទ្រង់ និងលក្ខណៈរបស់ទ្រង់ . . . » ហើយកោតសរសើរចំពោះ « ចរិតលក្ខណដ៏ល្អវិសេស [ របស់ទ្រង់ ] » ។[៣]

ខ្ញុំចង់ថ្លែងបន្តនូវសំណូមពររបស់ព្យាការីទៅដល់យើងទាំងអស់គ្នា ហើយនិយាយថា យើង និងអ្នកផ្សព្វផ្សាយសាសនារបស់យើង សមាជិករបស់យើង និងអ្នករៀនថ្មីរបស់យើង ត្រូវតែដឹងឲ្យច្បាស់អំពីលក្ខណៈនៃសមាជិកនៃ *ក្រុមព្រះ* ។ យើងត្រូវតែមានគំនិតត្រឹមត្រូវមួយអំពីភាពឥតខ្ចោះ និងលក្ខណៈនៃតួអង្គនិមួយៗ ហើយកោតសរសើរចំពោះលក្ខណៈដ៏ល្អវិសេស *របស់ពួកទ្រង់* ។

វាពុំមែនជារឿងចៃដន្យនោះទេ ដែលមាត្រានៃសេចក្តីជំនឿទីមួយរបស់យើងចែងថា « យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និង ដល់ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ » ( មាត្រានៃសេចក្តីជំនឿ ១:១ ) ។ សារលិខិតនេះគឺច្បាស់លាស់សម្រាប់មនុស្សទាំងអស់ដែលបង្រៀនដំណឹងល្អ ។ វាពុំចាំបាច់មាននូវការពិភាក្សាអំពីសេចក្តីពិតផ្សេងទៀតដែលយើងជឿដោយហួសហេតុពេកទេ បើយើងពុំមានភាពជាក់ច្បាស់នៅក្នុងគំនិតរបស់យើង និងក្នុងគំនិតរបស់អស់អ្នកដែលយើងបង្រៀនអំពីតួនាទីដ៏វិសេសនៃក្រុមព្រះនៅក្នុងគោលលទ្ធិរបស់យើងនិងនៅក្នុងជោគវាសនាដ៏អស់កល្បជានិច្ចរបស់យើងផងនោះ ។ យើងត្រូវស្គាល់តួអង្គព្រះអាទិទេពទាំងនេះតាមគ្រប់វិធីដែលយើងអាចធ្វើបាន ។ យើងត្រូវស្រឡាញ់ពួកទ្រង់ ខិតទៅជិតទ្រង់ គោរពប្រតិបត្តិទ្រង់ ហើយព្យាយាមប្រែក្លាយដូចជាពួកទ្រង់ ។

*ការនិមិត្តដំបូង ដោយ វលធើរ រេន*

នៅពេលយើងនាំមនុស្សមកក្នុងសាសនាចក្រ យើងពុំមែនជ្រមុជទឹកដល់ពួកគេឲ្យចូលមកក្នុងសាសនាចក្រនៃមនុស្សទេ មិនថាមនុស្សនោះជា យ៉ូសែប ស៊្មីធ ឬ ព្រិកហាំ យ៉ង់ ឬ ថូម៉ាស អេស ម៉នសុននោះទេ — ទោះជាយើងគោរពដល់ពួកព្យាការីទាំងនោះក្តី ។ ហើយយើងក៏ពុំមែនជ្រមុជទឹកពួកគេមកក្នុងសាសនាចក្រនៃក្រុមគ្រួសារីករាយ ឬនៃក្រុមចម្រៀងពាងឧបោសថមរមននោះដែរ ។

នៅពេលយើងនាំមនុស្សមកក្នុងសាសនាចក្រ យើងជ្រមុជទឹកពួកគេនៅក្នុងព្រះនាមនៃព្រះវរបិតា នៃព្រះរាជបុត្រា និងនៃព្រះវិញ្ញាណបរិសុទ្ធ ។ ពេលធ្វើដូច្នោះ យើងកំពុងនាំពួកគេត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតា តាមរយៈការបម្រើ ដង្វាយធួន និងព្រះគុណនៃព្រះរាជបុត្រាទ្រង់ ដោយមានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ដឹកនាំពួកគេទៅរកគោលដៅនេះ ។ យើងត្រូវតែរក្សារឿងសំខាន់បំផុតអំពីក្រុមព្រះនេះនៅក្នុងគំនិតរបស់យើងជានិច្ច ទាំងនៅក្នុងគោលដៅមួយ និងរបៀបដើម្បីសម្រេចគោលដៅនោះ នៅពេលយើងធ្វើកិច្ចការនៃសេចក្តីសង្គ្រោះ ។

ដូចស្ដេចបេនយ៉ាមីន បានទូន្មាន បើយើង *ពិតជា* ស្គាល់តួអង្គអាទិទេពទាំងនេះ ដែលយើងបម្រើ ហើយដឹងប្រាកដថា ពួកទ្រង់ពុំមែនជាតួអង្គចម្លែកចំពោះយើង ហើយពួកទ្រង់ពុំដែលឃ្លាតឆ្ងាយពីគំនិត និងបំណងនៃដួងចិត្តរបស់យើង ( សូមមើលម៉ូសាយ ៥:១៣ ) ទៃនោះយើងអាចទទួលបានលទ្ធផលដូចជាស្ដេចបេនយ៉ាមីនបានទទួលដែរ ។ ហើយតើលទ្ធផលទាំងនោះគឺជាអ្វី ? រាស្ត្ររបស់ទ្រង់មានបទពិសោធន៍ « ការផ្លាស់ប្ដូរដ៏ធំ » « ពុំមានបំណងនឹងប្រព្រឹត្តអំពើទុច្ចរិតទៀតឡើយ ប៉ុន្តែចង់ប្រព្រឹត្តអំពើល្អជានិច្ចវិញ » ហើយ « យល់ព្រមចូលទៅក្នុងសេចក្ដីសញ្ញា . . . ដើម្បីធ្វើតាមព្រះហឫទ័យ [ របស់ព្រះ ] ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ចំពោះអ្វីៗទាំងអស់ ដែលទ្រង់ [ នឹង ] បញ្ជាដល់ [ ពួកគេ ] នៅក្នុងជីវិត [ របស់ពួកគេ ] ដែលនៅសល់ទាំងប៉ុន្មាន » ( ម៉ូសាយ ៥:២, ៥ ) ។

នោះគឺជាឥទ្ធិពលនៃការបង្រៀនរបស់ស្ដេចបេនយ៉ាមីន មកដល់ក្រុមជំនុំ ហើយវាគឺជានិយមន័យខាងបទគម្ពីរ *ដ៏ល្អឥតខ្ចោះមួយ* នៃ *ការរីកចម្រើនពិត* នៅក្នុងអ្នកផ្លាស់ប្រែចិត្តជឿរបស់យើង ដែលយើងកំពុងគូសបញ្ជាក់ នៅពេលយើងស្ថាបនាសាសនាចក្រនៅក្នុង « លោកិយទាំងមូល » ( ម៉ាកុស ១៦:១៥ ) ។

នៅពេលព្រះអង្គសង្គ្រោះបានបង្រៀនផ្ទាល់អំពី កិច្ចការផ្សព្វផ្សាយសាសនា — កិច្ចការនៃសេចក្តីសង្គ្រោះ — គឺដូចជាសំណាញ់មួយ ដែលយើងបោះដែលមានទំហំកាន់តែធំទៅៗ ទៅក្នុងលោកិយនៃជាតិសាសន៍ វប្បធម៌ និងប្រជាជនទាំងឡាយ ។ ដូច្នេះ យើងនឹងប្រមូលផ្តុំ ដូចរឿងប្រៀបប្រដូចបាននិយាយអំពីត្រី « គ្រប់មុខ » ( ម៉ាថាយ ១៣:៤៧ ) ។ « ត្រី » ជាច្រើនទាំងនោះដែលនៅក្នុងព្រំដែននៃការគ្រប់គ្រងរបស់យើង ពុំបានដឹងថាព្រះជានរណាទេ ឬភាពជាព្រះវរបិតារបស់ទ្រង់មានលក្ខណៈពិតយ៉ាងណាទេ ពួកគេពុំស្គាល់ព្រះយេស៊ូវគ្រីស្ទជានរណាពិតទេ ឬហេតុអ្វីក៏ព្រះនាមទ្រង់គឺជាព្រះនាមតែមួយនៅក្រោមមេឃ ដែលបានប្រទានឲ្យ ដើម្បីយើងអាចត្រូវបានសង្គ្រោះដូច្នេះ ( សូមមើល កិច្ចការ ៤:១២ ) ពួកគេពុំស្គាល់តួអង្គណាជាព្រះវិញ្ញាណបរិសុទ្ធ ឬហេតុអ្វីក៏សមាជិកនៃក្រុមព្រះអង្គនេះ « ត្រូវបានចាត់ឲ្យចេញទៅបង្រៀនពីសេចក្តីពិត » ដូច្នេះដែរ ( គ. និង ស. ៥០:១៤ ) ។

**ចំណេះដឹងអំពីក្រុមព្រះ**

ប្រាកដណាស់ មានរឿងផ្សេងៗទៀតជាច្រើនដែលត្រីទាំងនេះ ដែលត្រូវបានប្រមូលគ្រប់មុខ តែពុំបានដឹងទេ ប៉ុន្តែបើពួកគេត្រូវតែឱបក្រសោបយកដំណឹងល្អ ដែលបានស្ដារឡើងវិញ ហើយស្វែងរកសេចក្តីសង្គ្រោះពិតសម្រាប់ព្រលឹងរបស់ពួកគេ នោះវានឹងត្រូវចាប់ផ្តើមជាមួយនឹងចំណេះដឹងមួយចំនួន ហើយយល់អំពីសមាជិកនៃក្រុមព្រះ ។ ទីបំផុត « ការថ្វាយបង្គំពិត និងជាការថ្វាយបង្គំសម្រាប់ការសង្គ្រោះ គឺត្រូវបានរកឃើញតែនៅក្នុងចំណោមអស់អ្នកដែលស្គាល់សេចក្តីពិតអំពី . . . ក្រុមព្រះ ហើយយល់ពីទំនាក់ទំនងពិតដែលមនុស្សគួរតែមានជាមួយនឹងសមាជិកនៃ [ បងប្អូនប្រុសម្នាក់ដែលត្រូវបានហៅថា ] ជាគណៈប្រធានដ៏អស់កល្បជានិច្ចប៉ុណ្ណោះ » ។[៤]

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ( ឆ្នាំ ១៩១៥–៨៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានរំឭកយើងថា លូស៊ីហ្វើរ យល់អំពីសារៈសំខាន់នៃគោលលទ្ធិបែបនេះ ទោះជាយើងពុំយល់ក្តី ។ លោកបានមានប្រសាសន៍ ៖

*ឥទ្ធិពលនៃការបង្រៀនរបស់ស្ដេចបេនយ៉ាមីន មកដល់ក្រុមជំនុំ គឺជានិយមន័យខាងបទគម្ពីរដ៏ល្អឥតខ្ចោះមួយនៃការរីកចម្រើនពិតនៅក្នុងអ្នកផ្លាស់ប្រែចិត្តជឿរបស់យើង ដែលយើងកំពុងគូសបញ្ជាក់នៅពេលយើងស្ថាបនាសាសនាចក្រនៅក្នុង « លោកិយទាំងមូល » ។*



ខាងឆ្វេង ៖ *នៅក្នុងការបម្រើនៃព្រះរបស់អ្នក* ដោយ វលធើរ រេន ទទួលបានសិទ្ធិអនុញ្ញាតមកពីសារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ; ខាងស្ដាំ ៖ រូបភាពលម្អិតមកពី *ពិធីបុណ្យជ្រមុជទឹក* ដោយ ជេ ឃើក រីឆាដ



« វាគ្មាននូវសេចក្ដីសង្គ្រោះនោះទេនៅពេលយើងជឿទៅលើ . . . គោលលទ្ធិខុសឆ្គង ជាពិសេសទស្សនៈខុសឆ្គង ឬមិនឈ្លាសវៃ អំពីក្រុមព្រះ ឬសមាជិកណាមួយនៃក្រុមព្រះ ។ . . .

« ហេតុដូច្នោះហើយ អារក្សវាផ្សាយគោលលទ្ធិខុសឆ្គងអំពីព្រះ និងក្រុមព្រះ ហើយបង្កនូវអារម្មណ៍ខុសឆ្គងជាមួយនឹងសេចក្ដីយោងចំពោះតួអង្គណាមួយនៃក្រុមព្រះច្រើនជាងអ្វីផ្សេងៗទាំងអស់ដែលវាអាចធ្វើបាន » ។[៥]

ដូច្នេះគ្មានអ្នករៀនថ្មីណាម្នាក់ដែលចូលមកកាន់សាសនាចក្រនេះដោយទីបន្ទាល់ *ពិត* ដោយមានការផ្លាស់ប្រែចិត្តជឿ *ពិត* ដោយមានអ្វីដែលយើងកំពុងស្វែងរក ឬហៅថាជាការរីកចម្រើនពិតនៅក្នុងអ្នកផ្លាស់ប្រែចិត្តជឿម្នាក់ៗទេ លុះត្រាតែគាត់ ឬនាង មានយ៉ាងហោចណាស់នូវការចាប់ផ្ដើមផ្ទាល់ខ្លួនខ្លះៗ ខាងវិញ្ញាណ និងមានបទពិសោធន៍ពិតជាមួយព្រះសិន ។ ប្រភេទនៃបទពិសោធន៍ពិតនោះ អាចកើតមានឡើងតែនៅពេលដែលមានការដឹងច្បាស់ថា ទ្រង់គឺជាតួអង្គពិត ជាអង្គពិតមួយ ជាព្រះបិតាដែលមានសាច់ និងឆ្អឹងដោយពិត ដែលថ្លែង ហើយទតឃើញ និងដឹង ហើយទ្រង់ស្គាល់ឈ្មោះកូនចៅទ្រង់ទាំងអស់ ហើយដឹងពីតម្រូវការពួកគេទាំងអស់ ដែលស្ដាប់ឮការអធិស្ឋានទាំងអស់របស់ពួកគេ ហើយដែលសព្វព្រះទ័យចង់ឲ្យកូនចៅទាំងអស់របស់ទ្រង់មកក្នុងសាសនាចក្ររបស់ទ្រង់ ។ អ្នករៀនថ្មីទាំងនេះ ចាំបាច់ត្រូវដឹងថាទ្រង់មានផែនការមួយសម្រាប់សេចក្ដីសង្គ្រោះពួកគេ ហើយថាទ្រង់បានប្រទានបទបញ្ញត្តិទាំងឡាយ ជារបៀបដែលយើងស្វែងរកផ្លូវត្រឡប់ទៅរកទ្រង់វិញ ។

ព្រះដែលមានព្រះទ័យខ្វល់ចំពោះពួកគេដោយទន់ភ្លន់ដូចជាឪពុកម្ដាយមើលថែកូនតូចម្នាក់នោះ ពុំអាចជាអង្គដែលគ្មានរូបរាង ឬជាគំនិតទស្សនៈវិជ្ជាអរូបី ឬជាម្ចាស់នៃសកលលោកដែលគ្មានជីវិតនោះទេ ។ ទ្រង់ត្រូវតែបានគេទទួលស្គាល់ព្រះអង្គថាមានអត្តសញ្ញាណព្រះដោយពិត — គឺជាព្រះបិតាប្រកបដោយក្ដីមេត្តា និងព្រះគុណ ដែលកូនចៅរបស់ទ្រង់បានបង្កើតឡើងតាមរូបអង្គទ្រង់ ហើយជាអង្គដែលយើងទាំងអស់គ្នានឹងឈរនៅចំពោះព្រះភ័ក្ត្រ — ហើយលុតជង្គង់ចុះចំពោះទ្រង់នៅថ្ងៃណាមួយ ! អ្នករៀនថ្មីរបស់យើងមួយចំនួនតូចនឹងស្គាល់ពី *ថា* អំពីព្រះប្រភេទនោះក្នុងពេលឥឡូវនេះ ទាំងក្នុង ឬក្រៅព្រះវិហារពួកគ្រីស្ទានក្ដី ។

ចំពោះរឿងនោះ វាសំខាន់បំផុតដែលមេរៀនទី ១ នៅក្នុងសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* ចាប់ផ្ដើមដោយការប្រកាសយ៉ាងសាមញ្ញថា « ព្រះគឺជាព្រះវរបិតាសួគ៌របស់យើង » ។[៦] នៅក្នុងមេរៀននោះ ការប្ដេជ្ញាចិត្តដំបូងដែលអ្នកផ្សព្វផ្សាយសាសនាគួរស្វែងយល់គឺថា អ្វីដែលមនុស្សម្នាក់ៗត្រូវបានបង្រៀន គឺពួកគេយល់អំពីលក្ខណៈពិតរបស់ព្រះ ។

បើអ្នកផ្សព្វផ្សាយសាសនាអាចដាក់ការយល់ដឹងត្រឹមត្រូវអំពីព្រះ នៅក្នុងគំនិត និងដួងចិត្តរបស់អ្នករៀនថ្មីរបស់ពួកគេចាប់ពីដំបូងនៃការបង្រៀនរបស់ពួកគេ នោះអ្វីៗផ្សេងទៀតនឹងត្រូវបានយល់កាន់តែងាយស្រួលនៅក្នុងគ្រប់ការណែនាំដែលនឹងមានតាមក្រោយ ។

## បេសកកម្ម និង សារលិខិតរបស់ព្រះយេស៊ូវគ្រីស្ទ

តាមរបៀបដូចគ្នានោះ អែលឌើរ ស៊ីស្ទើរ និង អ្នករៀនថ្មី ច្បាស់ជាមានអំណរគុណច្រើនជាងដែលពួកគេមានទៅលើអានុភាពដ៏អស្ចារ្យនៃបេសកកម្ម និងសារលិខិតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានទទួលមកពីព្រះវរបិតា ហើយបានបង្រៀននូវអ្វីដែលព្រះបិតាបានបង្រៀនដល់ទ្រង់ ។ មនុស្សគ្រប់រូបត្រូវតែទទួលស្គាល់ថា ព្រះយេស៊ូវ យាងមកក្នុងជីវិតរមែងស្លាប់នេះដើម្បីបង្ហាញពីផ្លូវនៃ សេចក្ដីពិត និងជីវិតដល់យើង ។ ច្បាស់ណាស់ ពិតប្រាកដហើយថា ទ្រង់ *គឺជា* មាគ៌ា *តែមួយគត់* ជាសេចក្ដីពិត *ដ៏ពេញលេញ* ហើយជាជីវិត *ដ៏ឥតខ្ចោះ* ។ ដោយហេតុនោះ ទ្រង់គឺជាបុត្រតែមួយគត់នៅក្នុងគ្រួសារមនុស្សលោកដែលព្រះវរបិតា អាចមានបន្ទូលដោយពេញលេញទាំងស្រុងថា « នេះជាកូនស្ងួនភ្ងាយើង ជាទីគាប់ចិត្តយើងណាស់ » ( ម៉ាថាយ ១៧:៥ ) ។

*មនុស្សទាំងអស់ត្រូវតែទទួលស្គាល់ថា ព្រះយេស៊ូវ យាងមកក្នុងជីវិតរមែងស្លាប់នេះដើម្បីបង្ហាញផ្លូវ សេចក្ដីពិត និងជីវិតដល់យើង ។*

យើងត្រូវមានជំនឿទៅលើព្រះគ្រីស្ទ ទុកចិត្តថា ទ្រង់បានប្រោសលោះយើងពីការស្លាប់ខាងរាងកាយ និងស្ថាននរកខាងវិញ្ញាណ ហើយទទួលយកដង្វាយធួនរបស់ទ្រង់ទុកថាជាមធ្យោបាយ *តែមួយគត់* ដើម្បីសម្រុះសម្រួលខ្លួនយើងនៅចំពោះព្រះ ហើយទទួលស្គាល់ថា គ្មានផ្លូវណាផ្សេងទៀតនាំទៅរកសេចក្តីសង្គ្រោះឡើយ ។ បើពិភពលោកនេះត្រូវបានប្រោសលោះនោះត្រូវតែលុតជង្គង់ចុះ ហើយអណ្តាតត្រូវសារភាពថា ព្រះយេស៊ូវគ្រីស្ទ គឺព្រះគ្រីស្ទ ជាព្រះរាជបុត្រាដ៏មានព្រះជន្មរស់របស់ព្រះដ៏មានព្រះជន្មរស់ ។ យើងចាំបាច់ត្រូវបង្រៀនដោយសេចក្តីជំនឿ និង ដោយភ្លៀវក្លាអំពី « គោលលទ្ធិនៃព្រះគ្រីស្ទ » ( ហេព្រើរ ៦:១, យ៉ូហានទី ២ ១:៩, នីហ្វៃទី ២ ៣១:២, ២១, ៣២:៦, យ៉ាកុប ៧:២, ៦ ) ដូចបានប្រកាសនៅក្នុងបទគម្ពីរ និងដូចបានសង្ខេបនៅក្នុងមេរៀនទី ៣ នៃសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* ។

អ្នករៀនថ្មីរបស់យើង ចាំបាច់ត្រូវស្គាល់ថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាសមាជិកនៃក្រុមព្រះ ដែលពួកគេនឹងមានទំនាក់ទំនងញឹកញាប់បំផុត និងជិតស្និតបំផុត នៅពេលពួកគេទទួលអ្នកផ្សព្វផ្សាយសាសនា ហើយអធិស្ឋានសុំការដឹកនាំពីស្ថានសួគ៌ ស្តីអំពីសារលិខិតរបស់ពួកគេនោះ ។ គឺសមាជិកនៃក្រុមព្រះនេះហើយ ដែលនឹង *ដឹកនាំ* អ្នករៀនថ្មីទៅរកសេចក្តីពិត បន្ទាប់មកនឹង *ថ្លែងទីបន្ទាល់* អំពីសេចក្តីពិតនោះនៅពេលពួកគេជួបប្រទះនឹងកិច្ចការនេះ ។ អ្នករៀនថ្មី ត្រូវតែបានបង្រៀនឲ្យស្គាល់ព្រះវិញ្ញាណ នៅពេលដែលព្រះវិញ្ញាណសម្តែងឡើងអំឡុងពេលរៀនមេរៀនទាំងឡាយ ។ ប្រាកដណាស់ថា អ្នកផ្សព្វផ្សាយសាសនាត្រូវតែយល់អំពីតួនាទីដ៏ទេវភាពរបស់ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងដំណើរការនៃការផ្លាស់ប្រែចិត្តជឿ ហើយត្រូវតែព្យាយាមមានព្រះវិញ្ញាណគង់នៅជាមួយពួកគេគ្រប់ពេលវេលា ។

ព្រះអម្ចាស់បានសួរថា « តើអ្នកត្រូវបានតែងតាំងឲ្យធ្វើអ្វី ? » ។ « គឺដើម្បីផ្សាយដំណឹងល្អរបស់យើង ដោយសារព្រះវិញ្ញាណ គឺព្រះដ៏ជាជំនួយ ដែលបានចាត់ឲ្យចេញទៅបង្រៀនពីសេចក្តីពិត ។ . . .

« ហេតុដូច្នោះហើយ អ្នកដែលផ្សាយដំណឹងល្អ [ ដោយព្រះវិញ្ញាណ ] និងអ្នកដែលទទួល [ ដោយព្រះវិញ្ញាណ ] យល់គ្នាទៅវិញទៅមក ហើយទាំងពីរនាក់ត្រូវបានស្អាងឡើង ហើយត្រេកអរជាមួយគ្នា » ( គ. និង ស. ៥០:១៣–១៤, ២២ ) ។

យើងអាចដឹងយ៉ាងច្បាស់លាស់ថា វា *នឹងមិន* ដំណើរការល្អទេ — ចំពោះអ្នកផ្សព្វផ្សាយសាសនា និងអ្នករៀនរបស់ពួកគេ — បើយើងពុំបង្រៀនត្រឹមត្រូវអំពីក្រុមព្រះរបស់យើងនោះ ។ យើងពុំត្រូវបង្រៀនអំពីអ្នកដឹកនាំនៃជីវិតរមែងស្លាប់ មុនពេលយើងបង្រៀន និងថ្លែងទីបន្ទាល់អំពីអ្នកដឹកនាំខាងសេឡេស្ទាលឡើយ ។ យើងមិនត្រូវព្យាយាមបង្រៀនសេចក្តីពិតបន្ទាប់បន្សំ មុនពេលយើងបង្រៀនសេចក្តីពិតជាមូលដ្ឋានគ្រឹះឡើយ ។ យើងមិនត្រូវប្រញាប់ប្រញាល់ឆ្ពោះទៅកាន់បុណ្យជ្រមុជទឹក និងទទួលគោលដៅសម្រាប់អ្នកផ្លាស់ប្រែចិត្តជឿថ្មី ពីមុនយើងបានបង្រៀនសេចក្តីជំនឿពិតទៅលើព្រះយេស៊ូវគ្រីស្ទ ដែលបានពន្យល់អំពីតម្រូវការឲ្យមានការប្រែចិត្តជឿពិតទៅលើព្រះគ្រីស្ទ ហើយត្រូវប្រាកដថា ចំណុចទាំងនោះ ដែលផ្តោតសំខាន់ដំបូងគេទៅលើការរីកចម្រើនខាងទីបន្ទាល់របស់អ្នកផ្លាស់ប្រែចិត្តជឿ ត្រូវបានរក្សាឲ្យរឹងមាំ ហើយល្អ តាមរយៈការចិញ្ចឹមបីបាច់ពីភ្នាក់ងារនៃព្រះវិញ្ញាណបរិសុទ្ធ ។

*តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចបណ្តេញភាពងងឹតចេញពីក្នុងចំណោមយើង ហើយត្រូវបានព្រមានប្រាប់ពីគ្រោះថ្នាក់ និងភាពមិនពិត ។ ខ្ញុំថ្លែងជាសាក្សីថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសញ្ញាផងដែរ ដែលបញ្ជាក់ និងបង្ហាញថាសេចក្តីសញ្ញានិងពិធីបរិសុទ្ធត្រឹមត្រូវ ហើយនៅទីបំផុត ជាការផ្សារភ្ជាប់នូវពរជ័យនៃការសង្គ្រោះទាំងអស់ដល់ជីវិតអស់កល្បជានិច្ច ។*

**ការយល់ច្រឡំរបស់ពួកគ្រីស្ទាន**

ស្តីអំពីលក្ខណៈពិសេសនៃតួអង្គអាទិទេពទាំងនេះ វិវរណៈថ្ងៃចុងក្រោយបានបង្រៀនថា « ព្រះវរបិតា ទ្រង់មានព្រះកាយជាសាច់ និង ឆ្អឹង ដែលជាក់ស្តែងដូចជារូបកាយមនុស្ស ហើយព្រះរាជបុត្រាក៏ដូច្នោះដែរ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធពុំមានព្រះកាយជាសាច់ និង ឆ្អឹងឡើយ តែមានរូបជាវិញ្ញាណវិញ » ( គ. និង ស. ១៣០:២២ ) ។

អ្នកពុំអាចទទួលបានសេចក្តីថ្លែងការណ៍ណាដែលច្បាស់លាស់ជាងនេះទៀតទេ ! ប៉ុន្តែជាអកុសល រយៈពេលជិតពីរពាន់ឆ្នាំនៃប្រវត្តិសាស្ត្រពួកគ្រីស្ទាន បានសាបព្រោះនូវការយល់ច្រឡំដ៏ធំ និងកំហុសឆ្គងដែលស្ទើរតែវិនាសបង់នៅក្នុងរឿងនេះ ។ ការវិវត្តន៍ និងការបញ្ជាក់នៃលទ្ធិជំនឿខាងសាសនាជាច្រើន បកស្រាយខុសយ៉ាងខ្លាំងទៅនឹងភាពច្បាស់លាស់ដ៏សាមញ្ញនៃគោលលទ្ធិពិត ដោយប្រកាសថា ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ជាអរូបីបរិបូណ៌ អស្ចារ្យ ខ្ពស់ត្រដែត បិតបេរ មានខ្លឹមសារដូចគ្នាអស់កល្បជានិច្ចរួមគ្នា និង មិនអាចយល់បាន ដោយគ្មានរូបកាយ ជាផ្នែកសរីរៈ ឬមានអារម្មណ៍ ហើយរស់នៅក្រៅលំហអាកាស និងពេលវេលា ។

នៅក្នុងលទ្ធិសាសនាដូចនេះ សមាជិកទាំងបីអង្គ គឺមានរូបកាយតួអង្គផ្សេងគ្នា ប៉ុន្តែជាតួអង្គតែមួយ បានពិភាក្សាជារឿយៗអំពី « អាថ៌កំបាំងនៃក្រុមព្រះបីអង្គ » ។ ពួកទ្រង់គឺជាតួអង្គផ្សេងគ្នា ប៉ុន្តែពុំមែនជាព្រះបីអង្គទេ តែជាព្រះមួយអង្គ ។

តួអង្គផ្សេងគ្នាទាំងបី គឺពុំអាចយល់បានទេ ប៉ុន្តែគឺមានព្រះមួយអង្គដែលពុំអាចយល់បាន ។

យើងយល់ស្របនឹងការរិះគន់របស់យើងនៅត្រង់ចំណុចនោះ — ថាការពោលអំពីភាពជាព្រះដូច្នោះ គឺពុំអាចយល់បានទេ ។ ជាមួយនឹងនិយមន័យដ៏ច្របូកច្របល់នេះអំពីតួអង្គព្រះ ត្រូវបានគេដាក់មកលើសាសនាចក្រ តែវាពុំគួរឲ្យងឿងឆ្ងល់ទេ ដែលសង្ឃសតវត្សរ៍ទីបួនបានប្រកាសថា « វរហើយខ្ញុំ ! ពួកគេបានដកយកព្រះរបស់ខ្ញុំចេញពីខ្ញុំហើយ . . . ហើយខ្ញុំពុំស្គាល់អង្គដែលខ្ញុំត្រូវថ្វាយបង្គំ ឬទំនាក់ទំនងទៅទេ » ។[៧] តើយើងទុកចិត្ត ស្រឡាញ់ និងថ្វាយបង្គំ ព្យាយាមដើម្បីប្រែក្លាយដូចជាតួអង្គមួយដែលពុំអាចយល់ និងពុំអាចស្គាល់បានដោយរបៀបណា ? ការអធិស្ឋានរបស់ព្រះយេស៊ូវបានថ្លែងថា « នេះជាជីវិតដ៏អស់កល្បជានិច្ច គឺឲ្យគេបាន *ស្គាល់ដល់ទ្រង់* ដ៏ជាព្រះពិតតែមួយ *នឹងព្រះយេស៊ូវគ្រីស្ទ* ដែល *ទ្រង់* បានចាត់ឲ្យមកផង ? » ( យ៉ូហាន ១៧:៣ គូសបញ្ជាក់បន្ថែម ) ។

វាពុំមែនជាគោលបំណងរបស់យើងទៅបន្តុះបង្អាប់ដល់ជំនឿរបស់នរណាម្នាក់ ឬគោលលទ្ធិសាសនាណាមួយនោះទេ ។ យើងសូមផ្ដល់នូវការគោរពដូចគ្នាចំពោះគោលលទ្ធិរបស់ពួកគេ ដែលយើងសូមឲ្យមានការគោរពចំពោះគោលលទ្ធិរបស់យើងដែរ ។ ( នោះក៏ជាមាត្រានៃសេចក្ដីជំនឿរបស់យើងផងដែរ ) ។ ប៉ុន្តែ *វចនានុក្រមព្រះគម្ពីរប៊ីបរបស់ ហាបពើរ* ដែលអាចពឹងផ្អែកបាន ដែលបានចាត់ទុកថាបានអនុញ្ញាតនៅក្នុងការសិក្សាព្រះគម្ពីរប៊ីបកត់ត្រាថា « គោលលទ្ធិជាផ្លូវការអំពីក្រុមព្រះបីអង្គ ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាព្រះវិហារដ៏ធំនៃសតវត្សរ៍ទីបួន និងទីប្រាំ គឺពុំអាចរកឃើញ [ នៅកន្លែងណាមួយ ] នៅក្នុង [ ព្រះគម្ពីរសញ្ញាថ្មី ] ទេ » ។[៨]

ដូច្នេះ តាមពិតយើងមានចិត្តកក់ក្ដៅ និងប្រកាសដោយឥតលាក់លាមថា យើងពុំកាន់តាមទស្សនៈអំពីក្រុមព្រះដែលពួកឥតជំនឿសាសនាមានក្នុងសតវត្សរ៍ទីបួន ឬ ទីប្រាំ ឬពួកគ្រីស្ទានដំបូងដែលជាសាក្សីផ្ទាល់ភ្នែកនៃព្រះគ្រីស្ទដ៏មានព្រះជន្មរស់ទេ ។[៩] យើងគឺជាពួកគ្រីស្ទានសញ្ញាថ្មី — *ពុំមែន* ជាពួកគ្រីស្ទានដែលដើរតាមលទ្ធិនីសេនទេ ។

**ភាពសាមគ្គីគ្នានៃក្រុមព្រះ**

ទោះជាយ៉ាងណាក៏ដោយ ឥឡូវខ្ញុំសូមគូសបញ្ជាក់យ៉ាងរហ័សថា នៅពេលយើងបានលើកឡើងពីចំណុចអំពីភាពផ្សេងគ្នានៃតួអង្គរបស់ពួកទ្រង់ វាមានសារៈសំខាន់ស្មើនឹងការគូសបញ្ជាក់អំពីរបៀបដែលពួក ទ្រង់សាមគ្គីភាពគ្នា និងរបៀបដ៏ពិតអំពីក្រុមព្រះគឺ *តែមួយ* ។ ខ្ញុំគិតថា ខ្ញុំមានសុវត្ថិភាពដើម្បីនិយាយថា ចំណែកនៃមូលហេតុដែលយើងត្រូវបានអ្នកដទៃយល់ច្រឡំយ៉ាងខ្លាំង នៅក្នុងទំនៀមទម្លាប់នៃពួកគ្រីស្ទាន គឺដោយសារតែការគូសបញ្ជាក់អំពីតួអង្គផ្សេងៗគ្នានៃក្រុមព្រះនេះហើយ ទើបយើងពុំបានតាមដានឲ្យបានញឹកញាប់ល្មម ទាំងការព្រមទទួល និង *ការគូសបញ្ជាក់* អំពីសាមគ្គីភាពរបស់ពួកទ្រង់តាមរបៀបដែលអាចនឹកស្រមៃផ្សេងៗទៀតតាមការជាក់ស្ដែង ។ ដោយមូលហេតុនេះ យើងត្រូវបានរិះគន់


*បើពិភពលោកនេះត្រូវបានប្រោសលោះ នោះត្រូវតែលុតជង្គង់ចុះ ហើយអណ្ដាតត្រូវសារភាពថា ព្រះយេស៊ូវគ្រីស្ទ គឺព្រះគ្រីស្ទជាព្រះរាជបុត្រាដ៏មានព្រះជន្មរស់ របស់ព្រះដ៏មានព្រះជន្មរស់ ។*

រូបភាពលម្អិតមកពី *ការព្យាបាលមនុស្សខ្វាក់* ដោយ ខាល ហេនរីច ប្លូក

ហើយយើងបានធ្វើឲ្យជំហរជាពួកបរិសុទ្ធថ្ងៃចុងក្រោយរបស់យើង កាន់តែពិបាកយល់ជាងដែលវាចាំបាច់ត្រូវយល់ ។

ប្រាកដណាស់ វគ្គបទគម្ពីរ « គោលលទ្ធិនៃព្រះគ្រីស្ទ » នៅក្នុង នីហ្វៃទី ២ ៣១ បានបញ្ចប់ជាមួយនឹងការប្រកាសនេះ ៖ « នេះគឺជាគោលលទ្ធិនៃព្រះគ្រីស្ទ ហើយគឺជាគោលលទ្ធិតែមួយ ហើយពិតនៃព្រះវរបិតា និងព្រះរាជបុត្រា ហើយនឹងព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះពិតតែមួយ ដែលគ្មានចុងបំផុត » ( នីហ្វៃទី ២ ៣១:២១ ) ។

យើងទាំងអស់គ្នាបានអាននូវការអធិស្ឋានទូលសូមជំនួសដ៏ឧត្តុងឧត្ដមរបស់ព្រះអង្គសង្គ្រោះនៅក្នុងយ៉ូហាន ១៧ ។ យើងដឹងថាវាជាការប្រកាសមួយអំពីសាមគ្គីភាពរវាងព្រះវរបិតា និងព្រះរាជបុត្រា ហើយរវាងពួកទ្រង់នឹងពួកយើងដែលជាពួកសិស្សលើផែនដីរបស់ពួកទ្រង់ ។ សូមអានវាជាញឹកញាប់ ជាពិសេសចាប់តាំងពី ប្រធាន ដេវីឌ អូ មិកឃេ ( ឆ្នាំ ១៨៧៣–១៩៧០ ) ម្ដងនោះបានហៅថា « ការអធិស្ឋានដ៏អស្ចារ្យបំផុត . . . ដែលពុំធ្លាប់បានឮនៅក្នុងពិភពលោកនេះ » ទេ ។[10] យើងគប្បីព្យាយាមឲ្យក្លាយទៅជាតែមួយនឹងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ដូចដែលព្រះយេស៊ូវបានអធិស្ឋានឲ្យយើងប្រែក្លាយ ។

*យើងគប្បីព្យាយាមដើម្បីប្រែក្លាយទៅជាតែមួយនឹងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ដូចដែលព្រះយេស៊ូវបានអធិស្ឋានសុំឲ្យយើងប្រែក្លាយ ។*



**សាក្សីរបស់សាវក**

ខ្ញុំសូមបញ្ចប់ជាមួយនឹងទីបន្ទាល់របស់ខ្ញុំចំពោះតួអង្គអាទិទេពនិមួយៗ ដែលបង្កើតជា « គណៈប្រធានដ៏អស់កល្ប » ដូចដែលបានថ្លែងនោះ ។ ដោយសារការធ្វើជាសាក្សី និងការថ្លែងទីបន្ទាល់អំពីតួនាទីដ៏ធំពីរ ខ្ញុំសូមធ្វើជាសាក្សីអំពីព្រះវិញ្ញាណបរិសុទ្ធ *ដោយវិញ្ញាណ* នៃព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំសូមថ្លែងជាសាក្សីថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាគ្រូបង្រៀន ជាអង្គលួងលោមចិត្ត និងជាភ្នាក់ងារនៃវិវរណៈផ្ទាល់ខ្លួនមួយ ។ ខ្ញុំថ្លែងជាសាក្សីថា ព្រះវិញ្ញាណបរិសុទ្ធ នឹងនាំអ្វីៗគ្រប់យ៉ាងមកក្នុងការចងចាំរបស់យើង — ជាពរជ័យជាក់លាក់មួយ ដោយសារការចងចាំគឺជាបទបញ្ញត្តិធំមួយដែលបានប្រទានដល់យើង រួមមាននៅក្នុងការអធិស្ឋាននៃពិធីសាក្រាម៉ង់ ( សូមមើល គ. និង ស. ២០:៧៧, ៧៩ ) ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចបណ្ដេញភាពងងឹតចេញពីក្នុងចំណោមយើង ហើយត្រូវបានព្រមានប្រាប់ពីគ្រោះថ្នាក់ និងភាពមិនពិត ។ ខ្ញុំថ្លែងជាសាក្សីថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យាផងដែរ ដែលបញ្ជាក់ និងបង្ហាញថាសេចក្ដីសញ្ញា និង ពិធីបរិសុទ្ធត្រឹមត្រូវ ហើយទីបញ្ចប់ផ្សារភ្ជាប់នូវពរជ័យនៃការសង្គ្រោះទាំងអស់ដល់ជីវិតអស់កល្បជានិច្ច ។ ខ្ញុំមានការអស្ចារ្យដែលយើងមានលទ្ធភាពជាស្រេចដើម្បីទៅកាន់សមាជិកនៃក្រុមព្រះ ហើយមានលទ្ធភាពនេះដោយខ្ជាប់ខ្ជួន និងម្ដងហើយម្ដងទៀត បើយើងរស់នៅដោយសក្តិសមចំពោះព្រះវិញ្ញាណ ។ ខ្ញុំសូមសម្ដែងនូវការដឹងគុណហួសពីពាក្យដែលអាចថ្លែងបានចំពោះអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

ខ្ញុំថ្លែងជាសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាដ៏មានព្រះជន្មរស់របស់ព្រះដ៏មានព្រះជន្មរស់ ដែលបានបង់ថ្លៃលោះព្រលឹងរបស់អ្នក និងខ្ញុំ ហើយនឹងព្រលឹងមនុស្សគ្រប់រូប ទាំងបុរស និងស្ត្រី និងកុមារតូចៗ ចាប់តាំងពីជំនាន់អ័ដាម រហូតដល់ចុងបំផុតនៃលោកិយ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា គោលការណ៍ទីមួយនៃដំណឹងល្អគឺជា *សេចក្តីជំនឿ* ទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ហើយថាវាជាគ្រឹះ និងជាសារលិខិតសំខាន់នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា មនុស្សគ្រប់រូបដែលបានកើតមកក្នុងពិភពលោកនេះ គឺកើតមកដោយមានពន្លឺនៃព្រះគ្រីស្ទនៅក្នុងព្រលឹងរបស់គាត់ ឬនាង ។ ខ្ញុំថ្លែងជាសាក្សីថា ទ្រង់គឺជាអង្គដំបូងគេ និងចុងក្រោយគេ ជាដើម និងជាចុង ជាអាល់ផា និងអូមេកា នៃសេចក្ដីសង្គ្រោះរបស់យើង ។ ខ្ញុំសូមប្រកាសថា ទ្រង់គឺជាព្រះយេហូវ៉ាដ៏មហិមា ជាអង្គប្រោសលោះ ជាកូនចៀមនៃព្រះ ដែលត្រូវបានគេធ្វើគតតាំងពីមុនគ្រឹះនៃលោកិយមកម្ល៉េះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា នៅក្នុងទ្រង់គឺមានភាពពេញលេញ ហើយថាទ្រង់បានចាប់កំណើតមក បានរស់នៅ និងបានសុគតក្នុងនាមជាបុរសគ្មានបាប ល្អឥតខ្ចោះ ដោយគ្មានប្រឡាក់ស្នាមអ្វីឡើយ ។

ខ្ញុំមានអំណរគុណចំពោះសិទ្ធិអំណាចរបស់ព្រះយេស៊ូវគ្រីស្ទ ដែលគ្រប់គ្រងលើអ្វីៗទាំងអស់នៃសារៈសំខាន់ដ៏អស់កល្បជានិច្ច នៅក្នុងសាកលលោកនេះ ដែលវាថ្លែងនៅក្នុងព្រះនាមទ្រង់ — បព្វជិតភាពបរិសុទ្ធតាមលំដាប់នៃព្រះរាជបុត្រា

ខាងឆ្វេង ៖ កុំតាមទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ, ដោយ ហារី អេនឌើសិន ; ខាងស្ដាំ ៖ រូបភាពលម្អិតមកពី រូបសំណាកព្រះគ្រីស្ទ ជាអង្គល្អលោមចិត្ត ដោយ ខាល ហេនរីច ប្លក



នៃព្រះ ។ បើខ្ញុំនឹងរស់នៅដល់អាយុមួយពាន់ឆ្នាំ ខ្ញុំពុំអាចថ្លែងឲ្យបានគ្រប់គ្រាន់អំពីភាពអស្ចារ្យរបស់ខ្ញុំ និងថ្លែងពុំល្មមគ្រប់គ្រាន់នៅក្នុងការហៅឲ្យធ្វើជាសាវកមួយរូបរបស់ទ្រង់ ធ្វើជាសាក្សីអំពីព្រះនាមទ្រង់នៅក្នុងពិភពលោកទាំងមូលបានទេ ។

*ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យនូវក្ដីស្នេហ៍ព្រះគ្រីស្ទឲ្យខ្ញុំ*
*ទាំងឆ្ងល់ចំពោះព្រះគុណដែលព្រះអង្គបានប្រទាន*
*ដល់ខ្ញុំ ។*[១១]

ខ្ញុំថ្លែងជាសាក្សីអំពីព្រះ ជាព្រះវរបិតាសួគ៌ ព្រះអេឡូហិមដ៏មហិមា ព្រះវរបិតានៃខ្ញុំ និងអ្នករាល់គ្នា ដែលបានប្រទានជីវិតខាងវិញ្ញាណដល់យើង ។ ខ្ញុំថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុរសនៃបរិសុទ្ធភាព ដែលពាក្យព្រះគុណ និងសេចក្ដីល្អ សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណា គ្រាន់តែជាពាក្យចាប់ផ្ដើមពិពណ៌នាអំពីលក្ខណៈដ៏អស់កល្បជានិច្ច និងសំខាន់របស់ទ្រង់ប៉ុណ្ណោះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះគ្រីស្ទ បានយាងមកបង្ហាញដល់យើងអំពីព្រះវរបិតា ហើយដោយហេតុនេះហើយ ទើបទ្រង់ត្រូវបានហៅដោយពេញសិទ្ធិថាជាកូនមនុស្ស ( នៃបរិសុទ្ធភាព ) ។

ខ្ញុំសូមថ្លែងជាសាក្សីថា ព្រះ ដែលជាព្រះវរបិតារបស់យើង គឺជាអង្គនិពន្ធផែនការនៃសេចក្ដីសង្គ្រោះដ៏មហិមា ហើយថាអ្វីដែលត្រូវបានស្គាល់ថាជាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទក៏ត្រូវបានស្គាល់ថាជា «ដំណឹងល្អនៃព្រះ » ផងដែរ ( រ៉ូម ១:១ សូមមើលផងដែរ ខ ២–៣ ) ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះវរបិតា គឺជា និងជាអង្គបង្កបង្កើតនៃវត្ថុគ្រប់យ៉ាង ដែលធ្វើការតាមរយៈព្រះយេហូវ៉ា និងភ្នាក់ងារស្ថានសួគ៌ដទៃទៀត ដើម្បីសម្រេចនូវការបង្កបង្កើតនោះ ហើយចែកចាយនូវនាមជាអង្គបង្កបង្កើតជាមួយនឹងព្រះរាជបុត្រាសំណព្វរបស់ទ្រង់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា យើងត្រូវ *បម្រើ* ព្រះវរបិតា នៅក្នុងព្រះនាមនៃព្រះរាជបុត្រា ហើយយើងក៏ត្រូវ *អធិស្ឋាន* ទៅកាន់ព្រះវរបិតានៅក្នុងព្រះនាមនៃព្រះរាជបុត្រាដែរ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទ យាងមកដើម្បីធ្វើតាមព្រះហឫទ័យព្រះវរបិតា បានបង្រៀនគោលលទ្ធិអំពីព្រះវរបិតា ហើយបានទទួលសេចក្ដីសង្គ្រោះផ្ទាល់ព្រះអង្គទ្រង់តាមរយៈព្រះវរបិតា ។ ខ្ញុំសូមធ្វើជាសាក្សីដ៏ឧឡារិកបំផុតថា ព្រះវរបិតាស្រឡាញ់ពិភពលោកនេះយ៉ាងខ្លាំង ស្រឡាញ់កូនចៅរបស់ទ្រង់ រហូតដល់ទ្រង់បានប្រទានបុត្រដ៏ល្អបំផុតរបស់ទ្រង់មក ជាព្រះរាជបុត្រដ៏ល្អឥតខ្ចោះ បុត្រសំណព្វតែមួយគត់ ហើយនរណាដែលនឹងជឿទៅលើទ្រង់ នឹងមានជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល យ៉ូហាន ៣:៣៦; ៦:៤៧; ហេលេមិន ១៤:៨ ) ។

ខ្ញុំមានអំណរគុណចំពោះព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ដែលនៅក្នុងព្រះនាមដ៏ពិធីបរិសុទ្ធពិសិដ្ឋ និងការសង្គ្រោះ ចាប់ពីពិធីបុណ្យជ្រមុជទឹក ដល់ការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ត្រូវបានធ្វើឡើងនៅក្នុងសាសនាចក្រនេះ ។ ខ្ញុំសូមអញ្ជើញបងប្អូនម្នាក់ៗឲ្យស្គាល់តួអង្គព្រះទាំងនេះឲ្យកាន់តែខ្លាំង ។ ■

ព្រះយេស៊ូវគ្រីស្ទ យាងមកធ្វើតាមព្រះហឫទ័យព្រះវរបិតា បានបង្រៀនគោលលទ្ធិអំពីព្រះវរបិតា ហើយបានទទួលសេចក្ដីសង្គ្រោះផ្ទាល់ព្រះអង្គទ្រង់តាមរយៈព្រះវរបិតា ។

កំណត់ចំណាំ

១. យ៉ូសែបស្ម៊ីធ, *នៅក្នុង History of the Church,* ៦:៣០៥ ។
២. យ៉ូសែបស្ម៊ីធ, *នៅក្នុង History of the Church,* ៦:៣០៥ ។
៣. *Lectures on Faith* ( ឆ្នាំ ១៩៨៥ ), ទំព័រ ៣៨, ៤២ ។
៤. ប្រ៊ូស អ័រ ម៉ាក់ខន់ឃី « Our Relationship with the Lord » (Brigham Young University devotional, ថ្ងៃទី ២ ខែ មិនា ឆ្នាំ ១៩៨២), ១, speeches.byu.edu ។
៥. ប្រ៊ូស អ័រ ម៉ាក់ខន់ឃី « Our Relationship with the Lord, » ទំព័រ ១–២ ។
៦. *ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ ២០០៤ ) ទំព័រ ៣១ ។
៧. នៅក្នុង Owen Chadwick, ed., *Western Asceticism* ( ឆ្នាំ ១៩៥៨ ), ២៣៥ ។
៨. Paul J. Achtemeier, ed., *Harper's Bible Dictionary* ( ឆ្នាំ ១៩៨៥ ) ទំព័រ ១០៩៩ ។
៩. សម្រាប់ការពិភាក្សាលម្អិតមួយអំពីរឿងនេះ សូមមើល Stephen E. Robinson, *Are Mormons Christians?* ( ឆ្នាំ ១៩៩១ ), ទំព័រ ៧១–៨៩; សូមមើលផងដែរ Robert L. Millet, *Getting at the Truth: Responding to Difficult Questions about LDS Beliefs* ( ឆ្នាំ ២០០៤ ), ទំព័រ ១០៦–២២ ។
១០. ដេវីឌ អូ. មិកឃេ នៅ ក្នុង ខែ តុលា ឆ្នាំ ១៩៦៧, ទំព័រ ៥ ។
១១. « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » *ទំនុកតម្កើង*, លេខ ១១៥ ។

# ខ្ញុំបានទទួលស្គាល់ព្រះបន្ទូលនៃព្រះ

ខណៈដែលនៅក្នុងអាកាសយានដ្ឋានជាច្រើនឆ្នាំមុន នៅទីក្រុងសៅ ផាឡូ ប្រទេសប្រេស៊ីល ខ្ញុំបានឃើញសៀវភៅមួយក្បាលនៅក្នុងកន្លែងដាក់សៀវភៅតាំងក្នុងហាងសៀវភៅមួយ មានចំណងជើង « ព្រះគម្ពីរមរមន ៖ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » ។ ខ្ញុំបានឆ្ងល់ថានៅក្នុងពិភពលោកដែលពោរពេញដោយភាពអសីលធម៌ និងគ្មានការដឹកនាំនេះ នឹងទទួលយកសក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទឬទេ ហើយខ្ញុំបានចំណាយពេលចុងសប្ដាហ៍គិតអំពីសៀវភៅនេះ ។

ទីបំផុត ខ្ញុំពុំអាចស៊ូទ្រាំសង្ស័យទៀតបាន ខ្ញុំបានត្រឡប់ទៅហាងសៀវភៅនោះទិញវា ។ ទោះជាយ៉ាងណាក៏ដោយ ពេលខ្ញុំមកដល់ ខ្ញុំរកវាពុំឃើញទេ ។ ខ្ញុំបានពិពណ៌នាអំពីសៀវភៅនោះទៅអ្នកលក់ក្នុងហាង ប៉ុន្តែគាត់បាននិយាយថា គាត់ពុំដែលមើលឃើញវាទេ ។ គាត់ពុំអាចរកឃើញនៅក្នុងកំណត់ត្រាណាមួយសោះ ទោះជាសៀវភៅទាំងអស់ដែលដាក់តាំងនៅហាងក្នុងតាឡុកក្ដី ។

ពេលក្រោយមក នៅក្នុងឱសថស្ថានមួយកន្លែង ខ្ញុំបានកត់សម្គាល់ឃើញសៀវភៅមួយក្បាលបើកចំហរនៅលើតុមួយ ។ នៅពេលខ្ញុំចាប់ផ្ដើមអានវា ខ្ញុំបានដឹងអំពីបុរសម្នាក់ដែលឈ្មោះកូរីហូរ ដែលនៅតែនិយាយថា គាត់សង្ស័យអំពីព្រះចេស្ដារបស់ព្រះ ហើយទីបំផុតត្រូវបានក្លាយជាគ ។ នៅពេលខ្ញុំបាននឹកគិតអំពីពាក្យទាំងឡាយដែលខ្ញុំអាន ខ្ញុំបានដឹងថាគឺមកពីព្រះ ។

អំឡុងពេលនេះ ខ្ញុំកំពុងតែស្វែងរកការដឹកនាំមកពីព្រះ ។ នៅថ្ងៃមួយ ខ្ញុំបានលុតជង្គង់ ហើយបានអធិស្ឋានយ៉ាងក្លៀវក្លាទូលសូមដល់ព្រះឲ្យបង្ហាញខ្ញុំនូវផ្លូវត្រូវដែលនឹងនាំខ្ញុំទៅរកទ្រង់ ។ ប៉ុន្មានថ្ងៃក្រោយមក កូនប្រុសរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ ដូច្នេះខ្ញុំបានត្រឡប់ទៅហាងឱសថនោះវិញ ។ ពេលខ្ញុំហៀបនឹងចេញពីហាង នោះមានយុវជនជនជាតិអាមេរិកកាំងបីនាក់ ពាក់ស្លាកឈ្មោះដើរចូលមក ។ រំពេចនោះខ្ញុំមានអារម្មណ៍កក់ក្ដៅនៅក្នុងទ្រូង ដែលបានបំផុសគំនិតខ្ញុំឲ្យនិយាយទៅពួកគេ ។

ពួកគេបានប្រាប់ខ្ញុំថា ពួកគេនៅក្នុងប្រទេសប្រេស៊ីល ផ្សាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំបានសួរថា តើពួកគេអាចបង្រៀនខ្ញុំបានឬទេ ហើយយើងបានដាក់កាលវិភាគណាត់ជួបគ្នាមួយ ។

នៅពេលខ្ញុំស្ដាប់ឮអំពីព្យាការី យ៉ូសែប ស្ម៊ីធ ជាលើកដំបូង ខ្ញុំបានដឹងថាការអធិស្ឋានរបស់ខ្ញុំត្រូវបានឆ្លើយតបហើយ ។ បន្ទាប់មកអ្នកផ្សព្វផ្សាយសាសនាបានឲ្យសៀវភៅមួយក្បាលមកខ្ញុំ ។ ជាការភ្ញាក់ផ្អើល វាគឺជាព្រះគម្ពីរមរមន — ដូចជាសៀវភៅមួយក្បាលដែលខ្ញុំបានឃើញនៅកន្លែងដាក់តាំងសៀវភៅនោះ ។ ជាថ្មីម្ដងទៀតខ្ញុំបានមានអារម្មណ៍កក់ក្ដៅដ៏ផ្អែមល្ហែម ហើយបានរីករាយជាខ្លាំង ដែលខ្ញុំពុំអាចថ្លែងបាន ។

អ្នកផ្សព្វផ្សាយសាសនា បានពន្យល់អំពីធាតុដើមនៃព្រះគម្ពីរ ហើយបានសុំឲ្យខ្ញុំអធិស្ឋានរួចសួរដល់ព្រះ ថាតើវាជាព្រះគម្ពីរពិតដែរឬទេ ។ ខ្ញុំក៏បានដឹងយ៉ាងពិតប្រាកដអំពីទេវភាពនៃគម្ពីរនេះរួចទៅហើយ ដ្បិតព្រះអម្ចាស់បានបង្ហាញវាដល់ខ្ញុំ — ពីរដងរួចមកហើយ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានអានវាយ៉ាងយកចិត្តទុកដាក់បំផុត ។ ពេលអានជំពូក ១៧ នៅក្នុងនីហ្វៃទី ៣ ខ្ញុំបានដឹងថាវាមានរឿងដ៏ទេវភាពមួយ ដោយសារវាមាននូវព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ។

មូលដ្ឋានគ្រឹះនៃទីបន្ទាល់របស់ខ្ញុំគឺនៅត្រង់ការដឹងថា ព្រះគម្ពីរមរមនមាននូវព្រះបន្ទូលរបស់ព្រះ ។ វាបានផ្លាស់ប្ដូរខ្ញុំ ហើយបន្តផ្លាស់ប្ដូរខ្ញុំ ។ ■

ហូសេ អ៊ីវ៉ានីលដូ ម៉ាទីអាស ហ្វេីណានដេស ទីក្រុងសៅ ផាឡូ ប្រទេសប្រេស៊ីល



ពេលក្រោយមក នៅក្នុងឱសថស្ថានមួយកន្លែង ខ្ញុំបានកត់សម្គាល់ឃើញសៀវភៅមួយក្បាលបើកចំហរនៅលើតុមួយ ។ នៅពេលខ្ញុំបាននឹកគិតអំពីពាក្យទាំងឡាយដែលខ្ញុំអាន ខ្ញុំបានដឹងថាគឺមកពីព្រះ ។

រូបភាពគំនូរដោយ



ខ្ញុំពុំដឹងច្បាស់ថានឹងត្រូវចំណាយពេលយូរប៉ុណ្ណាទេ ប៉ុន្តែថ្ងៃមួយ ខ្ញុំអាចនឹងភ្លក់សេចក្តីស្រឡាញ់នៃព្រះម្តងទៀតនៅទីបំផុត ។ វាគឺដូចជាពន្លឺព្រះអាទិត្យដ៏កក់ក្តៅបន្ទាប់ពីរដូវរងារដ៏យូរអង្វែងមួយ ។

# ការស្វែងរកផ្លូវរបស់ខ្ញុំឆ្លងកាត់អ័ព្ទនៃភាពងងឹត

ខ្ញុំបានគិតត្រឡប់ទៅរដូវកាលជាពិសេសដ៏ខ្មៅងងឹតមួយនៃជីវិតរបស់ខ្ញុំកាលពីប៉ុន្មានឆ្នាំមុន ។ ខ្ញុំបានជួបនឹងឧបសគ្គលំបាកៗជាច្រើន ហើយខ្ញុំមានអារម្មណ៍ស្រយុតចិត្ត និងទទួលនូវអារម្មណ៍ដ៏លើសលុបដោយបន្ទុកដ៏ធ្ងន់ ។

នៅព្រះវិហារថ្ងៃអាទិត្យមួយ ខ្ញុំបានក្រឡេកមើលជុំវិញទៅក្រុមគ្រួសារដ៏រីករាយទាំងអស់ដែលច្រៀងទំនុកតម្កើង ហើយទទួលទានសេចក្តីស្រឡាញ់នៃព្រះ ។ ខ្ញុំចង់មានអារម្មណ៍ដូចគ្នានោះដែរ ប៉ុន្តែមានអ្វីមួយដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាខុសប្លែកខាងរាងកាយរបស់ខ្ញុំ ។

ខ្ញុំធ្លាប់មានអារម្មណ៍ពីព្រះវិញ្ញាណកាលពីមុន ប៉ុន្តែខ្ញុំខានមានអារម្មណ៍បែបនោះមួយរយៈហើយ ។ ដូចនៅក្នុងការនិមិត្តរបស់លីហៃអំពីដើមឈើជីវិត ខ្ញុំបានដឹងថា ខ្ញុំដូចជាត្រូវបានរុំព័ទ្ធដោយទាំងស្រុងនៅកណ្តាលភាពងងឹត — ខ្ញុំពុំអាចមើលឃើញដើមឈើឡើយ ( សូមមើលនីហ្វៃទី ១ ៨:២–២៤ ) ។

នៅពេលការអធិស្ឋានសាក្រាម៉ង់បានចាប់ផ្តើម ខ្ញុំបានបិទភ្នែក ហើយបានផ្ចង់ទៅព្រះវរបិតាសួគ៌ទូលអង្វរសុំការបញ្ជាក់នៃសេចក្តីស្រឡាញ់របស់ទ្រង់ ។ ខ្ញុំបានទូលសួរទ្រង់ថាហេតុអ្វីក៏ខ្ញុំពុំអាចភ្លក់ផ្លែឈើនៃដើមជីវិតបានដូច្នេះ ។

នៅពេលខ្ញុំបានសញ្ជឹងគិតអំពីសុបិនរបស់លីហៃ ខ្ញុំបានទទួលការដឹងដោយអានុភាពមួយ ។ ខ្ញុំបានគិតថា « ហេតុអ្វីក៏ខ្ញុំពុំបានចាំអំពីរឿងនេះកាលពីមុនមក ? » ការធ្វើដំណើរនៅកណ្តាលភាពងងឹត គឺជាចំណែកមួយដ៏សាមញ្ញបំផុតនៃផែនការរបស់ព្រះ ។ ទ្រង់ទុកឲ្យយើងមានបទពិសោធន៍ការលំបាកពីមួយគ្រាទៅមួយគ្រាដើម្បីយើងអាចពឹងអាស្រ័យទៅលើទ្រង់ និងព្រះរាជបុត្រារបស់ទ្រង់ទាំងស្រុង ។ គន្លឹះដើម្បីតោងឲ្យជាប់នឹងដំបងដែក ។ ខ្ញុំនៅតែមើលឃើញខ្លួនឯងស្ថិតនៅកណ្តាលភាពងងឹតប៉ុន្តែខ្ញុំមានសេចក្តីសង្ឃឹម ។

នៅពេលអារម្មណ៍នេះចាកចេញពីគំនិតខ្ញុំនោះខ្ញុំបានទទួលអារម្មណ៍នូវការអះអាងដ៏ផ្អែមល្ហែមមកពីព្រះវិញ្ញាណបរិសុទ្ធថា ការលំបាករបស់ខ្ញុំនឹងកន្លងផុតទៅ ។ ព្រះវិញ្ញាណថ្លែងទីបន្ទាល់ថាព្រះវរបិតាសួគ៌ គង់នៅទីនោះ ។ ខ្ញុំបានជូតទឹកភ្នែកពីភ្នែក មានអំណរគុណដែលខ្ញុំអាចទទួលបានព្រះវិញ្ញាណម្តងទៀត ។

ខ្ញុំបានចាប់ផ្តើមដាក់ខ្លួនខ្ញុំទៅក្នុងបទគម្ពីរ ។ ខ្ញុំនៅតែមានថ្ងៃងងឹតងងល់ជាច្រើន ប៉ុន្តែខ្ញុំមានសេចក្តីជំនឿថា បើខ្ញុំតោងជាប់នឹងដំបងដែក — ដែលជាព្រះបន្ទូលនៃព្រះ ( សូមមើល នីហ្វៃទី ១ ១១:២៥ ) — នោះខ្ញុំនឹងបានរួចចេញពីកណ្តាលនៃភាពងងឹត ។ ខ្ញុំពុំដឹងច្បាស់ថានឹងត្រូវចំណាយពេលយូរប៉ុណ្ណាទេ ប៉ុន្តែថ្ងៃមួយ ខ្ញុំអាចនឹងភ្លក់សេចក្តីស្រឡាញ់នៃព្រះម្តងទៀតនៅទីបំផុត ។ វាគឺដូចជាពន្លឺព្រះអាទិត្យដ៏កក់ក្តៅបន្ទាប់ពីរដូវរងារដ៏យូរអង្វែងមួយ ។

នៅពេលខ្ញុំពុះពារនឹងការលំបាកទាំងឡាយនៃជីវិត ខ្ញុំបានចងចាំការសន្យារបស់ខ្ញុំថាត្រូវតោងឲ្យជាប់ទៅនឹងដំបងដែក តាមរយៈការសិក្សាព្រះគម្ពីរ និងប្រសាសន៍របស់ពួកព្យាការី ។ ខ្ញុំដឹងថា នៅពេលស្ថិតនៅកណ្តាលអ័ព្ទនៃភាពងងឹត ខ្ញុំមានវិធីសំខាន់ៗដែលអាចមើលឃើញផ្លូវរបស់ខ្ញុំដើម្បីដើរឆ្លងកាត់វា ហើយមាននូវការសន្យានៃការទទួលយកដ៏កក់ក្តៅមួយនៅឯកន្លែងម្ខាងទៀត ។ ■

យូវ៉ានតា វេស្សានី រដ្ឋកាលីហ្វូញ៉ា ស.រ.អា

រូបភាពលម្អដោយ ស្ទែន ហ្វេឡូ

# អ្នកដឹងហើយថាវាជាការពិត !

នៅថ្ងៃមួយពេលខ្ញុំកំពុងធ្វើការនៅក្នុងផ្សារទំនើបធំមួយ នៅទីក្រុង អូកលែន្ត រដ្ឋកាលីហ្វូញ៉ា ស.រ.អា នោះមានមិត្តម្នាក់បានមកលេង ហើយអញ្ជើញខ្ញុំឲ្យទៅបរិភោគអាហារពេលល្ងាច ។ នាងបាននិយាយថា នាងនឹងមានអ្នកផ្សព្វផ្សាយសាសនាមរមនពីរនាក់មកចូលរួមនឹងយើងផងដែរ ។

បន្ទាប់ពីអាហារពេលល្ងាច អ្នកផ្សព្វផ្សាយសាសនាបានរៀបចំបន្ទះក្ដារស្ដើងមួយ ហើយបានចាប់ផ្ដើមសួរសំណួរខ្ញុំ ។ ខ្ញុំបានមានអារម្មណ៍ខឹងបន្តិច ។ ខ្ញុំគ្រាន់តែចង់ស្ដាប់ពួកគេ រួចហើយចាកចេញទៅ ។

ទោះជាយ៉ាងណាក៏ដោយ នៅចុងបញ្ចប់នៃការពិភាក្សា អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងម្នាក់មកពីរដ្ឋ យូថាហ៍ បានទាញកៅអីរបស់គាត់មកជិត ហើយមើលចំភ្នែកខ្ញុំ រួចហុចព្រះគម្ពីរមរមនមួយក្បាលឲ្យខ្ញុំ ហើយថ្លែងទីបន្ទាល់របស់គាត់ ។ គាត់បាននិយាយថា គាត់ដឹងថាសាសនាចក្រនេះពិត ហើយថាខ្ញុំក៏អាចដឹងផងដែរ តាមរយៈការអានសៀវភៅនេះ ។ បន្ទាប់មកគាត់បានដកស្រង់ពាក្យ មរ៉ូណៃ ១០:៤ ហើយនិយាយថា បើខ្ញុំនឹងសូមសួរដល់ព្រះដោយអស់ពីដួងចិត្ត និងដោយបំណងពិត នោះទ្រង់នឹងបើកសម្ដែងសេចក្ដីពិតនៃសៀវភៅនេះមកដល់ខ្ញុំ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

អំឡុងសប្ដាហ៍បន្ទាប់មក ខ្ញុំអានបានចំនួនពីរបីជំពូក ហើយយើងបានជួបគ្នាម្ដងទៀតនៅផ្ទះមិត្តរបស់ខ្ញុំ ។ បន្ទាប់ពីការពិភាក្សាទីបីរបស់យើង អ្នកផ្សព្វផ្សាយសាសនា មកពីរដ្ឋ យូថាហ៍ បានបញ្ចប់បេសកកម្មរបស់គាត់ ហើយបានត្រឡប់ទៅផ្ទះវិញ ។

ខ្ញុំបានបន្តអាន និងអធិស្ឋានរាល់យប់ ដោយសួរថាតើសៀវភៅនេះពិតឬទេ ។ បន្ទាប់ពីការអធិស្ឋាននៅយប់មួយ ខ្ញុំបានឡើងដេកលើគ្រែ ហើយអានពីរបីជំពូកបន្ថែមទៀត ។ រំពេចនោះ ខ្ញុំបានស្ដាប់ឮសំឡេងមួយថ្លែងនូវពាក្យបួនម៉ាត់ដ៏សាមញ្ញថា ៖ « អ្នកដឹងហើយថាវាជាការពិត ! »

ខ្ញុំពុំដែលឮព្រះវិញ្ញាណថ្លែងមកកាន់ខ្ញុំពីមុនមកនោះទេ ។ ប៉ុន្តែពេលនោះខ្ញុំដឹងថា ព្រះស្គាល់ខ្ញុំ និងស្រឡាញ់ខ្ញុំ ។ ខ្ញុំក៏បានគ្រប់ដណ្ដប់ដោយរឿងនោះ ដែលខ្ញុំពុំអាចទប់ទឹកភ្នែកបានឡើយ ។ ខ្ញុំដឹងថា ខ្ញុំចាំបាច់ត្រូវចូលរួមនឹងសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំក៏យល់ផងដែរ ដែលអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងមកពីរដ្ឋ យូថាហ៍ អាចនិយាយថា គាត់ដឹងថាសាសនាចក្រនេះពិតជាយ៉ាងណានោះ ។

ខ្ញុំបានចូលរួមក្នុងសាសនាចក្រ ហើយក្រោយមកបានរៀបការនឹងយុវនារីដ៏ស្រស់ស្អាតម្នាក់នៅក្នុង

ខ្ញុំបានទទួលយកគម្ពីរ មើលចំភ្នែកគាត់ ហើយបានហុចគម្ពីរត្រឡប់ទៅគាត់វិញ ហើយនិយាយថា « ខ្ញុំដឹងថា គម្ពីរនេះពិត ! »



រូបភាពគំនូរដោយ អេឌែម ហ្វានស៍

ព្រះវិហារបរិសុទ្ធអូកលែន្ត កាលីហ្វូញ៉ា ។ យើងមានកូនប្រាំបីនាក់ ហើយបានរស់នៅក្នុងរដ្ឋកាលីហ្វូញ៉ា អស់រយៈពេល ៣៣ ឆ្នាំមុនពេលផ្លាស់មករដ្ឋ យូថាហ៍ ។

ប៉ុន្មានឆ្នាំមុន នៅពេលកូនស្រីពៅរបស់យើងរៀបចំដើម្បីចេញបេសកកម្មរបស់នាង នាងបានសួរខ្ញុំបើខ្ញុំធ្លាប់ព្យាយាមទាក់ទងនឹងអ្នកផ្សព្វផ្សាយសាសនាវ័យក្មេង ដែលបានបង្រៀនខ្ញុំដែរឬទេ ។

ខ្ញុំបានតបថា « ខ្ញុំធ្លាប់គិតអំពីគាត់អស់រយៈពេលជាច្រើនឆ្នាំមកនេះ ប៉ុន្តែខ្ញុំពុំដឹងថាត្រូវទាក់ទងគាត់តាមរបៀបណាទេ » ។

ក្នុងរយៈពេល ១០ នាទី នាងបានត្រឡប់មកវិញ ហើយនិយាយថា « នេះជាលេខទូរសព្ទរបស់គាត់ » ។

នៅពេលខ្ញុំបានទាក់ទងទៅគាត់ យើងបានមានការសន្ទនាមួយដ៏យូរ ។ គាត់បានសុំអាសយដ្ឋានអ៊ីម៉ែលរបស់ខ្ញុំ ដើម្បីគាត់អាច « ប្រាប់អំពីជីវិតបច្ចុប្បន្នរបស់គាត់ » ។ ស្អែកឡើង នៅក្នុងអ៊ីម៉ែលរបស់គាត់គាត់បានប្រាប់ខ្ញុំថា គាត់ពុំបានធ្វើជាសមាជិកសាសនាចក្រជាង ៤០ ឆ្នាំមកហើយ ហើយសង្ឃឹមថា ខ្ញុំពុំខកចិត្តនោះទេ ។

« តើខ្ញុំអាចនឹងខកចិត្តដោយរបៀបណា ? » ខ្ញុំបានតបអ៊ីម៉ែលរបស់គាត់ភ្លាម ។ « អ្នកបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ ! »

យើងបានឆ្លើយឆ្លងអ៊ីមែលគ្នាជាច្រើនអ៊ីម៉ែល ហើយក៏យល់ព្រមដើម្បីជួបគ្នា ។ ខ្ញុំបានបើកឡានទៅដល់ផ្ទះរបស់គាត់ភ្លាម ជាកន្លែងដែលគាត់អញ្ជើញខ្ញុំឲ្យចូលលេង ហើយណែនាំខ្ញុំឲ្យស្គាល់ភរិយារបស់គាត់ ។ នៅពេលយើងនិយាយអំពីអតីតកាលរបស់យើង ខ្ញុំបានសួរគាត់ ថាតើគាត់នៅមានព្រះគម្ពីរមរមនឬទេ ។ គាត់បានឡើងទៅបន្ទប់ខាងលើ ហើយបាននាំយកគម្ពីរមួយក្បាលមក ។ ខ្ញុំបានយកសៀវភៅ មើលចំភ្នែករបស់គាត់ ហើយបានហុចគម្ពីរត្រឡប់ទៅគាត់វិញ ហើយនិយាយថា ៖ « ខ្ញុំដឹងថា គម្ពីរនេះពិត ។ បើអ្នកអាន ម៉ូរ៉ូណៃ ១០:៤ ហើយអធិស្ឋានអំពីវា អ្នកក៏អាចក៏ទទួលបានទីបន្ទាល់មួយអំពីសេចក្តីពិតរបស់វាផងដែរ » ។

ជាច្រើនឆ្នាំក្រោយមក គាត់បានអាន បានអធិស្ឋាន ហើយបានប្រែចិត្ត ។ មិនយូរប៉ុន្មាន កូនប្រុសអាយុ ១៨ ឆ្នាំរបស់គាត់ បានជ្រមុជទឹកម្តងទៀត ហើយខ្ញុំមានពរដើម្បីធ្វើពិធីបញ្ជាក់ដល់គាត់ ។

ខ្ញុំដឹងថា កូនស្រីរបស់ខ្ញុំត្រូវបានបំផុសគំនិតឲ្យសួរសំណួរ ហើយខ្ញុំដឹងថា ព្រះវរបិតាសួគ៌ បានរៀបចំយើងទាំងពីរនាក់ឲ្យជួបគ្នាឡើងវិញក្នុងរយៈពេល ៤៥ ឆ្នាំ ។ ខ្ញុំបានរៀនអំពីព្រះចេស្តានៃព្រះគម្ពីរមរមន ។ ខ្ញុំក៏បានរៀនផងដែរថា កុំឲ្យបោះបង់ចោលនរណាម្នាក់ដែលបានដើរវង្វេងពីសាសនាចក្រផងដែរ ។ ■

*ហែនរី ( ហែង ) ប្រោណ រដ្ឋយូថាហ៍ ស.រ.អា*

# តើការសិក្សារបស់ខ្ញុំបានគ្រប់គ្រាន់ឬទេ ?

ខ្ញុំបានអានព្រះគម្ពីរមរមនប្រចាំថ្ងៃដោយសេចក្តីជំនឿ ចាប់តាំងពីខ្ញុំនៅជាយុវវ័យមកម្ល៉េះ ។ ទោះជានៅយប់ដែលខ្ញុំដេកលក់ទាំងអស់កម្លាំង ហើយបានដឹងថា ខ្ញុំពុំបានអានព្រះគម្ពីរនៅថ្ងៃនោះ នោះខ្ញុំនឹងលើកគម្ពីរឡើងអានឲ្យបានយ៉ាងហោចណាស់ពីរបីខដែរ ។

ពីរឆ្នាំកន្លងទៅ ខ្ញុំត្រូវបានសុំឲ្យបង្រៀនគម្ពីរសញ្ញាចាស់ នៅក្នុងថ្នាក់សិក្ខាសាលាពេលព្រឹកព្រលឹម ។ ខ្ញុំពុំសូវស្គាល់គម្ពីរសញ្ញាចាស់ដូចគម្ពីរផ្សេងៗទេ ដូច្នេះថ្ងៃខ្លះ ខ្ញុំបានចំណាយពេលបីទៅបួនម៉ោងដើម្បីសិក្សា និងរៀបចំមេរៀនរបស់ខ្ញុំ ។ ដោយសារតែខ្ញុំបានចំណាយពេលច្រើនសិក្សាព្រះគម្ពីរប៊ីប និងវិវរណៈថ្ងៃចុងក្រោយ នោះខ្ញុំបានឈប់អានព្រះគម្ពីរមរមនប្រចាំថ្ងៃ ។ យើងបានអានវាជាគ្រួសារនៅពេលយប់ ហើយខ្ញុំនឹងប្រើវាសម្រាប់សេចក្តីយោងខគម្ពីរម្តងម្កាល ដូច្នេះខ្ញុំមានអារម្មណ៍ថា ខ្ញុំបានសិក្សាដំណឹងល្អប្រចាំថ្ងៃគ្រប់គ្រាន់ហើយ ។

នៅពាក់កណ្តាលឆ្នាំសិក្សានៅខែមករា ប្រធានស្តេករបស់ខ្ញុំ បានសំណូមពរដល់ស្តេកទាំងមូលឲ្យអានគម្ពីរមរមនមួយជំពូកជារៀងរាល់ថ្ងៃ ។ ទោះជាខ្ញុំបានងឿងឆ្ងល់ថា តើខ្ញុំនឹងរកពេលយ៉ាងណាដើម្បីសិក្សាសម្រាប់ថ្នាក់សិក្ខាសាលាដ៏ច្រើនរបស់ខ្ញុំក្តី ក៏ខ្ញុំបានសម្រេចចិត្តថាខ្ញុំគប្បីទទួលយកសំណូមពរនោះដែរ ។ ខ្ញុំចាំបាច់ត្រូវធ្វើវា ពុំគ្រាន់តែដើម្បីពង្រឹងខ្លួនខ្ញុំនោះទេ ប៉ុន្តែក៏ដើម្បីធ្វើជាគំរូដល់កូនៗ និងសិស្សរបស់ខ្ញុំផងដែរ ។

ចាប់តាំងពីគ្រានោះមក ខ្ញុំបានអានព្រះគម្ពីរមរមនមួយជំពូកជារៀងរាល់ថ្ងៃ នៅពេលខ្ញុំចាប់ផ្តើមរៀបចំមេរៀនថ្នាក់សិក្ខាសាលារបស់ខ្ញុំ ឬនៅពេលខ្ញុំហៀបនឹងចូលដេក ។ អារម្មណ៍ និងអំណាចមួយ ដែលខ្ញុំពុំដឹងថាវាបានបាត់បង់ បានត្រឡប់មកក្នុងជីវិតរបស់ខ្ញុំវិញ ។ មេរៀនថ្នាក់សិក្ខាសាលារបស់ខ្ញុំដែលខ្ញុំបានធ្វើយ៉ាងល្អ នោះបានប្រែក្លាយទៅជាកាន់តែល្អប្រសើរឡើង ។ ចំណុចជាច្រើនក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលពិបាកយល់ បានក្លាយទៅជាកាន់តែច្បាស់ឡើងវិញ ។ ខ្ញុំក៏បានដឹងផងដែរថា ខ្ញុំបានយល់ព្រះគម្ពីរមរមនល្អប្រសើរ ជាលទ្ធផលមកពីការសិក្សាដ៏មុតមាំដែលខ្ញុំបានសិក្សាអំពីពួកព្យាការីទាំងឡាយ និងក្រឹត្យវិន័យរបស់ម៉ូសេ ។

អារម្ភកថាអំពីព្រះគម្ពីរមរមន មានរួមបញ្ចូលទាំងពាក្យដកស្រង់នេះ ចេញមកពីព្យាការី យ៉ូសែប ស្ម៊ីធ ៖ « ខ្ញុំបានប្រាប់បងប្អូនទាំងឡាយថាព្រះគម្ពីរមរមន គឺជាគម្ពីរដ៏ត្រឹមត្រូវបំផុតជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនាចក្ររបស់យើង ហើយបុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារធ្វើតាមសិក្ខាបទទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់ » ។

ព្រះគម្ពីរមរមន មាននូវផ្នែកទាំងអស់នៃដំណឹងល្អ ហើយមាននូវទីបន្ទាល់ដ៏មានអានុភាពអំពីព្រះយេស៊ូវគ្រីស្ទ និងផែនការនៃសេចក្តីសង្គ្រោះ ។ វាជួយធ្វើឲ្យអ្វីៗផ្សេងទៀតនៅក្នុងជីវិតរបស់ខ្ញុំ មានន័យ ។ ខ្ញុំមានអំណរគុណចំពោះព្រះគម្ពីរមរមន ជាចំណែកនៃជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ។ ■

*អ៊ែនជី នីកូឡាស រដ្ឋ តិចសាស ស.រ.អា*



**ដោយ អែលឌើរ ប៉ូល ប៊ី ផៃបភើរ**
នៃពួកចិតសិបនាក់

# ភាពពិតដែលបានបើកសម្តែងអំពី **ជីវិតរមែងស្លាប់**

មនុស្សម្នាក់ៗត្រូវបានដាក់នៅលើផែនដីក្នុងស្ថានភាពជាក់លាក់ ។ មិនថាភាពជាក់លាក់របស់យើងដូចម្តេចទេ ព្រះអម្ចាស់បានបើកសម្តែងសេចក្តីពិតអំពីគោលបំណងនៃជីវិតរមែងស្លាប់ដែលអនុវត្តចំពោះយើងទាំងអស់គ្នា ។ ទ្រង់បានបង្រៀនសេចក្តីពិតទាំងនេះដល់ឪពុកម្តាយដំបូងរបស់យើង គឺ អ័ដាម និង នាងអេវ៉ា ហើយបានបញ្ជាក់សារជាថ្មីនៅក្នុងជំនាន់របស់យើង ។

ខ្ញុំយោងសេចក្តីពិតទាំងនេះថាជា « ភាពពិតអំពីជីវិតរមែងស្លាប់ » ។ បើយើងចង់ទទួលពរជ័យពេញលេញបំផុត និងដ៏មានប្រយោជន៍បំផុតមកពីបទពិសោធន៍ជីវិតរមែងស្លាប់របស់យើង នោះយើងត្រូវតែយល់ ហើយឱបក្រសោបភាពពិតដែលបានបើកសម្តែងទាំងនេះ ។ ការមិនយល់ ឬអ្វីដែលអាក្រក់ជាងនោះ ការបដិសេធភាពពិតទាំងឡាយដោយចេតនានឹងនាំមកនូវការប្រើពេលវេលាមិនត្រឹមត្រូវ ប្រើឥតមានប្រសិទ្ធភាព ហើយប្រហែលជាត្រូវវិនាសទាំងស្រុង ។

វាពុំគ្រប់គ្រាន់ទេ បើគ្រាន់តែមកផែនដីនេះទទួលយករូបកាយរមែងស្លាប់ ហើយរស់នៅទីនេះអស់មួយជីវិតនោះ ។ ដើម្បីធ្វើឲ្យពេលវេលាដែលយើងនៅទីនេះមានអត្ថន័យ យើងត្រូវតែរស់នៅ ហើយទទួលពិសោធន៍នូវគោលបំណងនៃជីវិតរមែងស្លាប់ដែលបានតែងតាំងដោយព្រះ — ដោយពេញលេញទាំងមូល និងដោយអស់ពីដួងចិត្ត — ជាជាងត្រូវរំខានដោយរឿងជាច្រើនដែលគួរឲ្យចាប់អារម្មណ៍ សុខស្រួល និងងាយស្រួលនោះ ។

នៅពេល អ័ដាម និង នាងអេវ៉ា ត្រូវបានបណ្តេញចេញពីសួនអេដែន នោះពួកគេបានចូលទៅក្នុងពិភពរមែងស្លាប់មួយ ។ ព្រះអម្ចាស់បានរៀបចំពួកគេដើម្បីទទួលបទពិសោធន៍ជីវិតរមែងស្លាប់របស់ពួកគេ ដោយបង្រៀនពួកគេអំពីភាពពិតទាំងឡាយដែលពួកគេនឹងទទួលពិសោធន៍ ។ ខ្ញុំចង់រំឭកអំពីភាពពិតទាំងបីនេះ ។

នៅពេលខ្ញុំចាប់ផ្តើម ចូរចងចាំថា វិញ្ញាណនៃជីវិតមុនជីវិតរមែងស្លាប់ជាច្រើន ពុំបានទទួលរូបកាយរមែងស្លាប់ទេ ដោយសារពួកគេពុំរក្សានូវសណ្ឋានទីមួយរបស់ពួកគេ ។[១] ពួកគេមានបំណងរារាំងយើងពីការទទួលពិសោធន៍នូវភាពពេញលេញនៃជីវិតរមែងស្លាប់នោះ ។ ពួកគេព្យាយាមរារាំងយើងមិនឲ្យទទួលបទពិសោធន៍ទាំងឡាយ ដែលដឹកនាំយើងទៅកាន់សុភមង្គលដ៏នៅអស់កល្បជានិច្ចរបស់យើង ។

### ភាពពិតទី១ ៖ ការងារជួយយើងឲ្យអភិវឌ្ឍគុណសម្បត្តិ និងអាកប្បកិរិយាសំខាន់សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។

ព្រះមានបន្ទូលទៅអ័ដាមថា « ឯងនឹងបានអាហារស៊ីដោយការបែកញើស ដរាបដល់ឯងត្រឡប់ទៅជាដីវិញ ពីព្រោះយើងបានយកឯងពីដីមក » ( ម៉ូសេ ៤:២៥ សូមមើលផងដែរ លោកុប្បត្តិ ៣:១៩ ) ។ មនុស្សមួយចំនួនបានចាត់ទុកព្រះបន្ទូលរបស់ព្រះអម្ចាស់ថាជាបណ្តាសារចំពោះអ័ដាម និងកូនចៅរបស់លោកដោយសារតែការទទួលទានផ្លែឈើដែលបានហាមឃាត់នោះ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានស្តាប់ឮព្រះបន្ទូលទាំងនេះថាជាការថ្លែងចេញមកពីព្រះវរបិតាជាទីស្រឡាញ់ពន្យល់ដល់យុវជនម្នាក់ និងជាកូនដែលពុំមានបទពិសោធន៍ក្នុងស្ថានភាពធ្លាក់ ជាពិភពរមែងស្លាប់ ដែលកូនប្រុសនោះ នឹងមករស់នៅក្នុងពេលឆាប់ៗនេះ ។

ក៏ដូចជាឪពុកលើផែនដីម្នាក់ ដែលរៀបចំកូនប្រុសដែលនឹងចេញឆ្ងាយពីផ្ទះដែរ ព្រះវរបិតាកំពុងជួយបុរសដំបូងគេរូបនេះ ឲ្យរៀបចំខ្លួនដើម្បីរស់នៅដោយខ្លួនឯងនៅពេលនៅឆ្ងាយពីផ្ទះ ។ ទ្រង់បានពន្យល់ថាការងារគឺជាភាពពិតថ្មីមួយ — ជាភាពពិតអំពីជីវិតរមែងស្លាប់ ។

ព្រះវរបិតាសួគ៌ បានដឹងថា អ័ដាម និង អេវ៉ា នឹងត្រូវពុះពារនឹងធាតុទាំងឡាយនៅលើផែនដីក្នុងពេលឆាប់ៗ ។ វាផ្ទុយគ្នាទៅនឹងបទពិសោធន៍របស់ពួកគេនៅក្នុងសួនច្បារអេដែន ដែលអ្វីៗគ្រប់យ៉ាងត្រូវបានប្រទានឲ្យដល់ពួកគេ នោះជីវិតរមែងស្លាប់នឹងតម្រូវឲ្យមានការខិតខំទាំងខាងរាងកាយ និងខាងសតិអារម្មណ៍ បែកញើស អត់ធ្មត់ ហើយស៊ូទ្រាំដើម្បីរស់នៅ ។

ចូរយើងចៀសវាងពីគំនិត
ខុសឆ្គងនៃការបង្រៀនរបស់មនុស្ស
ហើយតោងជាប់ភាពពិតដែលបើក
សម្តែង ដែលបានប្រទានឲ្យដោយព្រះ
ដើម្បីឲ្យដំណើរជីវិតក្នុងជីវិតរមែង
ស្លាប់របស់យើង មានភាពបរិបូរណ៍
ពេញលេញ និង ពិត ។



ការរៀនធ្វើការ — ដែលជាការបំពាក់បំប៉ន និងការលត់ដំគំនិតរបស់យើង រូបកាយ និងវិញ្ញាណ ដើម្បីអនុវត្ត ផលិត សម្រេច និងរីកចម្រើន — គឺជាគ្រឹះមួយនៃភាពពិតនៃជីវិតរមែងស្លាប់គ្រប់រូប ។ វាគឺជាវិធីមួយដែលយើងប្រែក្លាយដូចជាព្រះ ហើយសម្រេចនូវព្រះរាជបំណងរបស់ទ្រង់នៅលើផែនដី ។ ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ធ្វើការទាំងអស់គ្នា ។ កិច្ចការរបស់ទ្រង់ និងសិរីល្អរបស់ទ្រង់ គឺ « ដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ ១:៣៩ ) ។ ភាពពិតគឺថា ពុំអាចមានសិរីល្អដោយគ្មានការធ្វើការនោះទេ ។

មូលហេតុដ៏ចម្បងមួយដែលបុរសចាំបាច់ត្រូវធ្វើការ គឺត្រូវផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ពួកគេ ។ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » សរសេរពាក្យ « ផ្គត់ផ្គង់ » ថាជាតួនាទីមួយនៃតួនាទីទាំងបី ដែលបានផ្តល់ឲ្យបុរសជាពិសេស ។[២] បុរសម្នាក់ដែលចេះធ្វើការ ហើយផ្គត់ផ្គង់ដល់ខ្លួនឯង មានទំនុកចិត្តថា គាត់អាចរៀបការ ហើយផ្គត់ផ្គង់ភរិយា និងកូនៗ ។

ប៊ីស្សព អេក ដេវីឌ បើតុន ជាអតីតប៊ីស្សពជាអធិបតីនៃសាសនាចក្រ បានមានប្រសាសន៍ ៖ « ការធ្វើការ — ដោយស្មោះត្រង់ និងដោយផលិតភាព — នាំមកនូវភាពសុខដុម និងមានអារម្មណ៍ពីតម្លៃខ្លួន ។ ការខិតខំដោយអស់ពីសមត្ថភាពដែលយើងអាចធ្វើបានដើម្បីមានភាពខ្លួនទីពឹងខ្លួន ដើម្បីផ្គត់ផ្គង់សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់យើងផ្ទាល់ និងអ្នកទាំងឡាយដែលជាគ្រួសាររបស់យើង នោះយើងអាចត្រឡប់ទៅព្រះអម្ចាស់ដោយទំនុកចិត្ត ដើម្បីទូលសួរពីអ្វីដែលយើងនៅខ្វះខាតនៅឡើយ » ។[៣]

សាតាំងត្រៀមខ្លួនជានិច្ចដើម្បីបំផ្លាញព្រះរាជបំណងរបស់ព្រះ ហើយចង់ធ្វើឲ្យបទពិសោធន៍ជីវិតរមែងស្លាប់របស់យើងមិនល្អ ។ ដើម្បីជំទាស់នឹងការសង្កត់ធ្ងន់របស់ព្រះវរបិតាអំពីការធ្វើការ នោះមារសត្រូវបានបញ្ចុះបញ្ចូលមនុស្សជាច្រើននៅជំនាន់របស់យើងថា គោលដៅសំខាន់មួយនៅក្នុងជីវិតនេះគឺកុំធ្វើការ ។ នៅក្នុងសង្គមសព្វថ្ងៃមនុស្សជាច្រើនបានសញ្ជឹងគិតថា ចង់ស្វែងរកការងារដែលឲ្យកម្រៃខ្ពស់ល្អ តែធ្វើការតិច ការវិនិយោគ ឬយុទ្ធសាស្ត្រហិរញ្ញវត្ថុជាច្រើន ដែលឲ្យកម្រៃខ្ពស់ដោយគ្មានការខិតខំ និងកម្មវិធីនានាដែលឲ្យកម្រៃដែលពួកគេចង់បាន ដោយពួកគេមិនចំណាយអ្វីសោះ ។ មនុស្សមួយចំនួនបានព្យាយាមមិនធ្វើការងារដោយការខ្ចីប្រាក់ និងរស់នៅដោយប្រាក់ដែលពួកគេមិនមានបំណងបង់សងវិញនោះ ។ ពួកគេពុំចង់ធ្វើការ ពុំធ្វើគម្រោងថវិការ ហើយពុំសន្សំសម្រាប់អ្វីដែលពួកគេចំណាយនោះទេ ។ ថ្នាក់ដឹកនាំសាសនាចក្របានប្រឹក្សាថា យើងគប្បីធ្វើការចំពោះអ្វីដែលយើងបានទទួល ហើយ « ចៀសវាងពីបំណុល លើកលែងតែសម្រាប់សេចក្តីត្រូវការជាមូលដ្ឋានគ្រឹះបំផុតតែប៉ុណ្ណោះ » ។[៤]

ល្បិចមួយទៀត ដែលមារសត្រូវប្រើនៅក្នុងជំនាន់នេះគឺដើម្បីផ្តោតមហិច្ឆិតាពីធម្មជាតិរបស់មនុស្សឲ្យធ្វើការ ហើយសម្រេចបាននៅក្នុងសកម្មភាពដែលគ្មានន័យ ។ ព្រះបានដាក់នៅក្នុងយុវជននូវបំណងប្រាថ្នាដើម្បីបំពេញ និងសម្រេចកិច្ចការ ដោយបំណងដែលពួកគេប្រើមហិច្ឆិតានេះ ដើម្បីក្លាយទៅជាអ្នកផ្គត់ផ្គង់ស្មោះត្រង់សម្រាប់គ្រួសារ ។ នៅក្នុងយុវវ័យរបស់យើង មហិច្ឆិតានេះ អាចត្រូវបានផ្តោតទៅលើ កន្លែងអប់រំ អត្តពលកម្ម និងការខិតខំដទៃទៀត ដែលជួយបង្រៀនឲ្យមានភាពខ្ជាប់ខ្ជួន ការលត់ដំ និងការងារ ។ ទោះជាយ៉ាងណា សាតាំងនឹងមានបំណងប្រាថ្នាយ៉ាងប្រសព្វដើម្បីគ្រប់គ្រងមហិច្ឆិតា និងការផ្តោតនោះទៅលើពិភពល្បែងវីដេអូដែលស៊ីពេលយ៉ាងច្រើន និងបំផ្លាញមហិច្ឆិតា និងនាំទៅរកការញៀន ។

មិនថាអ្នកលេងល្បែងវីដេអូខ្លាំងប៉ុណ្ណាទេ កិច្ចការដែលស្រមើលស្រមៃ ពុំអាចនាំអ្នកឲ្យមានភាពស្កប់ស្កល់ដែលទាក់ទងនឹងកិច្ចការងារពិតនោះទេ ។ កិច្ចការងារពិត គឺជាការខិតខំ ភាពខ្ជាប់ខ្ជួន ការអត់ធ្មត់ និងការលត់ដំ ដើម្បីសម្រេចបាននូវចំណេះដឹងដែលមានតម្លៃ ធ្វើកិច្ចការដែលត្រូវការធ្វើការដ៏ចាំបាច់ ឬសម្រេចគោលដៅដែលបានដាក់ឲ្យ ។

បើយើងពុំរៀនធ្វើការពេលនៅក្នុងជីវិតរមែងស្លាប់នេះទេ នោះយើងនឹងពុំសម្រេចនូវសក្តានុពលពេញលេញរបស់យើង និងសុភមង្គលនៅក្នុងជីវិតនេះទេ ហើយយើងនឹងពុំអភិវឌ្ឍគុណសម្បត្តិ និងអាកប្បកិរិយាដែលសំខាន់ចំពោះជីវិតអស់កល្បជានិច្ចឡើយ ។

**ភាពពិត ទី២ ៖ តាមរយៈអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច យើងអាចទទួលរាល់ពរជ័យដែលព្រះវរបិតាសួគ៌សព្វព្រះទ័យប្រទានដល់យើង ។**

ព្រះអម្ចាស់បានសន្យានៅក្នុងសម្បថ និងសេចក្តីសញ្ញានៃបព្វជិតភាព ៖

« ដ្បិតអស់អ្នកណាដែលស្មោះត្រង់ ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ ដែលយើងបានពោលដល់ . . . ត្រឡប់ជា . . . ពូជនៃលោកអ័ប្រាហាំ និងជាសាសនាចក្រ និងនគរ និងជាពួករើសតាំងនៃព្រះ ។

« ហើយអស់អ្នកណាដែលទទួលបព្វជិតភាពនេះ ឈ្មោះថា ទទួលយើងដែរ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ

« . . . ហើយអ្នកណាដែលទទួលយើង ឈ្មោះថាទទួលព្រះវរបិតាយើងដែរ

« ហើយអ្នកណាដែលទទួលព្រះវរបិតាយើង ឈ្មោះថាទទួលនគររបស់ព្រះវរបិតាយើងដែរ ហេតុដូច្នោះហើយ គ្រប់អ្វីៗទាំងអស់ដែលព្រះវរបិតាយើងមាន នោះនឹងត្រូវបានប្រទានដល់អ្នកនោះដែរ ។

« ហើយការណ៍នេះ គឺស្របតាមសម្បថ និងសេចក្តីសញ្ញា ដែលជារបស់ផងបព្វជិតភាព » ( គ និង ស ៨៤:៣៣–៣៥, ៣៧–៣៩ ) ។

ព្រះវរបិតាជាទីស្រឡាញ់របស់យើងសព្វព្រះទ័យឲ្យកូនចៅទ្រង់ម្នាក់ៗទទួលបានអ្វីៗទាំងអស់ — ភាពពេញលេញ ជាភាពពេញលេញរបស់ទ្រង់ ។ ដើម្បីទទួលបាននូវភាពពេញលេញនេះ « មនុស្សត្រូវចូលក្នុងរបៀបនៃបព្វជិតភាពនេះ [ មានន័យដល់សេចក្តីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍ ] » ( គ. និង ស. ១៣១:២ ) ។

អាពាហ៍ពិពាហ៍អស់កល្បជានិច្ច និងអ្វីៗទាំងអស់ដែលត្រូវបានគ្រោងឡើងដើម្បីជួយយើងឲ្យរៀន និងទទួលបទពិសោធន៍ គឺជាគន្លឹះដើម្បីទទួល

រាល់ពរជ័យដែលព្រះវរបិតាសួគ៌សព្វព្រះទ័យប្រទានដល់កូនចៅរបស់ទ្រង់ ។ មានតែគ្រួសារមួយ — ដែលមានបុរសម្នាក់ និងស្ត្រីម្នាក់ ដែលរស់នៅដោយសក្ដិសមដើម្បីចូលក្នុងដំណាក់នៃព្រះអម្ចាស់ ហើយត្រូវបានផ្សាភ្ជាប់នឹងគ្នាប៉ុណ្ណោះ — ទើបអាចក្លាយទៅជាសក្ដិសមបាន ។ ពរជ័យពេញលេញនៃបព្វជិតភាពគឺត្រូវបានទទួលរួមគ្នាក្នុងនាមជាស្វាមី និងភរិយា ឬមិនទទួលបានទាំងអស់គ្នា ។

វាគួរឲ្យចាប់អារម្មណ៍ដែលនៅក្នុងសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព ព្រះអម្ចាស់ប្រើកិរិយាសព្ទ *ទទួលបាន* និង *ទទួល* ។ ទ្រង់ពុំប្រើកិរិយាសព្ទ*តែងតាំង* ទេ ។ គឺនៅក្នុងព្រះវិហារបរិសុទ្ធដែលបុរស និងស្ត្រី — ទាំងពីរនាក់ — ទទួលបាន និងទទួលពរជ័យទាំងឡាយ និងអំណាចទាំងបព្វជិតភាពអើរ៉ុន និងបព្វជិតភាពមិលគីស្សាដែក ។ បន្ទាប់ពីគូស្វាមីភរិយាមួយគូបានទទួលពរជ័យទាំងនេះ នៅក្នុងដំណាក់នៃព្រះអម្ចាស់ហើយ វាគឺជាសំខាន់នៅក្នុងជីវិតគេហដ្ឋានរបស់ពួកគេ ដែលពួកគេត្រូវអភិវឌ្ឍចរិតលក្ខណៈ និងអាកប្បកិរិយាបរិសុទ្ធ — ពលិកម្ម និងបម្រើគ្នាទៅវិញទៅមក ស្រឡាញ់គ្នាទៅវិញទៅមកដោយភក្ដីភាពទាំងស្រុង ហើយមានសាមគ្គីភាពនៅក្នុងក្ដីស្រឡាញ់របស់ពួកគេចំពោះគ្នាទៅវិញទៅមក និងចំពោះព្រះ ។

*ភាពពេញលេញ បព្វជិតភាព គ្រួសារ* — ពាក្យទាក់ទងគ្នាទាំងបីនេះគឺជាចំណែកទាំងអស់នៅក្នុងភាពពិតនៃអាពាហ៍ពិពាហ៍អស់កល្បជានិច្ច ។ ការធ្វើអ្វីៗទាំងអស់នៅក្នុងអំណាចរបស់យើងដើម្បីធ្វើឲ្យអាពាហ៍ពិពាហ៍អស់កល្បជានិច្ច មានពិតនៅក្នុងជីវិតរមែងស្លាប់របស់យើង នឹងអះអាងថា យើងនឹងមិនចំណាយពេលរបស់យើងនៅលើផែនដីដោយឥតប្រយោជន៍នោះទេ ។

សាតាំង ជាមេបញ្ឆោត កំពុងធ្វើការនៅក្នុងជំនាន់របស់យើង មួលបង្កាច់ និងបំផ្លាញភាពពិតនៃជីវិតរមែងស្លាប់ ។ វាកំពុងធ្វើការបន្ថែមម៉ោងដើម្បីបំផ្លាញអត្ថន័យ និងសារៈសំខាន់នៃអាពាហ៍ពិពាហ៍នៅក្នុងគំនិតរបស់បុរស និងស្ត្រីទាំងឡាយ ។ ចំពោះមនុស្សខ្លះ វាបញ្ចុះបញ្ចូលថា អាពាហ៍ពិពាហ៍ គឺមិនចាំបាច់ទេ ថាក្ដីស្រឡាញ់គឺល្មមគ្រប់គ្រាន់ហើយ ។ ចំពោះមនុស្សខ្លះទៀត វាប៉ុនប៉ងប្រើនិយមន័យច្បាប់ថ្មីអំពី អាពាហ៍ពិពាហ៍ ដើម្បីឲ្យទទួលស្គាល់ថាទំនាក់ទំនងអសីលធម៌គឺជារឿងត្រឹមត្រូវ ។ ចំពោះអ្នកទាំងឡាយដែលជឿទៅលើអាពាហ៍ពិពាហ៍នៅពេលដែលព្រះបានកំណត់ឡើង នោះវានឹងបន្ទាបអាទិភាពរបស់វាទាក់ទងទៅនឹងការអប់រំ

**អាពាហ៍ពិពាហ៍ អស់កល្បជានិច្ច គឺជាគន្លឹះ ដើម្បីទទួលរាល់ពរជ័យ ដែលព្រះវរបិតាសួគ៌ សព្វព្រះទ័យចង់ប្រទាន ដល់កូនចៅរបស់ទ្រង់ ។**

និងសន្តិសុខខាងហិរញ្ញវត្ថុ ។ វាធ្វើឲ្យមនុស្សមានការភ័យខ្លាច អំពីការលះបង់ និងការពិបាកដែលមាននៅក្នុងអាពាហ៍ពិពាហ៍ ។ ដោយជាប់ស្ទះនឹងភាពភ័យខ្លាច នោះមនុស្សជាច្រើនបានអង្គុយស្ងៀមដូចជាវត្ថុដែលចាំទទួលសកម្មភាព ជាជាងផ្លាស់ទីទៅមុខ ហើយធ្វើសកម្មភាពដោយសេចក្ដីជំនឿ ។

មនុស្សមួយចំនួន ដែលបានមានអារម្មណ៍លើសលុបដោយសារតម្រូវការនៃការស្ថាបនាទំនាក់ទំនងពិត ប៉ុន្តែមានអារម្មណ៍បំណងប្រាថ្នាមួយចង់បានដៃគូ និងភាពស្និទ្ធស្នាលនោះ គឺត្រូវបានបញ្ឆោតដោយក្ដីសង្ឃឹមក្លែងក្លាយនៅក្នុងពិភព



ពុំពិតប្រាកដ ។ ការប៉ុនប៉ងចង់បានភាពស្និទ្ធស្នាលពុំពិតប្រាកដ ពុំនាំមកនូវអ្វី ក្រៅពីភាពទទេស្អាតការចង់បាន និងការខ្មាស់អៀននោះទេ ។ មានមនុស្សជាច្រើនបានខំស្រាវជ្រាវម្ដងហើយម្ដងទៀតដោយគ្មានប្រយោជន៍ រហូតដល់ផ្លូវរបស់ពួកគេបានក្លាយទៅជាការញៀនមួយ ដែលពុំអាចស្កប់ស្កល់បាន ។[៥] ពួកគេត្រូវបានចាប់ជាប់នៅក្នុងវដ្តមួយដែលបំផ្លាញឆន្ទៈរបស់ពួកគេដើម្បីឈរទប់ទល់បន្តិចម្ដង ។ ពួកគេនៅតែមានសិទ្ធិជ្រើសរើសរបស់ពួកគេ ប៉ុន្តែពុំមានសេចក្ដីសង្ឃឹមគ្រប់គ្រាន់ទៅលើសមត្ថភាពដើម្បីតស៊ូនឹងវាឡើយ ។ ដោយត្រូវបានចាប់ជាប់ក្នុងសំណាញ់នេះ នោះពួកគេប្រថុយខ្លួនក្នុងការបាត់បង់ភាពពេញលេញ និងក្ដីអំណរដែលជាភាពពិតដ៏ទេវភាពបំផុតមួយនៃជីវិតរមែងស្លាប់ — ជាអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច ។

បើអ្នកត្រូវជាប់នៅក្នុងសំណាញ់នេះ សូមរកជំនួយ ។ ចូរកុំរង់ចាំឡើយ ។ បើអ្នកចាំ អ្នកនឹងពន្យារពេលការរីកចម្រើន និងការលូតលាស់របស់អ្នកនៅក្នុងជីវិតរមែងស្លាប់នេះហើយ ។

ពិនិត្យលើជីវិតរបស់អ្នក ។ ចូរប្រាកដថា គំនិតរបស់អ្នកនឹងពុំត្រូវគ្របដណ្ដប់ដោយគំនិតខុសឆ្គងដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ។ ចូរចងចាំថាអាពាហ៍ពិពាហ៍ដ៏ជោគជ័យទាំងឡាយ គឺត្រូវស្ថាបនាឡើងនៅលើ « សេចក្ដីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ការគោរពគ្នា សេចក្ដីស្រឡាញ់ សេចក្ដីមេត្តាករុណា ការងារ និង កម្មវិធីកម្សាន្តល្អៗទាំងឡាយ » ។[៦]

សូមចាប់ផ្ដើមថ្ងៃនេះដើម្បីស្ថាបនាលក្ខណៈទាំងឡាយនោះនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នក ។ នៅពេលអ្នកធ្វើដូច្នោះ នោះព្រះអម្ចាស់នឹងបើកផ្លូវឲ្យអ្នកទទួលបានភាពពេញលេញនៃពរជ័យ ដែលទ្រង់បានរៀបចំទុកសម្រាប់កូនចៅរបស់ទ្រង់ — ជាសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍ ។ ចូរកុំឲ្យជីវិតរមែងស្លាប់របស់អ្នក « ត្រូវកំទេចចោលសូន្យឈឹង » ឡើយ ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:៣៩ ) ។

**អ័ដាម និង នាងអេវ៉ា យល់ថា ការបង្កើតកូនចៅ គឺជាភាពពិតដ៏សំខាន់មួយ នៃជីវិតរមែងស្លាប់ ។**

**ភាពពិត ទី៣ ៖ ការបង្កើត និងការចិញ្ចឹមបីបាច់កូនចៅ ជួយយើងឲ្យអភិវឌ្ឍសមត្ថភាពរបស់យើងដើម្បីប្រែក្លាយដូចជាព្រះ ។**

នៅពេលនោះ ទ្រង់ « បានប្រទានពរ » ឬផ្សារភ្ជាប់ អ័ដាម និង នាងអេវ៉ា ឲ្យបង្កើតគ្រួសារដំបូងនៅលើផែនដី[៧] ព្រះបានប្រទានពរដល់ពួកគេនូវបទបញ្ញត្តិមួយ ៖ ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ ( សូមមើលលោកុប្បត្តិ ១:២៨, ម៉ូសេ ២:២៨ ) ។ អាពាហ៍ពិពាហ៍និង កូនចៅទៅជាមួយគ្នា ។ អំណាចនៃការបង្កបង្កើតដែលធ្វើឲ្យមានកំណើតជីវិតរមែងស្លាប់ ត្រូវបានប្រើតែរវាងបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានរៀបការស្របច្បាប់ និងពេញច្បាប់ប៉ុណ្ណោះ ។[៨]

អ័ដាម និង នាងអេវ៉ា យល់ថា ការបង្កើតកូនចៅគឺជាភាពពិតដ៏សំខាន់នៃជីវិតរមែងស្លាប់ ។ ពួកគេបានគោរពតាមបទបញ្ញត្តិរបស់ព្រះ « ហើយអ័ដាមក៏ស្គាល់ប្រពន្ធគាត់ ហើយនាងបង្កើតបានកូនប្រុសកូនស្រីទាំងឡាយ ហើយពួកគេបានចាប់ផ្ដើមបង្កើតកូនជាច្រើនឡើង ហើយមានពាសពេញលើផែនដី » ( ម៉ូសេ ៥:២ ) ។ ពួកព្យាការីនៅក្នុងជំនាន់របស់យើងបានប្រកាសថា « ព្រះបញ្ញត្តិរបស់ព្រះសម្រាប់ឲ្យកូនចៅរបស់ទ្រង់បង្កើតកូនឲ្យចម្រើនជាច្រើនឡើងឲ្យមានពាសពេញលើផែនដីនេះនៅតែឲ្យប្រតិបត្តិនៅឡើយ » ។[៩]

ទោះជាយ៉ាងណាក៏ដោយ ពិភពលោកសព្វថ្ងៃមានមនុស្សជាច្រើនឈប់ជឿថា « កូនចៅជាមរតកមកពីព្រះយេហូវ៉ា » ( ទំនុកដំកើង ១២៧:៣ ) ។

ជាច្រើនឆ្នាំកន្លងទៅ គូស្វាមីភរិយាមួយគូដែលជិតរៀបការនឹងគ្នាបានមកជួបនឹងខ្ញុំ ។ ពួកគេបានសុំដំបូន្មានរបស់ខ្ញុំទាក់ទងនឹងកូនចៅ ។ ខ្ញុំបានរំឭកពួកគេអំពីបទបញ្ញត្តិដែលពួកគេនឹងទទួល



នៅពេលពួកគេត្រូវបានផ្សារភ្ជាប់ ហើយខ្ញុំបានទូន្មានពួកគេថា ពួកគេអាចរក្សាបទបញ្ញត្តិនេះក្នុងការប្រឹក្សាជាមួយព្រះអម្ចាស់ ។ ខ្ញុំបានរំឭកពួកគេថា វាជាបទបញ្ញត្តិមួយដូចជា ដង្វាយមួយភាគក្នុងដប់ ការរក្សាថ្ងៃឈប់សម្រាក និងបទបញ្ញត្តិដទៃទៀត ។ នៅពេលដែលសេចក្ដីសញ្ញាមួយត្រូវបានធ្វើឡើង នោះសំណួរគឺពុំមែនសួរថាតើត្រូវរក្សាវាឬក៏អត់នោះទេ តែត្រូវសួរថាតើត្រូវរក្សាវាតាមរបៀបមួយណា ដែលព្រះអម្ចាស់សព្វព្រះទ័យ និងអនុមតិឲ្យវិញ ។

ខ្ញុំបានមើល ពេលពួកគេបានចាប់ផ្ដើមអាពាហ៍ពិពាហ៍ពួកគេ ។ គាត់នៅរៀនមួយឆ្នាំទៀតដើម្បីបញ្ចប់មហាវិទ្យាល័យថ្នាក់បរិញ្ញាប័ត្រ ហើយនាងនៅសល់មួយឆ្នាំទៀតដើម្បីបញ្ចប់កម្មវិធីថ្នាក់អនុបណ្ឌិត ។ ពួកគេបានទទួលអារម្មណ៍ដឹកនាំថា ឲ្យមានកូនឆាប់ៗ — ទោះជាកំពុងនៅរៀន ហើយពុំមានការងារច្បាស់លាស់ក្ដី ។ វាពុំងាយស្រួល ឬសុខស្រួលទេ ដើម្បីមានកូនឆាប់ៗនោះ ។ គាត់ត្រូវស្វែងរកការងារមួយ ពួកគេត្រូវផ្លាស់លំនៅ ហើយនាងត្រូវបញ្ចប់ការសិក្សារបស់នាង ។ ពួកគេបានប្រឈមនឹងការស្មុគស្មាញ និងការលះបង់ ។ គាត់ត្រូវប្រញាប់មកផ្ទះវិញរាល់ថ្ងៃ ហើយមើលកូនតូចពេលនាងបានបញ្ចប់និក្ខេបបទ និងការបំពាក់បំប៉នផ្ទាល់របស់នាង ។ នាងបានសិក្សា ហើយបានសរសេរនិក្ខេបបទនៅចន្លោះពេលនៃការថែបីបាច់ និងការប្ដូរកន្ទបកូនក្មេង ។

ព្រះអម្ចាស់បានប្រទានពរ ហើយធ្វើឲ្យពួកគេចម្រើនឡើង ។ ខណៈដែលមនុស្សជាច្រើនទៀតបានបាត់បង់ការងារនៅក្នុងពេលសេដ្ឋកិច្ចធ្លាក់ចុះក្នុងឆ្នាំ ២០០៨ គាត់ត្រូវបានគេរក្សាទុក ហើយបានដំឡើងតួនាទី ។ ដោយសារពួកគេរស់នៅដោយសន្សំសំចៃ នោះពួកគេអាចរួចផុតពីបំណុល លើកលែងតែការបញ្ចាំទ្រព្យមួយ ហើយចាប់តាំងពីពេលនោះមក ពួកគេអាចបង់ថ្លៃកម្មវិធីថ្នាក់អនុបណ្ឌិតបានទាំងអស់ដោយគ្មានជំពាក់បំណុលអ្វីទេ ។ តាមបទពិសោធន៍នេះ ពួកគេបានបន្តរៀនមេរៀនដ៏មានតម្លៃ ដែលកើតចេញមកពីភាពជាឪពុកម្ដាយតែប៉ុណ្ណោះ ។ ការបង្កើតកូនចៅពុំងាយស្រួល ឬសុខស្រួលទេ ប៉ុន្តែវាជាបទបញ្ញត្តិមួយ ដែលជួយយើងបានដឹងអំពីពរជ័យពិតនៃជីវិតរមែងស្លាប់ ។

**អំណោយទានដ៏មហិមាមួយ**

ជីវិតរមែងស្លាប់គឺជាអំណោយទានដ៏មហិមាបំផុតមួយដែលព្រះវរបិតាសួគ៌បានប្រទានដល់យើង ។ ទ្រង់ស្រឡាញ់យើង ហើយចង់មានព្រះទ័យឲ្យយើងប្រើអំណោយនេះដោយពេញលេញ និង ទាំងស្រុង ។ មានតែដោយការឱបក្រសោប និងការផ្ដោតទៅលើភាពពិតទាំងឡាយ ដែលព្រះបានបើកសម្ដែងប៉ុណ្ណោះ ទើបយើងអាចបំពេញនូវគោលបំណងទាំងឡាយដែលយើងមកកាន់ផែនដីនេះ ។ សាតាំង ដឹងថាវាពុំអាចធ្វើអ្វីដើម្បីបញ្ឈប់យើងមិនឲ្យទទួលរូបកាយបានទេ ដូច្នេះវាព្យាយាមដើម្បីបង្វែរយើងចេញពីគោលបំណងទាំងឡាយ ដែលត្រូវបានបង្កើតឡើង — ដើម្បីធ្វើការរៀបការ និងបង្កើតកូនចៅ ។

ចូរយើងកុំរស់នៅដោយគ្មានបំណងប្រាថ្នា ហើយដោយគ្មានគោលបំណងឡើយ នៅទីបំផុតយើងនឹងឃើញថា យើងបានចំណាយពេលរបស់យើងនៅលើផែនដី ផ្ដាច់ចេញពីសេចក្ដីពិតដែលបានបើកសម្ដែងអំពីជីវិតរមែងស្លាប់ ដែលសំខាន់ដើម្បីសម្រេចគោលបំណងរបស់យើងនៅទីនេះនោះឡើយ ។ ចូរយើងចៀសវាងពីគំនិតខុសឆ្គងនៃការបង្រៀនរបស់មនុស្ស ហើយតោងជាប់ភាពពិតដែលបើកសម្ដែង ដែលបានប្រទានឲ្យពីព្រះ ដើម្បីឲ្យដំណើរជីវិតក្នុងជីវិតរមែងស្លាប់របស់យើង មានភាពបរិបូរណ៍ពេញលេញ និង ពិត ។ ■

*ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋានមួយ « ភាពពិតអំពីជីវិតរមែងស្លាប់ » បានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់-អៃដាហូ នៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៣ ។ ដើម្បីទទួលបានសុន្ទរកថាពេញលេញ ជាភាសាអង់គ្លេស សូមចូលទៅគេហទំព័រ web.byui.edu/devotionalsandspeeches ។*



**ការសន្យានៃការរីកចម្រើនដ៏នៅអស់កល្បជានិច្ច**

« អ្នកទាំងឡាយដែលពុំរៀបការ ឬ ពុំមានកូនចៅ គឺពុំត្រូវបានឃាត់ឃាំងពីពរជ័យដ៏អស់កល្បជានិច្ច ដែលពួកគេស្វែងរកនោះទេ ប៉ុន្តែឥឡូវនេះ វាហួសពីអ្វីដែលពួកគេអាចធ្វើ ។ យើងពុំដឹងពីរបៀប ឬពេលវេលាដែលពរជ័យនឹងកើតមានជានិច្ចនោះទេ ប៉ុន្តែការសន្យានៃការរីកចម្រើនដ៏អស់កល្ប នឹងពុំត្រូវបានបដិសេធពីបុគ្គលស្មោះត្រង់ ដែលបានចុះ ហើយរក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋណាមួយឡើយ » ។

ប្រធាន បិយដ៏ យេ ផាកកឺ ( ឆ្នាំ ១៩២៤–២០១៥ ) ប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **The Witness** » ***Liahona,*** ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៩៥ ។

**កំណត់ចំណាំ**

១. សូមមើល អ័ប្រាហាំ ៣:២៦, ២៨ ។
២. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *លីអាហូណា*, ខែវិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ១២៩ ) ។
៣. អេក ដេវីឌ បើរតុន « The Blessing of Work, » *Liahona,* ខែ ធ្នូ ឆ្នាំ ២០០៩, ៣៧ ។
៤. នែល អិល អាន់ឌើរសិន « ការមានគារវភាពចំពោះព្រះ គឺជាការចាប់ផ្ដើមនៃប្រាជ្ញា » *លីអាហូណា*, ខែ មករា ឆ្នាំ ២០១៣, ២៦; សូមមើលផងដែរ រ៉ូបឺត ឌី ហែល « Becoming Provident Providers Temporally and Spiritually » *លីអាហូណា*, ខែ ឧសភា ឆ្នាំ២០០៩, ៧–១០ ។
៥. អែលឌើរ រ៉ូបឺត ឌី ហែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ការញៀនគឺជាការស្រេកឃ្លានរបស់មនុស្សខាងសាច់ឈាម ហើយវាពុំអាចស្កប់ស្កល់បានទេ » ( « ការប្រែក្លាយទៅជាអ្នកផ្គត់ផ្គង់ខាងសាច់ឈាម និងខាងវិញ្ញាណ » ទំព័រ ១០ ) ។
៦. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។
៧. សូមមើល យ៉ូសែប ហ្វីលឌិង ស្ម៊ីធ *Doctrines of Salvation,* comp. Bruce R. McConkie, វ៉ុលទី ៣ ( ឆ្នាំ ១៩៥៤–៥៦ ), ១:១១៥, ២:៧១ ។
៨. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។
៩. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។

## បាវចនាម៉្ូឆលឆ្នាំ ២០១៦

*« ហេតុដូច្នេះហើយ អ្នករាល់គ្នាត្រូវតែ*

# ឈានទៅមុខ

### ដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ

*ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប ។ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាខិតខំជឿន ទៅមុខ ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត មើលចុះ នោះព្រះវរបិតា ទ្រង់មានព្រះបន្ទូលដូច្នេះថា ៖ អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច » ( នីហ្វៃទី ២ ៣១:២០ ) ។*

## ពរជ័យនៃការឈានទៅមុខ

### ដោយគណៈប្រធានយុវជនទូទៅ

ការរស់នៅជាសមាជិកស្មោះត្រង់នៃសាសនាចក្រនាំមកនូវពរជ័យដ៏អស្ចារ្យ ។ ប៉ុន្តែនោះពុំមានន័យថា ជីវិតនឹងពុំមានការលំបាកម្ដងម្កាលនោះទេ ។ ការល្បួង មិត្តភក្ដិដែលពុំមានចិត្តស្មោះត្រង់ បញ្ហាក្នុងគ្រួសារ អ្នកអាចនិយាយរៀបរាប់ជាច្រើន ។ មានរឿងជាច្រើនដែលវានឹងព្យាយាមទាញអ្នកឲ្យចេញពីផ្លូវនៃសេចក្ដីសញ្ញា ។

នោះជាមូលហេតុដែលបាវចនាម៉្ូឆលឆ្នាំនេះគឺ « ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ » ( នីហ្វៃទី ២ ៣១:២០ ) មាននូវសារលិខិតដ៏មានអានុភាពដូច្នេះ ។ នៅពេលអ្នកឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ កាន់យ៉ាងខ្ជាប់តាមសេចក្ដីសញ្ញារបស់អ្នក នោះព្រះអាចធ្វើនូវការណ៍ដ៏អស្ចារ្យសម្រាប់អ្នក និងតាមរយៈអ្នក ។ ហើយទ្រង់អាចជួយអ្នកមានអារម្មណ៍នៃសេចក្ដីសង្ឃឹម លួងលោមចិត្ត និងសុខសាន្តនៅក្នុងពេលដំណាលគ្នា ។

វាជាអ្វីមួយដែលព្យាការី យ៉ូសែប ស្ម៊ីធ បានដឹងយ៉ាងច្បាស់ ។ លោកទើបតែមានអាយុ ១៤ ឆ្នាំប៉ុណ្ណោះ ពេលលោកទទួលបានការនិមិត្តដំបូង ។ នៅពេលលោកលុតជង្គង់ចុះអធិស្ឋាននៅក្នុងព្រៃពិសិដ្ឋ លោកត្រូវបានវាយប្រហារដោយថាមពលដែលមើលមិនឃើញមួយ ដែលមានអំណាចដ៏ធំអនេក ដែលវាបានគំរាមកំហែងចង់បំផ្លាញលោកចោល ។ មានតែតាមរយៈការខិតខំដោយអស់ពីសមត្ថភាពរបស់លោក ដើម្បីទទូចអង្វរទៅព្រះទេ ទើបលោកត្រូវបានជួយសង្គ្រោះ ហើយបានទទួលនូវការយាងមកជួបពីព្រះវរបិតា និងព្រះរាជបុត្រា ។



*ស្ទីវិន ជ័បុលយូ អូវិន ប្រធាន ( កណ្ដាល )*
*ដូក្លាស ឌី ហូមស៍ ទីប្រឹក្សាទីមួយ ( ខាងឆ្វេង )*
*អិម យ៉ូសែប ប្រោហ្វ ទីប្រឹក្សាទីពីរ ( ខាងស្ដាំ )*

ក្រោយមកទៀត នៅពេលយ៉ូសែប បានចែកចាយបទពិសោធន៍របស់លោក លោកក៏ត្រូវបានមិត្តភក្ដិ និងអ្នកដឹកនាំក្នុងមូលដ្ឋានសើចចំអកដាក់លោក ( សូមមើលយ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១: ១៥–១៧, ២១–២៦ ) ។ សេចក្ដីបៀតបៀននោះពុំបានបញ្ចប់ឡើយ ហើយនៅទីបំផុត វាបានដកយកជីវិតរបស់លោកនៅរយៈពេល ២៤ ឆ្នាំក្រោយមក ។

ប៉ុន្តែយ៉ូសែប បានឈានទៅមុខដោយក្ដីសង្ឃឹម ហើយលោក



រីករាយដើម្បីធ្វើដូច្នោះនៅក្នុងការបម្រើព្រះអម្ចាស់ ។ នៅពេលលោកបន្តខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ហើយអនុវត្តសេចក្ដីជំនឿដើម្បីធ្វើអ្វីដែលត្រឹមត្រូវ នោះព្រះបានប្រទានពរ ហើយគាំទ្រដល់លោក ។ ហើយទ្រង់នឹងធ្វើដូចគ្នាចំពោះអ្នក ។

ដូច្នេះចូរឈានទៅមុខ ។ តាំងចិត្តរស់នៅតាមដំណឹងល្អ ។ ចូរអ្នកសម្លឹងដោយមុតមាំទៅលើព្រះអង្គសង្គ្រោះជានិច្ច ។ « ដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប » ។ « [ ទទួលទាន ] នូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ » ។ បម្រើនៅក្រោមការដឹកនាំរបស់បព្វជិតភាព ។ ព្យាយាមធ្វើនូវអ្វីដែលព្រះសព្វព្រះទ័យឲ្យអ្នកធ្វើ ។

នៅពេលអ្នកឈានទៅមុខ ធ្វើ និងរក្សាសេចក្ដីសញ្ញាទាំងឡាយនៅលើមាគ៌ានៃជីវិតអស់កល្បជានិច្ច នោះយើងសូមថ្លែងទីបន្ទាល់ថា អ្នកនឹងរកឃើញសុភមង្គល ។ ■

---

# ការឈានទៅមុខ

## ដោយគណៈប្រធានយុវនារីទូទៅ

**តើ**អ្នកធ្លាប់គិត អំពីទីកន្លែងណាដែលអ្នកធ្វើដំណើរទៅ និង ទីកន្លែងណាអ្នកចង់ទៅដល់ដែរឬទេ ? បាវចនាម្ជូឆលឆ្នាំ ២០១៦ គឺ នីហ្វៃទី ២ ៣១:២០ ហើយខគម្ពីរមួយនេះ បានផ្ដល់នូវដំបូន្មានប្រាំពីរចំណុចអំពីទិសដៅនៅក្នុងជីវិតរបស់អ្នក ។

ខាងស្ដាំ ៖ រូបថត ដោយ រូបថត ប៊ូសាត

នៅក្នុងនោះ អ្នកនឹងរកឃើញនូវសេចក្ដីត្រាស់បង្គាប់អំពី *ទិសដៅ សកម្មភាព អាកប្បកិរិយា ការរៀនសូត្រដែលមកពីព្រះ* និង *រង្វាន់ដែលបានសន្យាទុក* ចំពោះកិច្ចខិតខំរបស់អ្នក ។ ចូរមើលពាក្យគន្លឹះមួយចំនួននៅក្នុងខគម្ពីរនេះ ។

ដើម្បី **ឈានទៅមុខ** បញ្ជាក់ប្រាប់ថា អ្នកត្រូវបានសុំឲ្យធ្វើការខិតខំដ៏ពិតមួយទប់ទល់នឹងកម្លាំងជំទាស់មួយចំនួន ។ យើងត្រូវដាក់អានុភាពដើម្បីរស់នៅតាមដំណឹងល្អ ដោយសារយើងត្រូវបានរុំព័ទ្ធដោយការទទឹងផ្ទុយរបស់ពិភពលោក ចំពោះបទបញ្ញត្តិរបស់ព្រះ ។

តើអ្នក**ខ្ជាប់ខ្ជួន**នៅក្នុងព្រះគ្រីស្ទដែរឬទេ ? តើអ្នកស្ថិតនៅក្នុងភក្ដីភាពពុំងាករេចំពោះទ្រង់ដែរឬទេ ?

បើអ្នក « គោរពតាមទ្រង់ » ( សូមមើល យ៉ូហាន ១៥:៤ ) ហើយធ្វើតាមការបង្រៀនរបស់ទ្រង់ នោះអ្នកនៅខ្ជាប់ខ្ជួនដោយពិត ហើយពរជ័យទាំងឡាយនឹងកើតមានមកដល់អ្នកយ៉ាងពិត ។

សេចក្ដី **សង្ឃឹម** របស់អ្នក និង **សេចក្ដីស្រឡាញ់នៃព្រះ និងមនុស្ស**កើនឡើង នៅពេលអ្នកយល់ ហើយ



*បូនី អិល អូស្ការសុន ប្រធាន ( កណ្ដាល )*
*ខារ៉ុល អេហ្វ ម៉ាក់ខន់ឃី ទីប្រឹក្សាទីមួយ ( ខាងឆ្វេង )*
*នៀល អេហ្វ ម៉ារីយ៉ូត ទីប្រឹក្សាទីពីរ ( ខាងស្ដាំ )*

ស្គាល់សេចក្ដីស្រឡាញ់របស់ព្រះដោយផ្ទាល់ ។ ការយល់ដឹងនេះ រីកចម្រើន នៅពេលអ្នក **ទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ** នៅពេលអ្នកអនុវត្តតាមព្រះបន្ទូលរបស់ព្រះគ្រីស្ទនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នកប្រកបដោយការដឹងគុណ និងគោលបំណង ។

ហើយទីបំផុត អ្នកត្រូវតែ**កាន់ខ្ជាប់** ! តើរឿងនោះស្ដាប់ទៅហាក់ដូចជាស្រពាប់ស្រពោន ហើយធុញទ្រាន់ឬ ? តាមពិត ដើម្បី *កាន់ខ្ជាប់* អាចមានន័យថា បន្តទៅមុខដោយសេចក្ដីល្អដែលអ្នកកំពុងធ្វើ — មានភាពខ្ជាប់ខ្ជួននៅក្នុងការខិតខំឈានទៅមុខរបស់អ្នក ។ នៅពេលអ្នកស្ថិតនៅដោយខ្ជាប់ខ្ជួននៅលើមាគ៌ានៃដំណឹងល្អ នោះអ្នកកំពុងកាន់ខ្ជាប់ហើយ ។

តើវាស័ក្ដិសមដែរឬទេ ? បាទ/ចាស ! ព្រះវរបិតាសួគ៌ប្រកបដោយសេចក្ដីស្រឡាញ់របស់យើង សព្វព្រះទ័យឲ្យយើងត្រឡប់ទៅរកទ្រង់វិញ ដើម្បីមាន **ជីវិតអស់កល្បជានិច្ច** ជាមួយទ្រង់ ដោយសារតែទ្រង់ត្រាស់ដឹងថា នោះជាកន្លែងដែលយើងនឹងមានសុភមង្គលពិត យូរអង្វែង និងសេចក្ដីអំណរហួសពីអ្វីដែលយើងអាចនឹកដល់នាពេលនេះទៅទៀត ។ នោះជាមូលហេតុដែលនៅក្នុង នីហ្វៃទី ២ ៣១:២០ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីអ្វីដែលត្រូវធ្វើ ដើម្បីត្រឡប់ទៅរកទ្រង់វិញ ។ យើងអាចធ្វើការនេះដោយមានជំនួយមកពីទ្រង់ ។ ទ្រង់នឹងរៀបចំផ្លូវជានិច្ច សម្រាប់យើងឲ្យធ្វើនូវអ្វីដែលទ្រង់បញ្ជា ។ ■



# នីហ្វៃទី ២ ៣១:២០

*បាវចនាម៉ូធលឆ្នាំនេះ ជួយយើងមើលឃើញរបៀបដែលយើងអាចឈានទៅមុខខណៈពេលដែលកំពុងឈរដោយរឹងមាំ ។*



**កាន់ខ្ជាប់ដរាបដល់ចុងបំផុត**

« ការសាកល្បងដែលព្រះប្រកបដោយសេចក្ដីស្រឡាញ់បានដាក់នៅពីមុខយើង គឺពុំមែនដើម្បីមើលថាយើងអាចស៊ូទ្រាំនឹងការលំបាកនោះទេ ។ វាគឺដើម្បីមើលថា តើយើងអាចស៊ូទ្រាំបានល្អដែរឬអត់ ។ យើងនឹងប្រឡងជាប់ការសាកល្បងតាមរយៈការបង្ហាញថា យើងបានចងចាំទ្រង់ និងចងចាំបទបញ្ញត្តិដែលទ្រង់បានប្រទានដល់យើង » ។

ប្រធាន ហិនរី ប៊ី អារិង ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ « In the Strength of the Lord » *Liahona,* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១៧ ។



**ទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ**

« ដើម្បីទទួលទានមានន័យច្រើនជាងការភ្លក់ ។ ទទួលទានមានន័យថា ក្រេបយកឱជារស ។ យើងក្រេបឱជារសនៃព្រះគម្ពីរ តាមរយៈការសិក្សាព្រះគម្ពីរ នោះក្នុងស្មារតីនៃការរកមើលដោយអំណរអរ និង ការគោរពប្រតិបត្តិដ៏ស្មោះត្រង់ ។ នៅពេលយើងទទួលទានព្រះបន្ទូលនៃព្រះគ្រីស្ទ នោះព្រះបន្ទូល . . . ប្រែក្លាយទៅជាចំណែកដ៏សំខាន់នៃនិស្ស័យរបស់យើង » ។

ប្រធាន រ័សុល អិម ណិលសុន ប្រធាន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ «Living by Scriptural Guidance» *Ensign,* ខែ វិច្ឆិកា ឆ្នាំ ២០០០ ទំព័រ ១៧ ។



**ការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ**

« ខណៈដែលសេចក្ដីសង្ឃឹមទន់ខ្សោយបន្សល់ទុកឲ្យយើងស្ថិតនៅក្រោមអារម្មណ៍ និងព្រឹត្តការណ៍នោះ ‹ ការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ › នាំឲ្យបុគ្គលម្នាក់ៗបានពេញដោយពន្លឺ ។ នោះសេចក្ដីសង្ឃឹមរបស់ពួកគេនឹងត្រូវបានបង្ហាញឡើង ហើយអ្វីៗជាច្រើនក៏ត្រូវបានមើលឃើញដែរ ! . . . ពេលខ្លះនៅក្នុងភាពងងឹតដ៏ខ្លាំងបំផុត នោះគ្មានពន្លឺពីខាងក្រៅទេ — មានតែពន្លឺពីខាងក្នុងមួយ ដើម្បីដឹកនាំ និងធានាអះអាងប៉ុណ្ណោះ » ។

អែលឌើរ នែល អេ ម៉ាក់ស្វែល ( ឆ្នាំ ១៩២៦–២០០៤ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Brightness of Hope » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ។

**អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច**

តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ព្រះវរបិតាបានសន្យានឹងយើងនូវជីវិតអស់កល្បជានិច្ច — ដើម្បីប្រែក្លាយដូចជាទ្រង់ — បើយើងធ្វើនូវរឿងជាក់លាក់ ។ នេះគឺជាបទគម្ពីរខ្លះៗដែលប្រាប់នូវរឿងមួយចំនួនទាំងនោះ ៖

- យ៉ូហាន ៣:១៥; ៦:៥៤
- ម៉ូរ៉ូណៃ ៧:៤៧
- គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២២, ១០១:៣៨, ១៣៣:៦២
- ម៉ូសេ ៦:៥៩

២០ ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវតែឈានទៅមុខ ដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប ។ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាខិតខំជឿនទៅមុខ ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ ដរាបដល់ចុងបំផុត មើលចុះ នោះព្រះវរបិតា ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច ។

**ឈានទៅមុខ**

តើអ្នកចាំបាច់ត្រូវធ្វើអ្វីខ្លះ ខណៈដែលអ្នកឈានទៅមុខនៅលើផ្លូវទៅកាន់ជីវិតដ៏អស់កល្បជានិច្ច ? សូមអាននូវអ្វីដែលមនុស្សនៅក្នុងការនិមិត្តរបស់លីហៃអំពីដើមឈើជីវិតបានធ្វើ ( សូមមើលនីហ្វៃទី ១ ៨:៣០ ) ។ តើអ្នកអាចគិតអំពីគំរូផ្សេងទៀតមកពីបទគម្ពីរឬទេ ?

**ដោយមានចិត្តស្រឡាញ់ព្រះ និង មនុស្សគ្រប់រូប**

« ដោយមានចិត្តស្រឡាញ់ព្រះ និង មនុស្សគ្រប់រូប » គ្របដណ្ដប់នូវបទបញ្ញត្តិធំពីរ ( សូមមើល ម៉ាថាយ ២២:៣៧–៤០ ) ។ ជាពាក្យម៉្យាងទៀតសម្រាប់សេចក្ដីស្រឡាញ់ប្រភេទនេះ អាចជា *សេចក្ដីសប្បុរស* ឬសេចក្ដីស្រឡាញ់សុទ្ធសាធរបស់ព្រះគ្រីស្ទ ( សូមមើល ម៉ូរ៉ូណៃ ៧:៤៧ ) ។

**ភាពខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ**

ភាពខ្ជាប់ខ្ជួនមានន័យថា ឈររឹងមាំ ពុំផ្លាស់ប្ដូរ ។ ភាពខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ មានន័យថាមានសេចក្ដីជំនឿទៅលើទ្រង់ពុំងាករេ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ រួមមានទាំងការទទួល និងការធ្វើពិធីបរិសុទ្ធ ព្រមទាំងការរក្សាសេចក្ដីសញ្ញានានា ។

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅទំព័រនេះពុំមែនមានន័យថា វាពន្យល់ទូលំទូលាយពីចំណេះចំណានខគម្ពីរថ្នាក់សិក្ខាសាលាដែលបានជ្រើសរើសនោះទេ វាគ្រាន់តែជាចំណុចចាប់ផ្ដើមមួយសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ ។*



# ឈានទៅមុខ

ដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ។

នីហ្វៃទី ២ ៣១:២០

# ការរៀនអំពីព្រះវរបិតាសួគ៌ ៖ ការសិក្សាអំពីប្រធានបទសំខាន់ដ៏សម្បើម

អ្នកអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ប៉ុន្តែតើអ្នកធ្លាប់ងឿងឆ្ងល់ថាទ្រង់មានលក្ខណៈយ៉ាងណាឬទេ ? ឬក៏ថាហេតុអ្វីក៏ទ្រង់បានជួយអ្នកឲ្យរកឃើញកូនសោដែលបានបាត់កាលពីថ្ងៃមុនដូច្នេះ ? ឬតើទ្រង់ស្គាល់អ្នកច្បាស់ដល់កម្រិតណា ? ឬតើទ្រង់ទាក់ទងជាមួយអ្នកតាមរបៀបណា ?

ជាសំណាងល្អ វាពុំដែលយឺតពេលទេដើម្បីរៀនកាន់តែច្រើនអំពីព្រះ ។ ឥឡូវនេះ គឺជាឱកាសរបស់អ្នកដើម្បីចាប់ផ្ដើមការសិក្សាអំពីប្រធានបទសំខាន់ដ៏សម្បើម ជាកន្លែងដែលអ្នកនឹងរៀនយ៉ាងច្បាស់អំពីមូលហេតុដែលព្រះនៃសកលលោក — ដែលមានកូនចៅវិញ្ញាណរាប់ពាន់លាននាក់ — គិតអំពីអ្នក ។

ប៉ុន្តែវាអាចនឹងជារឿងលំបាកដើម្បីចាប់ផ្ដើមប្រធានបទសំខាន់ ដូច្នេះចូរឲ្យតារាងនេះជួយអ្នកឲ្យចាប់ផ្ដើម ។ រាល់ថ្ងៃអ្នកអាចរើសយកសំណួរមួយមកពីតារាង ។ នៅពេលអ្នកធ្វើតាមជំហានទាំងឡាយ ហើយឆ្លើយសំណួរ ចូរព្យាយាមគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះវរបិតាសួគ៌ ។ ចូរគិតអំពីតួនាទីរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក ហើយសួរខ្លួនអ្នកនូវអ្វីដែលអ្នកអាចធ្វើ ដើម្បីខិតចូលទៅកាន់តែជិតទ្រង់ ។ ■



**ពេលវេលាដ៏មានអត្ថន័យជាមួយទ្រង់**

« ដើម្បីពង្រឹងទំនាក់ទំនងរបស់យើងជាមួយព្រះ យើងត្រូវការពេលវេលាដ៏មានអត្ថន័យជាមួយទ្រង់ដោយឡែកតែឯង ។ ការយកចិត្តទុកដាក់ដោយស្ងាត់ៗលើការអធិស្ឋានផ្ទាល់ខ្លួន និង ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ មានគោលបំណងដើម្បីឲ្យមានភាពសក្ដិសមកាន់បណ្ណចូលព្រះវិហារបរិសុទ្ធមានសុពលភាពជានិច្ច — នេះហើយគឺជាការវិនិយោគដ៏ឆ្លាតវៃចំពោះពេលវេលារបស់យើង និង ការខិតខំរបស់យើង ដើម្បីខិតចូលចូលកាន់តែជិតព្រះវរបិតាសួគ៌ ។ ចូរឲ្យយើងស្ដាប់នូវការអញ្ជើញនៅក្នុងទំនុកតម្កើង ៖ ‹ ចូរបង្អង់សិន ហើយឲ្យបានដឹងថាយើងជាព្រះ › [ ទំនុកដំកើង ៤៦:១០ ] » ។

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « Of Things That Matter Most » *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ២១ ។

**មេរៀនសម្រាប់ថ្ងៃអាទិត្យ**

ប្រធានបទសម្រាប់ខែនេះ ៖ **ក្រុមព្រះ**

**តើព្រះមានលក្ខណៈដូចម្ដេច ?**

ម៉ាថាយ ៧:៩–១១
យ៉ូហានទី ១ ១:៥
អេធើរ ៣:១២

តើពាក្យមួយណាដែលអ្នកចាប់អារម្មណ៍ ? តើមានពាក្យណាខ្លះដែលថ្លែងម្ដងហើយម្ដងទៀត ? ចូររកមើលវានៅក្នុងវចនានុក្រម ឬសេចក្ដីណែនាំដល់បទគម្ពីរ ។

**តើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ មានភិនភាគដូចគ្នា ប៉ុន្តែជាតួអង្គផ្សេងគ្នាយ៉ាងដូចម្តេច ?**

យ៉ូហាន ៣:១៦, ៣៥

យ៉ូហាន ១៧:២០–២៣

មរមន ៧:៥–៧

ចូររៀបចំមេរៀនរាត្រីជួបជុំក្រុមគ្រួសារ អំពីអ្វីដែលអ្នកបានរៀន ។

**តើខ្ញុំអាចស្គាល់ព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ?**

យ៉ូហាន ១៤:៦–៩
យ៉ូហានទី ១ ៤:៧
អាលម៉ា ៣០:៤៤
គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:២២–២៤

ចូរស្រាវជ្រាវនៅលើ LDS.org រកពាក្យគន្លឹះដែលអ្នកឃើញនៅក្នុងព្រះគម្ពីរ ។ សូមចូលទៅ lds.org/media-library ដើម្បីមើលវីដេអូមួយអំពីប្រធានបទនោះ ។

**មានមនុស្សរាប់ពាន់លាននាក់នៅលើផែនដី ! តើព្រះវរបិតាសួគ៌អាចស្គាល់ខ្ញុំយ៉ាងដូចម្តេច ?**

សាំយ៉ូអែលទី១ ១៦:៧

ទំនុកតម្កើង ៨២:៦

លូកា ១២:៦–៧

គោលលទ្ធិ និង សេចក្តីសញ្ញា ៩៣:២៣

តើគំនិតចម្បងនៅក្នុងខគម្ពីរនិមួយៗមានអ្វីខ្លះ ? ចូរព្យាយាមសង្ខេបវាឲ្យតិចជាងប្រាំពាក្យ ។

**យើងត្រូវបានប្រាប់ឲ្យទូលទៅកាន់ព្រះវរបិតាសួគ៌នៅក្នុងការអធិស្ឋាន ។ ប៉ុន្តែតើព្រះវរបិតាសួគ៌មានបន្ទូលមកកាន់យើងតាមរបៀបណា ?**

គោលលទ្ធិ និង សេចក្តីសញ្ញា ១:៣៨
គោលលទ្ធិ និង សេចក្តីសញ្ញា ៨:២–៣
គោលលទ្ធិ និង សេចក្តីសញ្ញា ៩:៨–៩

តើអ្នកទូលទៅកាន់ព្រះតាមរបៀបណា ? តើអ្នកអាចផ្លាស់ប្តូរអ្វីខ្លះតាមរយៈអ្វី ដែលអ្នកបានរៀន ?

តើអ្នកមានសំណួរអ្វីផ្សេងទៀត អំពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ ឬព្រះវិញ្ញាណបរិសុទ្ធដែរឬទេ ? ចូរសរសេរវាទុក ហើយប្រើវាសម្រាប់ការសិក្សាព្រះគម្ពីរនាពេលអនាគត បន្ទាប់ពីអ្នកលែងមានសំណួរនៅក្នុងតារាងនេះទៀត ។ ហើយចូរកុំភ្លេចថាអ្នកតែងតែអាចប្រើប្រាស់ធនធាននានាដូចជា សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ *ពិតចំពោះសេចក្តីជំនឿ* និង *ប្រកាសដំណឹងល្អរបស់យើង* ដើម្បីរៀនបន្ថែមអំពីអ្វីដែលអ្នកកំពុងតែសិក្សា !



# មរ៉ូណៃ ម្ដាយខ្ញុំ និង មេរៀនមួយសម្រាប់ជីវិតរបស់ខ្ញុំ

*មេរៀននេះចេញមកពីព្រះគម្ពីរមរមន បានជួយខ្ញុំឲ្យដឹងថា ខ្ញុំពុំនៅតែម្នាក់ឯងខាងវិញ្ញាណនោះទេ ។*

ដោយ លូវីសា ហូ

មានរឿងជាច្រើនបានផ្លាស់ប្ដូរសម្រាប់ខ្ញុំ ក្នុងឆ្នាំដែលខ្ញុំឈានចូលដល់វ័យ ១៧ ឆ្នាំ ។ ខ្ញុំបានចូលទៅសាលាថ្មីមួយ ហើយបានបន្តទៅឆ្នាំទីបីនៃថ្នាក់សិក្ខាសាលារបស់ខ្ញុំ ។ មិនគ្រាន់តែប៉ុណ្ណោះ ប៉ុន្តែខ្ញុំក៏មានគ្រូថ្នាក់សិក្ខាសាលាថ្មី ៖ ម្ដាយរបស់ខ្ញុំ ។

តើខ្ញុំបានប្រាប់ថា ខ្ញុំគឺជាសិស្សតែម្នាក់គត់នៅក្នុងថ្នាក់របស់គាត់ដែរឬទេ ? ដោយសារតែសាលារៀនដែលខ្ញុំទៅរៀននោះ ត្រូវជិះរថភ្លើងរយៈពេលមួយម៉ោង ពីកន្លែងដែលខ្ញុំរស់នៅ នោះម្ដាយរបស់ខ្ញុំបានសម្រេចចិត្តដើម្បីបង្រៀនថ្នាក់សិក្ខាសាលាពេលព្រលឹមដល់ខ្ញុំនៅផ្ទះ ដូច្នេះខ្ញុំនឹងអាចទៅរៀនទាន់ម៉ោង ។ ខ្ញុំមានសំណាងល្អដើម្បីមានគាត់បង្រៀនខ្ញុំរាល់ថ្ងៃ ប៉ុន្តែវាក៏រសាប់រសល់ខ្លះៗដែរ ។ ខ្ញុំបានយកចិត្តទុកដាក់ទាំងស្រុងទៅលើគាត់ ហើយជាពិសេសវាលំបាកនៅម៉ោង ៥:៣០ ព្រឹក ។

នៅពេលយើងសិក្សាព្រះគម្ពីរមរមន យើងបានរៀនដល់មរ៉ូណៃ ជាព្យាការីម្នាក់ដែលខ្ញុំពិតជាគោរពសរសើរ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំតែងតែងឿងឆ្ងល់ ៖ ហេតុអ្វីក៏មរ៉ូណៃនៅតែម្នាក់ឯង ? ហេតុអ្វីក៏ព្រះវរបិតាសួគ៌មិនបញ្ជូននរណាម្នាក់ឲ្យនៅជាមួយនឹងលោក ? ហេតុអ្វីក៏លោកពុំរអ៊ូរទាំនៅពេលព្រះអម្ចាស់ទុកឲ្យលោកនៅតែឯងដើម្បីបញ្ចប់ព្រះគម្ពីរមរមន ?



**គេហដ្ឋាន ៖ រោងជាងរៀនសូត្រដំណឹងល្អ**

« កន្លែងមួយដែលយើងព្យាយាមឲ្យបានពោរពេញទៅដោយពន្លឺ និងសេចក្ដីពិតដ៏ល្អបំផុត គឺនៅក្នុងគេហដ្ឋានរបស់យើង ។ . . . ក្រុមគ្រួសារគឺជារោងជាងរបស់ព្រះអម្ចាស់នៅលើផែនដី ដើម្បីជួយយើងឲ្យរៀនសូត្រ និងរស់នៅតាមដំណឹងល្អ ។ យើងកើតមកក្នុងគ្រួសារយើងដោយមាននូវកាតព្វកិច្ចពិសិដ្ឋមួយ ដើម្បីជួយពង្រឹងដល់គ្នាទៅវិញទៅមកខាងវិញ្ញាណ ។

« ក្រុមគ្រួសារដ៏រឹងមាំអស់កល្បជានិច្ច និងគេហដ្ឋានដែលពេញដោយព្រះវិញ្ញាណ ពុំមែនកើតឡើងដោយឯកឯងនោះទេ ។ ពួកគេចាំបាច់ត្រូវខិតខំយ៉ាងខ្លាំង ពួកគេចំណាយពេល ហើយវាតម្រូវឲ្យសមាជិកក្រុមគ្រួសារម្នាក់ៗធ្វើនូវចំណែករបស់គាត់ ឬនាង ។ គេហដ្ឋាននិមួយៗ គឺផ្សេងគ្នា ប៉ុន្តែគ្រប់គេហដ្ឋានដែលមានមនុស្សតែម្នាក់ស្វែងរកសេចក្ដីពិត នោះអាចធ្វើឲ្យមានភាពខុសប្លែក » ។

**ធើរីល អេ អេសក្លីន ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានអង្គការបឋមសិក្សាទូទៅ « ការបំពេញក្នុងគេហដ្ឋានរបស់យើងដោយពន្លឺ និងសេចក្ដីពិត » *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៨ ។**

ព័ត៌មានលម្អិតចេញមកពី *MORONI BURYING THE PLATES,* ដោយ ហ្គែរី អឺណែស ស្មីធ



ម្ដាយរបស់ខ្ញុំបានពន្យល់ថា ដោយសារតែសេចក្ដីសុចរិត និងសេចក្ដីជំនឿរបស់លោកទៅលើព្រះវរបិតាសួគ៌ ទើបម៉ូរ៉ូណៃបានដឹងថា លោកពុំនៅតែម្នាក់ឯងនោះទេ ។ លោកមានព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ដើម្បីជួយលោកឲ្យបញ្ចប់ព្រះគម្ពីរមរមន ។ ពេលនោះខ្ញុំដឹងថា ម៉ូរ៉ូណៃ ពុំត្រូវការនរណាម្នាក់ខាងរូបកាយនៅទីនោះជាមួយលោកទេ ដោយសារលោកបានដឹងថា មានតួអង្គខាងវិញ្ញាណគង់នៅទីនោះ មើលថែដល់លោក ។ លោកបានដឹងថា ព្រះវរបិតាសួគ៌នឹងពុំទុកលោកចោលឡើយ ។

រឿងនោះមានឥទ្ធិពលដ៏ធំចំពោះខ្ញុំ ។ ឥឡូវខ្ញុំដឹងថា នៅពេលណាដែលខ្ញុំគិតថា ខ្ញុំនៅតែម្នាក់ឯង នោះខ្ញុំមិននៅតែម្នាក់ឯងខាងវិញ្ញាណទេ ពីព្រោះខ្ញុំមានដៃគូព្រះវិញ្ញាណបរិសុទ្ធ ដែលជួយខ្ញុំមានអារម្មណ៍កាន់តែជិតនឹងព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទរបស់ខ្ញុំ ។ ខ្ញុំដឹងថា ដរាបណាខ្ញុំមានសេចក្ដីជំនឿ ហើយទុកចិត្តទៅលើព្រះអម្ចាស់ នោះខ្ញុំនឹងពុំដើរតែឯកឯង ទេ ។

មេរៀនដ៏សំខាន់មួយនេះ បានមានអានុភាពលើសេចក្ដីជំនឿ និងទីបន្ទាល់របស់ខ្ញុំអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ ទោះជាខ្ញុំព្រួយបារម្ភអំពីការមានថ្នាក់សិក្ខាសាលានៅផ្ទះក្ដី ក៏ខ្ញុំឥឡូវមានអំណរគុណ ដោយសារវាបានផ្ដល់នូវបទពិសោធន៍រៀនសូត្រជាពិសេសដល់ខ្ញុំជាមួយនឹងម្ដាយខ្ញុំ ។ ■

*អ្នកនិពន្ធរស់នៅក្នុង ប្រទេសសិង្ហបុរី ។*

## គំនិតយោបល់សម្រាប់ការរៀនសូត្រ និង ការរស់នៅតាមដំណឹងល្អនៅក្នុងគេហដ្ឋាន

**កត់ត្រាការបំផុសគំនិតខាងវិញ្ញាណ ។** ការសរសេរនូវចំណាប់អារម្មណ៍របស់អ្នក អាចជួយអ្នកមានការដឹងជាមុនខាងវិញ្ញាណកាន់តែច្រើន រួមទាំងបន្ទាប់ពីអ្នកបានអធិស្ឋាន អានព្រះគម្ពីរ ឬចូលរួមក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។

**ចែកចាយនូវអ្វីដែលអ្នករៀន**មកពីថ្នាក់សិក្ខាសាលា ព្រះវិហារ ការសិក្សាព្រះគម្ពីររបស់អ្នក ឬគំនិតយោបល់ចេញមកពីជីវិតប្រចាំថ្ងៃរបស់អ្នក ។ ការចែកចាយគំនិតយោបល់ជួយពង្រឹងដល់អ្នកដទៃ ។

**រៀបចំរាត្រីជួបជុំក្រុមគ្រួសារ ។** ឧទាហរណ៍ អ្នកអាចសុំឪពុកម្ដាយរបស់អ្នកធ្វើកិច្ចការមួយ ឬគ្រួសារអ្នកអាចនឹងយល់ស្របដើម្បីឲ្យមនុស្សគ្រប់គ្នាអានសុន្ទរកថាសន្និសីទទូទៅមួយ ឬអានព្រះគម្ពីរមួយជំពូក ហើយពិភាក្សាវាជាមួយគ្នានៅក្នុងរាត្រីជួបជុំក្រុមគ្រួសាររបស់អ្នកនៅពេលក្រោយ ។

**រៀនចេញពីជីវិតប្រចាំថ្ងៃ ។** តើស្ថានភាពអ្វីខ្លះដែលតម្រូវឲ្យអ្នកអនុវត្តសេចក្ដីជំនឿ ? តើអ្នកមាននូវឱកាសអ្វីខ្លះ ដើម្បីរក្សាសេចក្ដីសញ្ញារបស់អ្នក ? តើអ្វីៗនៅជុំវិញអ្នក ធ្វើទីបន្ទាល់អំពីព្រះគ្រីស្ទយ៉ាងដូចម្ដេច ?

## តើព្រះគម្ពីរបង្រៀនអ្វីខ្លះ អំពីការរៀនសូត្រដំណឹងល្អ ?

« ផ្ចង់ចិត្តឲ្យបានយោបល់ » ។ — សុភាសិត ២:២

« ព្រះវិញ្ញាណនៃសេចក្ដីពិត . . . នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្ដីពិត » ។ — យ៉ូហាន ១៦:១៣

« ចូររៀននៅក្នុងយុវវ័យរបស់កូនឲ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ » ។ — អាលម៉ា ៣៧:៣៥

« ចូរស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និង ដោយសារសេចក្ដីជំនឿផង » ។
— គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨

# ទីកន្លែងរបស់យើង



## ការទទួលមេដាយយុវនារីរបស់ខ្ញុំ

ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដែលបានទទួលការទទួលស្គាល់ភាពជាយុវនារីរបស់ខ្ញុំ ។ ខ្ញុំមានមោទនភាពដើម្បីនិយាយថា ខ្ញុំរក្សាខ្លួនខ្ញុំឲ្យបរិសុទ្ធ ហើយស្អាតស្អំ ហើយថាខ្ញុំអាចពាក់មេដាយរបស់ខ្ញុំដោយមានមោទនភាព ។ « ឯស្ត្រីគ្រប់លក្ខណ៍ តើអ្នកណានឹងរកបាន ដ្បិតស្ត្រីយ៉ាងនោះមានតម្លៃជាជាងពួកត្បូងទទឹមទៅទៀត » ( សុភាសិត ៣១:១០ ) ។

អង្គការយុវនារី គឺអស្ចារ្យណាស់ ។ វាជួយយុវនារីឲ្យរីកចម្រើន ហើយត្រៀមខ្លួនសម្រាប់អាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធដ៏បរិសុទ្ធ ។ ខ្ញុំមានអំណរគុណដល់ព្រះវរបិតាសួគ៌របស់ខ្ញុំចំពោះអង្គការនេះ ។ តាមរយៈការទទួលបានមេដាយរបស់ខ្ញុំ ខ្ញុំបានបញ្ចប់គោលដៅមួយដែលខ្ញុំបានដាក់នៅក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំដឹងថា ខ្ញុំអាចបន្តធ្វើកិច្ចការល្អរបស់ព្រះអម្ចាស់បានយ៉ាងច្រើន ។

ខាធើរីន ម៉ូរីល្លូ ប្រទេស វ៉េណេស៊ូអេឡា

## ទេពកោសល្យរបស់យើង អាចធ្វើឲ្យពិភពលោកក្លាយជាកន្លែងដ៏ល្អប្រសើរមួយ

ដោយមានជំនួយពីម្ដាយ និងបងស្រីខ្ញុំ នោះខ្ញុំបានគូរគំនូរនៅលើបដានេះសម្រាប់កម្មវិធីកីឡាសមាគមសង្គ្រោះដែលធ្វើឡើងនៅក្នុងស្តេករបស់យើង ។ ម្ដាយរបស់ខ្ញុំបានណែនាំខ្ញុំទៅដល់ប្រធានសមាគមសង្គ្រោះ ដែលគាត់បានសុំឲ្យខ្ញុំធ្វើបដាសម្រាប់ពួកគាត់ ។ ខ្ញុំបានទទួលយកសេចក្តីស្នើរបស់ពួកគាត់ ហើយបានចាប់ផ្ដើមធ្វើការគូសព្រាង ។ តាមរយៈការខិតខំរួមគ្នារបស់គ្រួសារខ្ញុំ និងខ្ញុំ នោះយើងអាចបង្កើតនូវការរចនាសិល្បៈដ៏ស្រស់ស្អាតមួយដែលតំណាងឲ្យបាវចនា « ស្វែងរកភាពថ្លៃថ្នូរនៅក្នុងភាពជាម្ដាយ និងក្ដីអំណរនៅក្នុងភាពជាស្ត្រី » ។

ខ្ញុំដឹងថា បើយើងប្រើទេពកោសល្យរបស់យើងដើម្បីបម្រើដល់មនុស្សដទៃ នោះយើងពុំគ្រាន់តែនាំសុភមង្គលដល់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែយើងក៏អភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនរបស់យើងផងដែរ ។ ព្រះអម្ចាស់ប្រទានពរដល់អ្នកទាំងឡាយណា ដែលប្រើអំណោយទានរបស់ពួកគេមកពីទ្រង់ដើម្បីស្ថាបនានគររបស់ទ្រង់ ។ ដូចជារឿងប្រៀបធៀបអំពីប្រាក់បង្រៀនថា បើយើងពុំចែកចាយអំណោយទានរបស់យើងជាមួយអ្នកដទៃ នោះយើងនឹងបាត់បង់អំណោយទានទាំងឡាយនោះ ( សូមមើល ម៉ាថាយ ២៥:២៤–២៩ ) ។ ប៉ុន្តែបើយើងប្រើទេពកោសល្យរបស់យើងសម្រាប់ការណ៍ល្អ នោះយើងអាចធ្វើឲ្យពិភពលោកក្លាយទៅជាកន្លែងដ៏ល្អប្រសើរមួយ ។

វ៉ានេសា ផាមីតាន ប្រទេសហ្វីលីពីន



## អ្វីដែលអ្នកអាចរៀនមកពីកាតព្វកិច្ចចំពោះព្រះ



ដោយចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនានានៅក្នុងកូនសៀវភៅ *ការបំពេញកាតព្វកិច្ចរបស់ខ្ញុំចំពោះព្រះ* នោះវាតម្រូវឲ្យមាននូវដួងចិត្តទាំងមូលរបស់អ្នក ការលះបង់ កម្លាំង និងលើសអ្វីៗទាំងអស់ គឺសេចក្ដីជំនឿរបស់អ្នក ។ កាតព្វកិច្ចចំពោះព្រះគឺពិតជាបំផុសគំនិតណាស់ ។

ក្នុងនាមជាយុវជនមួយរូប អ្នកអាចរៀនអំពីការណ៍យ៉ាងអស្ចារ្យ ដែលអ្នកអាចអនុវត្តនៅពេញមួយជីវិតរបស់អ្នក ដោយការបំពេញតាមគោលដៅនៅក្នុងកូនសៀវភៅកាតព្វកិច្ចចំពោះព្រះ ៖ ខាងវិញ្ញាណ ខាងសាច់ឈាម ខាងរូបកាយ និងអ្វីផ្សេងជាច្រើនទៀត ។

ខ្ញុំអាចនិយាយថា វាមានតម្លៃក្នុងការខិតខំលះបង់ខ្លួនអ្នកដើម្បីសម្រេចនូវគោលដៅទាំងនេះ ។ ខ្ញុំបានរៀនធ្វើជាមនុស្សកាន់តែប្រសើរជាងមុន ខ្ញុំបានរីកចម្រើននៅក្នុងទីបន្ទាល់អំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយខ្ញុំបានត្រៀមខ្លួនកាន់តែល្អប្រសើរដើម្បីទទួលបព្វជិតភាពមិលគីស្សាដែក ។ វាស្កប់ស្កល់ដល់ចិត្ត ពេលដែលដឹងថា ខ្ញុំនឹងអាចធ្វើជាគំរូល្អសម្រាប់កូនចៅនាពេលអនាគតរបស់ខ្ញុំនៅថ្ងៃមួយ ដោយសារខ្ញុំបានសម្រេចនូវគោលដៅដ៏អស្ចារ្យ និងសំខាន់នេះ ។

ចូណាថាន អាហ្គូឡូ ប្រទេស វ៉េណេស៊្វេអេឡា

## បេសកកម្ម គឺល្អប្រសើរជាងអ្វីដែលបានរំពឹងទុក

ក្នុងនាមជាយុវនារីម្នាក់ ខ្ញុំទន្ទឹងរង់ចាំថ្ងៃដែលខ្ញុំនឹងបម្រើបេសកកម្មពេញម៉ោង ។ ទីបំផុត នៅពេលខ្ញុំបានចូលក្នុងតំបន់បេសកកម្ម ខ្ញុំបានឃើញថា ការបម្រើបេសកកម្មគឺពុំមែនជាអ្វី ដែលខ្ញុំបានរំពឹងទុកនោះទេ — វាល្អប្រសើរជាង ។ វាពិតជាពិបាកជាងអ្វីដែលខ្ញុំបានគិតទុក ប៉ុន្តែភាពស្កប់ស្កល់ក្នុងចិត្ត ដែលបានមកពីការធ្វើនូវអ្វីដែលព្រះអម្ចាស់បានសុំពីខ្ញុំ គឺពុំអាចថ្លែងបាននោះទេ ។

ខ្ញុំពុំធ្លាប់មានបទពិសោធន៍នូវក្ដីអំណរក្នុងការជួយដល់មនុស្សម្នាក់ឲ្យចូលរួមក្នុងព្រះវិហារពីមុនមកទេ ។ ខ្ញុំពុំធ្លាប់មានអារម្មណ៍ត្រេកអរដើម្បីស្ដាប់ឮនរណាម្នាក់និយាយថា « ប្រាកដណាស់ សូមចូលមក » ដើម្បីពួកគេអាចស្ដាប់ឮដំណឹងល្អដែលបានស្ដារឡើងវិញពីមុនមកទេ ។ ខ្ញុំពុំធ្លាប់បានដឹងពីភាពពិតនៃព្រះចេស្ដាដែលកើតមកពេលយើងប្រកាសអំពីការប្រែចិត្តពីមុនមកទេ ។ ខ្ញុំពុំធ្លាប់អធិស្ឋានដោយបំណងពិតពីមុនមកនោះទេ ។ ខ្ញុំពុំធ្លាប់បានសិក្សាព្រះគម្ពីររយៈពេលមួយម៉ោង ដែលពេលវេលាមួយម៉ោងនោះ បានកន្លងផុតទៅយ៉ាងលឿនដូច្នោះពីមុនមកនោះទេ ។ ខ្ញុំពុំដែលធ្លាប់ស្រក់ទឹកភ្នែកដោយសារតែបានដឹងពីភាពមិនល្អឥតខ្ចោះរបស់ខ្ញុំពីមុនមកទេ ។ ខ្ញុំពុំធ្លាប់មានបទពិសោធន៍ស្រងាកចិត្ត នឹងពាក្យថា « អែលឌើរ សូមកុំមកផ្ទះខ្ញុំម្ដងទៀត » ពីមុនមកនោះទេ ។ ខ្ញុំពុំធ្លាប់ដើរដល់ពងជើងដែលមានទំហំធំប៉ុនមេដៃរបស់ខ្ញុំពីមុនមកទេ ។ ខ្ញុំពុំធ្លាប់ទទួលអារម្មណ៍ថាត្រូវបានការពារយ៉ាងខ្លាំងពីមុនមកទេ ។ ខ្ញុំពុំធ្លាប់មានអារម្មណ៍ថាមានការទទួលខុសត្រូវយ៉ាងខ្លាំងចំពោះសកម្មភាពរបស់ខ្ញុំ ដោយសារតែខ្ញុំពាក់ស្លាកឈ្មោះ « ព្រះយេស៊ូវគ្រីស្ទ » នៅលើទ្រូងរបស់ខ្ញុំពីមុនមកទេ ។

ខ្ញុំពុំធ្លាប់បានទៅជិតនឹងព្រះវរបិតាសួគ៌របស់ខ្ញុំដូចពេលខ្ញុំមាននៅក្នុងបេសកកម្មពេញម៉ោងរបស់ខ្ញុំពីមុនមកទេ ។

ណាហូល កាប្រាណេស ប្រទេសពេរ៉ូ

ផ្នែកលើខាងឆ្វេង និងខាងស្ដាំ ៖ រូបភាពគំនូរដោយ ដាវីឌ ម៉ាឡាន



**អែលឌើរ**
**នែល អិល អាន់ឌើរសិន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

# របៀបដើម្បីឈានទៅមុខ

ឈា*នទៅមុខ* មានន័យលើសពីការណ៍គ្រាន់តែឆ្ពោះទៅមុខដោយសាមញ្ញទៅទៀត ។ *ឈាន* មានន័យថា មានអ្វីមួយដែលរារាំងការបោះជំហានទៅមុខរបស់អ្នក ហើយអ្នកត្រូវតែរុញឲ្យឆ្លងកាត់វា ។ ដើម្បីឆ្ពោះទៅមុខនៅក្នុងជីវិតនេះ អ្នកត្រូវតែ រុញការល្បួងចេញឈានទៅមុខឆ្លងកាត់ឧបសគ្គ ជាន់ភាពសង្ស័យ និងភាពភ័យខ្លាចឲ្យនៅក្រោមជើងអ្នក និង ឱបក្រសោបយកគុណធម៌ដ៏ទេវភាព នៃសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ ។

តើអ្នកអាចឈានទៅមុខដោយរបៀបណា ? នីហ្វៃបានឆ្លើយថា « ហេតុដូច្នេះហើយ អ្នករាល់គ្នាត្រូវតែឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប » ( នីហ្វៃទី ២ ៣១:២០ ) ។

ឈានទៅមុខដោយភាពខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ មានន័យថា ការមានសេចក្ដីជំនឿទៅលើទ្រង់ ។ វាមានន័យថា ការធ្វើឲ្យទ្រង់សំខាន់បំផុតនៅក្នុងការផ្ដោតគំនិត និងសកម្មភាពទាំងឡាយរបស់អ្នក ។ នៅពេលអ្នកធ្វើតាមទ្រង់ នោះការឈានទៅមុខគឺជាដំណើរដ៏ធំបំផុត ។

ការឈានទៅមុខមានន័យថា ការរុញចេញ នូវ « ការល្បួង និងការបារម្ភទាំងឡាយ » នៃលោកិយ ហើយកាន់តាមបទបញ្ញត្តិទាំងឡាយ ដោយត្រឹមត្រូវបំផុត ។ ព្រះយេស៊ូវមានព្រះបន្ទូលថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ » ( យ៉ូហាន ១៤:១៥ ) ។

នីហ្វៃបានបន្ថែមថា ដោយការខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទរបស់យើង នោះនាំឲ្យមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប ។ សេចក្ដីសង្ឃឹមញញឹមយ៉ាងស្រស់នៅចំពោះមុខយើង ។ យើងរកឃើញសេចក្ដីសុខសាន្ត ទោះជានៅក្នុងគ្រាលំបាកក្ដី ។ ភាពជាសិស្សអនុញ្ញាតឲ្យយើងមើលឃើញគោលបំណងពិតរបស់យើងនៅលើផែនដីនេះ ។ គោលបំណងទាំងនេះ ផ្ដោតសំខាន់បំផុតនៅក្នុង ការជួយក្រុមគ្រួសាររបស់យើង មនុស្សដែលយើងស្រឡាញ់ និងអ្នកទាំងឡាយដែលនៅជុំវិញយើង ។ វារួមមានទាំង ការស្ដាប់បង្គាប់របស់ព្រះ ហើយនៅពេលយើងធ្វើដូច្នោះ នោះយើងនឹងប្រែក្លាយទៅជាមនុស្សដែលយើងគប្បីប្រែក្លាយ ។

នីហ្វៃប្រាប់យើងថា យើងត្រូវឈានទៅមុខ ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ។ ទ្រង់មានព្រះបន្ទូលប្រាប់យើងថា ដោយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចនិយាយ ( និងយល់ ) ភាសានៃពួកទេវតា ( សូមមើល នីហ្វៃទី ២ ៣២:២–៥ ) ។ ខ្ញុំស្គាល់សំឡេងនេះ ។ វាគឺជាសំឡេងមួយដែលយើងត្រូវតែត្រៀមខ្លួនជាបន្តបន្ទាប់ យ៉ាងស្រេចបាច់ដើម្បីស្ដាប់ ។

នៅពេលអ្នកឈានទៅមុខដោយសេចក្ដីសុចរិត នោះព្រះយេស៊ូវគ្រីស្ទ « នឹងដឹកនាំអ្នករាល់គ្នា » ( គ. និង ស. ៧៨:១៨ ) ហើយអ្នកនឹងដឹងកាន់តែជាក់ច្បាស់ជាងមុនអំពីភាពពិតរបស់ទ្រង់ និងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះអ្នក ។ នៅពេលអ្នកឈានទៅមុខនៅក្នុងសេចក្ដីជំនឿ នោះព្រះវិញ្ញាណបរិសុទ្ធនឹងប្រាប់អ្នក ហើយបង្ហាញដល់អ្នកនូវរឿងទាំងឡាយដែលអ្នកគួរធ្វើ ( សូមមើល នីហ្វៃទី ២ ៣២:៥ ) ។ ■

*ដកស្រង់ចេញមកពីសុន្ទរកថាមួយដែលត្រូវបានផ្ដល់នៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ — រដ្ឋហាវ៉ៃ កាលពីថ្ងៃទី ១៤ ខែ ធ្នូឆ្នាំ ២០១៣ ។*



## តើអ្នកបានអនុវត្តគោលការណ៍នេះដោយរបៀបណា ?

គម្ពីរដែលខ្ញុំចូលចិត្តគឺ ម៉ាកុស ៤:៣៩ ពីព្រោះព្រះអង្គសង្គ្រោះមានបន្ទូលប៉ុន្មានម៉ាត់នេះ ៖ « ចូរស្ងៀមទៅ ហើយឈប់ចុះ » ។ ដូចជាពួកសិស្សដែលបានវង្វេងនៅក្នុងព្យុះដ៏អាក្រក់ដែរ ខ្ញុំបានឃើញថា ខ្លួនខ្ញុំបានវង្វេងនៅក្នុងសេចក្ដីវេទនា ដោយគ្មានសង្ឃឹមថាអាចរត់គេចបានឡើយ ។ ការណ៍នោះអាចកើតមានឡើងចំពោះមនុស្សគ្រប់គ្នា ។ ប៉ុន្តែខ្ញុំបានរៀនថា ព្រះអង្គសង្គ្រោះ អាចរម្ងាប់ព្យុះពិតដោយមានបន្ទូលនូវពាក្យសាមញ្ញទាំងនោះ ។ បើទ្រង់អាចរម្ងាប់ព្យុះពិតមួយបាន នោះខ្ញុំបានស្កប់ចិត្តដើម្បីដឹងថា បើខ្ញុំដាក់ការទុកចិត្តរបស់ខ្ញុំទៅលើទ្រង់ នោះទ្រង់អាចរម្ងាប់ព្យុះនៃជីវិតប្រចាំថ្ងៃទាំងឡាយបាន ។

***អានីកា ដឹបបលយូ អាយុ ១៨ ឆ្នាំ***
***យូថាហ៍ សហរដ្ឋ ស.រ.អា***

ព័ត៌មានលម្អិតមកពី *HOLD ON TIGHT* ដោយ លីស ល៉ីមុន ស៊្វីនឌល

# ចំទៅនឹងគោលដៅ

## មិត្ត របស់ខ្ញុំ បាន ឃ្លាតឆ្ងាយពី សាសនាចក្រដោយសារតែ អ្នកដទៃសើចចំអក ។ តើខ្ញុំ គួរតែធ្វើយ៉ាងដូចម្ដេច ?

ដំណោះស្រាយដ៏ល្អបំផុតដើម្បីធ្វើនៅក្នុងស្ថានភាពនោះគឺ ៖ ( ១ ) មានចិត្តល្អ ស្រឡាញ់ និងទទួលយកមិត្តរបស់អ្នក ហើយ ( ២ ) មិនត្រូវមានចិត្តរារែកនៅក្នុងទីបន្ទាល់របស់អ្នកទេ ។

បើអ្នកអនុវត្តដំណោះស្រាយទាំងនេះ នោះមិត្តរបស់អ្នកនឹងមានអារម្មណ៍ដឹងពីក្ដីស្រឡាញ់របស់អ្នក ហើយទទួលយក និងចង់នៅជិតអ្នកដោយក្ដីសង្ឃឹម ។ ហើយសូមសង្ឃឹមថាគាត់នឹងមើលឃើញថា ការចំអក និងរិះគន់នោះ គឺជារឿងដ៏អាក្រក់ ហើយថាមនុស្សដែលគាត់សរសើរហើយរាក់ទាក់ នឹងមិនវាយប្រហារដល់ជំនឿរបស់មនុស្សម្នាក់ទៀតតាមរបៀបនោះទេ ។

គំរូរបស់អ្នកអាចជាពំនឹងដ៏ល្អបំផុតមួយដែលមិត្តរបស់អ្នកអាចមាន ។ សូមធ្វើឲ្យដូចជាមនុស្សដែលនៅក្នុងសុបិនរបស់លីហៃ ដែលទទួលទានផ្លែឈើនៃជីវិត ហើយដែលត្រូវបានចំអកដោយមនុស្សដែលនៅលើអគារដ៏ធំ និងទូលាយ ប៉ុន្តែ « ឥតយកចិត្តទុកដាក់ដល់គេឡើយ » ( នីហ្វៃទី ១ ៨:៣៣ ) ។ បើមិត្តរបស់អ្នកមើលឃើញថា អ្នកលើកកម្ពស់ដល់ជំនឿរបស់អ្នក ហើយទប់ទល់ចំពោះការចំអករបស់អ្នកដទៃដោយសេចក្ដីថ្លៃថ្នូរ ការគោរព និងការលេងសើចក្នុងន័យល្អៗ នោះគាត់អាចមើលឃើញថា វាអាចទៅរួចសម្រាប់គាត់ដើម្បីធ្វើដូចគ្នានេះដែរ ។ បើសិនជាគាត់នៅតែមានគ្រាប់ពូជនៃទីបន្ទាល់មួយនៅក្នុងដួងចិត្តរបស់គាត់ នោះគំរូដែលអ្នកបានធ្វើ និង ទីបន្ទាល់ដែលអ្នកបានថ្លែង អាចនឹងជារឿងមួយចំនួនដែលជួយគាត់ឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណ ហើយចងចាំនូវអ្វីដែលគាត់ធ្លាប់បានស្គាល់ម្ដងរួចទៅហើយនោះ ។ ■



## តើសាសនាចក្រមាន គោលជំហរយ៉ាងដូចម្ដេច ចំពោះ ការលេងល្បែងស៊ីសង ?

សាសនាចក្រ ប្រឆាំងនឹងការលេងល្បែងស៊ីសងគ្រប់ប្រភេទ រួមទាំងការចាក់ឆ្នោត ( សូមមើល *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ ឆ្នាំ ២០០៧ ] ចំណុច ២១.១.១៩ ) ។ មូលហេតុដែលយើងត្រូវបានទូន្មានកុំឲ្យចំណាយពេលវេលា និងប្រាក់កាក់ជាអសារឥតការ លើរឿងនេះ គឺសាមញ្ញណាស់ ៖ « ការលេងល្បែងស៊ីសងគឺជារឿងខុស ។ . . . វាធ្វើឲ្យញៀន និងអាចនាំឲ្យបាត់បង់ឱកាស បំផ្លាញជីវិត និងបំបែកបំបាក់ក្រុមគ្រួសារ ។ វាគឺជាការខុសឆ្គងដែលជឿថា អ្នកអាចទទួលបានអ្វីមួយដោយទទេៗ » ( *ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ៤០ ) ។ ■

# សូមទុកឲ្យព្រះ
# ធ្វើជាស្ថាបត្យកររបស់អ្នក

*ជីវិតរបស់អ្នកអាចប្រែក្លាយកាន់តែល្អប្រសើរ ជាងអ្វីដែលអ្នកអាចនឹកស្រមៃដល់ទៅទៀត ។*

**ដោយ ដេវីឌ ឌីកសុន**
ទស្សនាវដ្ដី សាសនាចក្រ




អ្នកអាចឆ្លងកាត់ការសាកល្បងជាច្រើននៅក្នុងជីវិតដោយស្វែងរកដំណោះស្រាយនានា នៅពេលអ្នកជួប នៅតាមផ្លូវជីវិតនោះ ។ ទោះជាមានន័យថា ជាការមិនយកចិត្តទុកដាក់ដោយល្អិតល្អន់ចំពោះការណែនាំ ដែលសរសេរអំពីរបៀបផ្គុំគ្រឿងសង្ហារឹម ដែលមានរាប់លានបំណែក ឬការបង្រៀនខ្លួនអ្នកឲ្យចេះលេង ឧបករណ៍តន្ត្រីដោយការគោះចុចខ្ទង់ណាក៏បានឲ្យតែឮសំឡេងពិរោះក្ដី ក៏សមត្ថភាពរបស់ អ្នកដើម្បីរៀននៅក្នុង ការសាកល្បង និងកំហុសឆ្គង គឺពិតជាគ្មានដែនកំណត់ទេ ។

មានតែរឿងមួយគត់គឺថា ជាធម្មតា វាពុំងាយស្រួលតាមរបៀបនោះទេ ។

សូមស្រមៃអំពីអ្វីមួយដែលពិតជាស្មុគស្មាញ ។ ចុះបើអ្នកមានភារកិច្ចដឹកនាំក្នុងការសង់ផ្ទះផ្ទាល់ខ្លួនរបស់អ្នក ហើយមានសម្ភារទាំងអស់ដាក់នៅខាងមុខអ្នក ។ តើអ្នកអាចមើលស្រមៃឃើញគំនរសម្ភារដ៏ធំឬទេ ? មានក្ដារ ដែកគោល ទុយោទឹក ខ្សែភ្លើង ឧបករណ៍នានា និងអ្វីៗផ្សេងទៀតដែលអ្នកត្រូវការដើម្បីសង់ផ្ទះដ៏ប្រណីតមួយ សម្រាប់អ្នកផ្ទាល់ និងគ្រួសាររបស់អ្នក ។

តើអ្នកនឹងនៅតែចង់សង់វាដោយមិនបានគ្រោងទុកជាមុនឬ ? ឬតើអ្នកនឹងចង់បានជំនួយពីនរណាម្នាក់ ដែលពិតជាដឹងអំពីរបៀបប្រើសម្ភារទាំងអស់នោះដែរឬទេ ?

ផ្លូវជីវិតរបស់យើង គឺដូចគ្នា ។ យើងទាំងអស់គ្នាត្រូវការជំនួយដើម្បីស្ថាបនាជីវិតរស់នៅរបស់យើង ។ ហើយ គ្មានជាងសំណង់ណាប្រសព្វជាងព្រះនោះទេ ។

រចនារូបភាពដោយ ប្រាយអិន ប៊ីច

ដូចបានពន្យល់នៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន ៖* « ព្រះអម្ចាស់នឹងសម្រេចបានកាន់តែច្រើនថែមទៀត ចេញពីជីវិតរបស់អ្នក ជាជាងអ្នកអាចធ្វើបានដោយខ្លួនអ្នកផ្ទាល់ ។ ទ្រង់នឹងពង្រីកឱកាសរបស់អ្នក បន្ថែមទៅលើទស្សនវិស័យរបស់អ្នក និង ចម្រើនកម្លាំងដល់អ្នក ។ ទ្រង់នឹងប្រទានដល់អ្នកនូវជំនួយ ដែលអ្នកត្រូវការស្របទៅតាមការសាកល្បង និង ឧបសគ្គទាំងឡាយរបស់អ្នក ។ អ្នកនឹងទទួលបានទីបន្ទាល់កាន់តែរឹងមាំ និងរកឃើញនូវសេចក្តីអំណរដ៏ពិត នៅពេលដែលអ្នកចាប់ផ្តើមស្គាល់ព្រះវរបិតា ដែលគង់នៅឯស្ថានសួគ៌របស់អ្នក និងព្រះរាជបុត្ររបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះអ្នក » ( [ ឆ្នាំ ២០១១ ] ទំព័រ ៤៣ ) ។

នៅពេលយើងគោរពតាមបទបញ្ញត្តិរបស់ព្រះ ហើយធ្វើឲ្យទ្រង់មានចំណែកនៅក្នុងផែនការរបស់យើង នោះយើងក្លាយទៅជាមនុស្សដែលយើងចាំបាច់ត្រូវតែប្រែក្លាយ — ពុំមែនជាមនុស្សដែលយើងបានគិតចង់ប្រែក្លាយនោះទេ ។

នេះជាមនុស្សមួយចំនួនដែលបានរកឃើញផ្លូវល្អប្រសើរជាងផ្លូវមួយ ដែលពួកគេបានរើសដោយខ្លួនឯង ដោយមានជំនួយមកពីព្រះ ។

## ការបំភ្លេចចោលនូវកំហឹង

នៅក្នុងវីដេអូមួយក្នុង mormonchannel.org មានយុវជនម្នាក់ ឈ្មោះ ប៉ិបបា បានចែកចាយរឿងរបស់គាត់អំពីរបៀបដែលជីវិតរបស់គាត់បានធ្លាក់ទៅក្នុងភាពអន្តរាយ ។[1] គាត់បានធំឡើងនៅក្នុងផ្ទះដែលប្រើអំពើហិង្សា ដែលឪពុកគាត់ត្រូវបានគេសម្លាប់ នៅពេលប៉ិបបាមានអាយុត្រឹមបីឆ្នាំ ។

ប៉ិបបា បានធំឡើងដោយជ្រើសរើសយកជីវិតដដែល ដែលគាត់តែងតែមើលឃើញ ។ គាត់បានចូលរួមក្នុងក្រុមមនុស្សខូច ហើយចាប់ផ្តើមវាយមនុស្សដែលខ្វែងគំនិតនឹងគាត់ ។ មកដល់វិទ្យាល័យ គាត់បានគិតថា គាត់នឹងត្រូវជាប់គុក ។ ហើយគាត់មិនខ្វល់ទេ ។

ព្រះបានជួយអន្តរាគម ។ មកដល់ផ្លូវខ្វែងដ៏គ្រោះថ្នាក់នៅក្នុងជីវិតរបស់គាត់ ប៉ិបបា បានជួបនឹងគ្រួសារពួកបរិសុទ្ធថ្ងៃចុងក្រោយមួយ ដែលបង្ហាញសណ្តានចិត្តល្អ និងសេចក្តីល្អជាទីស្រឡាញ់ដល់គាត់ ។ គាត់ពុំធ្លាប់នៅក្នុងចំណោមមនុស្សដូចនេះពីមុនមកទេ — គឺក្រុមមនុស្សដែលបង្ហាញក្តីមេត្តា និងក្តីស្រឡាញ់ ។ គាត់បានចាប់ផ្តើមចំណាយពេលនៅជាមួយពួកគេឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ នៅពេលគាត់សួរដល់គ្រួសារនោះ ថាហេតុអ្វីក៏ពួកគេបានធ្វើទង្វើបែបនោះ នោះពួកគេបាននិយាយថា វាមកពីសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។

គាត់ចង់ស្វែងយល់អំពីអ្វីដែលពួកគេបានដឹង ។ គាត់បានចាប់ផ្តើមអធិស្ឋាន ហើយសិក្សាព្រះគម្ពីរ ។ ហើយមិនយូរប៉ុន្មានគាត់បានទទួលអារម្មណ៍អ្វីមួយ ដែលគាត់ពុំធ្លាប់មានពីមុនមក ។ « ប្រាកដណាស់ នោះគឺជាព្រះមួយអង្គ ហើយទ្រង់ស្រឡាញ់ខ្ញុំ ! » ប៉ិបបាបាននិយាយដូច្នោះ ។ ដោយមានជំនួយរបស់ព្រះ ប៉ិបបាបានចាប់ផ្តើមស្ថាបនាជីវិតរបស់គាត់សារជាថ្មី ដោយមានព្រះយេស៊ូវគ្រីស្ទគឺជាគ្រឹះ ដោយចាកចេញពីជីវិតចាស់របស់គាត់ ។

គាត់បានពោលថា « ចរិតលក្ខណៈរបស់ខ្ញុំបានផ្លាស់ប្តូរ ។ រូបខ្ញុំឥឡូវនេះ គឺខុសគ្នាពីរូបខ្ញុំកាលពីមុន ។ ឥឡូវខ្ញុំមានគោលបំណងមួយ ។ ខ្ញុំមានជោគវាសនាមួយ » ។ « ខ្ញុំមានកន្លែងមួយដែលខ្ញុំនឹងទៅ » ។

មកដល់ពេលនេះ ប៉ិបបា បានមើលឃើញអនាគតរបស់គាត់ ដោយភាពភ្លឺចិញ្ចែង សេចក្តីជំនឿ និងសេចក្តីសង្ឃឹម ។ គាត់បាននិយាយថា « ខ្ញុំដឹងថា គឺមានតែតាមរយៈព្រះយេស៊ូវគ្រីស្ទ និងជំនឿរបស់ខ្ញុំទៅលើទ្រង់ប៉ុណ្ណោះ ដែលនឹងជួយខ្ញុំឲ្យទៅដល់កន្លែងដែលខ្ញុំចង់ទៅ » ។[2]

## ការផ្លាស់ប្តូរទិសដៅ

ប្រធាន ហ៊្យូ ប៊ី ប្រោន ( ឆ្នាំ ១៨៨៣–១៩៧៥ ) ជាសមាជិកម្នាក់ក្នុង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងនៃគណៈប្រធានទីមួយ បានចែកចាយបទពិសោធន៍




នៅពេលយើងគោរពតាមបទបញ្ញត្តិរបស់ព្រះ ហើយបញ្ចូលទ្រង់នៅក្នុងផែនការរបស់យើង នោះយើងក្លាយទៅជាមនុស្សដែលយើងចាំបាច់ត្រូវតែប្រែក្លាយ — ពុំមែនជាមនុស្សដែលយើងបានគិតចង់ប្រែក្លាយនោះទេ ។

មួយដែលព្រះបានជួយគាត់ឲ្យសម្រេចបានកាន់តែច្រើន ចេញពីជីវិតរបស់លោក ជាជាងលោកអាចធ្វើបានដោយខ្លួនលោកផ្ទាល់ ។

លោក ហ៊្យូ បានបម្រើនៅក្នុងកងទ័ពកាណាដា ហើយរំពឹងថានឹងត្រូវបានដំឡើងសក្ដិទៅជាឧត្តមសេនីយ ។ គាត់បានធ្វើការ មានក្ដីសង្ឃឹម និងអធិស្ឋានសុំឲ្យមានការដំឡើងស័ក្ដិនោះអស់រយៈពេល១០ ឆ្នាំ ។

នៅពេលឱកាសដំឡើងសក្ដិនោះមកដល់ ទោះជាយ៉ាងណាក៏ដោយ លោកពុំត្រូវបានគេជ្រើសរើសទេ ដោយសារលោក គឺជាសមាជិកនៃសាសនាចក្រ ។ នោះគឺជាមូលហេតុតែមួយគត់ ហើយពួកគេបានប្រាប់លោកដូច្នោះ ។

លោក ហ៊្យូ បានខឹងយ៉ាងខ្លាំង ។ លោកបានមានប្រសាសន៍ ៖ « ខ្ញុំបានឡើងជិះរត់ភ្លើងត្រឡប់មកវិញ. . . ដោយខូចចិត្ត ដោយមានកំហឹងគុំគួននៅក្នុងព្រលឹងខ្ញុំ ។ . . . នៅពេលខ្ញុំចូលដល់ត្រសាលរបស់ខ្ញុំ . . . ខ្ញុំបានបោះមួករបស់ខ្ញុំទៅលើគ្រែ ។ ខ្ញុំបានក្ដាប់ដៃ ហើយខ្ញុំបានលើកដៃគ្រវីទៅលើដោយកំហឹងឆេះឆួល ។ ខ្ញុំបាននិយាយថា ‹ ព្រះអើយ យ៉ាងម៉េចបានជាទ្រង់ធ្វើដូច្នេះដាក់ខ្ញុំ ? ខ្ញុំបានខំធ្វើអ្វីៗគ្រប់យ៉ាងតាមដែលខ្ញុំអាចធ្វើដើម្បីឲ្យមានលក្ខណៈ សម្បត្តិនឹងតំណែងនោះ ។ គ្មានអ្វីទៀត ដែលខ្ញុំអាចធ្វើ — ដែលខ្ញុំគួរតែបានធ្វើ — ដែលខ្ញុំមិនបានធ្វើទេ ។ តើទ្រង់ធ្វើដូច្នេះដាក់ទូលបង្គំបានយ៉ាងដូចម្ដេច ? › ខ្ញុំមានភាពល្វីងជូរចត់ដូចទឹកប្រម៉ាត់អញ្ចឹង » ។[3]

បន្ទាប់មក ហ៊្យូ បានចាំបទពិសោធន៍មួយកាលពីច្រើនឆ្នាំមុន ។ គាត់ត្រូវបាននាំទៅចម្ការដែលគ្មានគេជួលកាប់គាស់ ដែលមានដើមឈើមួយបែបដុះស៊ុបទ្រុប ។ បើពុំកាត់តម្រឹមវាទេ នោះដើមឈើនោះនឹងពុំផ្ដល់ផ្លែឡើយ ។ ព្រោះអ្វីដែលដើមឈើនោះចង់ធ្វើ គឺដុះឲ្យបានកាន់តែខ្ពស់ ។

ដូច្នេះ ហ៊្យូ បានកាត់តម្រឹមវាយ៉ាងច្រើន ។ បន្ទាប់មក លោកបានមើលឃើញដំណំណក់ៗស្រក់ចេញមកតាមមែកដែលកាត់ចេញនីមួយៗទាំងនោះ ។ វាហាក់ដូចជាស្រក់ទឹកភ្នែកអញ្ចឹង ។ លោកបានប្រាប់ដល់ដើមឈើនោះថា « ខ្ញុំជាអ្នកមើលថែសួននៅទីនេះ » ។ ហ៊្យូ បានដឹងថាលោកចង់ឲ្យដើមឈើនោះប្រែទៅជាយ៉ាងណា ហើយវាពុំមែនជាដើមឈើយកម្លប់នោះទេ ។

បទពិសោធន៍នោះ បានជ្រៀតចូលក្នុងគំនិតរបស់លោក នៅពេលលោកតទល់នឹងកំហឹងចំពោះការមិនត្រូវបានគេដំឡើងសក្ដិ ។ « ខ្ញុំស្ដាប់ឮសំឡេងមួយ ហើយខ្ញុំស្គាល់សំឡេងនេះ ។ គឺជាសំឡេងរបស់ខ្ញុំ ហើយសំឡេងនេះបាននិយាយថា ‹ ខ្ញុំជាអ្នកមើលថែសួននៅទីនេះ ។ ខ្ញុំដឹងថាខ្ញុំចង់ឲ្យអ្នកធ្វើអ្វី › ។ ភាពល្វីងជូរចត់បានរសាយបាត់ទៅពីព្រលឹងរបស់ខ្ញុំ ហើយបានលុតជង្គង់ចុះនៅជិតគ្រែ ទូលសូមការអភ័យទោសចំពោះការមិនចេះដឹងគុណរបស់ខ្ញុំ ។ . . .

« . . . ហើយឥឡូវ ជិតរយៈពេល ៥០ ឆ្នាំក្រោយមក ខ្ញុំបានសម្លឹងមើលទៅ [ ព្រះ ] ហើយនិយាយថា ‹ សូមអរគុណ លោកអ្នកថែសួន ដែលបានកាត់តម្រឹមធ្វើឲ្យខ្ញុំឈឺចាប់ តែដោយសារតែស្រឡាញ់ខ្ញុំ › » ។[4]



« ខ្ញុំជាអ្នកមើលថែសួននៅទីនេះ ។
ខ្ញុំដឹងថាខ្ញុំចង់ឲ្យអ្នកធ្វើអ្វី » ។

លោកហ៊្យូ ពុំបានក្លាយជាឧត្តមសេនីយទេ ។ ប៉ុន្តែ ព្រះអម្ចាស់បានមានផែនការផ្សេងសម្រាប់ ប្រធានប្រោន ។ ដោយមានព្រះអម្ចាស់ធ្វើជាស្ថាបត្យកររបស់លោក នោះជីវិតប្រធាន ប្រោន បានក្លាយទៅជាអគារដ៏ប្រណិត ។

## ការសាងសង់ពីសូន្យ

កាលដែលត្រូវបានហៅថាជា « កូននៃស្ថាននរក » ដោយព្យាការីនៃព្រះ ប្រហែលជាពុំស្ដាប់ទៅដូចជាជីវិតរបស់អ្នកឆ្ពោះទៅរកគោលដៅល្អទេ ។ ប៉ុន្តែនោះជាអ្វីបានកើតឡើងយ៉ាងជាក់ចំពោះ ស៊ីអែសរ៉ុម ដែលជាមេធាវីម្នាក់នៅក្នុងព្រះគម្ពីរមរមន ។ ( សូមមើល អាលម៉ា ១១:២៣ ) ។

អាលម៉ា និង អាមុលេក កំពុងផ្សព្វផ្សាយនៅក្នុងទីកដី ដែលស៊ីអែសរ៉ុម កំពុងព្យាយាមដើម្បីប្រមូលប្រាក់កាស ក្នុងនាមជាមេធាវី ដោយញុះញង់ដល់ប្រជាជនឲ្យទាស់នឹងអាលម៉ា និង អាមុលេក ។ ស៊ីអែសរ៉ុម បានព្យាយាមប្រើកលល្បិចដាក់អាលម៉ា និងអាមុលេកដោយការសួរសំណួរជាច្រើនរបស់គាត់ ប៉ុន្តែពួកគេបានឆ្លើយ និងស្ដីបន្ទោសដល់គាត់ ។ គំនិតរបស់ស៊ីអែសរ៉ុម ត្រូវបានបើកបង្ហាញដោយព្រះវិញ្ញាណបរិសុទ្ធឲ្យពួកគាត់ដឹង ។ ( សូមមើល អាលម៉ា ១១–១២ ) ។

នៅពេលការសន្ទនាបានបន្ត នោះស៊ីអែសរ៉ុម បានតក់ស្លុតរហូតដល់នៅស្ងៀម ។ គាត់បានចាប់ផ្ដើមទទួលស្គាល់កំហុសរបស់គាត់ ហើយមានអារម្មណ៍ខុសធ្ងន់ធ្ងរក្នុងអំពើបាបរបស់គាត់ និងអ្វីដែលគាត់បានធ្វើ ដែលដឹកនាំមនុស្សឲ្យវង្វេង ។ មិនយូរប៉ុន្មាន គាត់បានព្យាយាមកែជួសជុលភាពខូចខាត

ដែលគាត់បានធ្វើខ្លះៗដោយនិយាយថា « មើលចុះខ្ញុំមានទោស រីឯអ្នកទាំងពីរនេះគ្មានទោសនៅចំពោះព្រះទេ » ( អាលម៉ា ១៤:៧ ) ។

ប៉ុន្តែនោះទៅមិនរួចឡើយ ។ ប្រជាជនបានបណ្ដេញស៊ីអែសរ៉ុមចេញពីទីក្រុងរបស់ពួកគេ ។ កំហុស និងក្ដីអស់សង្ឃឹមរបស់គាត់បានគ្របដណ្ដប់លើគាត់ចំពោះអ្វីដែលគាត់បានធ្វើ — រួមទាំងការភ័យខ្លាចចំពោះកំហុស ដែលគាត់បានផ្សាយទាស់នឹងអាលម៉ា និងអាមូលេក ដើម្បីនាំពួកគេទៅសម្លាប់នោះ — បានបណ្ដាលឲ្យស៊ីអែសរ៉ុម ធ្លាក់ខ្លួនឈឺគ្រុនក្ដៅ « ដែលកំពុងដុតរោល » ( អាលម៉ា ១៥:៣ ) ។

សំណង់ដែលគាត់បានសង់ឡើងសម្រាប់ជីវិតរបស់គាត់ ត្រូវបានរលំដួលចុះ ។ ប៉ុន្តែនោះពុំមែនជាទីបញ្ចប់នៃរឿងរបស់ស៊ីអែសរ៉ុមនោះទេ ។

នៅពេលគាត់បានដឹងថា អាលម៉ា និង អាមូលេក នៅរស់នៅឡើយ នោះស៊ីអែសរ៉ុម បានតាំងចិត្តក្លាហាន ហើយបានសុំឲ្យពួកគេមករកគាត់ ។ នៅពេលពួកគេមកដល់ ស៊ីអែសរ៉ុម បានសុំការព្យាបាល ។ ដោយសារសេចក្ដីជំនឿរបស់គាត់ នោះស៊ីអែសរ៉ុមត្រូវបានជាសះស្បើយទាំងស្រុង ។ រួចហើយ គាត់បានជ្រមុជទឹក ហើយបានចាប់ផ្ដើមផ្សាយចាប់តាំងពីពេលនោះមក ( សូមមើលអាលម៉ា ១៥:១១–១២ ) ។

ជីវិតថ្មីរបស់ស៊ីអែសរ៉ុម នៅពេលនេះដែលមានព្រះជាស្ថាបត្យកររបស់គាត់ ទើបតែបានចាប់ផ្ដើម ។

## លើសពីញញួរ និងដែកគោល

ដំណឹងល្អនោះ គឺថាយើងពុំចង់ឆ្លងកាត់ជីវិតនេះតែឯកឯងនោះទេ ។ ព្រះសព្វព្រះហឫទ័យជួយយើងគ្រប់ជំហាននៅតាមផ្លូវ ។ ហើយនៅពេលយើងអនុញ្ញាតឲ្យទ្រង់ជួយយើង នោះសក្ដានុភាពរបស់យើងនឹងគ្មានកម្រិតនោះទេ ។ ■

**កំណត់ចំណាំ**


១. សេរីវីដេអូ « His Grace » នៅលើគេហទំព័រ mormonchannel.org ។
២. « From Gang Member to ‹ Good Man › » ( វីដេអូ ) នៅលើគេហទំព័រ mormonchannel.org។
៣. ហ៊ូ ប៊ី ប្រោន « The Currant Bush » *Liahona,* ខែ មិនា ឆ្នាំ ២០០២, ២៤; *New Era,* ខែ មករា ឆ្នាំ ១៩៧៣, ១៥ ។
៤. ហ៊ូ ប៊ី ប្រោន , « The Currant Bush, » *Liahona,* ២២, ២៤; *New Era,* ១៤, ១៥ ។
៥. នែល អេ ម៉ាក់ស្វែល « Response to a Call » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៧៤,ទំព័រ ១១២ ។





**ខាងសាច់ឈាម ផ្ទុយពី ជីវិតអស់កល្បជានិច្ច**

នៅក្នុងជីវិតនេះ យើងមានឱកាសជាច្រើនដើម្បីប្រើសិទ្ធិជ្រើសរើសរបស់យើង ។ គ្រប់បណ្ដាញសង្គម ប្រជាប្រិយភាព និងមិត្តភក្ដិទាំងអស់ហាក់ដូចជាសំខាន់នៅក្នុងជីវិតនេះ ប៉ុន្តែនៅចុងបញ្ចប់វាគឺជានគរព្រះ ដែលនឹងសំខាន់បំផុត ។ មានពាក្យដកស្រង់មួយដែលខ្ញុំពេញចិត្ត ដែលអែលឌើរ នែល អេ ម៉ាក់ស្វែល ( ឆ្នាំ ១៩២៦–២០០៤ ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍នៅក្នុងសន្និសីទទូទៅ ៖ « បើអ្នកមិនជ្រើសរើសនគរព្រះមុនទេ នោះវានឹងគ្មានអ្វីខុសប្លែកនៅក្នុងអ្វីដែលអ្នកបានជ្រើសរើស ពេលដល់ទីបញ្ចប់នោះទេ » ។[៥]

ពេលខ្លះយើងផ្ដោតចិត្តខ្លាំងពេកនៅក្នុងជីវិតនេះ រហូតដល់យើងភ្លេចនូវអ្វីដែលសំខាន់បំផុត ។ បើយើងអាចដករាំងននចេញពីមុខយើង នោះទស្សនវិស័យទាំងមូលរបស់យើងនឹងផ្លាស់ប្ដូរ ។ យើងនឹងកាន់តែមានភាពរាបសារជាងមុន ហើយផ្ដល់សារសំខាន់ចំពោះព្រះអម្ចាស់ច្រើនជាងផ្ដល់សារសំខាន់ដល់មនុស្ស ។

ខ្ញុំបានជឿថា ខ្ញុំចង់ក្លាយជាមនុស្សសុចរិត ហើយធ្វើតាមព្រះ ។ ខ្ញុំចង់មានទស្សនវិស័យអស់កល្បជានិច្ចមួយ ដូច្នេះខ្ញុំអាចចូលក្នុងនគរដ៏មហិមារបស់ទ្រង់បាន ។ ការណ៍នេះនឹងល្អប្រសើរជាងការមានប្រាក់ និងមានអំណាចនៃលោកិយនេះ ។ នៅក្នុងជីវិតនេះ យើងនឹងរស់នៅតែមួយរយៈពេលដ៏ខ្លីប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងភាពអស់កល្បជានិច្ច ។ សិរីល្អដែលយើងនឹងទទួលនឹងជាសិរីល្អដែលយើងនឹងមានជារៀងរហូត ។

**អ៊ីសាបែល អេ អាយុ ១៩ ឆ្នាំ ប្រទេសម៉ិកស៊ិកូ**

# ការឈររឹងមាំនៅក្នុងប្រទេសអេត្យូពី

ដោយ អេមី ជេន លែវិត

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*



ខ្ញុំឈ្មោះ

## ធីសុន !

ខ្ញុំរស់នៅក្នុងប្រទេស អេត្យូពី ជាប្រទេសមួយនៅអាហ្វ្រិកខាងកើត ។ ខ្ញុំចូលចិត្តលេងបាល់ទាត់ និងអានសៀវភៅ ។ ខ្ញុំចង់ក្លាយជាវេជ្ជបណ្ឌិត នៅពេលខ្ញុំធំឡើង ។ ខ្ញុំព្យាយាមឈររឹងមាំ ដោយការរស់នៅតាមដំណឹងល្អជារៀងរាល់ថ្ងៃ ហើយចែកចាយវាជាមួយនឹងមិត្តភក្តិរបស់ខ្ញុំ !



**របៀបដែលខ្ញុំទទួលបានទីបន្ទាល់**

*ខ្ញុំបានមកព្រះវិហារលើកដំបូង ពេលដែលខ្ញុំមានអាយុប្រាំបីឆ្នាំ ។ ខ្ញុំបានអានព្រះគម្ពីរមរមន ខ្ញុំបានស្តាប់អ្នកផ្សព្វផ្សាយសាសនា ហើយខ្ញុំបានអធិស្ឋាន ។ ព្រះវិញ្ញាណបានប្រាប់ខ្ញុំថា សាសនាចក្រពិត ហើយខ្ញុំចង់ទទួលបានបុណ្យជ្រមុជទឹក ។ ដំណឹងល្អធ្វើឲ្យខ្ញុំរីករាយ ។*

រូបថតផ្តល់ឲ្យដោយគ្រួសារធីសុន, រៀបចំរចនាដោយ ម៉ាក ព្រីនស៊ីន

## យោបល់របស់ធីសន សម្រាប់ការឈររឹងមាំ

- ទទួលទីបន្ទាល់មួយផ្ទាល់ខ្លួន ។ អានព្រះគម្ពីរ ហើយអធិស្ឋាន ។
- ចែកចាយទីបន្ទាល់របស់អ្នក ហើយធ្វើជាគំរូល្អដល់មិត្តភក្តិរបស់អ្នក ។
- ទៅព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ ហើយរស់នៅតាមបទដ្ឋានដំណឹងល្អ ។

### ការជួយដល់គ្រួសាររបស់ខ្ញុំ

*តាមធម្មតា គ្រួសាររបស់ខ្ញុំដើរទៅព្រះវិហារ ហើយត្រូវចំណាយពេលមួយម៉ោង ។ នៅពេលប្អូនប្រុសតូចរបស់ខ្ញុំហត់ បងប្រុសខ្ញុំ ឬខ្ញុំនឹងពគាត់ ។ ខ្ញុំជួយលាងចាន និងសម្អាតផ្ទះ ។*








### ការហៅបម្រើរបស់ខ្ញុំក្នុងព្រះវិហារ

*ផ្នែកដែលខ្ញុំចូលចិត្តអំពីព្រះវិហារ គឺការប្រជុំសាក្រាម៉ង់ ។ ខ្ញុំដឹកនាំតន្ត្រី ។*

*ខ្ញុំចូលចិត្តរៀនដំណឹងល្អ ។ រឿងព្រះគម្ពីរដែលខ្ញុំចូលចិត្តគឺដេវីឌ និងកូលីយ៉ាត ។ ចម្រៀងដែលខ្ញុំចូលចិត្តគឺ « រឿងនិទានព្រះគម្ពីរមរមន » ។*

### ការចែកចាយនូវអ្វីដែលខ្ញុំដឹង

*ខ្ញុំប្រាប់មិត្តភក្តិរបស់ខ្ញុំទាំងឡាយនៅសាលារៀនអំពីដំណឹងល្អដែលបានស្ដារឡើងវិញ ។ មិត្តម្នាក់ធ្លាប់បានសួរខ្ញុំអំពីសាសនាចក្រ — ក្រោយមកនាងក៏បានឈប់ទៅវិញមួយរំពេច ។ ខ្ញុំសួរនាងថាហេតុអ្វី ។ នាងបានប្រាប់ថា ឪពុកម្ដាយនាងមិនពេញចិត្តទេ ។ ខ្ញុំសង្ឃឹមថា ថ្ងៃណាមួយ ឪពុកម្ដាយរបស់នាង នឹងផ្លាស់ប្ដូរដួងចិត្តរបស់ពួកគាត់ ។*



### អត្ថន័យនៃការឈររឹងមាំចំពោះខ្ញុំ

*« ការឈររឹងមាំ » មានន័យថា រស់នៅតាមដំណឹងល្អជារៀងរាល់ថ្ងៃ ។ ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវ សព្វព្រះទ័យឲ្យខ្ញុំថ្លែងទីបន្ទាល់អំពីទ្រង់ ! ខ្ញុំចង់ឲ្យមិត្តរបស់ខ្ញុំទាំងអស់នៅជុំវិញពិភពលោក ចែកចាយដំណឹងល្អដែលបានស្ដារឡើងវិញជាមួយមិត្តរបស់ពួកគេ ។*

## សូមផ្ញើរឿងរបស់អ្នកមកកាន់យើង

តើអ្នកធ្វើតាមព្រះយេស៊ូវ ដោយការឈររឹងមាំយ៉ាងដូចម្ដេច ? សូមផ្ញើបទពិសោធន៍ និងរូបថតរបស់អ្នកមកកាន់យើងខ្ញុំ ព្រមជាមួយនឹងការអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកមកផងដែរ ។ សូមផ្ញើវា តាមអ៊ីម៉ែល liahona@ldschurch.org ។

# ការអានឲ្យល្អប្រសើរជារៀងរាល់ថ្ងៃ




**ដោយ ម៉ារីសា វីឌីសុន និងសូញ៉ា យ៉ូនណាទ្បាតា**
ផ្អែកទៅលើដំណើររឿងពិត

យ៉ូសែប បានបើកទំព័រសៀវភៅរបស់គាត់ ។ គាត់ជ្រួញចិញ្ចើម ។ គាត់នៅមានច្រើនទំព័រច្រើនទៀត ដែលមិនទាន់បានអាន ។

ម៉ាក់បានសួរថា « តើកូនមិនអីទេឬ ? »

យ៉ូសែប បាននិយាយថា « កូនចូលចិត្តអាន » ។ « ប៉ុន្តែកូនអានយឺតណាស់ ។ តើកូនអាចរៀនអានឲ្យបានល្អជាងនេះដោយរបៀបណា ? »

ម៉ាក់បាននិយាយថា « ម៉ាក់មានយោបល់មួយ » ។ « អានព្រះគម្ពីរមរមនមួយជំពូកជារៀងរាល់ថ្ងៃ ។ វានឹងជួយកូនរៀនអានបានកាន់តែល្អប្រសើរ » ។

យ៉ូសែបបានព្យាយាម ។ ដំបូងឡើយ គាត់បានចំណាយពេលច្រើនលើវា ។ គាត់ត្រូវរៀនពាក្យវែងៗ ។ ប៉ុន្តែគាត់បន្តអានជារៀងរាល់ថ្ងៃ ។ មិនយូរប៉ុន្មាន គាត់អាចអានបានច្រើនជាងមួយជំពូក ។

ពីរសប្តាហ៍បានកន្លងផុតទៅ ។ វត្ថុសិកចំណាំក្នុងសៀវភៅរបស់ យ៉ូសែប បានផ្លាស់ពីនីហ្វៃទី ១ ទៅនីហ្វៃទី ២ ។ បន្ទាប់មកវាត្រូវបានដាក់នៅក្នុងគម្ពីរយ៉ាកុប !




រូបភាពលម្អដោយ ខាធី ម៉ាក់នី

នៅយប់មួយ វាដល់វេនរបស់យ៉ូសែប ដើម្បីបង្រៀនមេរៀននៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។

យ៉ូសែបបានគិតថា « ខ្ញុំដឹងថាត្រូវធ្វើអ្វីហើយ ! » គាត់បានរកឃើញសៀវភៅ *រឿងនិទានអំពីព្រះគម្ពីរមរមន* ។ វាមានអក្សរ និងរូបភាព ។ គាត់បានបើកទៅទំព័រជាច្រើនរហូតដល់គាត់រកឃើញរឿងដ៏ល្អមួយ ។

យ៉ូសែប បានអានរឿងនោះឲ្យគ្រួសាររបស់គាត់ស្ដាប់ ។ គាត់បានអានពាក្យខ្លីៗ ដូចជា *កប៉ាល់* ។ គាត់អានពាក្យវែងៗ ដូចជា *ត្រូវបានបញ្ជា* ។ ពួកព្យាការីបានសរសេរពាក្យទាំងនេះជាយូរលង់មកហើយ ។ ពាក្យទាំងនេះងាយអាន ។

នៅពេលរឿងនោះបានចប់ ម៉ាក់បានស្រក់ទឹកភ្នែក ។

យ៉ូសែប បានសួរថា « ម៉ាក់ តើម៉ាក់មិនអីទេឬ ? »

ម៉ាក់បានប្រាប់ថា « មិនអីទេ » ។ « ម៉ាក់សប្បាយចិត្ត ។ កូនបានខិតខំណាស់ » ។

យ៉ូសែប ញញឹមយ៉ាងពព្រាយ ។

« ខ្ញុំបានអានរៀងរាល់ថ្ងៃ ដូចម៉ាក់បានប្រាប់ » ។ គាត់បានបង្ហាញដល់ម៉ាក់នូវព្រះគម្ពីរមរមនរបស់គាត់ ។ វត្ថុស៊ិកចំណាំក្នុងសៀវភៅរបស់គាត់ដាក់ដល់អាលម៉ា !

នៅថ្ងៃណាមួយវត្ថុស៊ិកចំណាំក្នុងសៀវភៅរបស់ យ៉ូសែប នឹងទៅដល់ចុងព្រះគម្ពីរ ។ រួចហើយ គាត់អាចអានសារឡើងវិញ ! ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា និង ប្រទេសបូលីវី ។*

ចម្លើយមកពីសាវកម្នាក់



# តើខ្ញុំអាចទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនដោយរបៀបណា ?

**ដោយ អែលឌើរ រ៉ូបឺត ឌី ហែល**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់



ទីបន្ទាល់របស់អ្នក នឹងរីកចម្រើន នៅពេលអ្នករៀនអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវ ។



អ្នកអាចរៀនមកពីការអានព្រះគម្ពីរ ។



អ្នកអាចរៀនមកពីការបង្រៀន និងទីបន្ទាល់របស់ឪពុកម្ដាយ
និងគ្រូបង្រៀនរបស់អ្នក ។

ជាក្មេងប្រុសម្នាក់
នេះជារបៀបដែល
ខ្ញុំបានដឹងដោយ
ខ្លួនឯង ។



នៅពេលអ្នកធ្វើអ្វីដែល
ត្រឹមត្រូវ នោះព្រះវិញ្ញាណបរិសុទ្ធ
នឹងជួយអ្នក ។

គំនូរដោយ ប្រាត ធៀរ

*ចេញមកពី « ជីវិតដ៏នៅអស់កល្បជានិច្ច — ដើម្បីស្គាល់ព្រះវរបិតាសួគ៌របស់យើង និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ »* លីអាហូណា, *ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៨០–៨២ ។*



# ការតមអាហាររបស់ វិលហ្វូឌ

**ដោយអែលឌើរ**
**ឈី ហុង ( សាំ ) វ៉ុង**
នៃពួកចិតសិបនាក់



ថ្ងៃមួយ ខ្ញុំឃើញកូនប្រុសច្បងរបស់ខ្ញុំ វិលហ្វូឌ រៀបចំស្រោមសំបុត្រដង្វាយមួយភាគក្នុងដប់ ។ គាត់មានអាយុប្រហែលជាប្រាំឆ្នាំនាពេលនោះ ។ វិលហ្វូឌ ពុំមានប្រាក់ចំណូលអ្វីទេ ដូច្នេះខ្ញុំឆ្ងល់ថាហេតុអ្វីក៏គាត់បង់ដង្វាយមួយភាគក្នុងដប់ ។ នៅពេលខ្ញុំសួរគាត់ គាត់បានប្រាប់ខ្ញុំថា តាមពិតគាត់បង់ដង្វាយតមអាហារ ។

វិលហ្វូឌ ពុំមានប្រាក់ច្រើនដោយខ្លួនគាត់ទេ ។ ប៉ុន្តែគាត់នៅតែរំភើបចិត្តដើម្បីបង់ដង្វាយតមអាហារ ។

ខ្ញុំមានការស្ងើចសរសើរចំពោះទង្វើនៃសណ្ដានចិត្តដ៏ល្អនេះ ។ ខ្ញុំបានសួរគាត់ថា ហេតុអ្វីក៏គាត់សម្រេចចិត្តធ្វើដូច្នោះ ។

វិលហ្វូឌ បានតបថា « ខ្ញុំពុំមានតម្រូវការអ្វីទេ ។ ប៉ុន្តែខ្ញុំដឹងថា អ្នកដទៃមានតម្រូវការ » ។ គាត់បានដឹងថាប្រាក់របស់គាត់ នឹងជួយដល់មនុស្សដទៃ ។ គាត់សប្បាយចិត្តណាស់អំពីរឿងនោះ ។

បទពិសោធន៍ដ៏សាមញ្ញនេះ បានបង្រៀនខ្ញុំនូវមេរៀនដ៏ល្អមួយ ៖ កុមារតូចៗពិតជាត្រូវបានញ៉ាំងចិត្តដោយព្រះវិញ្ញាណ ហើយមានក្ដីស្រឡាញ់ដូចជាព្រះគ្រីស្ទពីធម្មជាតិមែន ។ វិលហ្វូឌ មានអ្វីដែលគាត់ពុំត្រូវការ ហើយបានដឹងថា វានឹងជួយអ្នកដទៃទៀត ។ គាត់ស្ម័គ្រចិត្តធ្វើការលះបង់ ។

ការសន្សំប្រាក់គឺជាការល្អ ។ ប៉ុន្តែកូនប្រុសតូចរបស់ខ្ញុំ បានបង្រៀនខ្ញុំនូវមេរៀនមួយទៀត តាមរយៈគំរូរបស់គាត់ ។ តាមរយៈការស្ដាប់តាមព្រះវិញ្ញាណ នោះយើងអាចប្រទានពរដល់ជីវិតមនុស្សផ្សេងទៀត ពេលយើងចែកចាយនូវអ្វីដែលយើងមាន ។ ■

រូបភាពដោយ ម៉ាត ស្មីទ

# ព្រះគម្ពីរមរមនបង្រៀន អំពី ព្រះយេស៊ូវគ្រីស្ទ



នៅពេលអ្នកអានព្រះគម្ពីរមរមន នោះអ្នកនឹងធ្វើដំណើរផ្សងព្រេងជាច្រើន ។ អ្នកនឹងធ្វើដំណើរនៅក្នុងទីរហោស្ថានជាមួយគ្រួសារលីហៃ និងសារ៉ាយ ហើយមើលនីហ្វៃសង់សំពៅមួយ ។ អ្នកនឹងជួបព្យាការីជាច្រើនផងដែរ — ដូចជា លីហៃ នីហ្វៃ អ័ប៊ីណាដៃ សាំយ៉ូអែល និង មរមន ។ គ្រប់ព្យាការីទាំងអស់ដែលនៅក្នុងព្រះគម្ពីរមរមន បានបង្រៀនអំពីព្រះយេស៊ូវ ។ ពួកគាត់មួយចំនួនបានទាំងឃើញទ្រង់ផង ។ តាមពិតនោះជាមូលហេតុដែលព្រះវរបិតាសួគ៌ ប្រទានដល់យើងនូវព្រះគម្ពីរពិសេសនេះ — ដើម្បីជួយមនុស្សគ្រប់ទីកន្លែងឲ្យរៀនបន្ថែមទៀតអំពីព្រះយេស៊ូវ ! ■

**ដាក់ផែនការមួយ !**

ចូរដាក់ផែនការមួយ ដើម្បីអានព្រះគម្ពីរមរមនឆ្នាំនេះ ។ ចូររកកាតវិរៈបុរសព្រះគម្ពីរមរមនខែនេះ ហើយអានសំណូមពរ នៅទំព័រ ៧៤–៧៥ ។

សូមមើល « ជំពូកទី ១ ៖ របៀបដែលយើងទទួលបានព្រះគម្ពីរមរមន » នៅលើគេហទំព័រ scripturestories.lds.org ។ សូមចុចនៅលើ « ព្រះគម្ពីរមរមន » ។

ដាក់វេនអានខគម្ពីរទាំងនេះ ។ ចូរសរសេរចំនួនខគម្ពីរដែលត្រូវគ្នានឹងព្យាការីនៃព្រះគម្ពីរមរមនម្នាក់ៗ ។ ចូរពិនិត្យចម្លើយរបស់អ្នកដូចខាងក្រោម ។




១. អេធើរ ១២:៣៩, ៤១
២. នីហ្វៃទី ១ ១:៥, ៩
៣. នីហ្វៃទី ១ ១១:២៦–២៧
៤. ម៉ូសាយ ១៦:៨–៩
៥. អាលម៉ា ៦:៨
៦. មរ៉ូណៃ ៩:២២


















**ចូរសរសេរអំពីវា !**

តើព្រះយេស៊ូវគ្រីស្ទបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើងនៅក្នុងព្រះគម្ពីរមរមនយ៉ាងដូចម្ដេច ?

ចម្លើយ ៖ ១ ។ មរ៉ូណៃ ២ ។ លីហៃ ៣ ។ នីហ្វៃ ៤ ។ អ័ប៊ីណាដៃ ៥ ។ អាលម៉ា ៦ ។ មរមន

រចនារូបភាពដោយ ស្ទី ក្រុប

# នីហ្វៃគោរពប្រតិបត្តិ

នីហ្វៃត្រូវធ្វើការណ៍លំបាកៗ និងគួរភ័យខ្លាចជាច្រើន ។ គាត់ត្រូវចាកចេញពីផ្ទះរបស់គាត់ ទៅយកផ្ទាំងលង្ហិនពីមនុស្សទុច្ចរិតម្នាក់ ហើយជួយគ្រួសាររបស់គាត់ឲ្យនៅរស់រានមានជីវិតនៅក្នុងទីរហោស្ថាន ។ ប៉ុន្តែគាត់បានទុកចិត្តលើព្រះ ហើយបានរកឃើញភាពក្លាហានដើម្បីគោរពតាម ។ តើអ្នកអាចធ្វើតាមគំរូរបស់នីហ្វៃក្នុងខែនេះយ៉ាងដូចម្ដេច ?



ម្ដាយរបស់ខ្ញុំ និង ខ្ញុំបានចាប់ផ្ដើមអានព្រះគម្ពីរមរមន ។ នៅពេលយើងអានអំពី នីហ្វៃ ខ្ញុំបានដឹងថា នីហ្វៃ តែងតែគោរពតាម ហើយគាត់ត្រូវបានប្រទានពរដោយសារតែការគោរពតាមនោះ ។ ខ្ញុំមានអារម្មណ៍ថា នេះគឺជារបៀបដ៏ត្រឹមត្រូវដែលត្រូវធ្វើ ហើយខ្ញុំចង់ធ្វើដូចជានីហ្វៃដែរ ។ ដូច្នេះឥឡូវនេះ ពេលម្ដាយខ្ញុំប្រាប់ថា « យកសម្រាមទៅចោល » នោះខ្ញុំនិយាយថា « បាទ ម៉ាក់ ! »

**ហីឌី អិម អាយុ ១០ ឆ្នាំ យីងណាម ប្រទេសកូរ៉េខាងត្បូង**



*អេនលី ប៊ី អាយុ ៨ ឆ្នាំ វ៉េយូថាហ៍ ស.រ.អា.*

រចនារូបភាពដោយ យ៉ារេឌ បេកស្ត្រេន

កាត់ បត់ ហើយរក្សាកាតសំណួមពរនេះ !




## ខ្ញុំអាចគោរពប្រតិបត្តិតាមបាន !

- ☐ ចូរទន្ទេញ នីហ្វៃទី ១ ៣:៧ ។
- ☐ នៅពេលឪពុកម្ដាយរបស់អ្នកសុំឲ្យអ្នកធ្វើអ្វីមួយ ចូរគោរពប្រតិបត្តិតាមដូចជានីហ្វៃ !
- ☐ សូមមើលវីដេអូព្រះគម្ពីរមរមន ជំពូក ២–៩ នៅលើគេហទំព័រ scripturestories.lds.org ។
- ☐ ខ្ញុំសំណូមពរដល់ខ្លួនឯងដើម្បី . . .

____________________

## បទគម្ពីរសម្រាប់ខែនេះ

បន្ទាប់ពីអ្នកអានវគ្គបទគម្ពីរសូមផាត់ពណ៌លើផ្នែកមានចុះលេខដែលត្រូវគ្នាលើលីអាហូណា !

**១** នីហ្វៃទី ១ ១:១–១០

**២** នីហ្វៃទី ១ ២:១–៧, ១៦–២០

**៣** នីហ្វៃទី ១ ៣:១–៩

**៤** នីហ្វៃទី ១ ៣:២២–៣១, ៤:១

**៥** នីហ្វៃទី ១ ៤:៤–៣៥

**៦** នីហ្វៃទី ១ ៨:២, ៥–១៨

**៧** នីហ្វៃទី ១ ៨:១៩–៣៣

**៨** នីហ្វៃទី ១ ១៦:៩–១៦






## លីអាហូណា

នៅពេលគ្រួសារលីហៃបានធ្វើដំណើរឆ្លងកាត់ទីរហោស្ថាន ព្រះអម្ចាស់បានប្រទានត្រីវិស័យដ៏ពិសេសមួយដល់ពួកគេ ដែលហៅថា លីអាហូណា ។ នៅពេលពួកគេស្មោះត្រង់ នោះលីអាហូណាបានប្រាប់ពួកគេនូវទីកន្លែងដើម្បីធ្វើដំណើរទៅ ហើយថែមទាំងប្រាប់អំពីកន្លែងដើម្បីរកអាហារផងដែរ ! សូមអានបន្ថែមអំពីលីអាហូណានៅទំព័រ ៧៦–៧៨ ។ ហើយរកមើលសំណូមពរការអានផ្សេងទៀតនៅច្បាប់ក្រោយ ! ■

រចនារូបភាពដោយ យ៉ារេឌ បេ៊កស្រ្តែន ,ដកស្រង់ពិស្តារចេញមកពី*លីអាហូណា*ដោយ អាណុល ហ្វ្រីប៊ើហ្គ

សម្រាប់កុមារតូចៗ

# ការធ្វើដំណើរនៅក្នុងទីរហោស្ថាន



នីហ្វៃបានរស់នៅជាមួយនឹងគ្រួសាររបស់គាត់នៅទីក្រុងយេរូសាឡិម ។ ឪពុករបស់គាត់ លីហៃ គឺជាព្យាការី ។ ម្ដាយរបស់គាត់ ឈ្មោះ សារ៉ាយ ។ បងប្រុសរបស់គាត់ ឈ្មោះ លេមិន លេមយួល និង សាំ ។



ឪពុករបស់នីហ្វៃបានអធិស្ឋាន ។ ព្រះវរបិតាសួគ៌ បានមានព្រះបន្ទូលប្រាប់លោកថា គ្រួសារលោកចាំបាច់ត្រូវចាកចេញពីទីក្រុងនេះ ដើម្បីឲ្យពួកគេអាចមានសុវត្ថិភាព ។ វាជាការលំបាកដើម្បីចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ។ ប៉ុន្តែគ្រួសាររបស់នីហ្វៃ បានគោរពប្រតិបត្តិតាម ។

រចនារូបភាពដោយ អាប៊្រីល ស្តុត



គ្រួសាររបស់នីហ្វៃ បានចេញទៅក្នុងទីរហោស្ថាន ។ បន្ទាប់មកព្រះវរបិតាសួគ៌ បានមានព្រះបន្ទូលប្រាប់ថា នីហ្វៃ និងបងៗរបស់គាត់ចាំបាច់ត្រូវតែត្រឡប់ទៅទីក្រុងនោះវិញដើម្បីទៅយកព្រះគម្ពីរ ។ វាគឺជារឿងលំបាកធ្វើ ។ ប៉ុន្តែ នីហ្វៃគឺជាគំរូល្អមួយ ខណៈពេលបងប្រុសរបស់គាត់ពុំចង់គោរពតាមនោះ ។ គាត់បានប្រាប់ថា គាត់នឹងធ្វើនូវអ្វី ដែលព្រះវរបិតាសួគ៌បញ្ជាឲ្យគាត់ធ្វើ ។



ព្រះវរបិតាសួគ៌ បានប្រទានដល់ក្រុមគ្រួសារនីហ្វៃនូវគ្រឿងវិស័យពិសេសមួយ ។ វាត្រូវបានហៅថា លីអាហូណា ។ នៅពេលគ្រួសារនីហ្វៃគោរពតាមព្រះវរបិតាសួគ៌ នោះវាបង្ហាញផ្លូវដល់ពួកគេឲ្យធ្វើដំណើរនៅក្នុងទីរហោស្ថាន ។ វាក៏បង្ហាញដល់នីហ្វៃអំពីទីកន្លែងដើម្បីទៅរកអាហារសម្រាប់គ្រួសាររបស់គាត់ផងដែរ ។



យើងអាចធ្វើដូចជានីហ្វៃដែរ នៅពេលយើងគោរពតាមបទបញ្ញត្តិ
ទាំងឡាយ ហើយធ្វើតាមព្រះវរបិតាសួគ៌ ! ■

# ខ្ញុំអាចជ្រើសរើសផ្លូវត្រូវ



រចនារូបភាពដោយ អាព្រិល ស្កត



ដោយអែលឌើរ ជេម អ៊ី ថាល់មេហ្គ
( ឆ្នាំ ១៨៦២–១៩៣៣ )
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់



# រឿងប្រៀបធៀបអំពីរថភ្លើងទីទុយ

*ខ្ញុំបានគិតយ៉ាងល្អិតល្អន់អំពីពាក្យសម្ដីរបស់វិស្វករដែលប្រឡាក់សុទ្ធតែប្រេងម៉ាស៊ីនដ៏កខ្វក់នោះ ។*

អំឡុងពេលខ្ញុំរៀននៅមហាវិទ្យាល័យ ខ្ញុំគឺជាសិស្សម្នាក់ដែលបានចាត់តាំងឲ្យទៅធ្វើការដែលជាផ្នែកមួយនៃវគ្គសិក្សារបស់យើងនៅក្នុងភូមិវិទ្យា ។ . . .

កិច្ចការមួយចំនួនបានទុកឲ្យយើងធ្វើនៅក្នុងកន្លែងការងារនោះជាច្រើនថ្ងៃ ។ . . . នៅពេលដែលការសិក្សាស្រាវជ្រាវជិតដល់ពេលបញ្ចប់នោះយើងត្រូវបានព្យុះកំណាចមួយបោកបក់មកលើដែលមាននូវព្រិលដ៏ក្រាស់ — កើតមានដោយពុំបានរំពឹងទុក ពុំសមហេតុផល ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏វាបានបង្កើនកម្លាំងកាន់តែខ្លាំង ដូច្នេះយើងអាចស្ថិតនៅក្នុងគ្រោះថ្នាក់ជាប់ក្នុងគំនរទឹកកកនៅលើភ្នំ ។ ព្យុះនោះបានកើតឡើងកាន់តែខ្លាំងពេលយើងដើរចុះតាមជម្រាលជើងភ្នំយ៉ាងចោទដែលមានចម្ងាយរាប់គីឡូម៉ែត្រទៀតទម្រាំទៅដល់ស្ថានីយ៍រថភ្លើងតូចមួយ ដែលយើងសង្ឃឹមថា នឹងជិះរថភ្លើងនៅយប់នោះធ្វើដំណើរមកផ្ទះវិញ ។ យើងបានខិតខំយ៉ាងខ្លាំង ក៏បានមកដល់បានស្ថានីយ៍ក្នុងពេលយប់អាធ្រាត្រខណៈដែលព្យុះមានកម្លាំងកាន់តែខ្លាំង ។ . . .

. . . រថភ្លើងដែលយើងទន្ទឹងរង់ចាំ និងរំពឹងទុកដោយក្ដីសង្ឃឹមបំផុត គឺរថភ្លើងទីទុយ — ជារថភ្លើងពេលយប់ដែលមានល្បឿនលឿនទៅកាន់ទីក្រុងធំៗ ។ . . .

ចាប់ពីពាក់កណ្ដាលអាធ្រាត្រក្រោយមក រថភ្លើងក៏បានមកដល់នៅក្នុងព្យុះព្រិល និងខ្យល់គួចដ៏កំណាច ។ ខ្ញុំបាននៅអែរអង់ពីក្រោយដៃគូរបស់ខ្ញុំ នៅពេលពួកគេឡើងចូលរថភ្លើងដោយប្រញាប់ប្រញាល់នោះ ដោយសារខ្ញុំចាប់អារម្មណ៍នឹងវិស្វករ អំឡុងពេលឈប់មួយភ្លែតនោះ ខណៈដែលអ្នកជំនួយការរបស់គាត់បានចាក់ទឹកបំពេញមមារញ៉ីកនឹងគ្រឿងម៉ាស៊ីន ចាក់ប្រេងនៅផ្នែកខ្លះ កែសម្រួលអ្វីផ្សេងៗ ហើយពិនិត្យមើលនូវការអូសទាញបន្ទុកយ៉ាងធ្ងន់នៃក្បាលរថភ្លើង ។ ខ្ញុំចង់និយាយនឹងគាត់ ទោះជាគាត់រវល់យ៉ាងណាក្ដី ។ ខ្ញុំបានសួរគាត់ថាតើគាត់មានអារម្មណ៍យ៉ាងណានៅពេលយប់ — ដែលចម្លែក សាហាវ និងទ្រគោះបោះបោកដូច្នេះ ជាពេលដែលអំណាចនៃការបំផ្លិចបំផ្លាញហាក់ដូចជាត្រូវបានដោះលែង ហើយគ្មានអ្វីគ្រប់គ្រងបាន ជាពេលដែលព្យុះស្រែករោរ៍ ហើយគ្រោះថ្នាក់បានគម្រាមគំហែងមកពីគ្រប់ទិសទីនោះ ។ . . .

ចម្លើយរបស់គាត់ គឺជាមេរៀនមួយដែលពុំអាចបំភ្លេចបាន ។ តាមពិតគាត់មានប្រសាសន៍ទាំងពាក្យដែលកន្ត្រាក់ៗ ហើយដាច់ៗថា ៖ « មើលទៅភ្លើងហ្វារនៅក្បាលម៉ាស៊ីន ។ តើភ្លើងនោះពុំបំភ្លឺផ្លូវរថភ្លើងមួយរយយ៉ាត [ ៩០ ម៉ែត្រ ] ឬលើសពីនោះទេឬ ? មែនហើយ អ្វីដែលខ្ញុំព្យាយាមធ្វើ គឺត្រូវមើលផ្លូវដែលបំភ្លឺនៅចម្ងាយមួយរយយ៉ាតនោះ ។ នោះខ្ញុំអាចមើលឃើញ ហើយក្នុងចម្ងាយនោះ ខ្ញុំដឹងថាគ្រឹះថ្នល់ថភ្លើងគ្មានអ្វីរាំង ហើយមានសុវត្ថិភាព ។ . . . ភ្លើងហ្វារក្បាលរថភ្លើង គឺតែងតែទៅមុខខ្ញុំជានិច្ច ! »

នៅពេលគាត់ឡើងចូលទៅកន្លែងបើករបស់គាត់វិញ ខ្ញុំបានប្រញាប់ទៅឡើងជិះទូររថភ្លើងសម្រាប់អ្នកធ្វើដំណើរទីមួយ ហើយពេលខ្ញុំអង្គុយនៅលើកៅអីពូកទន់នោះ ដោយក្ដីរីករាយនឹងភាពកក់ក្ដៅ និងសុខសាន្ត ខ្ញុំពុំគិតអំពីយប់ដ៏សាហាវនោះឡើយ តែខ្ញុំបានគិតយ៉ាងខ្លាំងអំពីពាក្យសម្ដីរបស់វិស្វករដែលប្រឡាក់សុទ្ធតែប្រេងម៉ាស៊ីនកខ្វក់នោះ ។ ពួកគេមានសេចក្ដីជំនឿពោរពេញ — ជាជំនឿដែលសម្រេចនូវកិច្ចការដ៏អស្ចារ្យៗជាច្រើន ជាសេចក្ដីជំនឿដែលផ្ដល់នូវការលើកទឹកចិត្ត និងការប្ដេជ្ញាចិត្ត ។ . . .

យើងប្រហែលជាពុំអាចដឹងអ្វី ដែលស្ថិតនៅខាងមុខយើងក្នុងឆ្នាំអនាគតទេ ទាំងមិនដឹងអំពីថ្ងៃ ឬម៉ោងក្រោយនោះភ្លាមៗផងដែរ ។ ប៉ុន្តែសម្រាប់ចម្ងាយពីរបីយ៉ាត ឬគ្រាន់តែពីរបីហ្វីត នោះផ្លូវរបស់យើងគឺពុំមានអ្វីរាំងស្ទះ នោះកាតព្វកិច្ចរបស់យើងច្បាស់លាស់ទិសដៅរបស់យើងត្រូវបានបំភ្លឺហើយ ។ ព្រោះរយៈចម្ងាយខ្លីនោះ ឬជំហានបន្ទាប់នោះ បានបំភ្លឺដោយការបំផុសគំនិតមកពីព្រះ ចូរបន្តទៅមុខ ! ■

*ចេញមកពី « Three Parables — The Unwise Bee, the Owl Express, and Two Lamps » លីអាហូណា, ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ៣៦–៤១ ។*

រូបភាព © HEMERA/THINKSTOCK, ISTOCK/THINKSTOCK

# ការយល់ដឹងជ្រៀលជ្រៅ



*ព្រះវិហារបរិសុទ្ធ អូហ្គឌិន យូថាហ៍ ដែលទើបតែឧទ្ទិសឆ្លងឡើងវិញ*

**តើយើងប្រែក្លាយទៅជាអ្នកដែលសកម្មចូលរួមព្រះវិហារបរិសុទ្ធដោយរបៀបណា ?**

« ចូរយើងធ្វើជាមនុស្សដែលសកម្មចូលរួមក្នុងព្រះវិហារបរិសុទ្ធ ។ សូមចូលព្រះវិហារបរិសុទ្ធឲ្យបានញឹកញាប់ តាមដែលពេលវេលាផ្ដល់ឲ្យ ។ សូមដាក់រូបថតព្រះវិហារបរិសុទ្ធនៅក្នុងផ្ទះបងប្អូន ដើម្បីឲ្យកូនៗអាចមើលឃើញ ។ សូមបង្រៀនពួកគេពីគោលបំណងនៃដំណាក់របស់ព្រះអម្ចាស់ ។ សូមឲ្យពួកគេដាក់ផែនការតាំងពីក្មេង ដើម្បីទៅកាន់ទីនោះ និងបន្តមានភាពសក្ដិសមដើម្បីទទួលពរជ័យនោះ » ។

**ប្រធាន ហាវើដ ដបុលយូ ហ៊ីនធើរ** ( ឆ្នាំ ១៩០៧–៩៥ ) « Exceeding Great and Precious Promises » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៨ ។

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ

### បានបើកបង្ហាញភាពពិតអំពីជីវិតរមែងស្លាប់

ទំព័រ ៤៤

យើងអាចរស់នៅក្នុងជីវិតដែលមានអត្ថន័យ និង មានគោលបំណងដោយការឱបក្រសោបយកភាពពិតបីយ៉ាងនៃជីវិតរមែងស្លាប់ ដែលព្រះអម្ចាស់បានបង្រៀនដល់អ័ដាម និងអេវ៉ា ។



## សម្រាប់យុវវ័យ



ទំព័រ ៥០

### បាវចនាម្ចូលឆ្នាំ ២០១៦

គណៈប្រធានយុវជន និងយុវនារីទូទៅ បានពន្យល់អំពីបាវចនាឆ្នាំនេះ និងអត្ថន័យដើម្បី « ឈានទៅមុខដោយភាពខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ » ( នីហ្វៃទី ២ ៣១:២០ ) ។

## សម្រាប់កុមារ

### ព្រះគម្ពីរមរមនបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ

ខណៈដែលអានព្រះគម្ពីរមរមនឆ្នាំនេះ អ្នកនឹងរៀនអំពីព្យាការីជាច្រើន ដែលពួកគាត់ទាំងអស់គ្នាមានបំណងចង់បាននូវរឿងដូចគ្នា--ដើម្បីបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ !



ទំព័រ ៧២

CAMBODIAN
4 02132 81258 0

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ